01059646

E314/12/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 30 / 01 / 2015
ម៉ោង (Time/Heure) : 16:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **ធូ មណី** ជាប្រធាន |
| | ចៅក្រម **Rowan DOWNING** |
| | ចៅក្រម **Chang-ho CHUNG** |
| | ចៅក្រម **ហួត វុទ្ធី** |
| | ចៅក្រម **ប្រាក់ គឹមសាន** |
| កាលបរិច្ឆេទ: | ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

# សំអាងហេតុចំពោះសេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចៅក្រម

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង
Nicholas KOUMJIAN

**<u>សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ
Marie GUIRAUD

**<u>ជនជាប់ចោទ</u>**

នួន ជា
ខៀវ សំផន

**<u>មេធាវីជនជាប់ចោទ</u>**

សុន អរុណ
Victor KOPPE
គង់ សំអុន
Arthur VERCKEN
Anta GUISSÉ

# I. សេចក្តីផ្តើម

១. ក្រុមប្រឹក្សាជំនុំជម្រះពិសេសនៃអង្គជំនុំជម្រះសាលាដំបូង (ក្រុមប្រឹក្សាពិសេស) ត្រូវបានរៀបចំបង្កើតឡើងដោយប្រធានគណៈកម្មាធិការរដ្ឋបាលតុលាការ (គណៈកម្មាធិការរដ្ឋបាល) អនុលោមតាមវិធាន ៣៤ (៦) នៃវិធានផ្ទៃក្នុង ដើម្បីសម្រេចទៅលើបណ្តឹងជំទាស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងចេញពីការជំនុំជម្រះសំណុំរឿង ០០២/០២។

២. នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤ ខៀវ សំផន បានដាក់សំណើមួយដែលស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងផ្អាកការជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២ រហូតដល់កិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ បានបញ្ចប់រួចរាល់។ គាត់បានស្នើនូវដំណោះស្រាយដែលជាជម្រើសមួយថា ត្រូវដក ចៅក្រម និល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE ចៅក្រម យូរ ឧត្តរា និងចៅក្រម Claudia FENZ ចេញពីសំណុំរឿង ០០២/០២ ("សំណើរបស់ ខៀវ សំផន")[1]។ សហព្រះរាជអាជ្ញាបានឆ្លើយតបទៅនឹងសំណើរបស់ ខៀវ សំផន នៅថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៤[2]។

៣. នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ នួន ជា បានដាក់បណ្តឹងជំទាស់មួយដែលស្នើសុំឱ្យ៖ (i) ដកចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម យូរ ឧត្តរា ចេញពីកិច្ចដំណើរការនីតិវិធីក្រោយៗប្រឆាំងនឹងរូបគាត់ (ii) ចៅក្រមទាំងនោះ "លាលែងពីតំណែងដោយស្ម័គ្រចិត្ត អនុលោមតាមវិធាន ៣៤(៥) នៃវិធានផ្ទៃក្នុង" ក្នុងខណៈដែលមានការសម្រេចលើបណ្តឹងជំទាស់របស់គាត់ (iii) សវនាការលើភស្តុតាងក្នុងសំណុំរឿង ០០២/០២ ត្រូវបានផ្អាករហូតដល់មានការសម្រេចលើបណ្តឹងជំទាស់របស់គាត់ និង (iv) បណ្តឹងជំទាស់នេះត្រូវបានចាត់ទុកជាបណ្តឹង

---

[1] សំណើរបស់លោក ខៀវ សំផន សុំឱ្យពិនិត្យឡើងវិញពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមក្នុងសំណុំរឿង ០០២/០១ ចូលជាស្ថាពរ មុននឹងចាប់ផ្តើមការជំនុំជម្រះសំណុំរឿង ០០២/០២ និងសុំឱ្យពិនិត្យឡើងវិញពីការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះថ្មីមួយ ឯកសារ E314/1 ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤ ។

[2] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន សុំឱ្យផ្អាកកិច្ចដំណើរការនីតិវិធី ឬប្តឹងជំទាស់ចៅក្រម ឯកសារ E314/3 ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៤ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន")។

ដែលត្រូវចាត់ការជាបន្ទាន់ ("បណ្តឹងជំទាស់របស់ នួន ជា")[3]។ សហព្រះរាជអាជ្ញាបានឆ្លើយតបទៅនឹងបណ្តឹងជំទាស់របស់ នួន ជា នៅថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៤ ជាភាសាអង់គ្លេស ហើយបានផ្តល់សំណៅបកប្រែជាភាសាខ្មែរនៅថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៤[4]។

៤. នៅថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៤ ខៀវ សំផន បានដាក់បណ្តឹងជំទាស់សាជាថ្មី។ ក្នុងចំណោមចំណុចផ្សេងៗទៀត បណ្តឹងជំទាស់នោះស្នើសុំឱ្យបញ្ចូលទឡ្ហីករណ៍នៅក្នុងបណ្តឹងជំទាស់របស់ នួន ជា និងបានកត់សម្គាល់ថា ចៅក្រម Silvia CARTWRIGHT បានឈប់ធ្វើជាចៅក្រមនៅ អ.វ.ត.ក ទៀតហើយ ("បណ្តឹងជំទាស់សាជាថ្មីរបស់ ខៀវ សំផន")[5]។

៥. នៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ក្រុមប្រឹក្សាជំនុំជម្រះពិសេសបានសម្រេចថា បណ្តឹងជំទាស់ទាំងនេះអាចទទួលយកបាន ដោយបានបដិសេធជាឯកច្ឆ័ន្ទចំពោះបណ្តឹងរបស់ ខៀវ សំផន សុំដកចៅក្រម Claudia FENZ និងបានបដិសេធដោយសំឡេងភាគច្រើនចំពោះបណ្តឹងជំទាស់របស់ នួន ជា និង ខៀវ សំផន ត្រង់ចំណុចដែលពាក់ព័ន្ធនឹងចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម យូរ ឧត្តរា ដោយមានការជំទាស់ពីចៅក្រម DOWNING[6]។

---

[3] បណ្តឹងជំទាស់របស់ នួន ជា ប្រឆាំងនឹងចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម យូរ ឧត្តរា ឯកសារ E314/6 ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ។

[4] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងជំទាស់របស់ នួន ជា ឯកសារ E314/9 ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៤ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងជំទាស់របស់ នួន ជា")។

[5] បណ្តឹងជំទាស់សាជាថ្មី ប្រឆាំងនឹងសមាសភាពចៅក្រមបច្ចុប្បន្ននៃអង្គជំនុំជម្រះសាលាដំបូងដែលត្រូវសម្រេចលើសំណុំរឿង ០០២/០២ ឯកសារ E314/8 ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៤ ។ ជាការសមស្របដែលត្រូវយោងទៅបណ្តឹងរបស់ នួន ជា ជាមួយនឹង សំណើ ខៀវ សំផន និង បណ្តឹងសាជាថ្មីទៀត ប៉ុន្តែ បណ្តឹង និងសំណើទាំងអស់នេះហៅថា "បណ្តឹងជំទាស់"។

[6] សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង ឯកសារ E314/12 ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤។ សូមមើលផងដែរ សេចក្តីសម្រេចលើសំណើបន្ទាន់បង្ហ ពាក់ព័ន្ធនឹងបណ្តឹងជំទាស់ ឯកសារ E314/11 ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ដែលធ្វើឱ្យសេចក្តីសម្រេចពីមុនៗទាក់ទិនទៅនឹងសំណើនានាក្លាយជាសេចក្តីសម្រេចជាផ្លូវការ៖ (i) ស្នើសុំបង្កើនចំនួនទំព័រកំណត់ និងដាក់ឯកសារតែមួយភាសាសិន, (ii) សុំផ្អាកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២/០២ រហូតដល់បញ្ចប់កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ និង (iii) សុំឱ្យមានសវនាការផ្ទាល់មាត់ស្តីពីបណ្តឹងជំទាស់។ ក្រុមប្រឹក្សាជំនុំជម្រះពិសេស បានកោះប្រជុំអនុលោមតាមវិធាន ៣៤(៦) នៃវិធានផ្ទៃក្នុង ដែលពីដំបូងមានចៅក្រម ប៉ែន ពេជ្រសាលី មិនមែនចៅក្រម ប្រាក់ គឹមសាន ទេ (*សូមមើល* សេចក្តីសម្រេចរបស់គណៈកម្មាធិការរដ្ឋបាលតុលាការ ទាក់ទងនឹងការចាត់តាំងសមាសភាពចៅក្រមដើម្បីពិនិត្យ និងវិនិច្ឆ័យលើបណ្តឹងជំទាស់ប្រឆាំងនឹងចៅក្រមអង្គ

សំអាងហេតុនៃសេចក្ដីសម្រេចនោះត្រូវបានផ្ដល់ជូននៅពេលនេះ។

៦. បណ្ដឹងជំទាស់ជាច្រើន កើតចេញមកពីការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២ និងគោលបំណងរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបន្តដំណើរការសវនាការសំណុំរឿង ០០២/០២ បន្ទាប់ពីបានផ្ដន្ទាទោស នួន ជា និង ខៀវ សំផន រួចហើយនៅក្នុងសំណុំរឿង ០០២/០១ នោះ។ ហេតុ-ដូច្នេះ សេចក្ដីសង្ខេបនៃប្រវត្តិនីតិវិធីក្នុងសំណុំរឿង ០០២ ត្រូវបានផ្ដល់ជូនរួចហើយ។ នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានចោទប្រកាន់ ខៀវ សំផន និង នួន ជា ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងការរំលោភបំពានលើក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦[7]។ នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានតម្កល់ដីកាដំណោះស្រាយ ដោយមានការកែសម្រួលមួយចំនួន[8]។ នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូង បានចេញដីកាបំបែកកិច្ចដំណើរការនីតិវិធីដែលកំណត់ពីវិសាលភាពនៃការជំនុំជម្រះវគ្គដំបូងក្នុងសំណុំរឿង ០០២ ដែលអង្គជំនុំជម្រះចាត់ទុកថាជាសំណុំរឿង ០០២/០១ ត្រឹមការចោទប្រកាន់លើអង្គហេតុដែលត្រូវបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជននៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលទាំងនោះ[9]។

---

ជំនុំជម្រះសាលាដំបូង ឯកសារ E314/4 ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៤)។ ទោះបីជាយ៉ាងណាក៏ដោយ នៅថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៤ នួន ជា បានស្នើសុំឲ្យដកចៅក្រម ប៉ែន ពេជ្រសាលី (*សូមមើល* បណ្ដឹងជំទាស់របស់ នួន ជា សុំដកចៅក្រម ប៉ែន ពេជ្រសាលី ឯកសារ E314/4/1 ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៤)។ នៅថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៤ ចៅក្រម ប៉ែន ពេជ្រសាលី បានជូនដំណឹងដល់ក្រុមប្រឹក្សាជំនុំជម្រះពិសេសថា គាត់បានសម្រេចចិត្តដកខ្លួនគាត់ចេញ។ ដូច្នេះ នៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤ គណៈកម្មាធិការរដ្ឋបាលតុលាការបានជ្រើសតាំងចៅក្រម ប្រាក់ គីមសាន ដើម្បីជំនួសចៅក្រម ប៉ែន ពេជ្រសាលី (សូមមើល សេចក្ដីសម្រេចរបស់គណៈកម្មាធិការរដ្ឋបាលតុលាការ ជ្រើសតាំងចៅក្រមជាតិមួយរូបបន្ទាប់ដើម្បីជំនួសចៅក្រម ប៉ែន ពេជ្រសាលី ឯកសារ E314/4/5 ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤)។

[7] ដីកាដំណោះស្រាយ (ក.ស.ច.ស) ឯកសារ D427 ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ១៦១៣។

[8] សូមមើល សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ (អបជ) ឯកសារ D427/2/12 ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ (អ.ប.ជ) ឯកសារ D427/4/14 ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១។

[9] ដីកាបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ឯកសារ E124 ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១។ ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូងនៅក្នុងសំណុំរឿង ០០២ ដែលបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់

សេចក្តីសន្និដ្ឋានបើកសវនាការលើអង្គសេចក្តីបានចាប់ផ្តើមនៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១។ ក្រោយមក អង្គជំនុំជម្រះសាលាដំបូងបានពង្រីកវិសាលភាពសំណុំរឿង ០០២/០១ ដោយដាក់បញ្ចូលការសម្លាប់អតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ[10]។

៧. នៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូលបានធ្វើមោឃភាពដីកាបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ របស់អង្គជំនុំជម្រះសាលាដំបូង ("សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើការបំបែកកិច្ចដំណើរការនីតិវិធីលើកទី១")[11]។ នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២ ជាថ្មីម្តងទៀត ដោយផ្អែកលើមូលដ្ឋានដដែលដូចពីមុន[12]។ នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២ ជាថ្មីម្តងទៀត ("សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើការបំបែកកិច្ចដំណើរការនីតិវិធីលើកទី២")[13]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ចប់សវនាការលើភស្តុតាងក្នុងសំណុំរឿង ០០២/០១ នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣។

---

សហព្រះរាជអាជ្ញាក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០១ (E163) ឯកសារ E124/7.3។

[10] សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163) និងពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន (អ.ជ.ស.ដ) ឯកសារ E163/5 ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២។

[11] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ (អ.ជ.ត.ក) ឯកសារ E163/5/1/13 ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[12] ប្រតិចារឹក ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ទំព័រ ២-៤ (ភាសាអង់គ្លេស)។ សំអាងហេតុពេញលេញ មាននៅក្នុងសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E284 ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣។

[13] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ សេចក្តីសង្ខេបនៃសំអាងហេតុ (អ.ជ.ត.ក) ឯកសារ E284/4/7 ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣។ សំអាងហេតុពេញលេញមាននៅក្នុង សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ (អ.ជ.ត.ក) ឯកសារ E284/4/8 ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣។

៨. នៅថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចមួយលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ ដែលនៅក្នុងសេចក្តីសម្រេចនោះ អង្គជំនុំ-ជម្រះបានបង្ហាញពីវិសាលភាពនៃអង្គហេតុ ដែលអង្គជំនុំជម្រះចាត់ទុកថា ជាសំណុំរឿង ០០២/០២ នោះ[14]។ នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ ("សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើការបំបែកកិច្ចដំណើរការនីតិវិធីលើកទី៣")[15]។

៩. បណ្តឹងជំទាស់ទាំងនេះត្រូវបានធ្វើឡើងបន្ទាប់ពីមានការចេញសាលក្រមក្នុងសំណុំរឿង ០០២/០១ នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ("សាលក្រមសំណុំរឿង ០០២/០១")[16]។ អង្គជំនុំជម្រះសាលាដំបូងបានផ្តន្ទាទោស ខៀវ សំផន និង នួន ជា ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងបានផ្តន្ទាទោសជនជាប់ចោទទាំងពីរនាក់ដាក់ពន្ធនាគារអស់មួយជីវិត[17]។ បណ្តឹងជំទាស់ទាំងនេះបានអះអាង ក្នុងចំណោមចំណុចអះអាងផ្សេងៗទៀតថា សំអាងហេតុនៅក្នុងសាលក្រមសំណុំរឿង ០០២/០១ បង្ហាញឱ្យឃើញនូវភាពលម្អៀងជាក់ស្តែងរបស់ចៅក្រមដែលត្រូវបានប្តឹងជំទាស់ទាំងនោះ និង/ឬបានលើកឡើងនូវការយល់ឃើញដ៏សមហេតុផលអំពីភាពលម្អៀងទាក់ទិននឹងកិច្ចដំណើរការនីតិវិធីនាពេលអនាគត។ នៅក្នុងថ្ងៃដែលចេញសាលក្រមសំណុំរឿង ០០២/០១ នោះ អង្គជំនុំជម្រះសាលាដំបូងក៏បានចេញសេចក្តីសម្រេចស្តាពរស្តីពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ ផងដែរ ("សេចក្តីសម្រេចស្តាពរស្តីពីសាក្សី")[18]។ សេចក្តីសម្រេចស្តាពរស្តីពីសាក្សីនេះ

---

[14] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ (អ.ជ.ស.ដ) ឯកសារ E301/9/1 ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ ("សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២")។

[15] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ (អ.ជ.ត.ក) ឯកសារ E301/9/1/1/3 ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ ("សេចក្តីសម្រេចលើកិច្ចដំណើរការនីតិវិធីទីបីរបស់ អ.ជ.ត.ក")។

[16] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ E313 ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ("សាលក្រមសំណុំរឿង ០០២/០១") ។

[17] សូមមើល សាលក្រមសំណុំរឿង ០០២/០១ ឯកសារ E313 ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៩៤០-៩៤២, ១០៥៣-១០៥៤, ១១០៦-១១០៧, និងទំព័រ ៦២២-៦២៣។

[18] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ E312 ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ("សេចក្តីសម្រេចស្តាពរស្តីពីសាក្សី")។

បានបង្ហាញពីវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានយកមកអនុវត្តដើម្បី "កំណត់អត្តសញ្ញាណ និងជ្រើសរើសបុគ្គលទាំងឡាយណាដែលយល់ឃើញថាមានភាពចាំបាច់ដើម្បីស្តាប់សក្ខីកម្ម" ក្នុងអំឡុងពេលនៃសំណុំរឿង ០០២/០១[19]។ អង្គជំនុំជម្រះសាលាដំបូងមិនអាចរកសម្លេងគាំទ្រទៅលើសំណើរបស់ នួន ជា ស្នើសុំកោះហៅសាក្សីចំនួនពីររូបគឺ ហេង សំរិន និង អ៊ុក ប៊ុនឈឿន ឡើយ[20]។ ចៅក្រម Silvia CARTWRIGHT និងចៅក្រម Jean-Marc LAVERGNE បានសន្និដ្ឋានថា បុគ្គលទាំងពីរនេះគួរត្រូវបានកោះហៅឲ្យមកផ្តល់សក្ខីកម្ម ចំណែកឯចៅក្រម និល ណុន ចៅក្រម យ៉ា សុខន និងចៅក្រម យូរ ឧត្តរា បានសន្និដ្ឋានថា ពួកគាត់មិនគួរត្រូវបានកោះហៅឲ្យមកផ្តល់សក្ខីកម្មនោះទេ ដែលជាហេតុនាំឲ្យមិនមានបុគ្គលណាម្នាក់ក្នុងចំណោមបុគ្គលទាំងពីរនេះ ត្រូវបានកោះហៅឲ្យមកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ ឡើយ។

១០. ខៀវ សំផន និង នួន ជា បានប្តឹងសាទុក្ខចំពោះសាលក្រមសំណុំរឿង ០០២/០១[21]។ បណ្តឹងសាទុក្ខរបស់ នួន ជា រួមបញ្ចូលទាំងការជំទាស់តវ៉ាទៅនឹងការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការកោះហៅ ហេង សំរិន និង អ៊ុក ប៊ុនឈឿន ឲ្យមកផ្តល់សក្ខីកម្មផងដែរ[22]។

## II. សារណារបស់ភាគី

### ក. សំណើរបស់ ខៀវ សំផន

១១. ជាដំណោះស្រាយមួយផ្សេងទៀត សំណើរបស់ ខៀវ សំផន ស្នើសុំប្តឹងជំទាស់ចិត្ត ដោយផ្អែកលើ

---

[19] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី កថាខណ្ឌ ២។

[20] *សូមមើល* សេចក្តីសម្រេចស្តាពរស្តីពីសាក្សី កថាខណ្ឌ ៨៦-១១១ និង ១១៥-១២០ ត្រង់ចំណុចដែល ហេង សំរិន ត្រូវបានយោងដោយរហស្សនាម TCW-223 និង អ៊ុក ប៊ុនឈឿន ត្រូវបានយោងដោយរហស្សនាម TCW-494។ ឈ្មោះរបស់ពួកគាត់ម្នាក់ៗ ត្រូវបានបង្ហាញទៅក្នុងកថាខណ្ឌ ៧២ និងកថាខណ្ឌ ១២៤។

[21] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១ ឯកសារ E313/1/1 ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ខៀវ សំផន ប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ E313/2/1។

[22] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១ ឯកសារ E313/1/1 ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ទំព័រ ៥-៦ មូលដ្ឋាន ៦។ *សូមមើលផងដែរ* បណ្តឹងជំទាស់ចិត្តសាជាថ្មីរបស់ ខៀវ សំផន ជើងទំព័រ ១០ ដែលយោងទៅលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ខៀវ សំផន ប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១ ឯកសារ E313/2/1 ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ កថាខណ្ឌ ១១ និងកថាខណ្ឌ ៤០ ជើងទំព័រ ៤៣។

មូលដ្ឋានថា ប្រសិនបើសំណុំរឿង ០០២/០២ ត្រូវចាប់ផ្ដើមភ្លាមៗនោះ សំណុំរឿងនេះគួរត្រូវបានជំនុំជម្រះដោយចៅក្រមដែលមិនបានសម្រេចទៅលើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ របស់ ខៀវ សំផន ទាក់ទិននឹងបញ្ហានានាដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០២[23]។ ខៀវ សំផន បានលើកឡើងថា សាលក្រមសំណុំរឿង ០០២/០១ រួមមាន សំអាងហេតុស្ដីពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ ទាក់ទិននឹងបញ្ហានានាដែលត្រូវយកមកវិនិច្ឆ័យនៅក្នុងសំណុំរឿង ០០២/០២[24]។ គាត់បានផ្ដោតទៅលើសំណើពីរ។ សំណើទីមួយ គឺថា សាលក្រមសំណុំរឿង ០០២/០១ បានឈានចេញហួសពីវិសាលភាពដែលត្រូវបានអនុញ្ញាតសម្រាប់ការជំនុំជម្រះនោះ ដោយសារតែមានការវិនិច្ឆ័យទៅលើបញ្ហានានា ដែលមិនមែនជាផ្នែកមួយនៃសំណុំរឿង ០០២/០១ ប៉ុន្ដែជាផ្នែកមួយនៃសំណុំរឿង ០០២/០២[25]។ សំណើទីពីរ ដោយមិនគិតអំពីថាតើសាលក្រមសំណុំរឿង ០០២/០១ នៅតែស្ថិតនៅក្នុងវិសាលភាពត្រឹមត្រូវ ឬយ៉ាងណានោះឡើយ "បញ្ហាជាន់គ្នា" ត្រូវបានអះអាងថាកើតមានឡើង ទាក់ទិននឹងបញ្ហានានាដែលជាបញ្ហារួមតែមួយចំពោះសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២ ដូចជា បរិបទប្រវត្តិសាស្ត្រ រចនាសម្ព័ន្ធរដ្ឋបាល និងរចនាសម្ព័ន្ធទំនាក់ទំនងការងារ និងតួនាទី និងមុខងាររបស់ជនជាប់ចោទ[26]។ សំអាងហេតុនៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ត្រូវបានអះអាងថាធ្វើឱ្យបាត់នូវសច្ចធារណ៍នៃភាពមិនលម្អៀងរបស់ចៅក្រមដែលប្រកបដោយវិជ្ជាជីវៈ[27]។

១២. ទាក់ទិនទៅនឹងសំណើដែលថា សាលក្រមសំណុំរឿង ០០២/០១ បានឈានចេញហួសពីវិសាលភាពដែលត្រូវបានអនុញ្ញាតនោះ ខៀវ សំផន លើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានកម្រិតសំណុំរឿង ០០២/០១ ត្រឹមការពិនិត្យមើលទៅលើប្រវត្តិបក្សកុម្មុយនីស្ដកម្ពុជា និងប្រវត្តិនៃគោលនយោបាយចំនួនពីរក្នុងចំណោមគោលនយោបាយចំនួនប្រាំ ដែលបានកំណត់នៅក្នុងដីកាដំណោះស្រាយ ដែលជាការផ្លាស់ទីលំនៅប្រជាជន និងការកំណត់គោលដៅចំពោះអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[28]។ ផ្ទុយទៅវិញ នៅក្នុងផ្នែកមួយនៃសាលក្រមសំណុំរឿង ០០២/០១ ដែលមានចំណងជើងថា "បរិបទប្រវត្តិសាស្ត្រ" មានសំអាងហេតុទៅលើគោលនយោបាយចំនួនបីទៀត ដែល

---

[23] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៤៨។

[24] បណ្ដឹងជំទាស់ជាថ្មីរបស់ ខៀវ សំផន កថាខណ្ឌ ១១។

[25] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៦, ១០-៤៣, ៤៥, ៤៧ និង ៥៣-៥៤។

[26] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៤៧។

[27] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៤២ និង ៥១។

[28] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ១៩។

ត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយគឺ គោលនយោបាយក្នុងការ (i) បង្កើតសហករណ៍ និងការដ្ឋានការងារនានា (ii) អប់រំកែប្រែសមាសភាពមិនល្អ និងការកម្ទេចខ្មាំង និង (iii) ការរៀបការដោយបង្ខំ[29]។ ខៀវ សំផន អះអាងថា អង្គជំនុំជម្រះសាលាដំបូងបានផ្អែកទៅលើសំអាងហេតុទាំងនេះដើម្បីសម្រេចអំពីអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម[30] និងសន្និដ្ឋានថា អំពើរបស់គាត់ជាអំពើឧក្រិដ្ឋ[31]។ ខៀវ សំផន ក៏បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានផ្អែកទៅលើបញ្ហានានា មុនយុត្តាធិការតាមពេលវេលារបស់ អ.វ.ត.ក[32]។

១៣. សំណើរបស់ ខៀវ សំផន ដែលជាប់ពាក់ព័ន្ធទៅដល់ចៅក្រម FENZ បានផ្អែកទៅលើមូលដ្ឋានដែលថាលោកស្រី "បានចូលរួមជំនុំជម្រះជាច្រើនដងក្នុងអំឡុងសវនាការសំណុំរឿង ០០២/០១ និងបានចូលរួមចេញសេចក្តីសម្រេចមួយចំនួនផងដែរ"[33]។ បណ្តឹងជំទាស់មិនដូចដែលថាថ្មីរបស់ ខៀវ សំផន បង្ហាញអំពីឱកាសផ្សេងៗដែលចៅក្រម FENZ បានជំនួសចៅក្រម CARTWRIGHT ឬ ចៅក្រម LAVERGNE ក្នុងអំឡុងសវនាការសំណុំរឿង ០០២/០១ ដូច្នេះហើយ ទោះបីជាក្នុងនាមជាចៅក្រមបម្រុងក៏ដោយ ក៏លោកស្រី គួរត្រូវបានដកចេញពីសំណុំរឿង ០០២/០២ ដែរ[34]។

## ខ. ចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះសំណើរបស់ ខៀវ សំផន

១៤. សហព្រះរាជអាជ្ញាឆ្លើយតបថា សំណើរបស់ ខៀវ សំផន មិនអនុលោមទៅតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុងនោះទេ ពីព្រោះការប្តឹងជំទាស់មិនដូចដែលថា មិនមែនជម្រើសមួយផ្សេងទៀត ដើម្បីជួសជុលការខូចខាត

---

[29] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ២០-២៨ ដែលយោងទៅលើសាលក្រមសំណុំរឿង ០០២/០១ ៖ ផ្នែក ៣.៣.២ ការបង្កើតសហករណ៍ និងការដ្ឋាន មុនខែ មេសា ឆ្នាំ ១៩៧៥ ជាពិសេស កថាខណ្ឌ ១១៦។ ផ្នែក ៣.៣.៣ ការអប់រំកែប្រែសមាសភាពមិនល្អ និងការកម្ទេចខ្មាំង ជាពិសេស កថាខណ្ឌ ១១៧។ ផ្នែក ៣.៣.៥ ការរៀបការដោយបង្ខំ ជាពិសេស កថាខណ្ឌ ១២៨។

[30] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៣៤-៣៥ ដែលយោងទៅលើសាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧២៥។

[31] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ២៨-២៩ ដែលយោងទៅលើសាលក្រមសំណុំរឿង ០០២/០១ ជើងទំព័រ ១៩៥ និង កថាខណ្ឌ ៣៥ ដែលអះអាងថា ផ្នែកនៃសាលក្រមសំណុំរឿង ០០២/០១ ដែលមានចំណងជើងថា "ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន" បានផ្អែកទៅលើការវិភាគជារួមមួយទៅលើចលនាខ្មែរក្រហម និងរបបកម្ពុជាប្រជាធិបតេយ្យ តាមរយៈការបង្កើត និងការអនុវត្តនូវគោលនយោបាយទាំងប្រាំ។

[32] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៣៤-៣៥។

[33] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៤៨។

[34] បណ្តឹងជំទាស់មិនដូចដែលថាថ្មីរបស់ ខៀវ សំផន កថាខណ្ឌ ១២។

ឬប៉ះប៉ូវអ្វីឡើយ[35]។ សហព្រះរាជអាជ្ញាលើកឡើងថា បណ្ដឹងជំទាស់មិនមានមូលដ្ឋានសមស្របឡើយ ពីព្រោះចៅក្រមវិជ្ជាជីវៈអាចជំនុំជម្រះលើសំណុំរឿងមួយចំនួន ដែលកើតចេញពីព្រឹត្តការណ៍ដូចគ្នា[36]។ សហព្រះរាជអាជ្ញាផ្អែកទៅលើយុត្តិសាស្ត្រពីតុលាការសិទ្ធិមនុស្សអឺរ៉ុប ("តុលាការ ECtHR") ដោយពួកគាត់អះអាងថា ចៅក្រមទាំងឡាយត្រូវបានអនុញ្ញាតឱ្យធ្វើការសម្រេចទៅលើសំណុំរឿងមួយចំនួន ដែលកើតចេញមកពីអង្គហេតុតែមួយ លើកលែងតែសាលក្រមកន្លងមក "ពិតជាមានបុរេវិនិច្ឆ័យ" ទៅលើពិរុទ្ធភាពរបស់បុគ្គលមែន[37]។ សហព្រះរាជអាជ្ញាលើកឡើងថា បុរេវិនិច្ឆ័យដែលជាការហាមឃាត់នេះ តម្រូវឱ្យមានការសម្រេច "អំពីលក្ខខណ្ឌពាក់ព័ន្ធទាំងអស់ចាំបាច់ដើម្បីបង្កើតបានជាបទល្មើស និងការរកឃើញថាជនជាប់ចោទ មានពិរុទ្ធក្នុងការប្រព្រឹត្តិបទល្មើសនោះ ហួសពីវិមតិសង្ស័យ"[38]។ សហព្រះរាជអាជ្ញាលើកឡើងថា ទោះបីជាសាលក្រមសំណុំរឿង ០០២/០១ មានសំអាងហេតុទៅលើបញ្ហានានាដែលនឹងលេចឡើងជាថ្មីនៅក្នុងសំណុំរឿង ០០២/០២ ក៏ដោយ ក៏សាលក្រមសំណុំរឿង ០០២/០១ ពុំបានបញ្ចូលសំអាងហេតុអំពីការទទួលខុសត្រូវរបស់ ខៀវ សំផន ទាក់ទិននឹងឧក្រិដ្ឋកម្មនៃសំណុំរឿង ០០២/០២ ឡើយ[39]។ សហព្រះរាជអាជ្ញាក៏បានផ្អែកផងដែរទៅលើយុត្តិសាស្ត្រពីសហរដ្ឋអាមេរិក ដោយពួកគាត់លើកឡើងថា ចៅក្រមជាធម្មតាធ្វើការជំនុំជម្រះលើរឿងក្ដីជាច្រើនប្រឆាំងនឹងចុងចោទតែម្នាក់[40]។

---

[35] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ ខៀវ សំផន កថាខណ្ឌ ៨-៩។

[36] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ ខៀវ សំផន កថាខណ្ឌ ១២។

[37] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ ខៀវ សំផន កថាខណ្ឌ ១២-១៣ ដែលផ្អែកលើ រឿងក្ដី *Poppe តទល់នឹងប្រទេសហូឡង់* សាលក្រម តុលាការ ECtHR សំណើលេខ 32271/04 ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៩ *("សាលក្រមលើរឿងក្ដី Poppe តទល់នឹងប្រទេសហូឡង់")* កថាខណ្ឌ ២៦ និង ២៨ និង រឿងក្ដី *Schwarzenberger តទល់នឹងប្រទេសអាល្លឺម៉ង់* សាលក្រម តុលាការ ECtHR សំណើលេខ 75737/01 ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៦ *("សាលក្រមលើរឿងក្ដី Schwarzenberger តទល់នឹង ប្រទេសអាល្លឺម៉ង់")* កថាខណ្ឌ ៤៣។

[38] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ ខៀវ សំផន កថាខណ្ឌ ១៣ ដែលដកស្រង់សាលក្រមលើរឿងក្ដី *Poppe តទល់នឹង ប្រទេសហូឡង់* កថាខណ្ឌ ២៨។

[39] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ ខៀវ សំផន កថាខណ្ឌ ១៤, ១៥ និង ២០។

[40] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ ខៀវ សំផន កថាខណ្ឌ ១៨-១៩។

## គ. បណ្តឹងជំទាស់របស់ នួន ជា

១៥. បណ្តឹងជំទាស់របស់ នួន ជា លើកឡើងនូវមូលដ្ឋានជាច្រើន ដែលគាត់បានអះអាងថា ការចូលរួមរបស់ចៅក្រមដែលត្រូវបានប្តឹងជំទាស់ទាំងនោះ នៅក្នុងសំណុំរឿង ០០២/០២ នឹងរំលោភទៅលើសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ពីតុលាការឯករាជ្យ និងមិនលម្អៀង[41]។ នួន ជា លើកឡើងថា ចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម យូរ ឧត្តរា គួរត្រូវបានដកចេញ ដោយសារតែសំអាងហេតុរបស់ពួកគាត់នៅក្នុងសាលក្រមសំណុំរឿង ០០២/០១[42]។ គាត់លើកឡើងបន្ថែមទៀតថា ចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE គួរត្រូវបានដកចេញ ដោយសារតែសំអាងហេតុរបស់ពួកគាត់នៅក្នុងសាលក្រមសំណុំរឿង ០០១[43]។ ជាពិសេស នួន ជា លើកឡើងថា ចៅក្រមដែលមានសំអាងហេតុនៅក្នុងសាលក្រមសំណុំរឿង ០០២/០១[44] និងសាលក្រមសំណុំរឿង ០០១[45] បានកំណត់ជាមុន ពីបញ្ហានានាដែលទាក់ទិននឹងការចោទប្រកាន់អំពីពិរុទ្ធភាពរបស់គាត់នៅក្នុងសំណុំរឿង ០០២/០២ ឬមានទស្សនៈអវិជ្ជមានទៅលើមេធាវីការពារក្តីរបស់គាត់ ដូច្នេះ នាំឱ្យអ្នកសង្កេតការណ៍មិនលម្អៀងយល់ថា មានលេចចេញនូវភាពលម្អៀងដែលមិនអាចទទួលយកបាន[46]។

១៦. ទាក់ទិននឹងសាលក្រមសំណុំរឿង ០០១ នួន ជា បានអះអាងថា ការបដិសេធបណ្តឹងជំទាស់ដែលគាត់បានធ្វើឡើងកាលពីខែ កុម្ភៈ ឆ្នាំ ២០១១ ប្រឆាំងនឹងចៅក្រមដែលបានចូលរួមយ៉ាងសកម្មនៅក្នុងរឿងក្តីនោះ កើតចេញមកពីការបកស្រាយច្បាប់មិនត្រឹមត្រូវ[47]។ គាត់បានដកស្រង់សំណើដែលបានលើកឡើងនៅក្នុងបណ្តឹងជំទាស់មុនៗរបស់គាត់ ដែលគាត់បានកំណត់ថាបានផ្តោតទៅលើធាតុផ្សំទូទៅជាពិសេស ឧក្រិដ្ឋកម្មជាក់លាក់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅ

---

[41] បណ្តឹងជំទាស់របស់ នួន ជា កថាខណ្ឌ ១៣៦។

[42] បណ្តឹងជំទាស់របស់ នួន ជា៖ ផ្នែក ឃ កថាខណ្ឌ ៦១-៧០, ផ្នែក ង កថាខណ្ឌ ៧១-៩២, ផ្នែក ច កថាខណ្ឌ ៩៣-១១៤, ផ្នែក ជ កថាខណ្ឌ ១២២ និងផ្នែក I កថាខណ្ឌ ១២៣-១៣៣។

[43] សាលក្រមលើរឿងក្តី កាំង ហ្គេកអ៊ាវ ឯកសារ E188 ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១ ("សាលក្រមលើសំណុំរឿង ០០១")។ បណ្តឹងជំទាស់របស់ នួន ជា៖ ផ្នែក ឆ កថាខណ្ឌ ១១៥-១២១, ផ្នែក ជ កថាខណ្ឌ ១២២។

[44] បណ្តឹងជំទាស់របស់ នួន ជា កថាខណ្ឌ ៩៣, ១១៤។

[45] បណ្តឹងជំទាស់របស់ នួន ជា កថាខណ្ឌ ១២១។

[46] បណ្តឹងជំទាស់របស់ នួន ជា កថាខណ្ឌ ២៩-៣២។

[47] បណ្តឹងជំទាស់របស់ នួន ជា កថាខណ្ឌ ១១៦។

លើអនុសញ្ញាទីក្រុងហ្សឺណែវ[48] ហើយបានដាក់បន្ថែម "ការផ្តោតថ្មី" មួយទៅលើសំអាងហេតុចំនួនប្រាំមួយទៀតដូចតទៅនេះ នៅក្នុងសាលក្រមសំណុំរឿង ០០១ ដែលគាត់អះអាងថា បានកំណត់ជាមុនទៅលើបញ្ហានានាក្នុងសំណុំរឿង ០០២/០២ ដោយរួមមាន (i) ចំពោះការកាប់សម្លាប់នៅមន្ទីរស-២១ (ii) ចំពោះលទ្ធភាពនៃការដោះលែងចេញពីមន្ទីរស-២១ (iii) ចំពោះ "គោលនយោបាយកម្ទេច" ដូចដែលបានចោទប្រកាន់ (iv) ចំពោះការសួរចម្លើយ (v) ចំពោះការធ្វើទារុណកម្ម និង (vi) ចំពោះការសម្លាប់កុមារតូចៗ[49]។

១៧. ទាក់ទិននឹងសាលក្រមសំណុំរឿង ០០២/០១ នួន ជា លើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យមើលគោលនយោបាយទាំងប្រាំរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវបានចោទប្រកាន់ ដែលនៅពេលនោះ មានតែគោលនយោបាយចំនួនពីរប៉ុណ្ណោះក្នុងចំណោមគោលនយោបាយទាំងនោះ ដែលស្ថិតនៅក្រោមវិសាលភាពនៃសំណុំរឿង ០០២/០១។ គាត់លើកឡើងថា សំអាងហេតុរបស់ចៅក្រមទាក់ទិននឹងអត្ថិភាពនៃការបង្កើត និងការវិវឌ្ឍនៃគោលនយោបាយទាំងនោះ និងទំនាក់ទំនងនៃគោលនយោបាយទាំងនោះទៅនឹងសហឧក្រិដ្ឋកម្មរួមដែលត្រូវបានចោទប្រកាន់នោះ បានកំណត់ជាមុនលើបញ្ហានានាដែលសំខាន់ចំពោះពិរុទ្ធភាពរបស់គាត់ដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០២[50]។ គាត់លើកឡើងថា សាលក្រមសំណុំរឿង ០០២/០១ ក៏មានសំអាងហេតុជាច្រើនអំពីគោលនយោបាយក្នុងការកំណត់គោលដៅ "ខ្មាំង" ជាពិសេស "ប្រជាជនថ្មី" និងអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ ដូច្នេះនេះគឺជាការកំណត់ជាមុនទៅលើបញ្ហាទាំងនោះនៅក្នុងសំណុំរឿង ០០២/០២[51]។ សាលក្រមសំណុំរឿង ០០២/០១ ក៏រួមមានសំអាងហេតុអំពីតួនាទីរបស់ នួន ជា ក្នុងការបង្កើត និងអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា[52]។ នួន ជា លើកឡើងថា សំអាងហេតុបែបនេះគឺជាការកំណត់ជាមុនទៅលើបញ្ហាសំខាន់ៗទាក់ទងនឹងពិរុទ្ធភាពរបស់គាត់នៅក្នុងសំណុំរឿង ០០២/០២[53]។ នួន ជា លើកឡើងទៀតថា ចៅក្រមមានទស្សនះអវិជ្ជមានអំពីបក្សកុម្មុយនីស្តកម្ពុជា និងអំពីទឡ្ហីករណ៍សំខាន់មួយចំនួនរបស់គាត់ និងបានកំណត់ជាមុនទៅលើបញ្ហានានាប្រឆាំងនឹងរូបគាត់ ដែលនាំឱ្យមានការលេចចេញនូវភាព

[48] បណ្តឹងមិនចិត្តរបស់ នួន ជា កថាខណ្ឌ ១១៩ និង ១២១។

[49] បណ្តឹងមិនចិត្តរបស់ នួន ជា ផ្នែក ឆ កថាខណ្ឌ ១១៦-១២១។

[50] បណ្តឹងមិនចិត្តរបស់ នួន ជា កថាខណ្ឌ ផ្នែក ច (i)-(ii) កថាខណ្ឌ ៩៣-១០០។

[51] បណ្តឹងមិនចិត្តរបស់ នួន ជា កថាខណ្ឌ ផ្នែក ច (iii) កថាខណ្ឌ ១០១-១០៥។

[52] បណ្តឹងមិនចិត្តរបស់ នួន ជា កថាខណ្ឌ ផ្នែក ច (iv) កថាខណ្ឌ ១០៦-១១១។

[53] បណ្តឹងមិនចិត្តរបស់ នួន ជា កថាខណ្ឌ ១១០។

លម្អៀងដែលមិនអាចទទួលយកបាន[54]។

១៨. នួន ជា ក៏បានលើកឡើងផងដែរថា សាលក្រមសំណុំរឿង ០០២/០១ មានកំហុសឆ្គង ដែលបង្ហាញឱ្យឃើញពីការលេចចេញនូវភាពលម្អៀង។ គាត់ផ្តោតទៅលើសំអាងហេតុមិនត្រឹមត្រូវ ដែលត្រូវបានចោទប្រកាន់ទាក់ទិននឹង៖ (i) រចនាសម្ព័ន្ធនៃបក្សកុម្មុយនីស្តកម្ពុជា (ii) អត្ថិភាពនៃគោលនយោបាយទាក់ទងនឹងការដាក់បទបញ្ជាទាក់ទងនឹងអាពាហ៍ពិពាហ៍ (iii) ការយោងទៅលើការវិភាគអំពីប្រជាសាស្ត្រ និង (iv) ការកំណត់និយមន័យរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើពាក្យ "កម្ទេច" ដោយយោងទៅលើសាលក្រមសំណុំរឿង ០០១[55]។

១៩. នួន ជា លើកឡើងបន្ថែមទៀតថា "ពាក្យបច្ចេកទេស" មួយចំនួននៅក្នុងសាលក្រមសំណុំរឿង ០០២/០១ បង្កើតបានជាការលេចចេញនូវភាពលម្អៀង ពោលគឺ៖ (i) គុណនាមស្រពិចស្រពិល ដូចជា "ដែលត្រូវបានអះអាង" ឬ "ដែលត្រូវបានយល់ឃើញ" យកមកពិពណ៌នាភស្តុតាង (ii) សញ្ញាអម្ពត្តរៈ ដែលបញ្ជាក់ថា ចៅក្រមមិនយល់ស្របជាមួយនឹងន័យត្រង់នៃពាក្យដែលពួកគាត់បានប្រើប្រាស់ ដូចជា "ខ្មាំង" (iii) ការជ្រើសរើសប្រើប្រាស់សញ្ញាអម្ពត្តរៈដើម្បីបង្ហាញអំពីមន្ទិលសង្ស័យចំពោះភស្តុ-តាង និង (iv) នាមប្រមាថមើលងាយ ដូចជា ការបិទបាំង[56]។ នួន ជា អះអាងថា បច្ចេកទេសទាំងនេះបង្ហាញឱ្យឃើញនូវកង្វះភាពអព្យាក្រឹតទៅលើបញ្ហាមួយចំនួន ដូចជា (i) ការគំរាមកំហែងពីខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅ (i) គោលនយោបាយ និងសកម្មភាពរបស់បក្សកុម្មុយនីស្តកម្ពុជា (iii) សកម្មភាព និងនយោបាយរបស់របប លន់ នល់ និង (iv) តួនាទីរបស់នរោត្តម នរោត្តម សីហនុ[57]។

២០. នួន ជា លើកឡើងទៀតថា សំអាងហេតុរួមដែលត្រូវបានបង្កើតឡើងដោយចៅក្រមពាក់ព័ន្ធនៅក្នុងសាលក្រមសំណុំរឿង ០០១ និងសាលក្រមសំណុំរឿង ០០២/០១ គឺជាការច្រានចោលបន្ទុកនៃការបង្ហាញភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២[58]។ គាត់បានអះអាងថា សំណើរបស់គាត់បង្ហាញថា ចៅក្រមដែលត្រូវបានប្តឹងជំទាស់ មិនមានសុចរិតភាពផ្នែកវិជ្ជាជីវៈ ដែលអាចទទួលយកបាន ហើយថា ដំណើរការដែលឈានទៅដល់ការចេញសាលក្រមលើសំណុំរឿង ០០២/០១ នោះ គឺជា "ឆាកល្ខោន

---

[54] បណ្តឹងជំទាស់របស់ នួន ជា កថាខណ្ឌ ផ្នែក ច (v) កថាខណ្ឌ ១១១-១១៤។

[55] បណ្តឹងជំទាស់របស់ នួន ជា៖ ផ្នែក ង កថាខណ្ឌ ៧១-៩២។

[56] បណ្តឹងជំទាស់របស់ នួន ជា ផ្នែក ឃ កថាខណ្ឌ ៦១-៧០។

[57] បណ្តឹងជំទាស់របស់ នួន ជា៖ ផ្នែក ឃ កថាខណ្ឌ ៦៣-៦៧។

[58] បណ្តឹងជំទាស់របស់ នួន ជា ផ្នែក ជ កថាខណ្ឌ ១២២។

មួយប៉ុណ្ណោះ”[59]។ គាត់អះអាងថា សាលក្រមសំណុំរឿង ០០២/០១ បានផ្អែកហួសហេតុពេកទៅលើអ្នកជំនាញ Anglo-French ដែលគាត់ចោទប្រកាន់ថា អ្នកទាំងនោះគឺជាពួកអាណានិគម និងពួកចក្រពត្តិ ហើយថា ចៅក្រមអន្តរជាតិមកពីប្រទេសដែលមានមនោគមវិជ្ជាដូចគ្នា ដូច្នេះហើយធ្វើឱ្យលេចចេញនូវភាពលម្អៀង[60]។

២១. ទាក់ទិននឹងសេចក្តីសម្រេចស្ដាពរស្ដីពីសាក្សីនោះ នួន ជា លើកឡើងថា ការខកខានមិនបានកោះហៅ ហេង សំរិន ឱ្យមកផ្ដល់សក្ខីកម្ម បង្ហាញឱ្យឃើញនូវភាពលម្អៀងរបស់ចៅក្រមកម្ពុជា[61]។ គាត់បានបញ្ជាក់ថា សេចក្តីសម្រេចរបស់ចៅក្រមកម្ពុជាជាប់ទាក់ទិនទៅនឹងអំពើពុករលួយ ឥទ្ធិពលពីសហព្រះរាជអាជ្ញា ឯករាជ្យភាពមានកម្រិតរបស់ចៅក្រមកម្ពុជាជាទូទៅ[62]។ គាត់អះអាងថា សេចក្តីសម្រេចរបស់ចៅក្រមកម្ពុជាមិនកោះហៅ ហេង សំរិន ឱ្យមកផ្ដល់សក្ខីកម្ម មិនបានផ្អែកទៅលើការវាយតម្លៃដោយសុក្រឹតលើអង្គច្បាប់ និងអង្គហេតុឡើយ ហើយបង្ហាញឱ្យឃើញនូវទស្សនៈកំណត់ជាមុនថា សំណើរបស់ នួន ជា ស្នើសុំឱ្យកោះហៅ ហេង សំរិន នៅក្នុងសំណុំរឿង ០០២/០២ គឺជាយុទ្ធសាស្ត្រជំនុំជម្រះ មិនមែនជាសំណើដែលមានលក្ខណៈសុក្រឹតពិតប្រាកដឡើយ[63]។ គាត់ក៏បានលើកឡើងផងដែរថា ចៅក្រម LAVERGNE បានបង្ហាញនូវកង្វះសុច្ចរិតភាពវិជ្ជាជីវៈ ពីព្រោះការខកខានមិនបានកោះហៅ ហេង សំរិន ឱ្យមកផ្ដល់សក្ខីកម្ម គួរតែនាំឱ្យចៅក្រម LAVERGNE សម្រេចឱ្យជនជាប់ចោទរួចផុតពីពិរុទ្ធភាព[64]។

២២. បណ្ដឹងជំទាស់របស់ នួន ជា ផ្អែកទៅលើបញ្ហានានាដែលកើតឡើងមុនថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ដែលគាត់អះអាងថាមានភាពជាប់ពាក់ព័ន្ធផ្អែកបរិបទ។ ក្រៅពីសាលក្រមសំណុំរឿង ០០១[65] នួន ជា ផ្អែកទៅលើសេចក្តីថ្លែងជាសាធារណៈរបស់ចៅក្រម CARTWRIGHT នៅឯវិទ្យាស្ថាន Aspen កាលពីខែ វិច្ឆិកា ឆ្នាំ ២០១៣[66] និងសៀវភៅមួយក្បាល ដែលបោះពុម្ពនៅក្នុងខែ មករា ឆ្នាំ

---

[59] បណ្ដឹងជំទាស់របស់ នួន ជា ផ្នែក ជ កថាខណ្ឌ ១២២។

[60] បណ្ដឹងជំទាស់របស់ នួន ជា ផ្នែក ឈ កថាខណ្ឌ ១២៩។

[61] បណ្ដឹងជំទាស់របស់ នួន ជា ផ្នែក ខ កថាខណ្ឌ ៣៨-៥៣។

[62] បណ្ដឹងជំទាស់របស់ នួន ជា ផ្នែក ខ កថាខណ្ឌ ៤៣-៤៩។

[63] បណ្ដឹងជំទាស់របស់ នួន ជា ផ្នែក ខ កថាខណ្ឌ ៥២។

[64] បណ្ដឹងជំទាស់របស់ នួន ជា ផ្នែក ឈ កថាខណ្ឌ ១៣០-១៣២។

[65] បណ្ដឹងជំទាស់របស់ នួន ជា កថាខណ្ឌ ១១៧។

[66] បណ្ដឹងជំទាស់របស់ នួន ជា ផ្នែក គ កថាខណ្ឌ ៥៣-៦០។

២០១៣ ដោយអតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចៅក្រម LEMONDE[67] ក្នុងគោលបំណង ដើម្បីលើកឡើងថា ចៅក្រមកម្ពុជាអាចមិនមានអនាគតិ ដោយសារតែបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគាត់ និង/ឬការចោទប្រកាន់អំពីទំនាក់ទំនងរបស់ពួកគាត់ជាមួយនឹងរដ្ឋាភិបាលកម្ពុជា។ គាត់លើកឡើងថា ចៅក្រមកម្ពុជាខ្វះសន្តិសុខក្នុងការរក្សាមុខតំណែង គ្រប់គ្រងដោយនីតិប្រតិបត្តិ ហើយថា សហព្រះរាជអាជ្ញាកម្ពុជាមានតួនាទីនៅក្នុងស្ថាប័នដែលទទួលបន្ទុកក្នុងការតែងតាំង ដាក់វិន័យ និងដកតំណែងចៅក្រម[68] ដូច្នេះពុំមានការការពារគ្រប់គ្រាន់ប្រឆាំងនឹងសម្ពាធពីខាងក្រៅឡើយ[69]។

## ឃ. ចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះបណ្តឹងរបស់ នួន ជា

២៣. សហព្រះរាជអាជ្ញាឆ្លើយតបថា បណ្តឹងជំទាស់របស់ នួន ជា ពុំបានបង្ហាញនូវភាពលម្អៀងជាក់ស្តែង ឬការលេចចេញនូវភាពលម្អៀងឡើយ។ ចំពោះការចោទប្រកាន់ពីការធ្វើបុរេវិនិច្ឆ័យ សហព្រះរាជអាជ្ញាអះអាងថា នួន ជា មិនបានបង្ហាញពីបុរេវិនិច្ឆ័យចំពោះធាតុផ្សំនីមួយៗនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ដែលពួកគាត់អះអាងថាចាំបាច់ដើម្បីឈានទៅដល់ការលេចចេញនូវភាពលម្អៀងដែលមិនអាចទទួលយកបាននោះ[70]។ ពួកគាត់លើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមិនចេញសំអាងហេតុ ដែលបង្ហាញពីការសន្និដ្ឋានអំពីការទទួលខុសត្រូវព្រហ្មទណ្ឌទាក់ទិននឹងបទចោទនានានៅក្នុងសំណុំរឿង ០០២/០២ នោះឡើយ ដូច្នេះ ពុំមានការបង្ហាញឱ្យឃើញពីភាពលម្អៀងជាក់ស្តែង ឬការយល់ឃើញដ៏សមហេតុផលអំពីភាពលម្អៀងឡើយ[71]។

២៤. ទាក់ទងនឹងសំអាងហេតុមិនត្រឹមត្រូវដែលត្រូវបានចោទប្រកាន់នោះ សហព្រះរាជអាជ្ញាលើកឡើងថា គ្មានចំណុចណាមួយក្នុងចំណោមចំណុចទាំងឡាយដែលបានបញ្ជាក់នៅក្នុងបណ្តឹងជំទាស់របស់ នួន ជា បង្ហាញឱ្យឃើញពីការលេចចេញនូវភាពលម្អៀង ទៅលើការទទួលខុសត្រូវព្រហ្មទណ្ឌនៅក្នុងសំណុំរឿង ០០២/០២ ឡើយ និង/ឬថា ទឡ្ហីករណ៍បែបនោះគឺជាបញ្ហាសម្រាប់ការប្តឹងសាទុក្ខ មិនមែនជាការប្តឹងជំទាស់ឡើយ[72]។ ទាក់ទិននឹងពាក្យបច្ចេកទេសវិញ សហព្រះរាជអាជ្ញាអះអាងថា

[67] បណ្តឹងជំទាស់របស់ នួន ជា កថាខណ្ឌ ១១, ៣៧ និង ៤៥។

[68] បណ្តឹងជំទាស់របស់ នួន ជា កថាខណ្ឌ ៤៦។

[69] បណ្តឹងជំទាស់របស់ នួន ជា កថាខណ្ឌ ៤៩។

[70] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងជំទាស់របស់ នួន ជា កថាខណ្ឌ ៣៤ និង ៤៦។

[71] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងជំទាស់របស់ នួន ជា កថាខណ្ឌ ៣០-៤៦។

[72] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងជំទាស់របស់ នួន ជា កថាខណ្ឌ ៣៧-៤៣។

សំណើរបស់ នួន ជា មិនសំខាន់ឡើយ ហើយក្នុងករណីណាក៏ដោយ ការប្រើប្រាស់ពាក្យបច្ចេកទេស នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ មិនមែនជាការលេចចេញនូវភាពលម្អៀងឡើយ[73]។ ទាក់ទិននឹងការពឹងផ្អែករបស់អង្គជំនុំជម្រះសាលាដំបូងទៅលើភ័ស្តុតាងរបស់អ្នកជំនាញនោះ សហព្រះរាជអាជ្ញាឆ្លើយតបថា ការពឹងផ្អែកបែបនេះមិនបានបង្ហាញឱ្យឃើញនូវភាពលម្អៀងជាក់ស្តែង និងមិនអាចធ្វើឱ្យអ្នកសង្កេតការណ៍មិនលម្អៀងយល់ឃើញពីភាពលម្អៀងក្នុងករណីនេះឡើយ[74]។

២៥. ទាក់ទិននឹងការខកខានមិនបានកោះហៅ ហេង សំរិន ឱ្យមកផ្តល់សក្ខីកម្មនោះ សហព្រះរាជអាជ្ញាលើកឡើងថា នួន ជា មិនបានចង្អុលបង្ហាញទៅអង្គហេតុណាមួយដែលថា ហេង សំរិន គួរមកផ្តល់សក្ខីកម្មទៅលើអង្គហេតុដែលអាចនាំទៅដល់ការលើកលែងចោទប្រកាន់ នៅក្នុងសំណុំរឿង ០០២/០១ នោះឡើយ[75]។ ពួកគាត់លើកឡើងបន្ថែមទៀតថា ចៅក្រមកម្ពុជា របស់ អ.វ.ត.ក ស្ថិតនៅដាច់ដោយឡែកពីប្រព័ន្ធយុត្តិធម៌កម្ពុជាជារួម និងទទួលបានអភ័យឯកសិទ្ធិលើដំណើរការច្បាប់[76]។ លើសពីនេះទៀត នៅក្នុងស្ថានភាពសន្មតមួយដែលថា ចៅក្រមកម្ពុជាប្រឈមនឹងការដាក់វិន័យនោះ សហព្រះរាជអាជ្ញាអះអាងថា ពួកគាត់ត្រូវប្រឈមមុខជាមួយនឹងក្រុមប្រឹក្សាវិន័យ ដែលសហព្រះរាជអាជ្ញាកម្ពុជាមិនមានតួនាទីអ្វីទាំងអស់[77]។ សហព្រះរាជអាជ្ញាលើកឡើងថា សំណើរបស់ នួន ជា ទាក់ទិននឹងចៅក្រម LAVERGNE មិនមានមូលដ្ឋាននោះទេ និងជាការវាយប្រហារជាបុគ្គលដោយគ្មានមូលដ្ឋាន ដែលមិនបានបង្ហាញពីភាពលម្អៀងឡើយ[78]។ ទាក់ទិននឹងសេចក្តីថ្លែងរបស់ចៅក្រម CARTWRIGHT នៅឯវិទ្យាស្ថាន Aspen កាលពីខែ វិច្ឆិកា ឆ្នាំ ២០១៣ នោះ សហព្រះរាជអាជ្ញាលើកឡើងថា សេចក្តីអត្ថាធិប្បាយទាំងនោះមិនបានបង្ហាញនូវភាពលម្អៀងជាក់ស្តែង និងមិនបានបង្ហាញនូវការយល់ឃើញដ៏សមហេតុផលអំពីភាពលម្អៀងរបស់ចៅក្រមកម្ពុជានោះឡើយ[79]។

---

[73] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងជំទាស់ចិត្តរបស់ នួន ជា កថាខណ្ឌ ៤៨-៥២។

[74] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងជំទាស់ចិត្តរបស់ នួន ជា កថាខណ្ឌ ៤៧។

[75] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងជំទាស់ចិត្តរបស់ នួន ជា កថាខណ្ឌ ២៩។

[76] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងជំទាស់ចិត្តរបស់ នួន ជា កថាខណ្ឌ ៥៣។

[77] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងជំទាស់ចិត្តរបស់ នួន ជា កថាខណ្ឌ ៥៦។

[78] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងជំទាស់ចិត្តរបស់ នួន ជា កថាខណ្ឌ ២៨។

[79] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងជំទាស់ចិត្តរបស់ នួន ជា កថាខណ្ឌ ២៧។

# III. សំអាងហេតុ

## ក. ភាពអាចទទួលយកបាន

២៦. អនុលោមតាមវិធានផ្ទៃក្នុង បណ្ដឹងជំទាស់អាជ្ញាយិតចិត្តត្រូវតែ "បង្ហាញឱ្យច្បាស់លាស់អំពីមូលហេតុនៃបណ្ដឹង និងត្រូវមានភ័ស្ដុតាងបញ្ជាក់ផងដែរ" និង "ត្រូវធ្វើឡើងឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅពេលណាដែលភាគីបានដឹងអំពីមូលហេតុនោះ"[80]។

២៧. សំណើរបស់ ខៀវ សំផន សុំប្ដឹងជំទាស់អាជ្ញាយិតចិត្ត ជាសំណើជាជម្រើសមួយជាមួយនឹងសំណើចម្បងរបស់គាត់ ដែលស្នើសុំឱ្យផ្អាកសំណុំរឿង ០០២/០២ រហូតដល់ពេលអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចទៅលើបណ្ដឹងសាទុក្ខផ្សេងៗទាក់ទិននឹងសំណុំរឿង០០២/០១[81] រួចរាល់។ ទោះបីជាយ៉ាងណាក៏ដោយ ក៏បណ្ដឹងជំទាស់អាជ្ញាយិតចិត្តសាជាថ្មីរបស់ ខៀវ សំផន សុំប្ដឹងជំទាស់អាជ្ញាយិតចិត្តយ៉ាងច្បាស់ និងកម្រិតសំណើរបស់គាត់សុំផ្អាកកិច្ចដំណើរការនីតិវិធីនោះ នៅត្រឹមពេលដែលមានការសម្រេចពេញលេញលើសំណើរបស់គាត់[82]។ ខៀវ សំផន ពុំបានពន្យល់អំពីមូលដ្ឋានដែលថា ការប្ដឹងជំទាស់អាជ្ញាយិតចិត្តនោះគឺជាឧបាស្រ័យជាជម្រើស ឬហេតុផលចំពោះជំហរខុសគ្នា ដែលបានលើកឡើងនៅក្នុងបណ្ដឹងជំទាស់អាជ្ញាយិតចិត្តសាជាថ្មីរបស់គាត់ឡើយ។ គាត់ក៏មិនបានផ្ដល់យុត្តិកម្មថា ហេតុអ្វីបានជាចំណុចទាំងឡាយដែលបានលើកឡើងនៅក្នុងបណ្ដឹងជំទាស់អាជ្ញាយិតចិត្តសាជាថ្មីរបស់គាត់ មិនត្រូវបានដាក់បញ្ចូលទៅក្នុងសំណើដំបូងរបស់គាត់នោះ។ ទោះបីជាយ៉ាងណាក៏ដោយ សំណើរបស់ ខៀវ សំផន ផ្ដោតទៅលើសំអាងហេតុនានានៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ដែលបានចេញនៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤។

២៨. នួន ជា លើកឡើងថា បណ្ដឹងជំទាស់អាជ្ញាយិតចិត្តរបស់គាត់អាចទទួលយកបាន ពីព្រោះបណ្ដឹងនេះផ្អែកទៅលើសាលក្រមសំណុំរឿង ០០២/០១ និងសេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី ដែលសេចក្ដីសម្រេចទាំងពីរនេះត្រូវបានចេញនៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤។ នួន ជា លើកឡើងបន្ថែមទៀត ដោយពឹងផ្អែកទៅលើសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលថា គាត់មានសិទ្ធិបង្ហាញភ័ស្ដុតាងកាលពីអតីតកាល ដើម្បី "ពន្យល់ និងគាំទ្របន្ថែមទៀត" ដល់ភ័ស្ដុតាងថ្មី នៅពេលដែលភ័ស្ដុតាងកាលពីអតីតកាលនោះ

---

[80] វិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង។

[81] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៥៤។

[82] បណ្ដឹងជំទាស់អាជ្ញាយិតចិត្តសាជាថ្មីរបស់ ខៀវ សំផន ទំព័រ ៥។

ទើបតែជាប់ពាក់ព័ន្ធផ្នែកបរិបទ ដោយសារតែព្រឹត្តិការណ៍ថ្មីៗ[83]។ បណ្តឹងជំទាស់របស់ នួន ជា ផ្អែកទៅលើសាលក្រមសំណុំរឿង ០០១ ដែលបានចេញនៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១០[84] មតិយោបល់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ LEMONDE នៅក្នុងសៀវភៅដែលបានបោះពុម្ពផ្សាយនៅក្នុងខែ មករា ឆ្នាំ ២០១៣[85] សេចក្តីថ្លែងរបស់ចៅក្រម CARTWRIGHT នៅឯវិទ្យាស្ថាន Aspen កាលពីខែ វិច្ឆិកា ឆ្នាំ ២០១៣[86] ការវាយតម្លៃរបស់គាត់ និងអ្នកផ្សេងទៀតទៅលើប្រព័ន្ធអភិបាលកិច្ចរបស់ប្រទេសកម្ពុជា[87] និងការព្រួយបារម្ភរបស់គាត់ទៅលើសញ្ជាតិរបស់ចៅក្រម និង "មនោគមន៍វិជ្ជា" នៃប្រទេសកំណើតរបស់ចៅក្រមទាំងនោះ[88]។ នួន ជា លើកឡើងថា បញ្ហាបែបនេះ "ជាប់ពាក់ព័ន្ធផ្នែកបរិបទ" ដោយសារតែសាលក្រមសំណុំរឿង ០០២/០១ និងសេចក្តីសម្រេចស្តាពរស្តីពីសាក្សី[89]។ បណ្តឹងជំទាស់សាជាថ្មីរបស់ ខៀវ សំផន ឯកភាពជាមួយនឹងការពឹងផ្អែករបស់ នួន ជា ទៅលើសៀវភៅរបស់ចៅក្រម LEMONDE សេចក្តីថ្លែងរបស់ចៅក្រម CARTWRIGHT និងសេចក្តីសម្រេចស្តាពរស្តីពីសាក្សី[90]។

២៩. នៅក្នុងសេចក្តីសម្រេចដែល នួន ជា បានផ្អែកទៅលើនោះ អង្គបុរេជំនុំជម្រះបានសម្រេចដូចខាងក្រោម៖

> ភាគីអាចបង្ហាញភ័ស្តុតាងដែលទំនងជាមានលក្ខណៈខុសគ្នាកាលពីអតីតកាល ដែលត្រូវបានគេមើលឃើញថា ជាប់ពាក់ព័ន្ធផ្នែកបរិបទជាលើកដំបូង ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ថ្មីជាច្រើន។ ដើម្បីឱ្យស្ថិតនៅក្រោមវិសាលភាពនៃវិធានផ្ទៃក្នុង ៣៤(៣) ពួកគាត់បង្ហាញភ័ស្តុតាងនេះភ្លាម នៅពេលដែលបរិបទមានភាពច្បាស់ជាក់ស្តែងចំពោះពួកគាត់ សម្រាប់ជាមូលដ្ឋាន

[83] បណ្តឹងជំទាស់របស់ នួន ជា កថាខណ្ឌ ៣៤ និង ៣៧ ដែលផ្អែកលើសាលដីកាលើបណ្តឹងជំទាស់របស់ ខៀវ សំផន ចំពោះសហចៅក្រមស៊ើបអង្កេត Marcel Lemonde (អ.ប.ជ) ឯកសារ ៧ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ("សាលដីកាលើបណ្តឹងជំទាស់ចៅក្រម Lemonde") កថាខណ្ឌ ២០។

[84] បណ្តឹងជំទាស់របស់ នួន ជា ផ្នែក ឆ កថាខណ្ឌ ១១៥-១២១, ផ្នែក ជ កថាខណ្ឌ ១២២, ផ្នែក ឈ កថាខណ្ឌ ១២៣។

[85] បណ្តឹងជំទាស់របស់ នួន ជា ផ្នែក ខ កថាខណ្ឌ ៤១, ៤៥, ផ្នែក ឈ កថាខណ្ឌ ១២៣។

[86] បណ្តឹងជំទាស់របស់ នួន ជា ផ្នែក គ កថាខណ្ឌ ៥៣-៥៧, ផ្នែក ឃ កថាខណ្ឌ ៦៨-៦៩, ផ្នែក ឈ កថាខណ្ឌ ១២៧។

[87] បណ្តឹងជំទាស់របស់ នួន ជា ផ្នែក ខ កថាខណ្ឌ ៤៤-៤៩ ដែលរួមមានការយោងទៅលើរបាយការណ៍មួយដែលចេញដោយអង្គការតម្លាភាពអន្តរជាតិ ក្នុងខែ កញ្ញា ឆ្នាំ ២០១៤។

[88] បណ្តឹងជំទាស់របស់ នួន ជា ផ្នែក គ កថាខណ្ឌ ៥៨ និងផ្នែក ឈ កថាខណ្ឌ ១២៩។

[89] បណ្តឹងជំទាស់របស់ នួន ជា កថាខណ្ឌ ៣៧, ១១៧។

[90] បណ្តឹងជំទាស់សាជាថ្មីរបស់ ខៀវ សំផន កថាខណ្ឌ ៩។

ឬជាការគាំទ្រដល់មូលហេតុ ដែលពួកគាត់ស្នើឡើង[91]។

៣០. មានមន្ទិលយ៉ាងខ្លាំងចំពោះថាតើ សាលក្រមសំណុំរឿង ០០២/០១ និងសេចក្តីសម្រេចស្តាពរ ស្តីពីសាក្សី មានន័យថា បញ្ហានានាបន្ថែមទៀតដែលបណ្តឹងជំទាស់បានពឹងផ្អែកទៅលើនោះ គួរត្រូវបាន ទទួលយកថាជាប់ពាក់ព័ន្ធផ្នែកបរិបទជាលើកដំបូង ឬយ៉ាងណា។ សាលក្រមសំណុំរឿង ០០១ គឺជា មូលដ្ឋានមួយដែល នួន ជា បានយកមកធ្វើជាសំអាង ដោយមិនទទួលបានជោគជ័យ នៅក្នុងបណ្តឹងជំទាស់ កាលពីមុន។ គាត់ក៏បានលើកឡើងផងដែរថា សេចក្តីថ្លែងរបស់ចៅក្រម CARTWRIGHT "នាំឱ្យ មានក្តីបារម្ភភ្លាមៗ" ប៉ុន្តែគាត់ "មិនបានប្រតិកម្មតបភ្លាមៗ" ដោយគ្មាន "ភស្តុតាងសំអាងបន្ថែម" ឡើយ[92]។ នួន ជា មិនបានលើកឡើងថា គាត់បានដឹងអំពីសៀវភៅរបស់ចៅក្រម LEMONDE តែនៅ ពេលថ្មីៗនេះប៉ុណ្ណោះ ឬក៏ថា សញ្ញាតិរបស់ចៅក្រម និង "មនោគមន៍វិជ្ជា" នៃប្រទេសកំណើតរបស់ ចៅក្រមទាំងនោះ គឺជាព័ត៌មានថ្មីៗនោះឡើយ។ ប្រសិនបើបញ្ហាបែបនេះត្រូវបានចាត់ទុកថាអាចបង្កើត បានជាការលេចចេញនូវភាពលម្អៀងនោះ បណ្តឹងជំទាស់គួរតែត្រូវបានធ្វើឡើងតាំងពីមុននេះយូរហើយ ពីព្រោះវាពាក់ព័ន្ធនឹងសាលក្រមសំណុំរឿង ០០១។

៣១. ទាក់ទិននឹងសាលក្រមសំណុំរឿង ០០២/០១ ប្រធានអង្គជំនុំជម្រះសាលាដំបូងបានប្រកាសនៅ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៣ ថា គាត់នឹងមិនផ្តល់អនុសាសន៍ឱ្យតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទីពីរដើម្បី ជំនុំជម្រះលើបទចោទដែលនៅសេសសល់ក្នុងសំណុំរឿង ០០២ បន្ទាប់ពីសំណុំរឿង ០០២/០១ នោះ ទេ[93]។ ដូច្នេះ ភាគីទាំងអស់បានដឹងតាំងពីយូរមកហើយអំពីគោលបំណងរបស់អង្គជំនុំជម្រះសាលា ដំបូង ក្នុងការបន្តដំណើរការដោយមានចៅក្រមដដែលនៅក្នុងសំណុំរឿង ០០២/០២ នោះ។ តាមពិត នៅក្នុងសវនាការលើវិសាលភាពនៃសំណុំរឿង ០០២/០២ នៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ មេធាវី ការពារក្តី នួន ជា បានលើកឡើងដូចខាងក្រោម៖

> សាលក្រមសំណុំរឿង ០០១ គឺមានហេតុផលគ្រប់គ្រាន់ដើម្បីធ្វើបណ្តឹងជំទាស់លើអង្គជំនុំជម្រះមិនឱ្យជំនុំជម្រះលើការទទួលខុសត្រូវរបស់ នួន ជា សម្រាប់ ស-២១។ ក៏ប៉ុន្តែ ទោះបី

[91] សាលដីកាលើបណ្តឹងជំទាស់ចៅក្រម Lemonde កថាខណ្ឌ ២០។

[92] បណ្តឹងជំទាស់របស់ នួន ជា កថាខណ្ឌ ៥៤។

[93] អនុស្សរណៈរបស់ប្រធានអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទីពីរនៅក្នុងអង្គជំនុំជម្រះសាលាដំបូងដើម្បីជំនុំជម្រះលើការចោទប្រកាន់ដែលមិនទាន់ត្រូវបានជំនុំជម្រះនៅក្នុងសំណុំរឿង ០០២ ឯកសារ E301/4 ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៣។

ជាយ៉ាងនេះក្ដី សាលក្រមសំណុំរឿង ០០១ គឺជាចំណុចចាប់ផ្ដើមតែប៉ុណ្ណោះ។ អង្គជំនុំជម្រះនឹងចេញសាលក្រមមួយក្នុងសំណុំរឿង ០០២/០១ ក្នុងពេលឆាប់ៗខាងមុខនេះ។ យើងមិនដឹងថាតើ សាលក្រមនេះនឹងមានការលើកឡើងអ្វីខ្លះនោះទេ។ ប៉ុន្តែ សេចក្ដីសន្និដ្ឋានជាច្រើន បានជំរុញឱ្យអង្គជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ លើកឡើងអំពីរចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា តួនាទីរបស់ នួន ជា គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលវាប៉ះពាល់ដល់ភាពអព្យាក្រឹតរបស់អង្គជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០២ [...]។ បញ្ហាអព្យាក្រឹតភាព គឺវាមានសារៈសំខាន់ណាស់ ពាក់ព័ន្ធទៅនឹងអង្គហេតុដែលនៅសល់នៅក្នុងដីកាដំណោះស្រាយ។ ប្រសិនបើអង្គជំនុំជម្រះផ្ដន្ទាទោស នួន ជា ចំពោះឧក្រិដ្ឋកម្មនានាដែល ត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១, ប្រសិនបើអង្គជំនុំជម្រះសម្រេចថា គាត់បានប្រព្រឹត្តដោយមានចេតនាឧក្រិដ្ឋ បង្កព្យសនកម្មទៅលើប្រជាជនរាប់រយពាន់នាក់នោះ ថាតើយើងអាចមើលឃើញវិធីសាស្ត្រដោះស្រាយរបស់អង្គជំនុំជម្រះចំពោះការទទួលខុសត្រូវរបស់ នួន ជា នៅក្នុងសំណុំរឿង ០០២/០២ ក្នុងលក្ខណៈអព្យាក្រឹតដោយរបៀបណា?[94]។

៣២. ការពន្យារពេលដ៏អាក្រក់បំផុត កើតមានឡើងនៅពេលដែលភាគីមួយដឹងរួចហើយអំពីអង្គហេតុដែលអះអាងថាបង្ហាញឱ្យឃើញពីការលេចចេញនូវភាពលម្អៀង ប៉ុន្តែភាគីនោះរង់ចាំរហូតដល់ក្រោយពីមានការចេញសេចក្ដីសម្រេចជាអវិជ្ជមាន ទើបលើកឡើងនូវបញ្ហានៃការប្ដឹងជំទាស់ចៅក្រម[95]។ ទោះបីយ៉ាងណាក៏ដោយ មូលហេតុជាច្រើននៅក្នុងបណ្ដឹងជំទាស់ចៅក្រម ផ្អែកទៅលើសំអាងហេតុជាក់លាក់នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ និងសេចក្ដីសម្រេចស្ដីពីសាក្សី ដែលជាក់ស្ដែងគេអាចដឹងបានតែនៅពេលមានការផ្សព្វផ្សាយជាសាធារណៈនៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ប៉ុណ្ណោះ។ ទោះបីជាមានមន្ទិលទាក់ទិនទៅនឹងការពឹងផ្អែករបស់ នួន ជា ទៅលើបញ្ហាប្រវត្តិសាស្ត្រនានា និងវិធីសាស្ត្រមិនច្បាស់លាស់នៅក្នុងសំណើ និងបណ្ដឹងជំទាស់ចៅក្រមសាជាថ្មីរបស់ ខៀវ សំផន ក៏ដោយ ក៏ជារួម ការទទួលយកបណ្ដឹងជំទាស់ចៅក្រមទាំងអស់ និងឆ្លើយតបចំពោះសំណើនានាដែលបានលើកឡើងនោះ គឺជាផលប្រយោជន៍នៃយុត្តិធម៌។

---

[94] ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ E1/239.1 ទំព័រ ៤៨-៥០ (ភាសាអង់គ្លេស)។

[95] រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Mladić* ប្រធានតុលាការ ICTY សំណុំរឿងលេខ IT-09-92-PT ដីកាសម្រេចបដិសេធញត្តិរបស់មេធាវីការពារក្ដី អនុលោមតាមវិធាន ១៥(ខ) ស្នើសុំប្ដឹងជំទាស់ចៅក្រមជំនុំជម្រះ Alphons Orie និងសុំផ្អាកកិច្ចដំណើរការនីតិវិធី ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១២ *("សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចៅក្រមរបស់ Mladić ប្ដឹងជំទាស់ចៅក្រម Orie")*, របាយការណ៍របស់ចៅក្រម Orie អនុលោមតាមវិធាន ១៥(ខ) ឧបសម្ព័ន្ធកោសលុប សាធារណៈ កថាខណ្ឌ ៤។

## ខ. ក្របខណ្ឌគតិយុត្ត

៣៣. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌រួមមានសិទ្ធិទទួលបានការជំនុំជម្រះដោយសាលាក្ដីមួយឯករាជ្យ និងមិនលម្អៀងផងដែរ[96]។ វិធាន ៣៤(២) នៃវិធានផ្ទៃក្នុងចែងថា "ភាគីអាចធ្វើបណ្ដឹងជំទាស់ចិត្តចំពោះសហចៅក្រមស៊ើបសួរ ឬ ចៅក្រមនៃអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង ឬ អង្គជំនុំជម្រះតុលាការកំពូលក្នុងករណីណាមួយដែលចៅក្រមរូបនោះមាន ឬ ធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬ ហិរញ្ញវត្ថុ ឬ មានការពាក់ព័ន្ធ ដែលអាចធ្វើឱ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬអាចបង្កើតឱ្យមានភាពលំអៀង"[97]។ អង្គជំនុំជម្រះតុលាការកំពូលបានអនុវត្តតាមក្រមខណ្ឌខាងក្រោមទាក់ទងនឹងការលេចឡើងនូវភាពលម្អៀង៖

> យុត្តិសាស្ត្ររបស់ អ.វ.ត.ក និងតុលាការអន្តរជាតិផ្សេងទៀត បានសម្រេចដោយមានភាពស៊ីសង្វាក់គ្នាថា លក្ខណវិនិច្ឆ័យនៃអនាគតិត្រូវបានរំលោភមិនមែនចាំបាច់តែចៅក្រមនោះមានភាពលំអៀងជាក់ស្ដែងនោះទេ គឺគ្រាន់តែស្ដែងចេញឱ្យឃើញអំពីភាពលម្អៀងក៏បានដែរ។ ការស្ដែងចេញឱ្យឃើញនូវភាពលម្អៀងរួមមាន (ក) ចៅក្រមរូបនោះគឺជាភាគីណាមួយក្នុងរឿងក្ដី ឬ មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬ ហិរញ្ញវត្ថុចំពោះលទ្ធផលនៃរឿងក្ដី ឬប្រសិនបើការសម្រេចរបស់ចៅក្រមរូបនោះនឹងនាំឱ្យកើតចេញនូវបុព្វហេតុអ្វីមួយទៀតដែលចៅក្រមរូបនោះមានការ

---

[96] មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦ អង្គការសហប្រជាជាតិ កម្រងសន្ធិសញ្ញា វ៉ុល ៩៩៩ ទំព័រ ១៧១ ("កតិកាសញ្ញាអន្តរជាតិ")។ សេចក្ដីសម្រេចលើបណ្ដឹងរបស់លោកអៀង សារី ដែលប្ដឹងជំទាស់ចិត្តចំពោះលោកចៅក្រម និល ណុន និងសំណើពាក់ព័ន្ធផ្សេងៗ (អ.ជ.ស.ដ) ឯកសារ E5/3 ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ កថាខណ្ឌ ៥។

[97] សូមមើល សេចក្ដីសម្រេចទាំងអស់ក្នុងរឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Radoslav Brđanin និង Momir Talić* អង្គជំនុំជម្រះសាលាដំបូង II នៃតុលាការ ICTY រឿងក្ដីលេខ IT-99-36-PT សេចក្ដីសម្រេចលើបណ្ដឹងរបស់ *Momir Talić* ប្ដឹងជំទាស់ចិត្ត និងប្ដឹងដកចៅក្រម ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០០ *("សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចិត្តរបស់ Brđanin និង Talić")*។ ចៅក្រម Hunt បានកត់សម្គាល់ពាក់ព័ន្ធនឹងបទប្បញ្ញត្តិដែលមានពាក្យពេចន៍ស្រដៀងគ្នានៅក្នុងវិធានស្ដីពីនីតិវិធីរបស់តុលាការ ICTY ថា ចំពោះទស្សនៈមួយ បទប្បញ្ញត្តិបានយោងលើតែអត្ថិភាពនៃភាពលម្អៀងជាក់ស្ដែង។ ក៏ប៉ុន្តែ ចៅក្រម Hunt បានសន្និដ្ឋានថា បទប្បញ្ញត្តិនេះមានចេតនាឆ្លុះបញ្ចាំងអំពីមូលដ្ឋានទូលំទូលាយជាងនេះសម្រាប់ការប្ដឹងជំទាស់ចិត្តដោយផ្អែកលើមូលដ្ឋាននៃការយល់ពីភាពលម្អៀងដ៏សមហេតុផល។ ចៅក្រម Hunt បានសន្និដ្ឋានថា មូលដ្ឋាននេះត្រូវបានទទួលស្គាល់នៅក្នុងប្រព័ន្ធច្បាប់ខំមិនឡ និងប្រព័ន្ធច្បាប់ស៊ីវិលឡ និងអនុលោមតាមអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប។ សូមមើល កថាខណ្ឌ ៨ ១៤ ១៩។ *សូមមើល ផងដែរ រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង Furundžija* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY រឿងក្ដីលេខ IT-95-17/1-A សាលដីកា ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០ *("សាលដីកា Furundžija")* កថាខណ្ឌ ១៨៩។

ពាក់ព័ន្ធឬ (ខ) កាលៈទេសៈទាំងនោះដែលធ្វើឱ្យអ្នកសង្កេតការណ៍មិនលម្អៀងម្នាក់ដែលបានទទួលព័ត៌មានគ្រប់គ្រាន់យល់ឃើញដោយសមហេតុផលថាមានភាពលម្អៀង។

អ្នកសង្កេតការណ៍មិនលម្អៀង ដែលឆ្លើយតបនឹងលក្ខណវិនិច្ឆ័យនេះត្រូវតែជា "បុគ្គលដែលបានទទួលព័ត៌មានគ្រប់កាលៈទេសៈពាក់ព័ន្ធទាំងអស់ ដោយរួមបញ្ចូលទាំងប្រពៃណីនៃសេចក្តីថ្លៃថ្នូរ និងភាពអនាគតិ ហើយអ្នកសង្កេតការណ៍នោះយល់ថា អនាគតិគឺជាភារកិច្ចមួយក្នុងចំណោមភារកិច្ចនានាដែលចៅក្រមត្រូវប្រកាន់យកឱ្យបានខ្ជាប់ខ្ជួន"។ ដូចដែលបានកត់សម្គាល់នៅក្នុងយុត្តិសាស្ត្រពីមុនរបស់ អ.វ.ត.ក ថា ចំណុចចាប់ផ្តើមនៃការកំណត់អំពីភាពលម្អៀងរបស់ចៅក្រមគឺការសន្មតជាមុនអំពីភាពមិនលម្អៀងដែលមានចំពោះចៅក្រមដោយផ្អែកលើការធ្វើសច្ចាប្រណិធានចូលកាន់តំណែងរបស់ចៅក្រម និងលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការតែងតាំងពួកគាត់ជាចៅក្រមនោះ[98]។

៣៤. ដូចបង្ហាញខាងក្រោម ភាគីបានដាក់សំណើដែលប្រទាញប្រទង់គ្នាពាក់ព័ន្ធនឹងផ្នែកផ្សេងៗនៃក្របខណ្ឌច្បាប់ដែលត្រូវយកមកអនុវត្ត។ បណ្តឹងជំទាស់ចិត្តសំអាងលើរឿងក្តីអន្តរជាតិ និងរឿងក្តីជាតិមួយចំនួនដើម្បីជាមូលដ្ឋានគាំទ្រលើសេចក្តីសន្និដ្ឋានថា ចៅក្រមដែលត្រូវបានប្តឹងជំទាស់ចិត្តគឺពិតជាលម្អៀង ឬថា អ្នកសង្កេតការណ៍មិនលម្អៀងយល់ថាមានភាពលម្អៀង ប្រសិនបើចៅក្រមទាំងនេះជំនុំ-ជម្រះសំណុំរឿង ០០២/០២។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បានបង្កើតស្ថានភាព "តែមួយគត់"[99] ឬ "ពិសេសប្លែកពីគេ"[100] ដែលនៅក្នុងស្ថាន-ភាពនេះ ជនជាប់ចោទនៅតាមសាលាក្តីអន្តរជាតិ ឬ អន្តរជាតូបនីយកម្ម ពុំដែលធ្លាប់ត្រូវបានជំនុំជម្រះជាលើកទីពីរដោយផ្អែកលើការចោទប្រកាន់ដែលជាផ្នែកមួយនៃឯកសារចោទប្រកាន់តែមួយនោះទេ។ សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា យុត្តិសាស្ត្រអន្តរជាតិផ្តល់គោលការណ៍ណែនាំតិចតួចអំពីករណីថាតើជនជាប់ចោទអាចត្រូវបានជំនុំជម្រះដោយចៅក្រមដដែល នៅក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះ

[98] សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ ប្តឹងជំទាស់ចិត្តចៅក្រម សោម សិរីវឌ្ឍ ដោយសារពុំមានភាពឯករាជ្យ (អ.ជ.ត.ក) ឯកសារ I/4 ចុះថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១១ *("សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ ប្តឹងជំទាស់ចិត្តចៅក្រម សោម សិរីវឌ្ឍ")* កថាខណ្ឌ ១០ ដែលបានយកតាមសេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ នួន ជា និង អៀង សារី ដែលប្តឹងជំទាស់ចិត្តចំពោះលោកចៅក្រម និល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី ឯកសារ E55/4 ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១១ *("សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តរបស់ អៀង ធីរិទ្ធ នួន ជា និង អៀង សារី")* កថាខណ្ឌ ១១-១២។

[99] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងរបស់ ខៀវ សំផន កថាខណ្ឌ ១៧។

[100] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងជំទាស់ចិត្តរបស់ នួន ជា កថាខណ្ឌ ១៤។

ទាំងពីរដែរ ឬទេ។ ទោះជាយ៉ាងណា សហព្រះរាជអាជ្ញាបានសំអាងលើសេចក្តីសម្រេចពីតុលាការជាតិជាពិសេស សហរដ្ឋអាមេរិក[101]។ សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា យុត្តិសាស្ត្រ [អន្តរជាតិ] ជាច្រើនមិនអាចយកមកប្រើប្រាស់បាននោះទេ ពីព្រោះវាពាក់ព័ន្ធទៅនឹងចៅក្រមដែលបានវិនិច្ឆ័យរឿងក្តីមុនៗដែលជនជាប់ចោទស្ថិតនៅក្នុងសំណុំរឿងផ្សេងគ្នា ដែលផ្ទុយពីករណីនៅ អ.វ.ត.ក ដោយសារតែជនជាប់ចោទបច្ចុប្បន្នស្ថិតនៅក្នុងសំណុំរឿងតែមួយ ០០២។ ក្នុងករណីខាងលើនេះ ហានិភ័យគឺនៅត្រង់ថាចៅក្រមបានចេញសេចក្តីសម្រេចរបស់ខ្លួនដោយមិនផ្តល់ឱកាសឱ្យជនជាប់ចោទតវ៉ាឡើយសម្រាប់ការជំនុំជម្រះនៅក្នុងរឿងក្តីមុន។ ផ្ទុយមកវិញ នួន ជា និង ខៀវ សំផន បានចូលរួមនៅក្នុងសំណុំរឿង ០០២/០១។

## (១) ការសន្មតអំពីភាពមិនលម្អៀង

៣៥. នួន ជា បានសន្និដ្ឋានថា ការសន្មតអំពីភាពមិនលម្អៀងដែលត្រូវបានចោទប្រកាន់ មិនតម្រូវឱ្យបង្ហាញភស្តុតាងជាក់លាក់នោះឡើយ[102]។ សេចក្តីសន្និដ្ឋាននេះត្រូវបានច្រាលចោល។ បណ្តឹងរបស់ នួន ជា សំអាងលើកថាខណ្ឌមួយពីក្នុងសេចក្តីសម្រេចមួយរបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ SCSL[103]។ នៅក្នុងសេចក្តីសម្រេចនោះ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ SCSL បានពិចារណាថា តើការលេចឡើងដោយសន្យានុម័តនូវភាពលម្អៀងអាចត្រូវបានបញ្ជាក់ដោយសមហេតុផលលើអង្គហេតុដែរ ឬទេ ហើយបានសន្និដ្ឋានថាមិនដូច្នេះទេ[104]។ នៅពេលសន្និដ្ឋានដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ SCSL បានអនុវត្តរឿងក្តីនានាដែលលើកឡើងយ៉ាងច្បាស់ថា អ្នក

---

[101] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងរបស់ ខៀវ សំផន កថាខណ្ឌ ១៧-១៨។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងរបស់ នួន ជា កថាខណ្ឌ ១៥-១៦។

[102] បណ្តឹងរបស់ នួន ជា កថាខណ្ឌ ១៩។

[103] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Sesay និងអ្នកផ្សេងទៀត* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ SCSL រឿងក្តីលេខ SCSL-04-15-T សាលដីកាប្រឆាំងនឹងសេចក្តីសម្រេចលើសំណើរបស់ Sesay, Kallon និង Gbao សុំប្តឹងជំទាស់ ឬឱ្យចៅក្រម Bankole Thompson ដកខ្លួនដោយស្ម័គ្រចិត្ត ពីរឿងក្តី RUF ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០៨ *("សាលដីកាប្រឆាំងនឹង*
*សេចក្តីសម្រេចលើបណ្តឹងរបស់ Sesay ប្តឹងជំទាស់ចៅក្រម Thompson")* កថាខណ្ឌ ១៣។

[104] *សាលដីកាប្រឆាំងនឹងសេចក្តីសម្រេចលើបណ្តឹងរបស់ Sesay ប្តឹងជំទាស់ចៅក្រម Thompson* កថាខណ្ឌ ១៤ ("បញ្ហាចោទបន្ទាប់សម្រាប់អង្គជំនុំជម្រះតុលាការកំពូលគឺថាតើកំហុសនេះធ្វើឱ្យសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមោឃៈឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលរកឃើញថា គ្មានការលេចឡើងជាសន្យានុម័តនូវភាពលម្អៀងដែលអាចបញ្ជាក់ដោយសមហេតុពីមតិយោបល់ដោយឡែកពីចៅក្រម Thompson"។

សង្កេតការណ៍មិនលម្អៀងសន្មតថាចៅក្រមមិនលម្អៀង ហើយការចោទប្រកាន់ថា អ្នកសង្កេតការណ៍មិនលម្អៀងនឹងយល់ថាមានភាពលម្អៀង ត្រូវតែ "បង្ហាញឱ្យបានច្បាស់" តាមរយៈភស្តុតាង[105]។ លក្ខខណ្ឌខ្ពស់នេះតម្រូវឱ្យមាន ពីព្រោះថា វាជាការគំរាមខ្លាំងមកលើផលប្រយោជន៍នៃការស្វែងរកយុត្តិធម៌ដោយមិនលម្អៀង និងយុត្តិធម៌ចំពោះចៅក្រមដែលត្រូវបានប្តឹងជំទាស់ ដោយផ្អែកលើការចោទប្រកាន់ដោយគ្មានមូលដ្ឋាន និងគ្មានភស្តុតាងគាំទ្រអំពីភាពលម្អៀងនោះ[106]។ ប្រសិនបើពុំមានភស្តុតាងផ្ទុយទេនោះ គេសន្មតថា ចៅក្រមអាចមិនមានទស្សនៈ បុរេវិនិច្ឆ័យ និងជំនឿផ្ទាល់ខ្លួនដែលពុំពាក់ព័ន្ធ ហើយចៅក្រមនឹងសម្រេចយ៉ាងយុត្តិធម៌លើបញ្ហានានានៅចំពោះមុខខ្លួន ដោយសំអាងតែទៅលើភស្តុ-

---

[105] *សូមមើល* រឿងក្តីនានាដែលត្រូវបានដកស្រង់នៅក្នុងលេខយោងជើងទំព័រ ២៥ នៃ*សាលដីកាប្រឆាំងនឹងសេចក្តីសម្រេចលើបណ្តឹងរបស់ Sesay ប្តឹងជំទាស់ចៅក្រម Thompson* ឧទាហរណ៍ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Norman* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ SCSL រឿងក្តីលេខ SCSL-2004-14-AR72(E) សេចក្តីសម្រេចលើសំណើសុំដកចៅក្រម Winter ពីការពិភាក្សាសម្រេចនៅក្នុងសំណើសុំបឋមលើការជ្រើសរើសទាហានកុមារ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៤ កថាខណ្ឌ ២៥ ("ចំណុចចាប់ផ្តើមសម្រាប់ការសម្រេចលើ [ការអះអាងអំពីការលេចឡើងនៃភាពលម្អៀង] គឺសច្ចធារណ៍នៃអនាគតិមានជាប់ជាមួយនឹងចៅក្រម [ដោយសារ] ចៅក្រមធ្វើសច្ចាប្រណិធាននៅពេលចូលកាន់មុខតំណែង និងគុណវុឌ្ឍិ[នៃ]ការតែងតាំងចៅក្រម [ដែល]បានដាក់បន្ទុកធ្ងន់លើភាគីធ្វើបណ្តឹងជំទាស់ចៅក្រមដើម្បីច្រានចោលសច្ចធារណ៍នេះ")។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Delalic និងអ្នកផ្សេងទៀត* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY រឿងក្តីលេខ IT-96-21-A សាលដីកា ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ៧០៧ ("មានលក្ខខណ្ឌខ្ពស់ដើម្បីជំទាស់សច្ចធារណ៍នៃអនាគតិ ពីព្រោះថា [ដោយសារការលេចឡើងជាក់ស្តែងនៃភាពលម្អៀងធ្វើឱ្យប៉ះពាល់លើ]ភាពជឿជាក់នៅក្នុងការស្វែងរកយុត្តិធម៌ [ចៅក្រមមិនគួរ]ជំទាស់ខ្លួនឯងដោយផ្អែកលើមូលដ្ឋាននៃការចោទប្រកាន់ដោយគ្មានមូលដ្ឋាន និងគ្មានឯកសារគាំទ្រនៃភាពលម្អៀងជាក់ស្តែង")៖ សាលដីកា *Furundžija* កថាខណ្ឌ ១៩៧ ("មានលក្ខខណ្ឌខ្ពស់ដើម្បីជំទាស់សច្ចធារណ៍នៃភាពលម្អៀង")។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Radoslav Brđanin* ការិយាល័យតុលាការ ICTY រឿងក្តីលេខ IT-99-36-R77 សេចក្តីសម្រេចលើបណ្តឹងជំទាស់ (ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៤) កថាខណ្ឌ ៧-៨ (អ្នកសង្កេតការណ៍មិនលម្អៀងត្រូវជាបុគ្គលដែលមានចំណេះដឹងគ្រប់គ្រាន់អំពីកាលៈទេសៈពាក់ព័ន្ធទាំងអស់ រួមទាំងប្រពៃណីនៃសុចរិតភាព និងអនាគតិ [... ហើយ] ករណីដែលថា អនាគតិគឺជាភារកិច្ចមួយដែលចៅក្រមសន្យាថានឹងគោរពខ្ជាប់ខ្លួន", "ដើម្បីជំទាស់សច្ចធារណ៍នៃអនាគតិ ការយល់ឃើញសមហេតុផលនៃអនាគតិត្រូវបង្ហាញឱ្យឃើញច្បាស់លាស់")។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karemera និងអ្នកផ្សេងទៀត* ការិយាល័យតុលាការ ICTY រឿងក្តីលេខ ICTR-98-44 សេចក្តីសម្រេចលើបណ្តឹងរបស់ *Karemera* ប្តឹងជំទាស់ចៅក្រមជំនុំជម្រះ ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៤ កថាខណ្ឌ ៨-១០ ("ចៅក្រម [...] ទទួលបានសច្ចធារណ៍នៃអនាគតិដោយផ្អែកលើការធ្វើសច្ចាប្រណិធាននៅពេលចូលកាន់តំណែង និងគុណវុឌ្ឍិ")។

[106] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karadžić* អង្គជំនុំជម្រះតុលាការ ICTY ត្រូវបានរៀបចំឡើងដោយសេចក្តីបង្គាប់របស់អនុប្រធាន រឿងក្តីលេខ IT-95-5/18-PT សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម Picard និងរបាយការណ៍ជូនអនុប្រធានអនុលោមវិធាន ១៥(ខ)(ii) ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៩ *("សេចក្តីសម្រេចលើបណ្តឹងជំទាស់ Karadžić")* កថាខណ្ឌ ១៧ និងឯកសារសំអាងដូចដែលបានដកស្រង់នៅក្នុងនោះ។

តាងដែលបានបង្ហាញនៅក្នុងរឿងក្តីជាក់លាក់តែប៉ុណ្ណោះ[107]។

### (២) ការចោទប្រកាន់អំពីភាពលម្អៀងដោយផ្អែកទៅលើសេចក្តីសម្រេចរបស់តុលាការ

៣៦. នៅពេលការចោទប្រកាន់អំពីភាពលម្អៀងផ្អែកលើសេចក្តីសម្រេចរបស់ចៅក្រម ភាគីមិនមានមូលដ្ឋានគ្រប់គ្រាន់ដោយគ្រាន់តែចោទប្រកាន់ថា សេចក្តីសម្រេចទាំងនេះមានកំហុសនោះទេ។ ការខ្វែងយោបល់គ្នាលើអង្គសេចក្តីនៃសេចក្តីសម្រេចមួយ គឺជាកម្មវត្ថុនៃបណ្តឹងសាទុក្ខ មិនមែនជាកម្មវត្ថុនៃបណ្តឹងជំទាស់ចៅក្រមនោះឡើយ[108]។ អ្វីដែលត្រូវបង្ហាញនោះគឺថា សេចក្តីសម្រេចទាំងនេះត្រូវបាន ឬ នឹងត្រូវបានយល់ឃើញយ៉ាងសមហេតុផលថា ជាលទ្ធផលនៃបុរេវិនិច្ឆ័យប្រឆាំងនឹងម្ចាស់បណ្តឹង ដែលមិនមែនជាការអនុវត្តច្បាប់ពិតប្រាកដ ផ្អែកលើលទ្ធផលនៃបកស្រាយច្បាប់ ឬការវាយតម្លៃរបស់ចៅក្រមលើនោះទៅលើអង្គហេតុនានា[109]។ សេចក្តីសម្រេចរបស់តុលាការដែលត្រូវបានដកស្រង់មកធ្វើជាភ័ស្តុតាងនៃភាពលម្អៀងគួរត្រូវពិនិត្យមើលឡើងវិញ ប៉ុន្តែគោលបំណងនៃការពិនិត្យមើលឡើងវិញនោះគឺមិនមែនដើម្បីរកកំហុសនោះទេ ប៉ុន្តែដើម្បីកំណត់ថាតើកំហុសទាំងនោះ ប្រសិនបើរកឃើញ បង្ហាញថាចៅក្រមរូបនោះពិតជាមានភាពលម្អៀងដែរ ឬទេ ហើយអ្នកសង្កេតការណ៍មិនលម្អៀងដែលយល់ដឹងអំពីកាលៈទេសៈពាក់ព័ន្ធ នឹងយល់ឃើញអំពីភាពលម្អៀងនេះប្រកបដោយហេតុផលដែរ ឬទេ[110]។ ការដែលជនជាប់ចោទត្រឹមតែសង្ស័យថា មានភាពលម្អៀង មិនមានភាពគ្រប់គ្រាន់នោះទេ។ លក្ខខណ្ឌ

---

[107] សាលដីកា *Furundžija* កថាខណ្ឌ ១៩៧។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Akayesu* អង្គជំនុំជម្រះតុលាការកំពូល ICTR រឿងក្តីលេខ ICTR096-4-A សាលដីកា ចុះថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០១ កថាខណ្ឌ ២៦៩។

[108] សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ នួន ជា និង អៀង សារី ដែលប្តឹងជំទាស់ចំពោះលោកចៅក្រម និល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី ឯកសារ E55/4 ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១១ កថាខណ្ឌ ១៣។ សាលដីកាលើបណ្តឹងជំទាស់របស់ ខៀវ សំផន ចំពោះសហចៅក្រមស៊ើបអង្កេត Marcel LEMONDE សំណុំរឿង ០០២/១៣-១០-២០០៩-អ.វ.ត.ក/អ.ប.ជ (០២) ឯកសារលេខ ៧ ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ កថាខណ្ឌ ៣៥។

[109] សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ នួន ជា និង អៀង សារី ដែលប្តឹងជំទាស់ចំពោះលោកចៅក្រម និល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី ឯកសារ E55/4 ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១១ កថាខណ្ឌ ១៣។ សាលដីកាលើបណ្តឹងជំទាស់របស់ ខៀវ សំផន ចំពោះសហចៅក្រមស៊ើបអង្កេត Marcel LEMONDE សំណុំរឿង ០០២/១៣-១០-២០០៩-អ.វ.ត.ក/អ.ប.ជ (០២) ឯកសារលេខ ៧ ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ កថាខណ្ឌ ៣៤។

[110] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Seromba* រឿងក្តីលេខ ICTR-2001-66-T សេចក្តីសម្រេចលើសំណើសុំប្តឹងជំទាស់ចៅក្រម (ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៦) កថាខណ្ឌ ១២។

តម្រូវនោះគឺការយល់ឃើញអំពីភាពលម្អៀងដែលមានហេតុផលត្រឹមត្រូវ និងមិនលម្អៀង ផ្អែកលើការយល់ដឹងអំពីកាលៈទេសៈពាក់ព័ន្ធទាំងអស់[111]។

**(៤) បុរេវិនិច្ឆ័យ ការសម្រេចជាមុន ឬការបង្កើតទស្សនៈជាមុន?**

៣៧. នួន ជា បានអះអាង[112]ថា យុត្តិសាស្ត្របង្ហាញថា ការលេចឡើងនូវភាពលម្អៀង អាចត្រូវបានបង្ហាញតាមរយៈ (i) បុរេវិនិច្ឆ័យលើពិរុទ្ធភាពនៅក្នុងសាលក្រមរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបក្នុងរឿងក្ដី *Ferrantelli និង Satangelo ទល់នឹង ប្រទេសអ៊ីតាលី*[113] និងរឿងក្ដី *Pope ទល់នឹង ប្រទេសហូឡង់* ដែល នួន ជា បានសំអាងលើ ហើយ នួន ជា បានសន្និដ្ឋានថា ការច្រាលចោលបណ្ដឹងជំទាស់ចៅក្រមនាពេលមុនរបស់ខ្លួនបានផ្អែកលើការបកស្រាយខុសលើរឿងក្ដី *Pope ទល់នឹង ប្រទេសហូឡង់* (ii) ការសម្រេចជាមុនលើបញ្ហានានាអំពីពិរុទ្ធភាព ទាក់ទងនឹងមតិជំទាស់ដោយចៅក្រម *Buergenthal* លើសមាសភាពតុលាការនៅក្នុងរឿងក្ដីរបស់តុលាការយុត្តិធម៌អន្តរជាតិស្ដីអំពីសមាសភាពតុលាការនៅក្នុងរឿងក្ដីរបស់តុលាការយុត្តិធម៌អន្តរជាតិ ដែល នួន ជា សំអាងលើ ពោលគឺរឿងក្ដី *ផលវិបាកផ្លូវច្បាប់នៃការសាងសង់ជញ្ជាំងនៅក្នុងទឹកដីដែល ប៉ាលេស្ទីនកាន់កាប់*[114] ឬ *(iii)* ការបង្កើតទស្សនៈអវិជ្ជមានជាមុនលើរឿងក្ដីរបស់ភាគី ទាក់ទងនឹងសាលក្រមរបស់តុលាការសិទ្ធិមនុស្សអន្តរជាតិនៅក្នុងរឿងក្ដី *Buscemi ទល់នឹង ប្រទេសអ៊ីតាលី*[115] និងរឿងក្ដី *Kyprianou ទល់នឹង ប្រទេសសាយប្រ៊ីស*[116] ដែល នួន ជា បានសំអាង។

---

[111] រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Bagosora និងអ្នកផ្សេងទៀត* រឿងក្ដីលេខ ICTR-98-41-T សេចក្ដីសម្រេចលើសំណើសុំប្ដឹងជំទាស់ចៅក្រម (ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៧) កថាខណ្ឌ ៧។

[112] បណ្ដឹងជំទាស់ចៅក្រមរបស់ នួន ជា កថាខណ្ឌ ២៩-៣២។

[113] រឿងក្ដី *Ferrantelli និង Santangelo តទល់នឹងប្រទេសអ៊ីតាលី* តុលាការ ECtHR សំណើលេខ 19874/92 សាលក្រមចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៦ *("សាលក្រមលើរឿងក្ដី Ferrantelli និង Santangelo តទល់នឹងប្រទេសអ៊ីតាលី")*។

[114] *ផលវិបាកផ្នែកច្បាប់នៃការសាងសង់ជញ្ជាំងនៅក្នុងទឹកដីដែលប៉ាឡេស្ទីនកាន់កាប់* ដីកាចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៤ របាយការណ៍របស់តុលាការយុត្តិធម៌អន្តរជាតិ ឆ្នាំ ២០០៤ មតិជំទាស់របស់ចៅក្រម Buergenthal ទំព័រ ៨ កថាខណ្ឌ ១៣។

[115] រឿងក្ដី *Buscemi តទល់នឹងប្រទេសអ៊ីតាលី* សាលក្រម តុលាការ ECtHR សំណើលេខ 29569/95 ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៩៩ *("សាលក្រមលើរឿងក្ដី Buscemi តទល់នឹងប្រទេសអ៊ីតាលី")*។

[116] រឿងក្ដី *Kyprianou ទល់នឹង ប្រទេសសាយប្រ៊ីស* សាលក្រម តុលាការ ECtHR សំណើលេខ 73797/01 ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៥។

៣៨. ទាក់ទងនឹងចំណុច (i) បុរេវិនិច្ឆ័យទៅលើពិរុទ្ធភាពនោះ នួន ជា និងសហព្រះរាជអាជ្ញា លើកឡើងការបកស្រាយខុសៗគ្នាអំពីពេលដែលពិរុទ្ធភាពត្រូវបានធ្វើឡើងដោយមានបុរេវិនិច្ឆ័យ។ នួន ជា អះអាងថា ពុំចាំបាច់ថាត្រូវចៅក្រមមានបុរេវិនិច្ឆ័យលើរាល់ធាតុផ្សំនៃឧក្រិដ្ឋកម្មដែលជនជាប់ចោទត្រូវបានចោទប្រកាន់នោះឡើយ[117]។ នួន ជា បានសន្និដ្ឋានថា មានភាពគ្រប់គ្រាន់នៅពេលចៅក្រមបានបង្កើតជាមុននូវការ "សន្និដ្ឋានទូទៅជាមុនអំពីគុណវុឌ្ឍិនៃការជាប់ពាក់ព័ន្ធរបស់ជនជាប់ចោទ ឧក្រិដ្ឋជន ឬ ផ្សេងពីនេះ"[118]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា "ការធ្វើបុរេវិនិច្ឆ័យចំពោះធាតុផ្សំទូទៅ និងធាតុផ្សំនីមួយៗនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ គឺជាលក្ខខណ្ឌតម្រូវមួយដែលនាំឱ្យមានការលេចឡើងនូវភាពលម្អៀងដែលមិនអាចទទួលយកបាន"[119]។ ការបកស្រាយប្រទាញប្រទង់គ្នាទាំងពីរនេះ សំអាងលើរឿងក្ដី *Poppe ទល់នឹង ប្រទេសហូឡង់* នៅតុលាការសិទ្ធិមនុស្សអឺរ៉ុប ដូចគ្នា។

៣៩. រឿងក្ដី *Poppe ទល់នឹង ប្រទេសហូឡង់* ជាប់ទាក់ទងនឹងបណ្ដឹងតវ៉ាអំពីបុរេវិនិច្ឆ័យ ពីព្រោះចៅក្រមពីររូបដែលចូលរួមជំនុំជម្រះអ្នកដាក់បណ្ដឹងតវ៉ាលើបទល្មើសទាក់ទងនឹងគ្រឿងញៀន ធ្លាប់បានសម្រេចនាពេលមុនឱ្យអ្នកសមគំនិតរបស់អ្នកដាក់បណ្ដឹងតវ៉ានេះមានពិរុទ្ធភាព ហើយដើម្បីសម្រេចដូច្នេះបាន ចៅក្រមបានយោងលើការចូលរួមរបស់អ្នកដាក់បណ្ដឹងតវ៉ា[120]។ ចៅក្រមភាគច្រើននៅតុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា សំអាងហេតុនៅក្នុងសាលក្រមមុន ពិតជាពុំមានបុរេវិនិច្ឆ័យលើពិរុទ្ធភាពរបស់អ្នកដាក់បណ្ដឹងតវ៉ានោះឡើយ។ នួន ជា និងសហព្រះរាជអាជ្ញា សំអាងលើកថាខណ្ឌខាងក្រោមក្នុងទិដ្ឋភាពខុសគ្នា៖

> នៅក្នុងសាលក្រមទាំងពីរ ឈ្មោះរបស់អ្នកដាក់បណ្ដឹងតវ៉ា និងអ្នកផ្សេងទៀត ត្រូវបានលើកឡើងដោយសង្ខេបដើម្បីបង្ហាញ និងបញ្ជាក់បំភ្លឺអំពីតួនាទីដឹកនាំដែលពិរុទ្ធជនបានបំពេញនៅក្នុងអង្គការឧក្រិដ្ឋ ពោលគឺ នៅ C3 និង C4។ ករណីថាតើអ្នកដាក់បណ្ដឹងតវ៉ាបានចូលរួមជាមួយ C3 និង D បានបំពេញលក្ខណវិនិច្ឆ័យចាំបាច់ទាំងអស់ដែរឬអត់ ដើម្បីចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ ហើយប្រសិនបើបានបំពេញមែននោះ ថាតើអ្នកដាក់បណ្ដឹងតវ៉ាមានពិរុទ្ធភាពឬសពី

---

[117] បណ្ដឹងរបស់ នួន ជា កថាខណ្ឌ ៣០។ នៅក្នុងករណីនេះ នួន ជា បានបញ្ជាជាមួយនឹងសេចក្ដីសម្រេចលើបណ្ដឹងជំទាស់របស់ អៀងធីរិទ្ធ នួន ជា និង អៀង សារី កថាខណ្ឌ ១៥។

[118] បណ្ដឹងរបស់ នួន ជា កថាខណ្ឌ ៣០, ១១៦។

[119] ចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះបណ្ដឹងជំទាស់របស់ នួន ជា ឯកសារ E314/9 ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ៣៤។

[120] សាលក្រមលើរឿងក្ដី *Poppe ទល់នឹងប្រទេសហូឡង់*។

វិមតិសង្ស័យថាបានប្រព្រឹត្តបទល្មើសបែបនេះដែរ ឬក៏អត់នោះ ករណីនេះគឺមិនបានលើកឡើងសម្រេច ឬវាយតម្លៃដោយចៅក្រមជំនុំជម្រះដែលអ្នកដាក់បណ្ដឹងតវ៉ាមានបំណងតវ៉ាលើអនាគតិរបស់ចៅក្រមទាំងនេះនោះទេ។ គ្មានលក្ខណវិនិច្ឆ័យជាក់លាក់លើការចូលរួមរបស់អ្នកដាក់បណ្ដឹងតវ៉ា ឬលើអំពើដែលបានប្រព្រឹត្តដោយជននេះ ដោយឧក្រិដ្ឋជន ឬ អ្នកផ្សេងទៀតនោះឡើយ។ នៅក្នុងករណីនេះ អង្គហេតុនៃរឿងក្ដីរបស់អ្នកដាក់បណ្ដឹងតវ៉ាខុសពីអង្គហេតុនៃរឿងក្ដី Ferrantelli និង Santangelo និង Rojas Morales។ ដូច្នេះ គេមិនអាចនិយាយបានថា ការភ័យខ្លាចដែលអ្នកដាក់ពាក្យបណ្ដឹងតវ៉ាអាចមាន អំពីភាពលម្អៀងរបស់តុលាការតំបន់ ជាការត្រឹមត្រូវទេ[121]។

៤០. ការច្រានចោលបណ្ដឹងជំទាស់មិនទទួលស្គាល់ចិត្តនាពេលមុនរបស់ នួន ជា ទាក់ទងនឹងការសម្រេចនៅក្នុងសាលក្រមសំណុំរឿង ០០១ បានសំអាងមួយផ្នែកទៅកថាខណ្ឌដូចគ្នានៃរឿងក្ដី Poppe *ទល់នឹង ប្រទេសហូឡង់* ដែលបានលើកឡើងដូចខាងក្រោម៖

> ដូចគ្នានេះដែរ មេធាវីការពារក្ដីរបស់ នួន ជា បានយោងទៅលើសំអាងរបស់តុលាការអឺរ៉ុបផ្នែកសិទ្ធិមនុស្សដែលបានសម្រេចថា ចៅក្រមត្រូវបានអនុញ្ញាតឱ្យជំនុំជម្រះរឿងក្ដីព្រហ្មទណ្ឌពីរដែលមានអង្គហេតុដូចគ្នាបាន តែក្នុងករណីដែលការសម្រេចពីពេលមុនរបស់តុលាការនេះ "ពិតជាមិនបានធ្វើបុរេវិនិច្ឆ័យ" លើពិរុទ្ធភាពរបស់ជនជាប់ចោទ។ ការសន្និដ្ឋានបែបនេះ រួមមានការសម្រេចនៅក្នុងមតិយោបល់ជាមុន "ចំពោះលក្ខណវិនិច្ឆ័យចាំបាច់ពាក់ព័ន្ធទាំងអស់ក្នុងការបង្កើតបានជាបទល្មើសព្រហ្មទណ្ឌ និង...ថាតើអ្នកដាក់ពាក្យសុំមានពិរុទ្ធភាពលើសពីវិមតិសង្ស័យចំពោះការប្រព្រឹត្តបទល្មើសបែបនេះ" ដែរ ឬយ៉ាងណា។[122]

[121] សាលក្រមលើរឿងក្ដី Poppe *តទល់នឹងប្រទេសហូឡង់* កថាខណ្ឌ ២៨។ សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីលើកទីបីរបស់ អ.ជ.ត.ក លេខយោងជើងទំព័រ ១៩៩ ក៏ដោយលើរឿងក្ដី *Ferrantelli និង Santangelo ទល់នឹង ប្រទេសអ៊ីតាលី*។ នៅក្នុងរឿងក្ដីនេះ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា ចៅក្រមម្នាក់ក្នុងចំណោមចៅក្រមដែលសម្រេចអ្នកដាក់ពាក្យសុំឱ្យមានពិរុទ្ធភាពលើបទមនុស្សឃាត មានភាពលម្អៀងដោយសារ ទីមួយ ចៅក្រមរូបនេះបានចេញសាលក្រមទាក់ទងនឹងបទល្មើសដូចគ្នាដែលរួមមាន "ដែលនិយាយសំដៅច្រើនលើអ្នកដាក់ពាក្យសុំ និងតួនាទីរបស់ពួកគេ" នៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលចោទប្រកាន់ និងនិយាយសំដៅលើអ្នកដាក់ពាក្យសុំថាជា "សហចារី" និង ទីពីរ សាលក្រមដែលនៅទីបំផុតបានសម្រេចឱ្យអ្នកដាក់ពាក្យសុំមានពិរុទ្ធភាព រួមមាន "ការដកស្រង់ជាច្រើន" ចេញពីសាលក្រមមុនៗ។

[122] សេចក្ដីសម្រេចលើបណ្ដឹងជំទាស់មិនទទួលស្គាល់ចិត្តរបស់ អៀង ធីរិទ្ធ នួន ជា និង អៀង សារី ដូចដែលបានចេញពីដំបូងដែរ កថាខណ្ឌ ២១ ដែលបានដកស្រង់សាលក្រមលើរឿងក្ដី Poppe *ទល់នឹង ប្រទេសហូឡង់* កថាខណ្ឌ ២៦ និង ២៨។

៤១. រឿងក្តី Poppe *ទល់នឹង ប្រទេសហូឡង់* ធ្លាប់ត្រូវបានពិចារណាដោយចៅក្រមនៅតុលាការ ICTY។ នៅក្នុងរឿងក្តី *Mladić* ជនជាប់ចោទបានស្នើសុំប្តឹងជំទាស់ចៅក្រម Orie ពីព្រោះចៅក្រមរូបនេះធ្លាប់ជំនុំជម្រះរឿងក្តី *Galić* និង *Krajišnik* និងធ្លាប់សម្រេចដោយមានបុរេវិនិច្ឆ័យលើបញ្ហានេះនៅក្នុងរឿងក្តីរបស់ *Mladić*។ ប្រធានតុលាការ ICTY បានចាត់ទុករបាយការណ៍របស់ Orie ថា សេចក្តីសម្រេចលើបញ្ហាជាន់គ្នាទាំងនេះ ពុំមែនជាបុរេវិនិច្ឆ័យលើពិរុទ្ធភាពរបស់ *Mladić* នោះទេ ហើយបានសម្រេចលើបណ្តឹងរបស់ *Mladić* ថាពុំអាចជឿជាក់បាន[123]។ របាយការណ៍របស់ចៅក្រម *Orie* បានលើកឡើងថា រឿងក្តី *Poppe ទល់នឹង ប្រទេសហូឡង់* តម្រូវលក្ខខណ្ឌថា តុលាការត្រូវ "ពិចារណា" អត្ថិភាព និងនត្ថិភាពនៃការសម្រេចលើលក្ខណវិនិច្ឆ័យចាំបាច់ពាក់ព័ន្ធទាំងអស់ដែលបង្កើតជាបទល្មើសព្រហ្មទណ្ឌ និងថាតើអ្នកជាប់បណ្តឹងមានពិរុទ្ធភាពហួសពីវិមតិសង្ស័យថាបានប្រព្រឹត្តបទល្មើសបែបនេះដែរ ឬទេ[124]។ ចៅក្រម *Orie* បានកត់សម្គាល់លើយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបដែលបានគូសបញ្ជាក់ថា ចៅក្រមវិជ្ជាជីវៈ (ខុសពីអ្នកជួយវាយតម្លៃជូន ចៅក្រម ឬ អ្នកវិនិច្ឆ័យធម្មតា) អាចមានវិជ្ជាជីវៈប្រសើរជាង ដោយមិនយកបទពិសោធន៍នៅក្នុងកិច្ចដំណើរការនីតិវិធីនាពេលមុនមកច្របូកច្របល់នោះទេ ដែលបទពិសោធន៍ទាំងនេះជួយឲ្យលទ្ធភាពរបស់ពួកគេក្នុងការពិនិត្យលើរឿងក្តីដោយគ្មានភាពលម្អៀង[125]។

៤២. នៅក្នុងបណ្តឹងជំទាស់មួយទៀត *Mladić* បានស្នើសុំប្តឹងជំទាស់ចៅក្រម *Flugge* ដោយសារធ្លាប់បានសម្រេចនៅក្នុងរឿងក្តី *Tolimir* និងបានលើកឡើងការប្តឹងជំទាស់ផ្សេងទៀតលើចៅក្រម Orie ដោយសារធ្លាប់បានសម្រេចនៅក្នុងរឿងក្តី *Stanišić និង Simatović*។ ចៅក្រម *Orie* និង *Flugge* បានផ្តល់របាយការណ៍បញ្ជូនទៅប្រធានតុលាការ *ICTY*។ របាយការណ៍ទាំងពីរបានយោងលើរឿងក្តី *Poppe ទល់នឹង ប្រទេសហូឡង់*។ ចៅក្រម Orie បានកត់សម្គាល់លើការសម្រេចនៅក្នុងរឿងក្តី *Stanišić* និង *Simatović* ថា បុគ្គលិកក្រោមបង្គាប់របស់ *Mladić* បានគ្រប់គ្រងលើអង្គភាពយោធាមួយ ប៉ុន្តែចៅក្រម

---

[123] សេចក្តីសម្រេចលើបណ្តឹងរបស់ *Mladić* ប្តឹងជំទាស់ចៅក្រម Orie ទំព័រ ៣។

[124] សេចក្តីសម្រេចលើបណ្តឹងរបស់ *Mladić* ប្តឹងជំទាស់ចៅក្រម Orie។ ឧបសម្ព័ន្ធ៖ របាយការណ៍របស់ចៅក្រម Orie អនុលោមតាមវិធាន ១៥(ខ) កថាខណ្ឌ ៣០។

[125] សេចក្តីសម្រេចលើបណ្តឹងរបស់ *Mladić* ប្តឹងជំទាស់ចៅក្រម Orie។ ឧបសម្ព័ន្ធ៖ របាយការណ៍របស់ចៅក្រម Orie អនុលោមតាមវិធាន ១៥(ខ) កថាខណ្ឌ ៣១ ដែលសំដៅលើរឿងក្តី *Miminoshvili ទល់នឹងប្រទេសរុស្ស៊ី* សាលក្រមតុលាការសិទ្ធិមនុស្សអឺរ៉ុប ពាក្យសុំលេខ ២០១៩៧/០៣ សាលក្រម ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ *("សាលក្រមលើរឿងក្តី Miminoshvili ទល់នឹងប្រទេសរុស្ស៊ី")*។

រូបនេះបានសន្និដ្ឋានថា ការភ័យខ្លាចអំពីភាពលម្អៀងអាចត្រឹមត្រូវដោយសត្យានុម័ត ប្រសិនណាបើកិច្ចដំណើរការនីតិវិធីនាពេលមុន "បានបំពេញលក្ខណវិនិច្ឆ័យចាំបាច់ពាក់ព័ន្ធទាំងអស់ដែលបង្កើតជាបទ-ល្មើសព្រហ្មទណ្ឌ និង ប្រសិនបើបានបំពេញមែននោះ តើអ្នកដាក់បណ្តឹងមានពិរុទ្ធភាពហួសពីវិមតិសង្ស័យថាបានប្រព្រឹត្តបទល្មើសបែបនេះដែរឬទេ"[126]។ របាយការណ៍របស់ចៅក្រម Flugge បានទទួលស្គាល់ថា មាន "អង្គហេតុសំខាន់ៗជាន់គ្នារវាងសំអាងហេតុនៅក្នុងសាលក្រមរឿងក្តី *Tolimir* ជាមួយនឹងភស្តុតាង និងការចោទប្រកាន់នៅក្នុងរឿងក្តី *Mladić*" រួមទាំង "ការចោទប្រកាន់អំពីទំនាក់ទំនងថ្នាក់លើ/បុគ្គលិកក្រោមបង្គាប់រវាង Messrs Tolimir និង Mladić"[127]។ ចៅក្រមរូបនេះបានកត់សម្គាល់ថា Mladić ត្រូវបាន "លើកឡើងជាញឹកញាប់នៅក្នុងសាលក្រមរឿងក្តី *Tolimir* រួមទាំងនៅក្នុងសំអាងហេតុ និងសំអាងច្បាប់ ដូចបានលើកឡើងនៅក្នុងនោះ"[128]។ ទោះបីជាយ៉ាងនេះក៏ដោយ ចៅក្រម Flugge បានសន្និដ្ឋានថា៖

> គ្មានករណីណាមួយដែលការចូលរួមរបស់ Mladić ជាមួយនឹងលោក Tolimir ឬ អ្នកផ្សេងទៀត ត្រូវបានពិភាក្សា ឬបង្ហាញដើម្បីបំពេញលក្ខណៈវិនិច្ឆ័យពាក់ព័ន្ធចាំបាច់ទាំងអស់ក្នុងការចាត់ទុកជាបទល្មើសដែលគាត់អាចទទួលខុសត្រូវនោះឡើយ។ ម្យ៉ាងវិញទៀត សាលក្រមក្នុងរឿងក្តី Tolimir ពុំមានការសម្រេច ឬវាយតម្លៃលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ Mladić ហួសពីវិមតិសង្ស័យនោះឡើយ[129]។

---

[126] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Mladić* ប្រធានតុលាការ ICTY រឿងក្តីលេខ IT-09-92-T សេចក្តីសម្រេចទាក់ទងនឹងសំណើរបស់មេធាវីការពារក្តីសុំលើសចំនួនពាក្យ និងសំណើសុំរបស់មេធាវីការពារក្តី អនុលោមតាមវិធាន ១៥(ខ) ស្នើសុំប្តឹងជំទាស់ចិត្តចៅក្រម Christoph Flugge ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៤ *("សេចក្តីសម្រេចលើបណ្តឹងរបស់ Mladić ប្តឹងជំទាស់ចិត្តចៅក្រម Flugge")* ឧបសម្ព័ន្ធ ខ (សាធារណៈ) កថាខណ្ឌ ២៩។

[127] សេចក្តីសម្រេចលើបណ្តឹងរបស់ Mladić ប្តឹងជំទាស់ចិត្តចៅក្រម Flugge ឧបសម្ព័ន្ធ ក (សាធារណៈ) កថាខណ្ឌ ៣២។

[128] សេចក្តីសម្រេចលើបណ្តឹងរបស់ Mladić ប្តឹងជំទាស់ចិត្តចៅក្រម Flugge ឧបសម្ព័ន្ធ ក (សាធារណៈ) កថាខណ្ឌ ៣២។

[129] សេចក្តីសម្រេចទៅលើបណ្តឹងជំទាស់ចិត្តរបស់ *Mladić* ទាក់ទងនឹងចៅក្រម Flugge ឧបសម្ព័ន្ធ ក (សាធារណៈ) កថាខណ្ឌ ៣៦ របាយការណ៍របស់ចៅក្រម Flugge នៅកថាខណ្ឌ ១៦ និង ៣៣ សំអាងទៅសេចក្តីសម្រេចមួយនៅក្នុងរឿងក្តី *Popović និងអ្នកផ្សេងទៀត* ដែលជាក់ស្តែងជាមូលដ្ឋានក្នុងការសម្រេចថា ការសន្មតទៅលើអនាគតិអនុវត្តឡើង ដោយមិនគិតថាចៅក្រមបានវាយតម្លៃវិជ្ជមាន ឬអវិជ្ជមានទៅលើភាពជឿជាក់នៃភស្តុតាងនៅក្នុងរឿងក្តីពីមុន (*រដ្ឋអាជ្ញា ទល់នឹង Popović និងអ្នកផ្សេងទៀត* ប្រធានតុលាការ ICTY IT-05-88-A) សេចក្តីសម្រេចទៅលើសំណើរបស់ Drago Nikolić សុំជំទាស់ចិត្តចៅក្រម Liu Daqun ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១១)។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះបណ្តឹង នួន ជា កថាខណ្ឌ ១៣ និង ៣៥ សំអាងទៅសេចក្តីសម្រេចមួយនៅក្នុងរឿងក្តី *Popović និងអ្នកផ្សេងទៀត*។ យ៉ាងណាក៏ដោយ

៤៣. ចៅក្រម Flugge បានកត់សម្គាល់បន្ថែមទៀតថា ពុំមានការពិភាក្សាអំពី*ធាតុផ្សំអត្តនោម័ត* របស់ Mladić ទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌទាំងនោះឡើយ[130]។ ក្រោយពីពិចារណាលើរបាយ-ការណ៍របស់ចៅក្រម Orie និងចៅក្រម Flugge ប្រធានតុលាការ ICTY បានសន្និដ្ឋានថា Mladić ពុំបានបង្ហាញថា អ្នកសង្កេតការណ៍មិនលម្អៀង ដែលបានដឹងព័ត៌មានគ្រប់គ្រាន់ហើយនោះ នឹងអាចឃើញពីភាពលម្អៀងយ៉ាងសមហេតុផលនោះឡើយ[131]។

៤៤. នៅពេលពិចារណាលើចំណុចខាងលើ សេចក្តីសន្និដ្ឋានរបស់ នួន ជា កំណត់មិនត្រឹមត្រូវចំពោះការផ្តន្ទាទោសនៅក្នុងរឿងក្តី *Poppe ទល់នឹង ប្រទេសហូឡង់* ដែលគាត់បានសំអាង។ តុលាការសិទ្ធិ-មនុស្សអឺរ៉ុបពុំបានលើកឡើងថា "ការយល់ឃើញជាទូទៅ" ចំពោះការកំណត់ពីការចូលរួមរបស់បុគ្គលម្នាក់ គ្រប់គ្រាន់ក្នុងការបង្ហាញពីភាពលម្អៀងនោះទេ។ ប៉ុន្តែ តុលាការសិទ្ធិមនុស្សបានចាត់ទុកការយល់ឃើញជាទូទៅនេះថាសំខាន់ផ្នែកអង្គហេតុ ដោយគ្មានការកំណត់ជាក់លាក់ពីការចូលរួមរបស់អ្នកដាក់ពាក្យសុំ ឬអំពើដែលបានប្រព្រឹត្តដោយជនរូបនេះឡើយ។ តុលាការសិទ្ធិមនុស្សនៅក្នុងរឿងក្តី *Poppe ទល់នឹង ប្រទេសហូឡង់* បានញែកដាច់រវាងរឿងក្តី *Ferrantelli ទល់នឹង ប្រទេសអ៊ីតាលី* ដែល នួន ជា ក៏បានសំអាងលើផងដែរ។ រឿងក្តី *Santangelo* ជាប់ទាក់ទងនឹងសំអាងហេតុនាពេលមុនអំពីតួនាទីសកម្មរបស់អ្នកដាក់ពាក្យសុំនៅក្នុងឧក្រិដ្ឋកម្មដូចគ្នាដែលពួកគេក្រោយមកត្រូវបានសម្រេចថាជាប់ពិរុទ្ធភាព[132]។ យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបក្រោយៗមកបង្ហាញថា ទោះបីជាបានលើកសេចក្តីថ្លែងនៅក្នុងរឿងក្តីមុនអំពីចរិតលក្ខណៈនិងតួនាទីរបស់ជននេះនៅក្នុងឧក្រិដ្ឋកម្មក៏ដោយ ប្រសិនបើតុលាការយល់ឃើញថា ពុំមែនជាការប្រកាសពិរុទ្ធភាពរបស់ជនជាប់ចោទទាក់ទងនឹងបទល្មើសនោះទេ ការលេចឡើងនូវភាពលម្អៀងមិនត្រូវបានបង្ហាញឡើយ[133]។ លើសពីនេះទៀត នៅក្នុងរឿងក្តី Thomann *ទល់នឹង ប្រទេសស្វីស* តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា ចៅក្រមដដែល ដែលបាន

---

សហព្រះរាជអាជ្ញាមិនបានផ្តល់ឱ្យក្រុមប្រឹក្សាជំនុំជម្រះពិសេសនូវឯកសារសេចក្តីសម្រេចទាំងស្រុងនៃសេចក្តីសម្រេចក្នុងរឿងក្តី *Popović* ឡើយ ដែលហាក់ដូចជាមិនអាចរកបានជាសាធារណៈទេ។ នៅក្នុងកាលៈទេសៈទាំងនោះ យើងមិនអាចផ្អែកទៅលើករណីនេះទេ។ ទោះយ៉ាងណាក៏ដោយ លទ្ធផលដែលចៅក្រម Flugge បានលើកឡើង ហាក់ដូចជាស្របទៅនឹងយុត្តិសាស្ត្រពីតុលាការមិនអចិន្ត្រៃយ៍។

[130] សេចក្តីសម្រេចលើបណ្តឹងរបស់ Mladić ប្តឹងជំទាស់ចៅក្រម Flugge ឧបសម្ព័ន្ធ ក (សាធារណៈ) កថាខណ្ឌ ៣៨។

[131] សេចក្តីសម្រេចលើបណ្តឹងរបស់ Mladić ប្តឹងជំទាស់ចៅក្រម Flugge ទំព័រ ៣។

[132] សាលក្រមលើរឿងក្តី *Ferrantelli និង Santangelo ទល់នឹង ប្រទេសអ៊ីតាលី* កថាខណ្ឌ ៥៩។

[133] សាលក្រមលើរឿងក្តី *Schwarzenberger ទល់នឹង ប្រទេសអាល្លឺម៉ង់* កថាខណ្ឌ ៤៣ និងសាលក្រមលើរឿងក្តី *iminoshvili ទល់នឹងប្រទេសរុស្ស៊ី* កថាខណ្ឌ ១១៦។

ផ្តន្ទាទោសជនជាប់ចោទម្នាក់ដោយកំបាំងមុខ អាចចូលរួមនៅក្នុងការជំនុំជម្រះជនជាប់ចោទសាជាថ្មីដោយមិនកំបាំងមុខ។ តុលាការនេះបានសម្រេចថា ការធ្វើបែបនេះមិនបានធ្វើឱ្យមានការសង្ស័យទៅលើភាពមិនលំអៀងរបស់ចៅក្រមនោះឡើយ ព្រោះថាចៅក្រមទាំងនោះនឹងធ្វើការពិចារណាថ្មីមួយទៅលើសំណុំរឿងទាំងមូល[134]។

៤៥. គ្មានឯកសារសំអាងណាមួយដែល នួន ជា យកមកធ្វើជាមូលដ្ឋាន បង្ហាញថា នៅក្នុងករណីមានការសម្រេចដោយតុលាការនោះ ថាការលេចឡើងនូវភាពលម្អៀងត្រូវបានបង្ហាញតាមរយៈ (ii) ការកំណត់ជាមុនលើបញ្ហាដែលអាចជាប់ពិរុទ្ធភាព ឬ (iii) ការបង្កើតជាមុននូវទស្សនៈអវិជ្ជមានលើរឿងក្តីរបស់ភាគី។ ទាក់ទងនឹងចំណុច (ii) ការសំអាងរបស់ នួន ជា លើមតិជំទាស់តែមួយគត់ពីក្នុងរឿងក្តីនេះនៅតុលាការយុត្តិធម៌អន្តរជាតិ ពុំអាចឱ្យជឿបានទេ។ ចៅក្រម Buergenthal បានផ្តល់មតិជំទាស់ខុសពីចៅក្រមភាគច្រើនចំនួន ១៣ រូបផ្សេងទៀត ដោយផ្អែកលើមូលដ្ឋាននៃកិច្ចសម្ភាសន៍ជាមួយសារព័ត៌មានដែលធ្វើឡើងដោយចៅក្រមដែលត្រូវបានគេប្តឹងជំទាស់[135]។ ទាក់ទងនឹងចំណុច (iii) រឿងក្តី *Buscemi ទល់នឹង* ប្រទេសអ៊ីតាលី ពាក់ព័ន្ធនឹង "ការផ្លាស់ប្តូរយោបល់គ្នាដ៏ក្តៅគគុក" រវាងចៅក្រមមួយរូប ជាមួយនឹងភាគីនៅក្នុងសារព័ត៌មាននៅមុនពេលជំនុំជម្រះ[136] ហើយរឿងក្តី *Kyprianou ទល់នឹង ប្រទេសសាយប្រ៊ស* ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីប្រមាថតុលាការ នៅពេលដែលការប្រព្រឹត្តរបស់មេធាវីម្នាក់បានធ្វើឡើងជាលក្ខណៈបុគ្គលចំពោះចៅក្រម ហើយចៅក្រមដដែលនេះបានសម្រេចចោទប្រកាន់ ជំនុំជម្រះបញ្ហានេះ និងដាក់ទោសជាប់ពន្ធនាគារភ្លាមៗទំនងក្នុងកម្រិតដ៏ធ្ងន់ធ្ងរបំផុតមួយ[137]។ ឧទាហរណ៍ទាំងនេះពុំបង្ហាញថា ការសម្រេចដោយចៅក្រមលើភាគីមួយមានន័យថាបញ្ហាទាំងនេះគឺជា "ការកំណត់ជាមុន" ឬ គឺជាទស្សនៈ "ដែលត្រូវបានបង្កើតឡើងជាមុន" ដែលអាចយកមកប្តឹងជំទាស់ចៅក្រមម្នាក់ពីកិច្ចដំណើរការនីតិវិធីនាពេលខាងមុនទាក់ទងនឹងភាគីនោះបានទេ។

---

[134] រឿងក្តី *Thomann ទល់នឹងប្រទេសស្វីស* សាលក្រម តុលាការតុលាការសិទ្ធិមនុស្សអឺរ៉ុប សំណើលេខ 17602/91 ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៦ កថាខណ្ឌ ៣៥, បែងចែកអង្គហេតុដោយសាលក្រមលើរឿងក្តី *San Leonard Band Club* ទល់នឹង *Malta* សំណើលេខ 77562/01 ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៤ កថាខណ្ឌ ៦៤។

[135] *ផលវិបាកផ្នែកច្បាប់នៃការសាងសង់ជញ្ជាំងនៅក្នុងទឹកដីដែលកាន់កាប់ដោយប៉ាឡេស្ទីន* ដីកាចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៤ របាយការណ៍របស់តុលាការយុត្តិធម៌អន្តរជាតិ ឆ្នាំ ២០០៤ មតិជំទាស់របស់ចៅក្រម Buergenthal កថាខណ្ឌ ៧-៨។

[136] សាលក្រមលើរឿងក្តី *Buscemi ទល់នឹងប្រទេសអ៊ីតាលី* កថាខណ្ឌ ៤៣។

[137] រឿងក្តី *Kyprianou ទល់នឹងប្រទេសសាយប្រ៊ស* សាលក្រម តុលាការសិទ្ធិមនុស្សអឺរ៉ុប ពាក្យសុំលេខ ៧៣៧៩៧/០១ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៥។

៤៦. បណ្ដឹងរបស់ នួន ជា បានបង្ហាញឧទាហរណ៍ចំនួនពីរដែលតុលាការឧក្រិដ្ឋកម្មអន្តរជាតិនានា បាននិតចិត្តចៅក្រមចំពោះការលេចឡើងនូវភាពលម្អៀង[138]។ ចៅក្រម Harhoff ត្រូវបាននិតចិត្តពីរឿងក្តី *Šešelj* ពីព្រោះតែលិខិតមួយច្បាប់ដែលបានសរសេរដោយបានយោងទៅ "កម្រងនៃការអនុវត្តមួយ" សម្រាប់សម្រេចឱ្យមេបញ្ជាការយោធាមានពិរុទ្ធភាព និងបានសំដែងការមិនពេញចិត្តរបស់គាត់ចំពោះការផ្លាស់ប្តូរទិសដៅរបស់តុលាការលើករណីនេះ[139]។ ក្រុមប្រឹក្សាជំនុំជម្រះនៅតុលាការ ICTY បានសម្រេចដោយចៅក្រមភាគច្រើនថា អ្នកសង្កេតការណ៍មិនលម្អៀងនឹងយល់ថា "ភាពលម្អៀងទៅរកការសម្រេចឱ្យជាប់ពិរុទ្ធភាពដោយពុំយោងលើការវាយតម្លៃភ័ស្តុតាងនៅក្នុងរឿងក្តីនីមួយៗ"[140]។ នៅក្នុងរឿងក្តី *Sesay និងអ្នកផ្សេងទៀត* អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ SCSL បាននិតចិត្តចៅក្រម Robertson ពីបញ្ហានានាដែលពាក់ព័ន្ធនឹង RUF ពីព្រោះតែអត្ថបទក្រាហ្វិកអំពី RUF នៅក្នុងសៀវភៅមួយដែលចៅក្រមរូបនេះបានបោះពុម្ពផ្សាយនាពេលមុន ដែលបានបង្ហាញពីទស្សនៈថា RUF និងថ្នាក់ដឹកនាំរបស់អង្គភាពនេះ មានពិរុទ្ធភាពលើអំពើឃោរឃៅក្នុងវិសាលភាពមួយដែលបានបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[141]។ គ្មានរឿងក្តីណាមួយពាក់ព័ន្ធនឹងការសម្រេចរបស់តុលាការ ឬលើកឡើងថា សច្ចធារណ៍នៃអនាគតិត្រូវបានបន្ថយមកត្រឹមលក្ខខណ្ឌអប្បបរមាទាបជាងមុន ដូច នួន ជា បានអះអាងនោះឡើយ ពោលគឺ នៅពេលមតិយោបល់របស់ចៅក្រមបានសម្រេចលើបញ្ហានានាដែលជាប់ទាក់ទងនឹងពិរុទ្ធភាពនៅក្នុងរឿងក្តីក្រោយៗ ឬនៅពេលចៅក្រមបានបង្ហាញទស្សនៈលម្អៀងអំពីផ្នែកផ្សេងៗនៃរឿងក្តីរបស់ភាគី។

៤៧. នៅក្នុងរឿងក្តី *Karadžić* ក៏មានភាពស្របជាមួយនឹងសេចក្តីសន្និដ្ឋាននេះដែរ ដោយនៅក្នុងរឿងក្តីនេះ ជនជាប់ចោទបានស្នើសុំប្តឹងនិតចិត្តចៅក្រម Picard ដោយផ្អែកលើមូលដ្ឋានផ្សេងៗ ក្នុងនោះរួមទាំងតួនាទីរបស់លោកស្រីចៅក្រមនាពេលមុនក្នុងនាមជាប្រធានសភាសិទ្ធិមនុស្សនៃ Bosnia

---

[138] បណ្តឹងនិតចិត្តរបស់ នួន ជា ជើងទំព័រ ១០៩។

[139] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Šešelj* អង្គជំនុំជម្រះតុលាការ ICTY ដែលត្រូវបានរៀបចំឡើងតាមសេចក្តីបង្គាប់របស់អនុប្រធាន រឿងក្តីលេខ IT-03-67-T សេចក្តីសម្រេចលើបណ្តឹងរបស់មេធាវីការពារក្តីប្តឹងនិតចិត្តចៅក្រម Frederik Harhoff និងរបាយការណ៍ទៅអនុប្រធាន ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ១២ ("សេចក្តីសម្រេចលើបណ្តឹងរបស់ *Šešelj* ប្តឹងនិតចិត្តចៅក្រម Harhoff"។

[140] សេចក្តីសម្រេចលើបណ្តឹងរបស់ *Šešelj* ប្តឹងនិតចិត្តចៅក្រម Harhoff កថាខណ្ឌ ១៣។

[141] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Sesay និងអ្នកផ្សេងទៀត* អង្គជំនុំជម្រះតុលាការកំពូល SCSL រឿងក្តីលេខ SCSL-2004-15-AR15 សេចក្តីសម្រេចលើបណ្តឹងនិតចិត្តចៅក្រម Robertson ពីអង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៤ កថាខណ្ឌ ១៤-១៨។

and Herzegovina ("សភាសិទ្ធិមនុស្ស") និងការរកឃើញថា ស្ថាប័ននេះបានបង្កើតឡើងឲ្យទទួលខុសត្រូវរបស់ Republika Srpska ចំពោះឧក្រិដ្ឋកម្ម។ សភាពិសេសនៃតុលាការ ICTY បានសម្រេចថា អ្នកសង្កេតការណ៍ដោយយុត្តិធម៌ម្នាក់នឹងដឹងអំពីយុត្តាធិការខុសគ្នារវាងសភាសិទ្ធិមនុស្ស និងតុលាការ ICTY ហើយលក្ខខណ្ឌផ្លូវច្បាប់ដែលនឹងយកមកអនុវត្ត "នឹងខុសគ្នាជាក់ស្តែង និងជាសារវ័ន្ត"[142]។ ម្យ៉ាងវិញទៀត បញ្ហាអង្គហេតុ និងអង្គច្បាប់នៅក្នុងរឿងក្តីនានា "មានភស្តុតាងខុសគ្នាពីបញ្ហានៃការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ Karadžić"[143]។ មានភាពខុសគ្នាសំខាន់រវាងការសម្រេចរបស់សភាសិទ្ធិមនុស្សលើការទទួលខុសត្រូវរបស់រដ្ឋាភិបាល Republika Srpska ជាមួយនឹងការទទួលខុសត្រូវរបស់ Karadžić ក្នុងនាមប្រធាន និងអគ្គមេបញ្ជាការជាន់ខ្ពស់នៃកងកម្លាំងប្រដាប់អាវុធ[144]។ ទោះបីជាសេចក្តីសង្ខេបនៃបរិបទប្រវត្តិសាស្ត្របានយោងលើការសម្រេចរបស់សាលាក្តីនៅក្នុងការជំនុំជម្រះនានារបស់តុលាការ ICTY ក៏ដោយ ក៏

> "អ្នកសង្កេតការណ៍ដោយយុត្តិធម៌ និងដែលបានទទួលព័ត៌មានគ្រប់គ្រាន់ នឹងទទួលស្គាល់ថាការយោងដោយប្រុងប្រយ័ត្នរបស់សភាសិទ្ធិមនុស្សលើការសម្រេចបែបនេះដែលធ្វើឡើងដោយសាលាក្តីក្នុងគោលបំណងតែមួយគត់ដើម្បីបង្ហាញសាវតារលើការអនុវត្តរបស់ខ្លួន គឺជាការបង្ហាញអំពីការទទួលស្គាល់នូវអាណត្តិយុត្តាធិការពេលវេលា និងយុត្តាធិការសិទ្ធិមនុស្សរបស់សភាសិទ្ធមនុស្ស"[145]។

៤៨. ក្រុមប្រឹក្សាជំនុំជម្រះបានសម្រេចថា ទោះបីជាសភាសិទ្ធិមនុស្សបានសម្រេចលើបញ្ហានៃភាពពាក់ព័ន្ធចំពោះការជំនុំជម្រះ *Karadžić* ក៏ដោយ ក៏គេអាចទុកចិត្តលើចៅក្រមវិជ្ជាជីវៈក្នុងការសម្រេចលើភស្តុតាងនៅក្នុងរឿងក្តីជាក់លាក់បានដែរ[146]។

### (៥) សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីលើកទីបីរបស់ អ.ជ.ត.ក

៤៩. បណ្តឹងជំទាស់ទាំងពីរផ្អែកលើសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីបីរបស់ អ.ជ.ត.ក

[142] សេចក្តីសម្រេចលើបណ្តឹងរបស់ *Karadžić* ប្តឹងជំទាស់ចៅក្រម Picard កថាខណ្ឌ ១៩។

[143] សេចក្តីសម្រេចលើបណ្តឹងរបស់ *Karadžić* ប្តឹងជំទាស់ចៅក្រម Picard កថាខណ្ឌ ២០។

[144] សេចក្តីសម្រេចលើបណ្តឹងរបស់ *Karadžić* ប្តឹងជំទាស់ចៅក្រម Picard កថាខណ្ឌ ២១។

[145] សេចក្តីសម្រេចលើបណ្តឹងរបស់ *Karadžić* ប្តឹងជំទាស់ចៅក្រម Picard កថាខណ្ឌ ២៣។

[146] សេចក្តីសម្រេចលើបណ្តឹងរបស់ *Karadžić* ប្តឹងជំទាស់ចៅក្រម Picard កថាខណ្ឌ ២៤។

ជាពិសេស ត្រង់កថាខណ្ឌ ៤៥ ៨៣ និង ៨៥[147]។ កថាខណ្ឌពាក់ព័ន្ធនៅក្នុងសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីលើកទីបីរបស់ អ.ជ.ត.ក ត្រូវបានរៀបរាប់ដូចខាងក្រោម ដោយចំណុចយោងនៅក្នុងជើងទំព័រត្រូវបានលុបចោល។

> ៤៥. សំណុំរឿងដែលបានបំបែកនីមួយៗ អាចត្រូវបានពិចារណា និងសម្រេចដោយចៅក្រមដដែលៗ ឬចៅក្រមផ្សេងៗទៀតបាន។ ការផ្លាស់ប្តូរក្រុមប្រឹក្សាជំនុំជម្រះ បន្ទាប់ពីដំណើរការសវនាការលើអង្គសេចក្តី បានរំខានទៅដល់ការបន្តការពិនិត្យភ័ស្តុតាងដោយផ្ទាល់។ ទោះជាយ៉ាងនេះក្តី នៅពេលដែលចៅក្រមដដែលធ្វើការពិចារណា និងសម្រេចលើបទចោទជាច្រើនប្រឆាំងនឹងជនជាប់ចោទដដែលនោះ នឹងមានបញ្ហាកើតឡើងពាក់ព័ន្ធនឹងភាពមិនលម្អៀងរបស់តុលាការ ក្នុងកម្រិតមួយដែលថា ការវិនិច្ឆ័យទៅលើផ្នែកមួយនៃបទចោទផ្សេងៗ នៅក្នុងការជំនុំជម្រះដដែល ឬការជំនុំជម្រះក្រោយមកទៀត អាចបង្កើតឱ្យមានការលម្អៀង )ឬការបង្ហាញឃើញនូវភាពលម្អៀង (ចំពោះជនជាប់ចោទ ឬក៏ជាការលម្អៀងដែលបណ្តាលមកពីការសម្រេចសេចក្តីផ្សេងៗដែលពាក់ព័ន្ធនឹងសំណុំរឿងដទៃទៀត ដែលចំណុចនេះគឺជាការព្រួយបារម្ភណ៍ដែលត្រូវបានលើកឡើងកាលពីលើកមុន ហើយត្រូវបានពិចារណានៅក្នុងយុត្តិសាស្ត្រអន្តរជាតិ និងប្រព័ន្ធក្នុងស្រុក[92]។ ហេតុដូច្នេះ នៅក្នុងប្រព័ន្ធច្បាប់ភាគច្រើន ការបំបែកកិច្ចដំណើរការនីតិវិធីគឺអាស្រ័យលើលទ្ធភាពអាចបំបែកសំណុំរឿង ដែលទោះបីជាមានការជាប់ពាក់ព័ន្ធ ជាចម្បង នឹងគោលការណ៍ ដែលមិនតម្រូវឱ្យរំខាន់ដល់អត្តសញ្ញាណនៃអំពើឧក្រិដ្ឋ ដែលមានលក្ខណៈស្មុគស្មាញយ៉ាងណាក៏ដោយ ក៏ភាពបំបែកបាននេះតម្រូវឱ្យរួមបញ្ចូលនូវកាតព្វកិច្ចការពារជាមុននូវបញ្ហាផ្សេងៗ ដែលអាចកើតឡើយដោយសារការបង្ហាញពីភាពរួមគ្នានៃអង្គហេតុផងដែរ។ នៅក្នុងប្រព័ន្ធដែលប្រើប្រាស់គណៈវិនិច្ឆ័យ ក្តីបារម្ភអំពីព្យសនកម្មដែលអាចកើតមាន អាចតម្រូវឱ្យមានការបំបែកកិច្ចដំណើរការនីតិវិធី ដោយខ្លួនឯង ហើយក្នុងករណីផ្សេងទៀត មានបញ្ហាអំពីការបង្កើតគណៈវិនិច្ឆ័យថ្មី ឬការដកគណៈវិនិច្ឆ័យចេញពីការជំនុំជម្រះផ្នែកនៃសំណុំរឿងដែលបានបំបែក[93]។ នៅក្នុងប្រព័ន្ធដែលមិនប្រើប្រាស់គណៈវិនិច្ឆ័យ បទដ្ឋានចំពោះភាពលំអៀងដែលមានមន្ទិលសង្ស័យ មានលក្ខណៈជាងនេះ[94]។ តែយ៉ាងណាក៏ដោយ លក្ខណៈវិនិច្ឆ័យនៃប្រយោជន៍យុត្តិធម៌នឹងគ្រប់ដណ្តប់លើក្តីបារម្ភពាក់ព័ន្ធនានា ដែលតុលាការជំនុំជម្រះមានកាតព្វកិច្ចត្រូវពិចារណានៅក្នុងសមត្ថកិច្ចរបស់ខ្លួន[95]។

---

[147] បណ្តឹងជំទាស់ (?) — បណ្តឹងមិតចិត្តរបស់ នួន ជា កថាខណ្ឌ ២៦-២៨, ៩៤។ សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៩, ៥០-៥១។

៨៣. ទោះបីជាយ៉ាងណាក្តី បញ្ហាមួយដែលកើតឡើងពីដីកាបំបែកលើមូលដ្ឋានភ័ស្តុតាង គឺមានការទាក់ទងទៅនឹងការយល់ឃើញដែលអាចមានការប៉ះពាល់លើបញ្ហាដែលជាប់ពាក់ព័ន្ធជារួម។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា នៅក្នុងតុលាការ*ពិសេស*ព្រហ្មទណ្ឌអន្តរជាតិ មានការសន្និដ្ឋានយ៉ាងមុតមាំអំពីភាពឥតលម្អៀងរបស់ចៅក្រមដែលមានជំនាញច្បាស់លាស់ នៅក្នុងរឿងក្តីដែលមានភ័ស្តុតាង ឬទម្រង់នៃអង្គហេតុជាន់គ្នា ដែលអនុញ្ញាតឱ្យមានការបដិសេធចោលលើអញ្ញត្រកម្មទាក់ទងនឹងការជំនុំជម្រះដែលច្រំដែលលើធាតុនៃបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ លើធាតុនៃអង្គហេតុដទៃទៀត លើបញ្ហាជាក់លាក់ផ្នែកច្បាប់ និងលើការប្រើប្រាស់នូវមធ្យោបាយជាក់លាក់នៃភ័ស្តុតាង[197]។ ទោះជាយ៉ាងណាក្តី យុត្តិសាស្ត្រនេះកើតចេញពីសំណុំរឿងដែលមិនមានការជំនុំជម្រះរួមលើអង្គសេចក្តី និងមិនមានជនជាប់ចោទរួម។ ធាតុពីរដែលមានលក្ខណៈខុសប្លែកគ្នានៃការបំបែកសំណុំរឿង ០០២/០២ មានលក្ខណៈគួរឱ្យកត់សម្គាល់។) ១ (នៅក្នុងតុលាការ*ពិសេស*ព្រហ្មទណ្ឌអន្តរជាតិ ភាពឥតលម្អៀងត្រូវបញ្ជាក់នៅពេលមានការសន្មតថា មានភ័ស្តុតាងដាច់ដោយឡែកមិនជាប់ពាក់ព័ន្ធក្នុងសំណុំរឿងនីមួយៗ ហើយព្រមទាំង ចៅក្រមមិនត្រឹមតែទទួលបានការហ្វឹកហ្វឺនប៉ុណ្ណោះទេ ថែមទាំងនឹងត្រូវផ្អែកលើភ័ស្តុតាងតែមួយគត់ ដែលបានបង្ហាញនៅក្នុងសំណុំរឿងនោះ[198]។ )២ (អញ្ញត្រកម្មត្រូវបានច្រានចោល ពីព្រោះការយល់ឃើញដំបូងរបស់ចៅក្រម មិនដែលបានកំណត់ពីបញ្ហានៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទជាប់ពាក់ព័ន្ធ។ ផ្ទុយទៅវិញ នៅពេលដែលការយល់ឃើញពីដំបូងត្រូវបានប្រកាសពីការទទួលខុសត្រូវព្រហ្មទណ្ឌ យុត្តិសាស្ត្រនេះអះអាងថា ការសន្មតនូវភាពឥតលម្អៀងនឹងអាចត្រូវបានលែងចោទជាបញ្ហា[199]។ អង្គជុំជម្រះតុលាការ ICTY ក្នុងសេចក្តីសម្រេច*រឿងក្តី Milošević* និង *Mladić* ដែលដោះស្រាយលើជនជាប់ចោទ និងបទចោទដដែល ពីបទចោទដែលកើតចេញពីផែនការរួមដូចគ្នា លើកឡើងនូវបញ្ហាស្តីពីភាពឥតលម្អៀង*នៅក្នុងតួនាទី* នៅក្នុងបទដ្ឋានរបស់ខ្លួន ដែលបណ្តាលឱ្យបដិសេធការបំបែកសំណុំរឿង។ សរុបសេចក្តីមក ដំណោះស្រាយពីរចំណុចត្រូវបានលើកឡើងថា៖ ដកភ័ស្តុតាងចេញពីចៅក្រមដែលត្រូវជំនុំជម្រះលើភ័ស្តុតាងនេះ[200] ឬចៅក្រមត្រូវដកខ្លួនចេញពីការជំនុំជម្រះលើភ័ស្តុតាងនេះ[201]។

៨៥. ដោយកត់សម្គាល់លើភាពផ្ទុយគ្នាជុំវិញសញ្ញាណនៃពាក្យ "មូលដ្ឋានទូទៅ "អង្គជំនុំជម្រះតុលាការកំពូលសង្កត់ធ្ងន់ថា គ្រប់កាលៈទេសៈទាំងអស់ វាជាការពុំអាចទទួលយកបាននោះទេចំពោះអង្គជំនុំជម្រះសាលាដំបូងដែលត្រូវបញ្ចូលការសន្មតលើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនៅក្នុងការជំនុំជម្រះនាពេលអនាគត ប្រសិនបើមានករណីនេះកើតមានបន្ទាប់ពីសំណុំរឿង មុនពេលការបញ្ចប់ជាស្ថាពរនៃការដាក់ពិរុទ្ធភាព។ បើទោះបីភ័ស្តុតាងនៅតែមាន

លក្ខណៈដូចគ្នាជាផ្លូវការទៅនឹងសំណុំរឿងដែលបានបំបែកក៏ដោយ ក៏ភាពរួមគ្នានេះមិនបានពន្លាតដល់ការយល់ឃើញ ហើយជាតួរួមនៃអង្គហេតុក្នុងសំណុំរឿងទាំងអស់ក្នុងសំណុំរឿង ០០២ ត្រូវបានបង្ហាញសាជាថ្មី។ នៅក្នុងស្ថានការណ៍ដែលសាលក្រមក្នុងសំណុំរឿង ០០២/០១ បានឈានដល់ការសម្រេចដាក់ពិរុទ្ធភាពមួយ នោះនឹងមានហានិភ័យលើបញ្ហាជាន់គ្នានៃការយល់ឃើញ ដែលកំណត់ពីការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលក្នុងការជំនុំជម្រះបន្តបន្ទាប់។ តាមន័យអរូបី នឹងមានការកើនឡើងនូវហានិភ័យជាមួយនឹងបញ្ហានៃការបំបែកសំណុំរឿងជាច្រើនផ្នែកបន្ថែមទៀត ប៉ុន្តែ បញ្ហានៅតែមានសុពលភាពសម្រាប់សំណុំរឿង ០០២/០២ ដោយមិនជាប់ពាក់ព័ន្ធនឹងការបំបែកឡើយ។ ដោយមានការសម្រេចបដិសេធលើសំណើសុំការរង់ចាំ នូវការបញ្ចប់នៃសំណុំរឿង ០០២/០១ និងក្នុងពេលតែមួយ ការបដិសេធក្នុងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរ ក្នុងអង្គជំនុំជម្រះសាលាដំបូង ដែលមួយក្នុងចំណោមនៃការស្នើឡើងទាំងពីរនេះ នឹងអាចជួយសម្រាលដល់ក្ដីកង្វល់នេះបាននោះ អង្គជំនុំ-ជម្រះតុលាការកំពូលអាចត្រូវតែធ្វើការសន្និតថា អង្គជំនុំជម្រះសាលាដំបូងនឹងមិនធ្វើឱ្យការយល់ឃើញក្នុងសំណុំរឿង ០០២/០១ ទៅបង្ហាញជាការសន្និតនូវការទទួលខុសត្រូវព្រហ្មទណ្ឌទៅលើសហជនជាប់ចោទ ទាក់ទងនឹងបទចោទដែលត្រូវជំនុំជម្រះក្នុងរឿងក្ដីបន្តបន្ទាប់នោះទេ។ ទោះបីជាយ៉ាងណាក្ដី ក្នុងដំណាក់កាលនេះ ដោយសារពុំទាន់មានសាលក្រមនៅក្នុងដៃ បញ្ហានៃភាពលំអៀងពុំទាន់កើតឡើងដែលជាការប៉ះពាល់ដល់សិទ្ធិជាក់ច្បាស់នៅឡើយទេ។

៥០. នួន ជា បានសន្និដ្ឋានថា យោងតាមអង្គជំនុំជម្រះតុលាការកំពូល នៅពេលរឿងក្ដីជាន់គ្នាមានជនជាប់ចោទ និងភ័ស្តុតាងដូចគ្នា លក្ខខណ្ឌនៃអនាគតិតម្រូវថា ភ័ស្តុតាងបុរេវិនិច្ឆ័យដែលចៅក្រមបានពិនិត្យរួចហើយ ត្រូវតែដកចេញពីរឿងក្ដីក្រោយៗ ឬថា ចៅក្រមទាំងនេះត្រូវដកចេញ[148]។ ខៀវ សំផន បានសន្និដ្ឋានថា អង្គជំនុំជម្រះតុលាការកំពូលបានបង្ហាញព្យសនកម្មដែលឃើញមានជាក់ស្ដែង ពោលគឺសាលក្រមសំណុំរឿង ០០២/០១ មានបុរេវិនិច្ឆ័យលើការទទួលខុសត្រូវរបស់ ខៀវ សំផន លើបញ្ហាទាំងឡាយដែលនឹងត្រូវសម្រេចនៅក្នុងសំណុំរឿង ០០២/០២[149]។ សហព្រះរាជអាជ្ញាមិនបានឆ្លើយតបទៅនឹងឃ្លាខាងលើនៅក្នុងសេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីលើកទីបីរបស់ អ.ជ.ត.ក ឡើយ។

---

[148] បណ្ដឹងជំទាស់របស់ នួន ជា កថាខណ្ឌ ២៦, ៩៤ ដែលសំអាងលើសេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីលើកទីបីរបស់ អ.ជ.ត.ក កថាខណ្ឌ ៨៣។

[149] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៩-១០, ៥០-៥១ ដែលសំអាងលើសេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីលើកទីបីរបស់ អ.ជ.ត.ក កថាខណ្ឌ ៤៥ ៨៣ និង ៨៥។

៥១. នៅក្នុងអត្ថបទដែលបានលើកមកសំអាងនៅក្នុងបណ្ដឹងជំទាស់ អង្គជំនុំជម្រះតុលាការកំពូលបានបង្ហាញអំពីលទ្ធភាពដែលថា នៅពេលចៅក្រមសម្រេចលើបទចោទច្រើនប្រឆាំងនឹងជនជាប់ចោទដដែល បញ្ហាចោទនានាអាចត្រូវបានលើកឡើងទាក់ទងនឹងអនាគតិរបស់ចៅក្រម[150]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូលជៀសវាងមិនផ្ដល់ចម្លើយចំពោះបញ្ហានេះទេ ទោះក្នុងន័យទូទៅ ឬ ជាក់លាក់ក៏ដោយ។ ស្រដៀងគ្នានេះដែរ រឿងក្ដី (*Milošević* និង *Mladić*) ដែលត្រូវបានបង្ហាញនៅកថាខណ្ឌ ៨៣ ដោយអង្គជំនុំជម្រះតុលាការកំពូល ក៏យកចិត្តទុកដាក់លើបញ្ហានេះដូចគ្នាដែរ។

៥២. នៅក្នុងរឿងក្ដី *Milošević* ស្ថាប័នអយ្យការបានស្នើឡើងថា អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTY បញ្ចូលដីកាបញ្ជូនរឿងទៅជំនុំជម្រះរួមគ្នាដើម្បីឱ្យមានការជំនុំជម្រះតែមួយ។ អង្គជំនុំជម្រះតុលាការកំពូលបានអនុញ្ញាតឱ្យស្ថាប័នអយ្យការប្ដឹងសាទុក្ខ។ ទោះបីជាយ៉ាងនេះក៏ដោយ នៅពេលពិភាក្សាអំពីលទ្ធភាពនៃការជំនុំជម្រះដោយឡែកពីគ្នា អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTY បានអនុញ្ញាតឱ្យមានលទ្ធភាពថា ចៅក្រមដដែលអាចចូលរួមនៅក្នុងការជំនុំជម្រះទាំងពីរបាន[151]

[150] សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីលើកទីបីរបស់ អ.ជ.ត.ក យោងលើសេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ ដែលលើកឡើងនៅក្នុងផ្នែកពាក់ព័ន្ធថា នៅក្នុងករណីមានការជំនុំជម្រះច្រើនជាងការជំនុំជម្រះតែមួយ វាអាចមាន "ការព្រួយបារម្ភលើផ្នែកច្បាប់ និងលើការគ្រប់គ្រងប្រសិនបើក្រុមប្រឹក្សាជំនុំជម្រះដដែលត្រូវបានចាត់តាំងលើរឿងក្ដីទីមួយ និងទីពីរ រួមទាំងលទ្ធភាពថា ភាពលម្អៀង និងការលេចឡើងនូវភាពលម្អៀងនៃអង្គជំនុំជម្រះអាចត្រូវបានលើកឡើង"។ សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរសង្ខេបវិធីសាស្ត្រដែលបានអនុវត្តនៅតាមប្រព័ន្ធតុលាការជាតិមួយចំនួនលើការបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងបរិបទនៃការចង់ជៀសវាងនូវសេចក្ដីសម្រេចដែលប្រទាំងប្រទិសគ្នា។ ចំណុចចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ឃើញថា សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរពុំបានពិភាក្សាអំពីភាពលម្អៀងជាក់ស្ដែង ឬ ដែលអាចត្រូវបានមើលឃើញនៅក្នុងការជំនុំជម្រះនាពេលក្រោយៗ ប្រសិនបើសំណុំរឿង ០០២/០១ នាំឱ្យមានការសម្រេចឱ្យមានពិរុទ្ធភាព។ ទោះបីជាយ៉ាងនេះក្ដី សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរពុំបានលើកឡើងថា ចៅក្រមត្រូវបានរារាំងពីការចូលរួមជំនុំជម្រះលើរឿងក្ដីក្រោយៗប្រឆាំងនឹងជនជាប់ចោទដដែល។

[151] រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Milošević* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY រឿងក្ដីលេខ IT-99-37-AR73, IT-01-50-AR73, IT-01-51-AR73 សំអាងហេតុនៃសេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខបន្ទាន់បន្ទំចំពោះការបដិសេធលើដីកាបង្គាប់ឱ្យដាក់បញ្ចូលគ្នា (ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០២) ("សេចក្ដីសម្រេច *Milošević*") កថាខណ្ឌ ២៩៖ "ប្រសិនបើភស្តុតាងត្រូវបានទទួលយកដាក់បញ្ចូលនៅក្នុងការជំនុំជម្រះលើករណី Kosovo ដែលនឹងធ្វើឱ្យមានបុរេវិនិច្ឆ័យលើជនជាប់ចោទនៅក្នុងការជំនុំជម្រះលើករណី Croatia និង Bosnia ក្រុមប្រឹក្សាជំនុំជម្រះនៃអង្គជំនុំជម្រះសាលាដំបូងក្នុងនាមជាចៅក្រមវិជ្ជា

។ អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTY ពុំបានស្នើឡើងថា ភស្តុតាងនៅក្នុងការជំនុំជម្រះលើកទីមួយនឹងមិនអាចទទួលយកបាននៅក្នុងការជំនុំជម្រះលើកទីពីរនោះទេ[152]។ ក៏ប៉ុន្តែ ចំណុចយោងជើងទំព័រ ២០០ នៅក្នុងសេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីលើកទីបីរបស់ អ.ជ.ត.ក បង្ហាញច្បាស់ថា ការយោងរបស់អង្គជំនុំជម្រះតុលាការកំពូលលើការដកចេញភស្តុតាង ទាក់ទងនឹងលទ្ធភាពដែលចៅក្រមវិជ្ជាជីវៈមិនគិតពិចារណាទៅលើឯកសារសម្ភារៈដែលមិនពាក់ព័ន្ធ ដែលមិនត្រូវបានទទួលយកធ្វើជាភស្តុតាងនៅក្នុងរឿងក្ដីទីពីរឡើយ និងសម្រេចថា រឿងក្ដីបានផ្អែកតែទៅលើភស្តុតាងដែលត្រូវបានដាក់បញ្ចូលនៅក្នុងរឿងក្ដីនេះតែប៉ុណ្ណោះ[153]។

៥៣. នៅក្នុងរឿងក្ដី *Mladić* ស្ថាប័នអយ្យការបានស្នើសុំបំបែកកិច្ចដំណើរការនីតិវិធីដើម្បីឱ្យមានការជំនុំជម្រះពីរបន្តបន្ទាប់គ្នាប្រឆាំងនឹងជនជាប់ចោទតែមួយ។ នៅក្នុងការច្រានចោលសំណើសុំរបស់ស្ថាប័នអយ្យការ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានទទួលស្គាល់លទ្ធភាពដែលថាចៅក្រមដែលត្រូវបានចាត់តាំងសម្រាប់ការជំនុំជម្រះលើកទីមួយ ក៏អាចត្រូវបានចាត់តាំងសម្រាប់ការជំនុំជម្រះលើកទីពីរផងដែរ ហើយនៅពេលនោះបានលើកឡើងថា នឹងមាន "ការព្រួយបារម្ភខាងផ្នែកច្បាប់ និងផ្នែកគ្រប់គ្រងនៅក្នុងស្ថានភាពនេះ។ ភាពលម្អៀង ឬការលេចឡើងនូវភាពលម្អៀងរបស់អង្គជំនុំជម្រះអាចត្រូវបានលើកឡើង ប្រសិនបើអង្គជំនុំជម្រះដដែលធ្វើការសម្រេចលើរឿងក្ដីទាំងពីរនោះ"[154]។ សំអាងហេតុមានកម្រិតនេះ ដោយមិនបានយោងលើឯកសារមូលដ្ឋានផ្សេងៗនោះ ត្រូវបានថ្លឹងថ្លែងថាជាកត្តាមួយ ក្នុងចំណោមកត្តាជាច្រើនប្រឆាំងនឹងការបំបែកកិច្ចដំណើរការនីតិវិធីលើរឿងក្ដី

---

ជីវៈនឹងមានលទ្ធភាពមិនគិតពីភស្តុតាងដែលមានបុរេវិនិច្ឆ័យនេះ នៅពេលដែលចៅក្រមធ្វើការសម្រេចលើបញ្ហានានានៅក្នុងករណី Croatia និង Bosnia នោះ"។

[152] រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង* *Milošević* រឿងក្ដីលេខ IT-99-37-AR73, IT-01-50-AR73, IT-01-51-AR73 សំអាងហេតុនៃសេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខបន្ទាន់បង្ខំចំពោះការបដិសេធលើដីកាបង្គាប់ឱ្យដាក់បញ្ចូលគ្នា (ចុះថ្ងៃទី ១៨ ខែមេសា ឆ្នាំ ២០០២) សេចក្ដីសម្រេច *Milošević* កថាខណ្ឌ ៣០៖ "ប្រសិនបើជាការជំនុំជម្រះពីរដោយឡែកពីគ្នា ចាំបាច់នឹងមានភស្តុតាងច្រើនដែលនឹងលើកឡើងដដែលៗនៅក្នុងការជំនុំជម្រះនីមួយៗ"។

[153] សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីលើកទីបី លេខយោងជើងទំព័រ ២០០ *ដែលយោងលើ*សេចក្ដីសម្រេច *Milošević* កថាខណ្ឌ ២៨-២៩ ដែលបញ្ជាក់បំភ្លឺថា ភស្តុតាងដែលមានបុរេវិនិច្ឆ័យពីរឿងក្ដីមួយនឹងដកចេញមិនឱ្យយកទៅគិតក្នុងចិត្តចៅក្រមសម្រាប់ពិចារណាក្នុងរឿងក្ដីមួយទៀត ជាជាងសម្រេចថា ភស្តុតាងនេះមិនអាចទទួលយក។

[154] រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង* *Mladić* អង្គជំនុំជម្រះតុលាការដំបូង រឿងក្ដីលេខ IT-09-92-PT សេចក្ដីសម្រេចលើសំណើរួមរបស់ស្ថាប័នអយ្យការសុំបំបែកដីកាបញ្ជូនរឿងទៅជំនុំជម្រះដើម្បីធ្វើការជំនុំជម្រះដោយឡែកពីគ្នា និងសុំកែប្រែដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១១) ("*Mladić*, សេចក្ដីសម្រេចលើសំណើរួម") កថាខណ្ឌ ៣៥។

នេះ[155]។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY មិនបានបន្តទៅពិចារណាថាតើ នៅក្នុងករណីមានការបំបែកកិច្ចដំណើរការនីតិវិធី ការចូលរួមរបស់ចៅក្រមដដែលនៅក្នុងរឿងក្តីទាំងពីរ នឹងបង្កើតភាពលម្អៀងជាក់ស្តែង ឬ ការលេចឡើងនូវភាពលម្អៀងដែរ ឬយ៉ាងណានោះទេ។

៥៤. ផ្ទុយនឹងការអះអាងរបស់ នួន ជា អង្គជំនុំជម្រះតុលាការកំពូលមិនបានសម្រេចថា រឿងក្តីក្រោយៗដែលពាក់ព័ន្ធនឹងជនជាប់ចោទ និងភស្តុតាងតែមួយ មានជម្រើសចំនួនពីររវាង (i) ការដកចៅក្រម ឬ (ii) ការដកភស្តុតាងដែលមិនអាចទទួលយកបាននោះឡើយ។ ទាំងអង្គជំនុំជម្រះតុលាការកំពូល ទាំងឯកសារមូលដ្ឋានដែលបានដកស្រង់ មិនបានដាក់នូវជម្រើសបែបនេះឡើយ។ ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូល បានបង្ហាញលក្ខខណ្ឌសម្រាប់ភាពលម្អៀងទាក់ទងនឹងសំអាងហេតុរបស់តុលាការនៅក្នុងរឿងក្តីមុន ថាតើសំអាងហេតុទាំងនេះ "បង្ហាញជាការសន្និតនូវការទទួលខុសត្រូវព្រហ្មទណ្ឌ" ទាក់ទងនឹងរឿងក្តីក្រោយដែរ ឬទេ[156]?

## (៥) មូលដ្ឋាននៃបទដ្ឋានដែលអង្គជំនុំជម្រះតុលាការកំពូលបានកំណត់

៥៥. អង្គជំនុំជម្រះតុលាការកំពូលបានកំណត់ឯកសារសំអាងចំនួនបី (រឿងក្តី *Gali,* រឿងក្តី *Ntawukulilyayo* និងរឿងក្តី *Kabashi*) ដើម្បីគាំទ្របទដ្ឋានដែលអង្គជំនុំជម្រះបានកំណត់ ពោលគឺ ថាតើសំអាងហេតុទាំងឡាយនោះ បង្ហាញជាការសន្និតនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទទាក់ទងនឹងបទចោទនានាដែលនឹងត្រូវវិនិច្ឆ័យនៅក្នុងរឿងក្តីក្រោយៗទៀតដែរឬទេ[157]។

៥៦. នៅក្នុងរឿងក្តី *Galić*[158] ជនជាប់ចោទបានប្តឹងជំទាស់ចៅក្រម Orie ដោយហេតុថា ចៅក្រមរូបនេះបានសម្រេចតម្កល់ដីកាចោទប្រកាន់បញ្ជូន *Mladić* ទៅជំនុំជម្រះ ដែលដីកានេះបានកំណត់ឈ្មោះ *Galić* ជាអ្នកចូលរួមម្នាក់នៅក្នុងសហឧក្រិដ្ឋកម្មរួមដែលត្រូវបានចោទប្រកាន់ដូចគ្នា។

---

[155] *Mladić,* សេចក្តីសម្រេចលើសំណើរួម កថាខណ្ឌ ៣១-៣៨ ដែលអង្គជំនុំជម្រះសាលាដំបូងពិចារណាលើកត្តានានាដែលរួមបញ្ចូលទាំងបន្ទុករបស់ជនជាប់ចោទ ផលប៉ះពាល់ដែលអាចកើតមានលើដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី និងបន្ទុកដែលអាចកើតមានចំពោះសាក្សីដែលបានផ្តល់សក្ខីកម្មពីរដង។

[156] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីលើកទីបីរបស់ អ.ជ.ត.ក កថាខណ្ឌ ៨៥។

[157] សេចក្តីសម្រេចលើការបំបែកិច្ចដំណើរការនីតិវិធីលើកទីបីរបស់ អ.ជ.ត.ក លេខយោងជើងទំព័រ ១៩៩។

[158] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Galić* ការិយាល័យតុលាការ ICTY រឿងក្តីលេខ IT-98-29-T សេចក្តីសម្រេចលើពាក្យសុំរបស់ *Galić* អនុលោមតាមវិធាន ១៥(ខ) ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៣ ("សេចក្តីសម្រេចលើបណ្តឹងជំទាស់របស់ *Galić*")។

ការិយាល័យតុលាការ ICTY បានច្រាលចោលបណ្ដឹងរបស់ *Galić* ដោយផ្អែកលើមូលដ្ឋានថា អ្នកសង្កេតការណ៍មិនលម្អៀងដែលបានទទួលព័ត៌មានគ្រប់គ្រាន់នោះ នឹងទទួលស្គាល់ថា ការសម្រេចតម្កល់ដីកាចោទ ប្រកាន់បញ្ជូន *Mladić* ទៅជំនុំជម្រះ របស់ចៅក្រម Orie ពុំមែនជាបុរេវិនិច្ឆ័យមិនសមស្របលើពិរុទ្ធ ភាពរបស់ *Galić* ដែលនឹងរារាំងចៅក្រមរូបនោះមិនឱ្យជំនុំជម្រះ *Galić* ដោយអញ្ញាក្រឹតឡើយ[159]។ ចំណុចនេះខុសពីស្ថានភាពដែលចៅក្រមសម្រេច "លើបញ្ហាចុងក្រោយអំពីពិរុទ្ធ-ភាពរបស់បុគ្គលណា ម្នាក់នៅក្នុងការចោទប្រកាន់ដែលជាប់ពាក់ព័ន្ធគ្នានោះ"[160]។

៥៧. នៅក្នុងរឿងក្ដី *Ntawukulilyayo*[161] ចៅក្រម Robinson បានច្រានចោលបណ្ដឹងជំទាស់ចៅក្រមបួនរូបចេញពីការដោះស្រាយបណ្ដឹងសាទុក្ខ ដោយសារតែធ្លាប់បានចូលរួមនៅក្នុងបណ្ដឹងសាទុក្ខមួយទៀត ដែលបានតម្កល់ការសម្រេចដាក់បន្ទុក *Ntawukulilyayo* និងទទួលស្គាល់ការទុកចិត្តលើសាក្សីពីររូបដែលបានមកផ្ដល់សក្ខីកម្មលើរឿងក្ដីទាំងពីរ ប៉ុន្តែ *Ntawukulilyayo* បានជំទាស់។ ចៅក្រម Robinson បានទទួលស្គាល់ថា ចៅក្រមបាន "បង្ហាញសេចក្ដីសន្និដ្ឋានមួយចំនួន" និងបាន "ចង្អុលយោងលើទង្វើរបស់ *Ntawukulilyayo*" ពោលគឺ ការសន្យារបស់គាត់អំពីការផ្ដល់ការជ្រកកោនដោយសុវត្ថិភាពនេះ គឺជាការកុហក។ ទោះបីជាយ៉ាងណាក៏ដោយ ចៅក្រម Robinson បានសន្និដ្ឋានថា បញ្ហាទាំងនេះពុំមែន "បង្ហាញពីការប្រកាសពិរុទ្ធភាពរបស់ជននោះទេ"[162]។

៥៨. រឿងក្ដី *Kabashi*[163] គឺជារឿងក្ដីប្រមាថតុលាការក្រោយពេលសាក្សីម្នាក់បដិសេធមិនមកឆ្លើយនៅក្នុងការជំនុំជម្រះលើកទីមួយនៅក្នុងរឿងក្ដី *Haradinaj និងអ្នកផ្សេងទៀត*។ លោក Kabashi បាន

---

[159] សេចក្ដីសម្រេចលើបណ្ដឹងជំទាស់របស់ *Galić* កថាខណ្ឌ ១៥។

[160] សេចក្ដីសម្រេចលើបណ្ដឹងជំទាស់របស់ *Galić* កថាខណ្ឌ ១៦។ *Galić* បានលើកឡើងទឡ្ហីករណ៍ស្រដៀងគ្នាក្នុងបណ្ដឹងសាទុក្ខ។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានបញ្ជាក់ថា អ្នកសង្កេតការណ៍ដោយយុត្តិធម៌ដឹងថា ការបណ្ដុះបណ្ដាល និងបទពិសោធន៍របស់ចៅក្រមផ្ដល់សមត្ថភាពឱ្យពួកគាត់សម្រេចរឿងក្ដីដោយផ្អែកលើតែភស្តុតាងដែលត្រូវបានបង្ហាញនៅក្នុងពេលជំនុំជម្រះតែប៉ុណ្ណោះ។ *សូមមើល* រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង* Galić អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY រឿងក្ដីលេខ IT-98-29-A សាលដីកា ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៦ កថាខណ្ឌ ៤៤។

[161] រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង* Ntawukulilyayo អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR រឿងក្ដីលេខ ICTR-05-82-A សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចៅក្រម ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១១ ("សេចក្ដីសម្រេចលើបណ្ដឹងជំទាស់របស់ *Ntawukulilyayo*")។

[162] សេចក្ដីសម្រេចលើបណ្ដឹងជំទាស់របស់ *Ntawukulilyayo* កថាខណ្ឌ ១៦-១៨។

[163] រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Shefqet Kabashi* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY រឿងក្ដីលេខ IT-04-84-R77.1-S សាលក្រមដាក់ទោស ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១១ ("សាលក្រមដាក់ទោសក្នុងរឿងក្ដី *Kabashi*")

ចាកចេញពីប្រទេសហូឡង់នៅមុនពេលចាប់ផ្តើមការជំនុំជម្រះលើបទប្រមាថតុលាការ[164]។ បន្ទាប់មក គាត់ត្រូវបានតុលាការកោះហៅឲ្យមកផ្តល់សក្ខីកម្មនៅក្នុងការជំនុំជម្រះឡើងវិញលើរឿងក្តី*Haradinaj និងអ្នកផ្សេងទៀត*។ នីតិវិធីលើបទប្រមាថតុលាការបានបន្តធ្វើឡើងស្របពេលជាមួយនឹងការជំនុំជម្រះឡើងវិញ។ ក្រុមប្រឹក្សាជំនុំជម្រះដែលត្រូវបានចាត់តាំងទៅការជំនុំជម្រះលើបទប្រមាថតុលាការរួមមានចៅក្រម Orie ដែលធ្លាប់ធ្វើជាចៅក្រមប្រធានក្នុងការជំនុំជម្រះលើកទីមួយក្នុងរឿងក្តី *Haradinaj និងអ្នកផ្សេងទៀត* ព្រមទាំងចៅក្រម Moloto និងចៅក្រម Delvoie ដែលចៅក្រមទាំងពីររូបនេះ ជាចៅក្រមចូលរួមក្នុងការជំនុំជម្រះឡើងវិញ[165]។ នៅក្នុងសប្តាហ៍ពីថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១១ លោក Kabashi ត្រូវបានកំណត់ឲ្យមកផ្តល់ភ័ស្តុតាងនៅក្នុងការជំនុំជម្រះឡើងវិញនេះ និងបន្ទាប់មកឲ្យបង្ហាញខ្លួនលើកដំបូងនៅក្នុងរឿងក្តីប្រមាថតុលាការ។ នៅពេលផ្តល់ភ័ស្តុតាងក្នុងការជំនុំជម្រះឡើងវិញ លោក Kabashi បាននិយាយថា គាត់មិនមានលទ្ធភាពឆ្លើយទៅនឹងសំណួរមួយចំនួននោះទេ។ ករណីនេះបានបណ្តាលឲ្យមានបណ្តឹងនានាពីស្ថាប័នអយ្យការ និងមេធាវីការពារក្តី ជាពិសេស ទាក់ទងនឹងស្ថានភាពប្រតិចារឹកនៃភ័ស្តុតាងរបស់លោក Kabashi ពីក្នុងរឿងក្តីមួយផ្សេងទៀត (រឿងក្តី *Limaj និងអ្នកផ្សេងទៀត*)។ យោងតាមសំណើសុំរបស់ស្ថាប័នអយ្យការ អង្គជំនុំជម្រះសាលាដំបូងបានទទួលយកប្រតិចារឹករបស់លោក Kabashi ពីក្នុងរឿងក្តី *Limaj និងអ្នកផ្សេងទៀត* មកដាក់បញ្ចូលជា ភ័ស្តុតាង។ ក្រោយមក នៅពេលលោក Kabashi បាននិយាយថា គាត់មិនមានលទ្ធ-ភាពឆ្លើយតបទៅនឹងសំណួរពីខាងមេធាវីការពារក្តី មេធាវីបានដាក់ពាក្យសុំដកប្រតិចារឹកចេញពីរឿងក្តី *Limaj និងអ្នកផ្សេងទៀត*[166]។

៥៩. នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១១ នៅពេលលោក Kabashi បង្ហាញខ្លួនលើកដំបូងនៅក្នុងរឿងក្តី ប្រមាថតុលាការ ពាក្យសុំទាំងនេះនៅកំពុងរង់ចាំការសម្រេចសេចក្តីនៅឡើយនៅក្នុងការជំនុំជម្រះឡើងវិញលើរឿងក្តី *Limaj និងអ្នកផ្សេងទៀត*។ ចៅក្រម Orie បានសម្រេចថា ការចូលរួម

---

[164] សូមមើល សាលក្រមដាក់ទោសក្នុងរឿងក្តី *Kabashi* កថាខណ្ឌ ១ និងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Haradinaj និងអ្នកផ្សេងទៀត* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY រឿងក្តីលេខ IT-04-84-T, សាលក្រម ចុះថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០០៨ កថាខណ្ឌ ២៧។

[165] សាលក្រមដាក់ទោសក្នុងរឿងក្តី *Kabashi* កថាខណ្ឌ ៥។

[166] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Haradinaj និងអ្នកផ្សេងទៀត* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY រឿងក្តីលេខ IT-04-84bis-T, សេចក្តីសម្រេចលើសំណើសុំផ្ទាល់មាត់រួមគ្នារបស់មេធាវីការពារក្តីអនុលោមតាមវិធាន ៨៩(ឃ) ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ១។

របស់គាត់នៅ ក្នុងការជំនុំជម្រះលើកទីមួយនៅក្នុងរឿងក្តី *Haradinaj និងអ្នកផ្សេងទៀត* ដែលក្នុងអំឡុងពេលនោះការចោទប្រកាន់អំពីការប្រមាថតុលាការបានលេចឡើងនោះ ពុំបានដិតចិត្តគាត់មិនឱ្យធ្វើជាចៅក្រម នៅក្នុងការជំនុំជម្រះលើរឿងក្តីប្រមាថតុលាការរបស់ Kabashi នោះទេ[167]។ ចៅក្រម Moloto និង Delvoie បានដកខ្លួនចេញពីរឿងក្តីប្រមាថតុលាការ ពីព្រោះមានការការវិវឌ្ឍថ្មីៗនៅក្នុងការជំនុំជម្រះ ឡើងវិញលើរឿងក្តី *Haradinaj និងអ្នកផ្សេងទៀត*។ ចៅក្រមទាំងពីរបានផ្តល់ការពន្យល់ខ្លីអំពីសេចក្តីសម្រេចរបស់ពួកគាត់រៀងៗខ្លួន។ ចៅក្រម Moloto បានពន្យល់សេចក្តីសម្រេចរបស់គាត់ថាមិនមែនតែអំពីបញ្ហាភាពលម្អៀងជាក់ស្តែងនោះទេ ប៉ុន្តែទាក់ទងនឹងការលេចឡើងនូវភាពលម្អៀងផងដែរ[168]។ ចៅក្រម Delvoie បានលើកឡើងថា ការព្រួយបារម្ភរបស់គាត់គឺបញ្ហាសុចរិតភាព និងវឌ្ឍនភាពនៃការជំនុំជម្រះឡើងវិញ[169]។

៦០. សំអាងហេតុសង្ខេបផ្តល់ដោយចៅក្រម Moloto និង Delvoie ធ្វើឱ្យមានការលំបាកក្នុងការញែកគោលការណ៍ជាក់លាក់ពីឧទាហរណ៍នេះណាស់។ ទោះបីជាយ៉ាងនេះក្តី កាលៈទេសៈជុំវិញនានាពុំបង្ហាញថា ចៅក្រមវិជ្ជាជីវៈត្រូវដិតចិត្តមិនឱ្យធ្វើការសម្រេចសេចក្តីលើពិរុទ្ធភាពរបស់ជនជាប់ចោទទាក់ទងនឹងកិច្ចដំណើរការនីតិវិធីពីរផ្សេងគ្នា ដូចចៅក្រម ឬអ្នកវិនិច្ឆ័យធម្មតានោះទេ។ នៅពេលអង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTY បានបង្គាប់ឱ្យជំនុំជម្រះឡើងវិញនៅក្នុងរឿងក្តី *Haradinaj និងអ្នកផ្សេងទៀត* អង្គជំនុំជម្រះនេះពុំបានផ្តល់ការណែនាំអំពីសមាសភាពនៃចៅក្រមនោះឡើយ ជាពិសេស អង្គជំនុំជម្រះនេះពុំបានលើកឡើងថា ចៅក្រមដែលបានចូលរួមនៅក្នុងការជំនុំជម្រះលើកទីមួយត្រូវដកសិទ្ធិចេញពីការជំនុំជម្រះឡើងវិញនោះទេ[170]។ ផ្ទុយមកវិញ នៅពេលចាត់តាំងចៅក្រមឱ្យជំនុំជម្រះឡើងវិញ ប្រធានតុលាការ ICTY បានពិចារណាអំពីតម្រូវការក្នុងការគ្រប់គ្រង

---

[167] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Shefqet Kabashi* រឿងក្តីលេខ IT-04-84-R77.1-S, ប្រតិចារឹក (អង់គ្លេស) ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១១ ទំព័រ ៦៣-៦៥ ("ការបង្ហាញខ្លួនជាលើកដំបូងរបស់ *Kabashi*")។

[168] ការបង្ហាញខ្លួនជាលើកដំបូងរបស់ *Kabashi* ទំព័រ ៦៨។

[169] ការបង្ហាញខ្លួនជាលើកដំបូងរបស់ *Kabashi* ទំព័រ ៦៩។

[170] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Haradinaj និងអ្នកផ្សេងទៀត* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY រឿងក្តីលេខ IT-04-84-A, សាលដីកា ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១០ ទំព័រ ១១៤។

ការជំនុំជម្រះ និងតម្រូវការក្នុងការបែងចែករឿងក្ដីរបស់សាលាក្ដី មិនមែនការពាក់ព័ន្ធនឹងរឿងក្ដី ឬ ដំណើរការនីតិវិធីពាក់ព័ន្ធនាពេលមុនរបស់ចៅក្រមជាក់លាក់ណាមួយនោះទេ[171]។

៦១. ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលទំនងជាមិនបានពិចារណាទៅលើរឿងក្ដីលោក *Kabashi* ក្នុងការលើកឡើងថា ចៅក្រមវិជ្ជាជីវៈចាំបាច់ត្រូវហាមឃាត់មិនឱ្យចូលរួមសម្រេចលើពិរុទ្ធភាពរបស់ជនជាប់ចោទដដែល នៅក្នុងកិច្ចដំណើរការនីតិវិធីមួយផ្សេងទៀតនោះទេ។ ស្របជាមួយនឹងការសន្និដ្ឋាននោះ នៅក្នុងរឿងក្ដី *Šešelj* ជនជាប់ចោទត្រូវបានជំនុំជម្រះលើបទ ប្រមាថតុលាការជាច្រើនដង ចំពោះការផ្សាយជាសាធារណៈដែលបានលាតត្រដាងព័ត៌មានលម្អិត អំពីសាក្សីដែលត្រូវបានការពារ។ ជនជាប់ចោទបានតវ៉ាថា ចៅក្រមទាំងពីរនាក់គួរត្រូវដិតចិត្តចេញពីរឿងក្ដីប្រមាថតុលាការលើកទីពីរ ពីព្រោះ ចៅក្រមទាំងពីរជាក្រុមប្រឹក្សាជំនុំជម្រះដែលបានសម្រេចឱ្យជនជាប់ចោទមានពិរុទ្ធភាពនៅក្នុងរឿងក្ដីប្រមាថតុលាការលើកទីមួយ។ អង្គជំនុំជម្រះដែលត្រូវបានតែងតាំងឱ្យសម្រេចលើបណ្ដឹងដិតចិត្តរបស់ *Šešelj* រួមមាន: ចៅក្រម *Delvoie* ដែលបានច្រានចោលសេចក្ដីសន្និដ្ឋានរបស់ *Šešelj* ដោយផ្អែកលើមូលដ្ឋានថា ទោះបីជាចៅក្រមទាំងនេះធ្លាប់បានសម្រេចឱ្យ *Šešelj* មានពិរុទ្ធភាពនាពេលមុនក៏ដោយ ក៏ Šešelj ខកខានមិនបានបង្ហាញថា ចៅក្រមទាំងនេះមានបុរេវិនិច្ឆ័យប្រឆាំងនឹងរូបគាត់ ដែលនឹងធ្វើឱ្យមានភាពលម្អៀងជាក់ស្ដែង ឬ នាំឱ្យអ្នកសង្កេតការណ៍មិនលម្អៀងយល់ឃើញពីភាពលម្អៀងនោះឡើយ[172]។ ការអះអាងថា ចៅក្រមមានភាពលម្អៀង ដោយសារតែចៅក្រមទាំងនេះបានសម្រេច ជាពិសេសពាក់ព័ន្ធនឹងជនជាប់ចោទនោះ គឺគ្មានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ការប្ដឹងដិតចិត្តនោះទេ[173]។

---

[171] រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង* Haradinaj *និងអ្នកផ្សេងទៀត* ប្រធានតុលាការ ICTY រឿងក្ដីលេខ IT004-84-PT*bis* ដីកាសម្រេចចាត់តាំងចៅក្រមលើរឿងក្ដីចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១០ ទំព័រ ២។

[172] រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង* Vojislav Šešelj អង្គជំនុំជម្រះតុលាការ ICTY ដែលត្រូវបានរៀបចំឡើងតាមសេចក្ដីបង្គាប់របស់ប្រធាន រឿងក្ដីលេខ IT-03-67-R77.3 សេចក្ដីសម្រេចលើសំណើរបស់សាស្ត្រាចារ្យ *Vojislav Šešelj* សុំប្ដឹងដិតចិត្តចៅក្រម O-Gon Kwon និងចៅក្រម Kevin Parker ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១០ ("សេចក្ដីសម្រេចលើបណ្ដឹងរបស់ *ešelj* ប្ដឹងដិតចិត្តចៅក្រម O-Gon Kwon និង Kevin Parker") កថាខណ្ឌ ២៥-២៩។

[173] សេចក្ដីសម្រេចលើបណ្ដឹងរបស់ *ešelj* ប្ដឹងដិតចិត្តចៅក្រម O-Gon Kwon និង Kevin Parker កថាខណ្ឌ ២៨-២៩ (ដែលបានឯកភាពលើសេចក្ដីសម្រេចលើបណ្ដឹងដិតចិត្ត *Brdanin និង Talić* កថាខណ្ឌ ១៨៖ "វាអាចមានស្ថានភាពដែលសេចក្ដីសម្រេចមុនៗរបស់មន្ត្រីតុលាការលើអង្គច្បាប់ និងអង្គហេតុ អាចបង្កើតឱ្យមានក្ដីរំពឹងទុកថា មន្ត្រីតុលាការនេះទំនងជា សម្រេចលើបញ្ហាទាំងឡាយនៅក្នុងរឿងក្ដីនោះ ដែលធ្វើឱ្យប៉ះពាល់ដល់ភាគីមួយចំណោមភាគីទាំងនោះ។ ប៉ុន្តែ នេះពុំ

៦២. ករណីនេះស្របនឹងយុត្តិសាស្ត្រដែលថា នៅពេលការចូលរួមរបស់ចៅក្រមនៅក្នុងកិច្ចដំណើរការនីតិវិធីនាពេលមុនត្រូវបានយកមកធ្វើជាមូលដ្ឋាន ក្នុងការបង្ហាញនូវការយល់ឃើញយ៉ាងសមហេតុផលអំពីភាពលម្អៀងនោះ លក្ខខណ្ឌមិនមែនថាតើចៅក្រមនឹងសម្រេចលើបញ្ហានានាតាមវិធីដដែលៗដូចដែលធ្លាប់បានសម្រេចលើបញ្ហាទាំងនោះនៅក្នុងកិច្ចដំណើរការនីតិវិធីមុនៗនោះទេ ប៉ុន្តែ គឺថាតើចៅក្រមនឹងមានការពិចារណាដោយភាពមិនលម្អៀង និងមិនមានបុរេវិនិច្ឆ័យលើរឿងក្តីបច្ចុប្បន្នដែរ ឬយ៉ាងណា[174]។ នៅពេលមានការបង្ហាញតាមរយៈមតិយោល់របស់ចៅក្រម បុរេវិនិច្ឆ័យលើដំណោះស្រាយមួយជាក់លាក់ ពុំមែនជាការលម្អៀងនោះទេ[175]។ ដូច្នេះ នៅក្នុងរឿងក្តី *Karemera និង អ្នកផ្សេងទៀត* ការិយាល័យរបស់សាលាជំនុំជម្រះក្តី ICTR បានច្រានចោលបណ្តឹងជំទាស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូងពីររូបចេញពីការវិនិច្ឆ័យសាជាថ្មី លើសេចក្តីសម្រេចដែលត្រូវច្រានចោលនៅក្នុងរឿងក្តីដដែលនេះ។ ការិយាល័យនេះបានសម្រេចថា "លទ្ធភាពដែលថា ដោយសារធ្លាប់បានសម្រេចនាពេលកន្លងមកលើអង្គសេចក្តីដែលពាក់ព័ន្ធ ចៅក្រម Byron និងចៅក្រម Kam មានបុរេវិនិច្ឆ័យក្នុងការអនុវត្តច្បាប់ និងវាយតម្លៃលើអង្គហេតុនៅក្នុងលក្ខណៈដូចគ្នា ហេតុដូច្នេះហើយ បើយោងតាមអង្គច្បាប់ លទ្ធភាពនេះ គឺគ្មានលក្ខណៈគ្រប់គ្រាន់ក្នុងការច្រានចោលសច្ចធារណ៍នៃភាពមិនលម្អៀងនោះទេ"[176]។ ទោះបីជាចៅក្រមទាំងនោះធ្លាប់បានសម្រេចរួចហើយ លើបញ្ហានានានៅក្នុងរឿងក្តីដដែលនេះក៏ដោយ ក៏ករណីនេះពុំបង្ហាញថា អ្នកសង្កេតការណ៍មិនលម្អៀងនឹងមានវិមតិសង្ស័យលើអនាគតិរបស់ចៅក្រមទាំងនេះ នោះទេ។

---

មានន័យថា មន្ត្រីតុលាការរូបនេះនឹងដោះស្រាយបញ្ហានៅក្នុងរឿងក្តីនេះខុសពីការពិចារណាដោយមិនលម្អៀង និងធ្វើឱ្យអន្តរាយក្នុងន័យដែលថា ពាក្យពេចន៍ដែលត្រូវបានប្រើប្រាស់នៅក្នុងឯកសារសំអាង ឬ សេចក្តីសម្រេចមុនរបស់គាត់ ផ្តល់មូលដ្ឋានអាចទទួលយកបានមួយសម្រាប់ការសន្និដ្ឋានថា វាអាចមើលដឹងយ៉ាងសមហេតុផលថា គាត់នឹងដោះស្រាយបញ្ហាទាំងនេះក្នុងផ្លូវមួយដែលប៉ះពាល់ដល់ភាគីឡើយ"។

[174] សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រមរបស់ អៀង ធីរិទ្ធ នួន ជា និង អៀង សារី កថាខណ្ឌ ១៥ និងឯកសារមូលដ្ឋានដែលត្រូវបានដកស្រង់នៅក្នុងឯកសារយោងនោះ។

[175] សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រមរបស់ អៀង ធីរិទ្ធ នួន ជា និង អៀង សារី កថាខណ្ឌ ១៥ ដែលដកស្រង់រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karemera និងអ្នកផ្សេងទៀត* ការិយាល័យតុលាការ ICTR រឿងក្តីលេខ ICTR-98-44-T សេចក្តីសម្រេចលើសំណើសុំច្រានចោលសេចក្តីសម្រេច និងសំណើសុំប្តឹងជំទាស់ចៅក្រម Byron និងចៅក្រម Kam ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៧ កថាខណ្ឌ ១៥។ *សូមមើលផងដែរ* សាលដីកា *Furundžija* កថាខណ្ឌ ១៨៩-១៩០។

[176] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karemera និងអ្នកផ្សេងទៀត* ការិយាល័យតុលាការ ICTR រឿងក្តីលេខ ICTR-98-44 សេចក្តីសម្រេចលើសំណើសុំច្រានចោលសេចក្តីសម្រេច និងសំណើសុំប្តឹងជំទាស់ចៅក្រម Byron និងចៅក្រម Kam ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៧ កថាខណ្ឌ ១៥។

៦៣. គោលការណ៍ណែនាំផ្សេងទៀតអាចយកចេញពីរឿងក្តី *Katanga* ។ ចៅក្រមពេញអង្គនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ICC បានច្រានចោលបណ្តឹងរបស់តំណាងជនរងគ្រោះដែលបានប្តឹងជំទាស់ចិត្តចៅក្រម Van den Wyngaert មិនឱ្យពិចារណាលើបញ្ហាសំណង ក្រោយពេលលោកស្រីចៅក្រមរូបនេះបានចេញមតិជំទាស់លើបញ្ហាពិរុទ្ធភាពរបស់ *Katanga*[177] ។ បណ្តឹងជំទាស់ចិត្តត្រូវបានដាក់ប្តឹងដោយផ្អែកលើមូលដ្ឋានមួយចំនួន ក្នុងចំណោមនោះ គឺ មតិជំទាស់របស់ចៅក្រម (ដែលជាការចែងនៅបណ្តឹងជំទាស់ចិត្តរបស់ នួន ជា ក៏បានយកមកធ្វើជាសំអាងផងដែរ សម្រាប់បរិបទមួយផ្សេងទៀត[178]) បានរិះគន់ចំពោះការវាយតម្លៃលើភស្តុតាងរបស់ចៅក្រមភាគច្រើន ហើយមតិជំទាស់នេះ បានច្រានចោលភាពអាចជឿជាក់បាននៃសាក្សីដែលជាជនរងគ្រោះផងដែរ ហេតុដូច្នេះ ការធ្វើបុរេវិនិច្ឆ័យលើភាពជឿជាក់បាន ឬ ភាពទុកចិត្តបាននៃសក្ខីកម្មរបស់សាក្សី ដោយសារតែសាក្សីរូបនេះបានទាមទារសំណង[179]។ ទោះបីជាបណ្តឹងនេះត្រូវបានសម្រេចថាមិនអាចទទួលយកបានក៏ដោយ ចៅក្រមពេញអង្គបានបង្ហាញទស្សនៈជាឯកច្ឆន្ទថា “ការសំដែងមតិយោបល់របស់ចៅក្រមភាគតិច ពុំអាចធ្វើឱ្យចៅក្រមលម្អៀង ឬ គ្មានអនាគតិនៅក្នុងកិច្ចដំណើរការនីតិវិធីនាពេលក្រោយៗនោះទេ”[180]។ ចៅក្រមពេញអង្គបានកត់សម្គាល់ថា ប្រសិនបើទទួលយកសំអាងហេតុនៅក្នុងបណ្តឹងនេះមែននោះ វាមានន័យថា នៅពេលដែលសេចក្តីសម្រេចធ្វើឡើងលើពិរុទ្ធភាព ឬ និរទោសរបស់ជនជាប់ចោទ ទោះដោយចៅក្រមភាគច្រើន ឬ ជាឯកច្ឆន្ទក្តី ក្រុមប្រឹក្សាជំនុំជម្រះដដែលនេះ នឹងពុំអាចបន្តវិនិច្ឆ័យលើកិច្ចដំណើរការនីតិវិធីលើសំណងនោះបានទេ។ ចៅក្រមពេញអង្គបានច្រានចោលការលើកឡើងសំអាងហេតុបែបនេះ[181]។

៦៤. ផ្ទុយទៅនឹងសំណើដែល នួន ជា បានលើកឡើង ហេតុដូច្នេះ គ្មានមូលដ្ឋានណាមួយដែលអាចសន្និដ្ឋានថា លក្ខខណ្ឌលើបញ្ហាលម្អៀងដោយសារចៅក្រមបានចេញសេចក្តីសម្រេចនាពេលមុនលើពិរុទ្ធភាពរបស់ជនណាម្នាក់ គួរតែជាលក្ខខណ្ឌអ្វីក្រៅពីលក្ខខណ្ឌដែលអង្គជំនុំជម្រះតុលាការកំពូលបាន

---

[177] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* Katanga កិច្ចប្រជុំពេញអង្គរបស់ចៅក្រមនៅតុលាការ ICC រឿងក្តីលេខ ICC-01/04-01/07-3504-ឧបសម្ព័ន្ធ សេចក្តីសម្រេចរបស់ចៅក្រមពេញអង្គលើសំណើរបស់អ្នកតំណាងផ្លូវច្បាប់របស់ជនរងគ្រោះសុំប្តឹងជំទាស់ចិត្តចៅក្រម Christine Van den Wyngaert ពីរឿងក្តី រដ្ឋអាជ្ញា ទល់នឹង Germain Katanga ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៤ (“សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តរបស់ *Katanga*”)

[178] បណ្តឹងជំទាស់ចិត្តរបស់ នួន ជា កថាខណ្ឌ ៣៩ ១២៤-១២៥, ១២៧, ១៣០-១៣១។

[179] សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តរបស់ *Katanga* កថាខណ្ឌ ១៨។

[180] សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តរបស់ *Katanga* កថាខណ្ឌ ៥១។

[181] សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តរបស់ *Katanga* កថាខណ្ឌ ៥២។

កំណត់ រួមទាំងលក្ខខណ្ឌនៅក្នុងឯកសារសំអាងនានាដែលអង្គជំនុំជម្រះតុលាការកំពូលយកមកធ្វើជាមូលដ្ឋានផងដែរនោះទេ (រឿងក្តី *Galić,* រឿងក្តី *Ntawukulilyayo* និងរឿងក្តី *Kabashi*) ។

### (៦) រឿងក្តីនានាទាក់ទងនឹង "កម្រងភ័ស្តុតាងដោយឡែក"

៦៥. អង្គជំនុំជម្រះតុលាការកំពូលក៏បានយោងទៅ "កម្រងយុត្តិសាស្ត្រ" ផងដែរ ដោយច្រានចោលបណ្តឹងជំទាស់ចៅក្រម ដែលបានសន្មតថា មាន "កម្រងភ័ស្តុតាងដោយឡែក" នៅក្នុងរឿងក្តីនីមួយៗ ដែលចៅក្រមត្រូវបានបណ្តុះបណ្តាលឱ្យផ្តោតទៅលើការសម្រេចចិត្តរបស់ខ្លួន[182]។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថា ចំណុចនេះបង្ហាញពីភាពខុសគ្នាទៅនឹងសំណុំរឿង ០០២ ហើយបានបង្ហាញរឿងក្តីចំនួនបីជាក់លាក់ គឺ រឿងក្តី *Stanišić និង Župljani,* រឿងក្តី *Renzaho* និងរឿងក្តី *Nahimana និងអ្នកផ្សេងទៀត*[183]។

៦៦. នៅក្នុងរឿងក្តី *Stanišić និង Župljanin* ជនជាប់ចោទទាំងពីរត្រូវបានអង្គជំនុំជម្រះសាលាដំបូង ក្នុងនោះមានចៅក្រម Harhoff[184] ផងដែរ សម្រេចឱ្យជាប់ពិរុទ្ធ។ ជនជាប់ចោទទាំងពីរបានប្តឹងសាទុក្ខ ហើយក្រុមប្រឹក្សាជំនុំជម្រះដែលត្រូវបានចាត់តាំងឱ្យសម្រេចលើបណ្តឹងសាទុក្ខទាំងនេះ រួមមានចៅក្រម Liu Daqun ផងដែរ។ ក្រោយមក នៅក្នុងការជំនុំជម្រះលើរឿងក្តី *Šešelj* អង្គជំនុំជម្រះមួយបានសម្រេចថា ចៅក្រម Liu Daqun បានចេញមតិជំទាស់ថា ចៅក្រម Harhoff គួរតែដកខ្លួនចេញពីក្នុងរឿងក្តីនេះ[185]។ បន្ទាប់មក ជនជាប់ចោទ Župljanin (i) បានដាក់សំណើទៅអង្គជំនុំជម្រះតុលាការកំពូលឱ្យច្រានចោលសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តីរបស់ខ្លួន និង (ii) បានដាក់បណ្តឹងជំទាស់ចៅក្រម Liu Daqun ចេញពីការសម្រេចសេចក្តីលើសំណើសុំនេះ ពីព្រោះថា យោងតាមសេចក្តីសន្និដ្ឋានរបស់ជនជាប់ចោទ ចៅក្រម Liu Daqun បានបង្ហាញទស្សនៈនៅក្នុងមតិជំទាស់របស់ខ្លួនរួចហើយ អំពីលិខិតរបស់ចៅក្រម Harhoff ក្នុងរឿងក្តី *Šešelj* ថា ចៅក្រម Harhoff នឹងមិនអាចវិនិច្ឆ័យលើសំណើសុំឱ្យច្រានចោលសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងបានទេ ដោយសារចៅក្រមរូបនេះ មានបុរេវិនិច្ឆ័យទៅលទ្ធផលជាក់លាក់មួយ។ នៅក្នុងការច្រានចោល

---

[182] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីលើកទីបីរបស់ អ.ជ.ត.ក កថាខណ្ឌ ៨៣។

[183] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីលើកទីបីរបស់ អ.ជ.ត.ក លេខយោងជើងទំព័រ ១៩៧។

[184] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Stanišić និង Župljanin* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY រឿងក្តីលេខ IT-08-91-T សាលក្រម ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣។

[185] សេចក្តីសម្រេចលើបណ្តឹងរបស់ *Šešelj* ប្តឹងដកខ្លួនចៅក្រម Harhoff។

បណ្ដឹងរបស់ Župljanin ប្ដឹងជំទាស់ចៅក្រម Liu Daqun ប្រធានសាលាក្ដីស្ដីទី គឺចៅក្រម Agius បានទទួលស្គាល់អំពីចំណុចជាន់គ្នារវាងមូលដ្ឋាននៃបណ្ដឹងរបស់ Šešelj ប្ដឹងជំទាស់ចៅក្រម Harhoff និងសំណើរបស់ Župljanin សុំឱ្យច្រានចោលសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ ទោះបីជាយ៉ាងនេះក៏ដោយ ប្រធានសាលាក្ដីស្ដីទីបានសន្និដ្ឋានថា បណ្ដឹងប្ដឹងជំទាស់មាន "លក្ខណៈខុសគ្នាខ្លាំង" ពីបញ្ហា ថាតើត្រូវច្រានចោលសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដែរឬក៏អត់។ មិនមានការបង្ហាញឱ្យឃើញថា ចៅក្រម Liu Daqun មិនបានពិចារណាដោយអនាគតិលើបញ្ហាអង្គហេតុ និងអង្គច្បាប់ដែលពាក់ព័ន្ធនោះទេ[186]។ ទោះជាអង្គជំនុំជម្រះតុលាការកំពូលមិនបានដកស្រង់ក្ដី ក្រោយមកវិធីសាស្ត្ររបស់ចៅក្រម Agius ត្រូវបានតម្កល់ដោយក្រុមប្រឹក្សាជំនុំជម្រះដែលត្រូវបានតែងតាំងយោងតាមសំណើរបស់ Župljanin សុំឱ្យវិនិច្ឆ័យលើបណ្ដឹងរបស់ខ្លួន ដែលបានប្ដឹងជំទាស់ចៅក្រម Liu Daqun[187]។ ក្រុមប្រឹក្សាជំនុំជម្រះនេះបានចាត់ទុកទឡ្ហីករណ៍ប្ដឹងជំទាស់ ថាជាទឡ្ហីករណ៍ "គ្មានមូលដ្ឋាន"[188]។

៦៧. នៅក្នុងរឿងក្ដី *Renzaho* ចៅក្រមទាំងបីរូបដែលបានចូលរួមជំនុំជម្រះនៅក្នុងរឿងក្ដី *Karera* ហើយចៅក្រមពីររូបក្នុងចំណោមនេះ ក៏បានចូលរួមជំនុំជម្រះនៅក្នុងរឿងក្ដី *Bagosora និងអ្នកផ្សេងទៀត* ផងដែរ។ អង្គជំនុំជម្រះតុលាការកំពូលរបស់សាលាក្ដី ICTR បានច្រានចោលសេចក្ដីសន្និដ្ឋានថា ចៅក្រមម្នាក់ដែលជំនុំជម្រះរឿងក្ដីពីរ ត្រូវតែជំទាស់ នៅពេលដែលសាក្សីនៅក្នុងរឿងក្ដីទីមួយបានផ្ដល់ភស្តុតាងដាក់បន្ទុកជនជាប់ចោទនៅក្នុងរឿងក្ដីទីពីរ។ អង្គជំនុំជម្រះតុលាការកំពូលរបស់សាលាក្ដី ICTR បាន សម្រេចថា៖

> ចៅក្រមមិនត្រូវជំទាស់ចេញពីការជំនុំជម្រះលើរឿងក្ដីពីរ ឬ ច្រើនដែលកើតចេញពីហេតុការណ៍ដូចៗគ្នា និងដែលពាក់ព័ន្ធនឹងភស្តុតាងស្រដៀងគ្នានោះទេ។ ហេតុដូច្នេះ ចៅក្រមដែលជំនុំជម្រះភស្តុតាងស្រដៀងគ្នាអាចស្ដាប់សាក្សីដដែលនៅក្នុងការជំនុំជម្រះលើសពីមួយបាន។ ដូចបាន

[186] រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Stanišić និង Župljanin* ប្រធានតុលាការ ICTY រឿងក្ដីលេខ IT-08-91-A សេចក្ដីសម្រេចលើសំណើសុំឱ្យដកខ្លួន ចុះថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១៣ កថាខណ្ឌ ២៣។

[187] រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Stanišić និង Župljanin* ក្រុមប្រឹក្សាជំនុំជម្រះនៃតុលាការ ICTY ដែលត្រូវបានរៀបចំឡើងដោយប្រធានស្ដីទី រឿងក្ដីលេខ IT-08-91-A សេចក្ដីសម្រេចលើសំណើសុំឱ្យចៅក្រម Liu ដកខ្លួនពីការវិនិច្ឆ័យលើសំណើសុំច្រានចោលសាលក្រមសាលាដំបូង ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៤ ("សេចក្ដីសម្រេចលើបណ្ដឹងរបស់ *Stanišić និង Župljanin* ប្ដឹងជំទាស់ចៅក្រម Liu")។

[188] សេចក្ដីសម្រេចលើបណ្ដឹងរបស់ *Stanišić និង Župljanin* ប្ដឹងជំទាស់ចៅក្រម Liu កថាខណ្ឌ ១៥។

រម្លឹកនាពេលមុន នៅពេលពុំមានភស្តុតាងផ្ទុយ ចៅក្រមត្រូវបានសន្មតថា មានអនាគតិ នៅពេលសម្រេចលើបញ្ហានានានៅចំពោះមុខពួកគេ ដោយសារបានផ្អែកតែលើភស្តុតាងដែលលេចចេញមកពីក្នុងរឿងក្តីទាំងស្រុងនៅក្នុងរឿងក្តីនីមួយៗតែប៉ុណ្ណោះ[189]។

៦៨. នៅក្នុងរឿងក្តី *Nahimana និងអ្នកផ្សេងទៀត* អង្គជំនុំជម្រះតុលាការកំពូលរបស់សាលាក្តី ICTR បានសម្រេចថា ចៅក្រមមិនត្រូវដិតចិត្តចេញពីការជំនុំជម្រះលើបណ្តឹងព្រហ្មទណ្ឌពីរ ឬ ច្រើនដែលកើតចេញពីហេតុការណ៍ដូចៗគ្នា ដែលចៅក្រមរូបនេះនឹងប្រឈមនឹងភស្តុតាងទាក់ទងនឹងហេតុការណ៍ទាំងនេះនៅក្នុងរឿងក្តីទាំងពីរនោះឡើយ[190]។ អង្គជំនុំជម្រះតុលាការកំពូលបានច្រានចោលការចោទប្រកាន់អំពីភាពលម្អៀង ដោយសារតែសំអាងហេតុនាពេលមុនអំពីលក្ខណៈញុះញង់នៃការផ្សាយវិទ្យុ និងកាសែតដែលជនជាប់ចោទនៅក្នុងរឿងក្តី *Nahimana និងអ្នកផ្សេងទៀត* ត្រូវបានចោទប្រកាន់ថាជាប់ពាក់ព័ន្ធនោះទេ។ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា សំអាងហេតុនៅក្នុងរឿងក្តី *Akayesu* គ្រាន់តែលើកឡើងតិចតួចអំពីការឃោសនា ហើយអត្ថបទ រូបតុក្កតា ឬ ការចាក់ផ្សាយមួយចំនួនតែប៉ុណ្ណោះ ទោះបីជាចំណុចទាំងនេះ បានដាក់បញ្ចូលទាំងស្រុងនៅក្នុងផ្នែកមួយនៅក្នុងសាលក្រមក្នុងរឿងក្តី *Nahimana និងអ្នកផ្សេងទៀត*ក៏ដោយ[191]។ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា ចៅក្រមបានវាយតម្លៃយ៉ាងប្រុងប្រយ័ត្នលើភស្តុតាងក្នុងពេលជំនុំជម្រះក្នុងរឿងក្តី និងបានចេញសំអាងហេតុដោយផ្អែកលើភស្តុតាងទាំងនោះ[192]។ អង្គជំនុំជម្រះតុលាការកំពូលក៏បានច្រានចោលសេចក្តីសន្និដ្ឋានផ្សេងទៀតដែលលើកឡើងថា សំអាងហេតុនៅក្នុងសាលក្រម ក្នុងរឿងក្តី *Ruggiu* បានសន្និដ្ឋានថា *Nahimana* ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌទាក់ទងនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់។ ទោះបីជាមានសំអាងហេតុទាំងនេះក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលពុំជឿថា សច្ចធារណ៍នៃ

---

[189] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Renzaho* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR រឿងក្តីលេខ ICTR-97-31-A សាលដីកា ចុះថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ៤៣។ ស្រដៀងគ្នានេះដែរ នៅក្នុងរឿងក្តី *Karera* អង្គជំនុំជម្រះតុលាការកំពូលនៃសាលាក្តី ICTR បានច្រានចោលការលើកឡើងថា ចៅក្រមគួរត្រូវបានដិតចិត្តពីព្រោះពួកគាត់បានចូលរួមជំនុំជម្រះករណី *Renzaho* ខណៈនៅក្នុងពេលជាមួយគ្នាពិភាក្សាសម្រេចលើសាលក្រមក្នុងរឿងក្តី *Karera* ។ *សូមមើល* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karera* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR រឿងក្តីលេខ ICTR-01-74-A សាលដីកា ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៩ កថាខណ្ឌ ៣៧៨។

[190] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Nahimana និងអ្នកផ្សេងទៀត* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR រឿងក្តីលេខ ICTR-99-52-A សាលដីកា ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ("សាលដីកា *Nahimana*") កថាខណ្ឌ ៧៨។

[191] សាលដីកា *Nahimana* កថាខណ្ឌ ៧៩។

[192] សាលដីកា *Nahimana* ៧៩។

អនាគតិត្រូវបានច្រានចោលនោះទេ ពីព្រោះចៅក្រមបានសម្រេចដោយផ្អែកលើភស្តុតាងនៅក្នុងរឿងក្តី[193]។

៦៩. អង្គជំនុំជម្រះតុលាការកំពូលពុំបានពន្យល់ ថាតើឃ្លាថា "កម្រងភស្តុតាងដោយឡែក" មានន័យយ៉ាងណានោះទេ។ ទោះបីជាយ៉ាងនេះក្តី ឯកសារសំអាងនានាខាងលើដែលអង្គជំនុំជម្រះតុលាការកំពូលបានដកស្រង់ និងការយោងនាពេលមុនៗលើរឿងក្តីដែលមានភស្តុតាង និងសំណុំអង្គហេតុជាន់គ្នាបានបង្ហាញឱ្យឃើញថា អង្គជំនុំជម្រះតុលាការកំពូលពុំមែនសំដៅលើភស្តុតាងមិនពាក់ព័ន្ធ ឬ ភស្តុតាងផ្សេងទាំងស្រុងនោះទេ។ ឧទាហរណ៍ សំណើសុំឱ្យច្រានចោលសាលក្រមនៅក្នុងរឿងក្តី *Stanišić* និងរឿងក្តី *Župljanin* ជាប់ទាក់ទងនឹងភស្តុតាងតែមួយដែលត្រូវបានយកមកធ្វើជាមូលដ្ឋានសម្រាប់ធ្វើបណ្តឹងជំទាស់ចៅក្រមនៅក្នុងរឿងក្តី *Stanišić* ពោលគឺ លិខិតរបស់ចៅក្រម Harhoff។ ក៏ប៉ុន្តែ ទោះបីជាយ៉ាណាក៏ដោយ ចំណុចនេះពុំគ្រប់គ្រាន់ក្នុងការបង្ហាញថា ចៅក្រម Liu Daqun នឹងពុំមានលទ្ធភាពពិចារណាដោយឯករាជ្យលើបណ្តឹងរបស់ Župljanin នោះទេ ។ ការជំនុំជម្រះនៅក្នុងរឿងក្តី *Renzaho* រឿងក្តី *Karera* និងរឿងក្តី *Bagosora* ជាប់ទាក់ទងនឹង "ភស្តុតាងស្រដៀងគ្នា" រួមទាំងសាក្សីមួយចំនួន ដូចគ្នាដែរ។ នៅក្នុងរឿងក្តី *Nahimana និងអ្នកផ្សេងទៀត* សំអាងហេតុនាពេលមុន ស្តីពីលក្ខណៈឧក្រិដ្ឋនៃអត្ថបទសារព័ត៌មាន ឬ ការផ្សាយវិទ្យុ ពុំរារាំងចៅក្រមមិនឱ្យវាយតម្លៃលើការទទួលខុសត្រូវរបស់ជនជាប់ចោទ ចំពោះការផ្សាយជាសាធារណៈនៅក្នុងរឿងក្តីក្រោយទៀតនោះទេ។

៧០. ហេតុដូច្នេះ ការយោងរបស់អង្គជំនុំជម្រះតុលាការកំពូលលើ "កម្រងភស្តុតាងដោយឡែក" បង្កប់ន័យថា រឿងក្តីនីមួយៗត្រូវបានចាត់ទុកថាមានភាពដោយឡែក ហើយចៅក្រមពុំគួរទទួលរងឥទ្ធិពលពីបញ្ហាពុំពាក់ព័ន្ធនានា ដែលរួមបញ្ចូលទាំងសំអាងហេតុនាពេលមុន នៅក្នុងរឿងក្តីមួយទៀតនោះទេ។ ចំពោះករណីនេះ អង្គជំនុំជម្រះតុលាការកំពូលទំនងជាមិនយល់ឃើញថា ការសម្រេចរបស់ចៅក្រម Moloto និងចៅក្រម Delvoie លើបទប្រមាថតុលាការរបស់ លោក Kabashi នឹងរារាំងចៅក្រមទាំងនេះមិនឱ្យចូលរួមសម្រេចលើភាពអាចទទួលយកបាននៃប្រតិចារឹករបស់ *Limaj* នៅក្នុងការជំនុំជម្រះឡើងវិញលើរឿងក្តី *Haradinaj និងអ្នកផ្សេងទៀត* នោះទេ ប្រហែលជាថា ការជំនុំជម្រះនិងការជំនុំជម្រះឡើងវិញជាប់ទាក់ទងនឹងកម្រងភស្តុតាងដោយឡែក។ យ៉ាងណាក៏ដោយ ចំណុចសំខាន់ដែលអង្គជំនុំជម្រះតុលាការកំពូលបានកំណត់ឡើង ហាក់ដូចជា ថាតើសំអាងហេតុនៅក្នុងរឿង

[193] សាលដីកា *Nahimana* កថាខណ្ឌ ៨៤-៨៥។

ក្ដីនាពេលមុនៗ បង្ហាញការសន្មតនូវការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទចោទនានាដែលត្រូវវិនិច្ឆ័យនៅក្នុងរឿងក្ដីក្រោយៗដែរឬទេ។ ដូច្នេះ ចំណុចនេះ គឺជាលក្ខណៈវិនិច្ឆ័យដែលត្រូវអនុវត្ត។

## គ. អង្គសេចក្ដីនៃបណ្ដឹងជំទាស់

៧១. សេចក្ដីសន្និដ្ឋាននានាដែលដាក់ជូននៅក្នុងបណ្ដឹងជំទាស់ ត្រូវបានរៀបចំជាក្រុមឱ្យបានត្រឹមត្រូវ និងដោះស្រាយតាមលំដាប់លំដោយដូចតទៅនេះ។ ចំណុចទីមួយ សំណើរបស់ ខៀវ សំផន ប្ដឹងជំទាស់ចៅក្រម FENZ។ ចំណុចទីពីរ សេចក្ដីសន្និដ្ឋានដែលលើកឡើងថា អ្នកសង្កេតការណ៍មិនលម្អៀងនឹងយល់ថាជាការលម្អៀងដោយសារកំហុសនានាដែលត្រូវបានចោទប្រកាន់ នៅក្នុងសាលក្រមក្នុងសំណុំរឿង ០០២/០១ និង/ឬ ភាសាដែលចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់ និង/ឬការសំអាងទៅលើភស្តុតាងរបស់សាក្សីជំនាញមួយចំនួន។ ចំណុចទីបី សេចក្ដីសន្និដ្ឋានដែលលើកឡើងថា សាលក្រមក្នុងសំណុំរឿង ០០១ ធ្វើបុរេវិនិច្ឆ័យលើសំណុំរឿង ០០២/០២ ។ ចំណុចទីបួន សេចក្ដីសន្និដ្ឋានដែលលើកឡើងថា សាលក្រមក្នុងសំណុំរឿង ០០២/០១ ធ្វើបុរេវិនិច្ឆ័យលើសំណុំរឿង ០០២/០២។ ចំណុចទីប្រាំ សេចក្ដីសន្និដ្ឋានដែលលើកឡើងថា សំអាងហេតុជាច្រើនគឺជាការព្រានចោលបន្ទុកក្នុងការបង្ហាញភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ និង/ឬបង្ហាញអំពីការខ្វះសុច្ចរិតភាពរបស់តុលាការ។ ចំណុចទីប្រាំមួយ សេចក្ដីសន្និដ្ឋានដែលលើកឡើងថា អ្នកសង្កេតការណ៍មិនលម្អៀងនឹងយល់ថា ជាការលម្អៀងដោយផ្អែកលើការខកខានមិនកោះហៅ ហេង សំរិន និង/ឬ ឯករាជ្យភាពនៃប្រព័ន្ធតុលាការកម្ពុជា ជារួម ។ ចំណុចចុងក្រោយ សេចក្ដីសន្និដ្ឋានដែលលើកឡើងថា ចៅក្រមកម្ពុជាមានផលប្រយោជន៍ផ្ទាល់ខ្លួននៅក្នុងសំណុំរឿង ០០២/០២ ដូច្នេះហើយ ត្រូវជំទាស់គាត់។

### (១) សំណើរបស់ ខៀវ សំផន ប្ដឹងជំទាស់ចៅក្រម FENZ

៧២. ទោះបីជាបណ្ដឹងជំទាស់ទាំងពីរសំដៅលើចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម យូ ឧត្តរា ក៏ដោយ ក៏បណ្ដឹងដំបូង និងបណ្ដឹងសាជាថ្មីរបស់ ខៀវ សំផន សំដៅលើចៅក្រម Claudia FENZ មួយរូបថែមទៀតដែលជាចៅក្រមបម្រុងមួយរូបនៅក្នុងសំណុំរឿង ០០២/០១។ បណ្ដឹងរបស់ ខៀវ សំផន បានលើកឡើងថា ចៅក្រម FENZ "បានចូលរួមជំនុំជម្រះជាច្រើននៅក្នុងសវនាការសំណុំរឿង ០០២/០១ ហើយបានចូលរួមចេញសេចក្ដីសម្រេចមួយចំនួនផងដែរ"[194]។ បណ្ដឹងសាជាថ្មីរបស់ ខៀវ សំផន ព្យាយាមគាំទ្រលើសេចក្ដីសន្និដ្ឋាននោះ

[194] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៤៨។

ដោយដាក់បញ្ចូលសវនាការមួយចំនួននៅក្នុងសំណុំរឿង ០០២/០១ នៅពេលចៅក្រម FENZ ជំនួស ចៅក្រម CARTWRIGHT ឬ ចៅក្រម LAVERGNE[195]។

៧៣. ក៏ប៉ុន្តែ បណ្តឹងជំទាស់ចំពោះមិនអនុវត្តភារកិច្ចខុសនិងការបង្អាក់ដំណើរ មិនមែនលេខយោងដែលមាន — 

៧៣. ក៏ប៉ុន្តែ បណ្ដឹងជំទាស់ចៅក្រមរបស់ ខៀវ សំផន បានផ្អែកលើកំហុសដែលត្រូវបានចោទប្រកាន់ថាមាន នៅក្នុង និងការចោទប្រកាន់អំពីបុរេវិនិច្ឆ័យពីក្នុងសាលក្រមនៃសំណុំរឿង០០២/០១។ សាលក្រមក្នុង សំណុំរឿង ០០២/០១ ពុំមានហត្ថលេខារបស់ចៅក្រម FENZ ទេ[196]។ ដូច្នេះ ចៅក្រម FENZ ពុំបាន ធ្វើសេចក្តីសម្រេចតុលាការទេ ហើយមិនអាចមានការលើកឡើងថា ចៅក្រមរូបនេះមានបុរេវិនិច្ឆ័យពិត ប្រាកដលើពិរុទ្ធភាពរបស់ ខៀវ សំផន នៅក្នុងសំណុំរឿង ០០២/០២ នោះទេ។ លើសពីនេះទៀត ជា ទូទៅ បើគ្រាន់តែទំនាក់ទំនងផ្លូវច្បាប់ពីមុនរបស់ចៅក្រមណាមួយជាមួយនឹងអង្គហេតុក្នុងសំណុំរឿង (ឬជាមួយនឹងជនជាប់ចោទ) មិនមានភាពគ្រប់គ្រាន់ក្នុងការយល់ឃើញថា មានការលេចឡើងនូវភាព មិនលម្អៀងដែលមិនអាចទទួលយកបានទេ។ អ្នកសង្កេតការណ៍ផ្នែកយុត្តិធម៌បានដឹងថា តួនាទីរបស់ ចៅក្រមអាចមានភាពខុសគ្នាពីបរិបទតុលាការមួយ ទៅតុលាការមួយផ្សេងទៀត[197]។ ខៀវ សំផន ពុំ បានពន្យល់អំពីមូលដ្ឋានដែល ថាតើការបំពេញភារកិច្ចម្តងម្កាលរបស់ចៅក្រម FENZ ក្នុងនាមជា ចៅក្រមបម្រុងនៅក្នុងអំឡុងពេលជំនុំជម្រះលើសំណុំរឿង ០០២/០១ មានន័យថា ចៅក្រមរូបនេះគួរ ត្រូវជំទាស់ចេញពីសំណុំរឿង ០០២/០២ នោះដែរឬទេ។ ហេតុដូច្នេះ បណ្តឹងរបស់ ខៀវ សំផន ប្តឹងជំទាស់ ចៅក្រម FENZ ត្រូវបានច្រានចោល។

## (២) កំហុសដែលត្រូវបានចោទប្រកាន់នៅក្នុងសាលក្រមសំណុំរឿង ០០២/០១

៧៤. បណ្តឹងជំទាស់ទាំងពីរអះអាងថា សាលក្រមសំណុំរឿង ០០២/០១ មានសំអាងហេតុមិនត្រឹម ត្រូវដែលនាំឲ្យលេចឡើងនូវភាពលម្អៀង។ សំអាងហេតុទាំងអស់ដែលបានលើកឡើងត្រូវបានពិនិត្យ មើលឡើងវិញ ពុំមែនដើម្បីកំណត់ថាតើសំអាងហេតុទាំងនោះមានកំហុសដែលជាកម្មវត្ថុនៃបណ្តឹង សាទុក្ខ ប៉ុន្តែ ដើម្បីវាយតម្លៃថាតើអ្នកសង្កេតការណ៍មិនលម្អៀងយល់ថាជាការលម្អៀងដោយសារ សំអាងហេតុទាំងនេះដែរឬទេ។

---

[195] បណ្តឹងជំទាស់ចៅក្រមសាជាថ្មីរបស់ ខៀវ សំផន លេខយោងជើងទំព័រ ១៤។

[196] សាលក្រមសំណុំរឿង ០០២/០១ ទំព័រ ៦២៣។

[197] នៅក្នុងសំណុំរឿងប្រឆាំងនឹង *Akhbar Beirut S.A.L.* និង *Ibrahim Mohamed Ali Al Amin* អង្គចៅក្រមជំនុំជម្រះត្រូវ បានបង្កើតឡើងអនុលោមតាមវិធាន ២៥ (ឃ) STL-14-06/PT/OTH/R25 សេចក្តីសម្រេចទៅលើសំណើជំទាស់ចៅក្រម Lettieri ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៤ កថាខណ្ឌ ២១។

## គោលនយោបាយរបស់ ប.ក.ក

៧៥. បណ្តឹងឧទ្ធរណ៍ទាំងពីរបានអះអាងថា សាលក្រមសំណុំរឿង ០០២/០១ មានវិសាលភាពលើសពីវិសាលភាពដែលត្រូវបានកំណត់សម្រាប់ការជំនុំជម្រះ ដោយមានសំអាងហេតុអំពីគោលនយោបាយរបស់ ប.ក.ក ដែលត្រូវបានចោទប្រកាន់ថា បាន (i) បង្កើតសហករណ៍ និងការដ្ឋានការងារ (ii) លត់ដំសមាសភាពមិនល្អ និងសម្លាប់ខ្មាំង និង (iii) រៀបចំអាពាហ៍ពិពាហ៍។ សំអាងហេតុទាំងនេះមាននៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ត្រង់ផ្នែកដែលមានចំណងជើងថា "បរិបទប្រវត្តិសាស្ត្រ" ដែលផ្នែកនេះចាប់ផ្តើមដោយបានពន្យល់ថា "អត្ថិភាពនៃគោលនយោបាយនីមួយៗនឹងត្រូវយកមកពិនិត្យនៅក្នុងផ្នែកនេះដើម្បីផ្តល់ទិដ្ឋភាពរួមអំពីស្ថានភាពនៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥"។ បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា គោលនយោបាយចំនួនពីរក្នុងចំណោមគោលនយោបាយ ចំនួន ៥ គឺជា "កម្មវត្ថុនៃការចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១" ហើយអាចនឹង "យកមកពិនិត្យឱ្យកាន់តែលម្អិតថែមទៀត"[198]។ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់អំពីមូលដ្ឋានដែលខ្លួនបានពិចារណាលើបរិបទទាក់ទងនឹងគោលនយោបាយចំនួន ៣ នៅក្នុងផ្នែកតូចខាងក្រោមដែលមានចំណងជើងថា "ការបង្កើតគោលនយោបាយ ប.ក.ក"។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ជាថ្មីម្តងទៀតថា មានតែគោលនយោបាយចំនួនតែ ២ ប៉ុណ្ណោះ ដែលជាកម្មវត្ថុនៃបទចោទក្នុងសំណុំរឿង ០០២/០១ ប៉ុន្តែបានលើកឡើងថា អត្ថិភាពនៃគោលនយោបាយផ្សេងទៀត ក៏ "មានការពាក់ព័ន្ធផងដែរ"[199]។ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ថា ការលើកឡើងនេះបានផ្អែកលើសេចក្តីសម្រេចមុនៗដែលមាននៅក្នុងដំណើរការជំនុំជម្រះ ដែលអង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា ខ្លួននឹងពិនិត្យមើល "អត្ថិភាព" នៃគោលនយោបាយទាំងអស់ចំនួន ៥ នៅក្នុងអំឡុងពេលជំនុំជម្រះសំណុំរឿង ០០២/០១ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងនឹងមិនពិនិត្យមើល "ការអនុវត្ត" គោលនយោបាយចំនួន ៣ ដែលនឹងត្រូវពិនិត្យមើលសម្រាប់ "គោលបំណងបរិបទតែប៉ុណ្ណោះ"[200]។

៧៦. បណ្តឹងឧទ្ធរណ៍ទាំងនេះអះអាងថា ការពិនិត្យមើលរបស់អង្គជំនុំជម្រះសាលាដំបូងលើគោលនយោបាយទាំង៣ដែលត្រូវបានលើកឡើងថាលើសពីវិសាលភាពនៃសំណុំរឿង ០០២/០១ ពុំត្រូវបានអនុញ្ញាតឱ្យធ្វើទេ ហើយ/ឬ សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងបង្ហាញថា អង្គជំនុំជម្រះ

---

[198] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៩។

[199] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៣។

[200] សាលក្រមសំណុំរឿង ០០២/០១ លេខយោងជើងទំព័រ ២៨៧។

សាលាដំបូងមិនមានលទ្ធភាពញែកឲ្យដាច់ការពិនិត្យលើអត្ថិភាពនៃគោលនយោបាយ ចេញពីការអនុវត្តគោលនយោបាយនោះទេ។ បញ្ហានេះគឺជាកម្មវត្ថុនៃបណ្តឹងសាទុក្ខ ពុំមែនជាកម្មវត្ថុនៃបណ្តឹងប្តឹងជំទាស់ទេ នោះឡើយ។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅពេលពិនិត្យមើលគោលនយោបាយទាំង ៣នោះក៏ដោយ ករណីនេះមិនអាចនាំឲ្យលេចចេញនូវភាពលម្អៀងនោះទេ។ ស្រដៀងគ្នានេះដែរ ការសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងបានផ្អែកលើគោលនយោបាយចំនួន ៣ ដែលពុំមែនជាកម្មវត្ថុនៃសំណុំរឿង ០០២/០១ ដើម្បីសន្និដ្ឋានអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួមដូចបានចោទប្រកាន់ គឺជាកម្មវត្ថុនៃបណ្តឹងសាទុក្ខ ពុំមែនជាកម្មវត្ថុនៃបណ្តឹងជំទាស់នោះទេ។ ទោះក្នុងករណីណាក៏ដោយ ផ្នែកដែលមានចំណងជើងថា "សហឧក្រិដ្ឋកម្មរួម" នៅក្នុងសាលក្រមក្នុងសំណុំរឿង ០០២/០១ ចាប់ផ្តើមដោយបង្ហាញគោលនយោបាយចំនួន ២ នៅក្នុងសំណុំរឿង០០២/០១[201]។ ផ្នែកនេះរួមមានសំអាងហេតុលម្អិតលើ "គោលនយោបាយ ស្តីពីការផ្លាស់ទីលំនៅប្រជាជន"[202] និង "គោលនយោបាយស្តីពីការកំណត់គោលដៅ"[203]។ គ្មានការវិភាគ ឬ ការសំអាងចំពោះគោលនយោបាយចំនួន ៣ ផ្សេងទៀតនោះទេ។ ការយោងរបស់អង្គជំនុំជម្រះសាលាដំបូងលើគោលនយោបាយផ្សេងទៀតនៅក្នុងកន្លែងផ្សេងៗ ក្នុងសាលក្រមសំណុំរឿង ០០២/០១ ពុំបានផ្តល់ជាមូលដ្ឋានសម្រាប់ឲ្យយល់ឃើញថា មានភាពលម្អៀងនោះទេ។

## <u>រចនាសម្ព័ន្ធ ប.ក.ក</u>

៧៧. ទាក់ទងនឹងរចនាសម្ព័ន្ធ ប.ក.ក នួន ជា អះអាងថា "កំហុសធ្ងន់ធ្ងរបំផុត" របស់អង្គជំនុំជម្រះសាលាដំបូង គឺការច្រានចោលភ័ស្តុតាង និងសេចក្តីសន្និដ្ឋានថា ភូមិភាគ គឺជាតំបន់ស្វយ័ត[204]។ នួន ជា សន្និដ្ឋានថា "កំហុសធ្ងន់ធ្ងរបំផុតបន្ទាប់មួយទៀត" គឺថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានទាក់ទងនឹងការបែកបាក់ផ្ទៃក្នុងនៅក្នុងប.ក.ក[205]។ ជាពិសេស នួន ជា

---

[201] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧២៣។

[202] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៧៩-៨១០។

[203] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៨១១-៨៣៧។

[204] បណ្តឹងរបស់ នួន ជា កថាខណ្ឌ ៧៣។

[205] បណ្តឹងរបស់ នួន ជា កថាខណ្ឌ ៧៣។

ជំទាស់នឹងសំអាងហេតុដែលថា គាត់បានចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម ជាមួយនឹងបុគ្គលដែលគាត់កំណត់ថាជា "គូសត្រូវផ្ទៃក្នុង" ជាពិសេស សោ ភឹម រស់ ញឹម វន វ៉េត និង កុយ ធួន[206]។

៧៨. ទាក់ទងនឹងការទទួលខុសត្រូវរបស់ភូមិភាគ ផ្នែក ១៥.២ នៅក្នុងសាលក្រមក្នុងសំណុំរឿង ០០២/០១ បានពិចារណាយ៉ាងច្បាស់លាស់ និងច្រានចោលការអះអាងរបស់ នួន ជា ថា ភូមិភាគទាំងឡាយបានធ្វើសកម្មភាពដោយឯករាជ្យខ្លួនឯងពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅរបស់ប្រជាជន និងការកំណត់គោលដៅអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[207]។ គ្មានមូលដ្ឋានក្នុងការសន្និដ្ឋានថា សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើឱ្យអ្នកសង្កេតការណ៍មិនលម្អៀងយល់ឃើញថា មានការលម្អៀងនោះទេ។ ឧបាស្រ័យសមស្របក្នុងការប្ដឹងតវ៉ាលើសំអាងហេតុនេះ គឺការធ្វើបណ្ដឹងសាទុក្ខ។

៧៩. ពាក់ព័ន្ធនឹងការបាក់បែកផ្ទៃក្នុង ប.ក.ក សាលក្រមក្នុងសំណុំរឿង ០០២/០១ មានសំអាងហេតុជាក់លាក់អំពីការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមដោយបុគ្គលដែល នួន ជា កំណត់ថាជាគូសត្រូវ[208]។ សាលក្រមក្នុងសំណុំរឿង ០០២/០១ មានសំអាងហេតុថា នៅក្នុងអំឡុងពេលជម្លៀសក្រុងភ្នំពេញ សោ ភឹម កុយ ធួន និង វន វ៉េត បានស្នើសុំ និងបានទទួលការណែនាំពី នួន ជា និងអ្នកផ្សេងទៀត[209]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចទៀតថា មេបញ្ជាការភូមិភាគទំនងជាមិនអាចបំពេញសកម្មភាពប្រឆាំង ឬ នៅក្រៅការឯកភាពគ្នាទៅលើគោលនយោបាយទូលំទូលាយដែលត្រូវបានដាក់ចេញដោយមជ្ឈិមនោះទេ[210]។ ទាក់ទងនឹងការផ្លាស់ទីលំនៅរបស់ប្រជាជន (ដំណាក់កាលទី២) អង្គ-ជំនុំជម្រះសាលាដំបូងបានពិចារណាលើភ័ស្តុតាងនៃកិច្ចប្រជុំ និងការទំនាក់ទំនងរវាង រស់ ញឹម សោ ភឹម វន វ៉េត និង នួន ជា ក្នុងចំណោមអ្នកផ្សេងទៀត[211]។ ចំពោះទួលពោធិ៍ជ្រៃ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា មានគោលនយោបាយមួយក្នុងការកំណត់គោលដៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដែលពាក់ព័ន្ធអំពើមនុស្សឃាត និងការសម្លាប់រង្គាលអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅទួលពោធិ៍ជ្រៃ[212]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា រស់ ញឹម បានធ្វើជា

---

[206] បណ្ដឹងរបស់ នួន ជា កថាខណ្ឌ ៧៧។

[207] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៥៩។

[208] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៧៧។

[209] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៣៩។

[210] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៩៥។

[211] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៧២, ៧៧៣។

[212] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៣៥។

ប្រធានអង្គប្រជុំមួយ ដែលក្នុងពេលនោះ មានការបង្គាប់ឱ្យកាប់សម្លាប់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[213] ហើយសេចក្តីសម្រេចមួយត្រូវបានធ្វើឡើងស្របតាមផែនការដែលបានអនុម័តក្នុងពេលប្រជុំនានា ដែល នួន ជា បានចូលរួមនៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ និង ខែ មេសា ឆ្នាំ ១៩៧៥[214]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា វស់ ញ៉ឹម និង នួន ជា មានទំនាក់ទំនងការងារជាមួយគ្នាជាយូរមកហើយ តាំងពីមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ មកម្លេះ[215]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ទោះបីជាគ្មានភ័ស្តុតាងបង្ហាញថា នួន ជា បានដឹងអំពីលក្ខណៈជាក់លាក់នៃឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃក៏ដោយ ក៏គាត់បានដឹងអំពីលំនាំជាហូរហែមកនៃការកំណត់គោលដៅលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[216]។

៨០. សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងអាចជាកម្មវត្ថុនៃបណ្តឹងសាទុក្ខ។ ទោះបីជាយ៉ាងនេះក៏ដោយ គ្មានមូលដ្ឋានណាមួយក្នុងការអះអាងថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងលើការងារផ្ទៃក្នុងរបស់ ប.ក.ក នឹងអាចឱ្យអ្នកសង្កេតការណ៍មិនលម្អៀងយល់ឃើញពីភាពលម្អៀងនៅក្នុងរឿងក្តី ០០២/០២ នោះទេ ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងបានផ្អែកសេចក្តីសន្និដ្ឋានរបស់ខ្លួនលើភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ ប៉ុណ្ណោះ។

## ការវិភាគផ្នែកប្រជាសាស្ត្រ

៨១. ការយោងរបស់អង្គជំនុំជម្រះសាលាដំបូងលើការវិភាគផ្នែកប្រជាសាស្ត្រ មាននៅក្នុងសាលក្រមក្នុងសំណុំរឿង ០០២/០១ ត្រង់ផ្នែកមួយដែលមានចំណងជើងថា "ទិដ្ឋភាពទូទៅ៖ ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩"។ អង្គជំនុំជម្រះបានសង្ខេបភ័ស្តុតាងរបស់អ្នកជំនាញយ៉ាងលម្អិត និងខុសៗគ្នាលើចំនួនមនុស្សស្លាប់ "ដោយសារតែលទ្ធផលនៃគោលនយោបាយ និងការប្រព្រឹត្តទាំងឡាយរបស់ខ្មែរក្រហម"[217]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់អំពីការប៉ាន់ស្មានក្នុងចន្លោះតួលេខធំមួយគឺ ចន្លោះពី ៦០០.០០០ នាក់ ទៅ ៣.០០០.០០០ នាក់ ដោយបានលើកឡើងថា "អ្នកជំនាញជាច្រើនទទួលយកការប៉ាន់ប្រមាណអំពីចំនួនអ្នកស្លាប់ពី ១.៥០០.០០០ នាក់ ទៅ

---

[213] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៣៦។

[214] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៤១។

[215] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៣៣។

[216] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៥៤។

[217] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១៧៤។

២.០០០.០០០ នាក់ ថាជាចំនួនដែលត្រឹមត្រូវបំផុត"[218]។ ជើងទំព័រវែងមួយបង្ហាញអំពីមូលដ្ឋាននៃការលើកឡើងដូច្នេះ។ ចំពោះការលើកឡើងរបស់ នួន ជា ថា អង្គជំនុំជម្រះសាលាដំបូងមិនបានពិភាក្សាទទ្បឹករណ៍ផ្ទុយគ្នា អំពីពេលវេលា ឬ មូលហេតុនៃការស្លាប់ ភ័ស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានយោង បានពិភាក្សាយ៉ាងច្បាស់លាស់អំពីមូលហេតុខុសៗគ្នា និងបានគូសបញ្ជាក់អំពីការលំបាកក្នុងការកំណត់តួលេខមួយច្បាស់លាស់[219]។ គ្មានអ្នកសង្កេតការណ៍មិនលម្អៀងណាម្នាក់នឹងយល់ឃើញពីភាពលម្អៀងពីវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងនេះទេ។

៨២. សាលក្រមក្នុងសំណុំរឿង ០០២/០១ មានសំអាងហេតុច្បាស់ជាងនេះ ទាក់ទងនឹងឧក្រិដ្ឋកម្មក្នុងសំណុំរឿង ០០២/០១ ។ ពាក់ព័ន្ធនឹងការជម្លៀសចេញពីក្រុងភ្នំពេញ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ភ័ស្តុតាងបានបង្ហាញថា មនុស្សចន្លោះពី ២.០០០ នាក់ ទៅ ២០.០០០ នាក់ បានស្លាប់[220]។ ទាក់ទងនឹងការផ្លាស់ទីលំនៅរបស់ប្រជាជន នាពេលក្រោយមក អង្គជំនុំជម្រះបានសម្រេចថាមិនមានការដឹងអំពីចំនួនមនុស្សដែលបានស្លាប់ពិតប្រាកដនោះទេ[221] ប៉ុន្តែមនុស្សស្លាប់មានចំនួនច្រើននាក់[222]។ ចំពោះទួលពោធិ៍ជ្រៃ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា យ៉ាងហោចណាស់មានមនុស្សចំនួន ២៥០ នាក់ ត្រូវបានគេសម្លាប់ចោល[223]។ គ្មានអ្នកសង្កេតការណ៍មិនលម្អៀងណាមួយអាចនឹងយល់ឃើញពីភាពលម្អៀងចេញពីការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូង អំពីភ័ស្តុតាងលើផ្នែកប្រជាសាស្ត្រ និងសំអាងហេតុជាក់លាក់ជាងមុននាពេលក្រោយៗមកពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលជនជាប់ចោទ ត្រូវបានចោទប្រកាន់នោះឡើយ។

---

[218] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១៧៤។

[219] សាលក្រមសំណុំរឿង ០០២/០១ លេងយោងជើងទំព័រ ៥២៣។ *សូមមើល ឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) (ភាសាអង់គ្លេស) ទំព័រ ៩-១២ (ឆ្លើយទៅនឹងសំណួរថាតើគេអាចបែងចែក និងដាក់បន្ទុកការស្លាប់មនុស្សលើរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ)។

[220] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៥២១។

[221] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៤៦។

[222] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៤៧។

[223] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៨១។

## ការសំអាងលើសាលក្រមក្នុងសំណុំរឿង ០០២/០១ ក្នុងការកំណត់និយមន័យ "ការកម្ទេច"

៨៣. នៅពេលពិចារណាលើអត្ថន័យនៃពាក្យ "កម្ទេច" សាលក្រមសំណុំរឿង ០០២/០១ យោងលើសាលក្រមសំណុំរឿង ០០១ នៅក្នុងកំណត់យោងជើងទំព័រចំនួនពីរ[224]។ ការយោងទាំងឡាយដែល នួន ជា បានបង្ហាញ មាននៅក្នុងការពិភាក្សារបស់អង្គជំនុំជម្រះសាលាដំបូងអំពីគោលនយោបាយមួយក្នុងចំណោមគោលនយោបាយចំនួន៣ ដែលបានលើកឡើង ថានៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ ពោលគឺ "ការលត់ដំសមាសភាពមិនល្អ និងការសម្លាប់ខ្លាំង"[225]។ នួន ជា បានសន្និដ្ឋានថា សាលក្រម ០០១ ពុំមែនជា "ភ័ស្តុតាង" នោះទេ ហើយការយោងរបស់អង្គជំនុំជម្រះសាលាដំបូងលើសាលក្រម ០០១ បង្ហាញថា ចៅក្រមមិនបានសំអាងតែទៅលើភ័ស្តុតាងក្នុងសំណុំរឿង ០០២/០១ ទាំងស្រុងនោះទេ[226]។

៨៤. តាមលក្ខណៈបច្ចេកទេស ជាការត្រឹមត្រូវដែលថា សាលក្រមមិនមែនជាភ័ស្តុតាងនោះទេ។ ក៏ប៉ុន្តែ កាំង ហ្កេកអ៊ាវ បានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២ ហើយជើងទំព័រដែល នួន ជា បានបង្ហាញ ក៏យោងលើសក្ខីកម្មរបស់ កាំង ហ្កេកអ៊ាវ នៅក្នុងសំណុំរឿង ០០២ និង/ឬ នៅក្នុងសំណុំរឿង ០០១ ផងដែរ (ដែលត្រូវបានទទួលយកមកដាក់បញ្ចូលជាភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២ ផងដែរ) ដែលនៅក្នុងអំឡុងពេលនេះ កាំង ហ្កេកអ៊ាវ បានពិភាក្សាអំពីអត្ថន័យនៃពាក្យ "កម្ទេច"។ ម្យ៉ាងវិញទៀត កថាខណ្ឌនានានៅក្នុងសាលក្រមសំណុំរឿង ០០១ ដែលអង្គជំនុំ- ជម្រះបានយោង សំអាងទៅលើសក្ខីកម្មរបស់ កាំង ហ្កេកអ៊ាវ នៅក្នុងរឿងក្តីនោះ។ ក្នុងកាលៈទេសៈទាំងនោះ អ្នកសង្កេតការណ៍មិនលម្អៀងនឹងមិនយល់ថា ករណីនេះថាជាបញ្ហាខុសប្រក្រតីនោះទេ ដោយចៅក្រមយោងទៅលើសាលក្រមមុនប្រឆាំងនឹងបុគ្គលដែលសក្ខីកម្មរបស់បុគ្គលនោះ ត្រូវបានទទួលយកមកបញ្ចូលជាភ័ស្តុតាងនៅក្នុងសំណុំរឿងនៅចំពោះមុខចៅក្រមទាំងនោះ។ អ្នកសង្កេតការណ៍មិនលម្អៀងនឹងមិនយល់ថា អង្គជំនុំជម្រះសាលាដំបូងមិនមានលទ្ធភាពសំអាងតែទៅលើភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ ទាំងស្រុងនោះទេ។

---

[224] បណ្តឹងរបស់ នួន ជា៖ ផ្នែក ង កថាខណ្ឌ ៨០ បង្ហាញលេខយោងជើងទំព័រ ៣២៦ និង ៣៣០ នៅក្នុងសាលក្រមសំណុំរឿង ០០២/០១។

[225] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១១៧។

[226] បណ្តឹងរបស់ នួន ជា៖ ផ្នែក ង កថាខណ្ឌ ៨១-៨២។

# ពាក្យបច្ចេកទេស

៨៥. នួន ជា សន្និដ្ឋានថា ការប្រើប្រាស់ពាក្យពេចន៍របស់អង្គជំនុំជម្រះសាលាដំបូង ដូចជា "ដែលត្រូវបានអះអាង" ឬ "ដែលត្រូវបានយល់ឃើញ" នៅពេលពិភាក្សាអំពីខ្មាំងរបស់ ប.ក.ក ឬ "ការបិទបាំង" នៅពេលពិភាក្សាអំពីរដ្ឋបាលរបស់រដ្ឋាភិបាលរួបរួមជាតិកម្ពុជា និង/ឬ ការប្រើប្រាស់អព្ភន្តរសញ្ញា ឧទាហរណ៍នៅពេលយោងលើ "ខ្មាំង" "សមាសភាពមិនល្អ" ឬ "ជនក្បត់" នឹងធ្វើឱ្យអ្នកសង្កេតការណ៍មិនលម្អៀងយល់ឃើញពីភាពលម្អៀង[227]។ នួន ជា អះអាងថា នៅពេលពិចារណាលើវិធីដែលសាលក្រមសំណុំរឿង ០០២/០១ បានរៀបរាប់ផ្នែកនានានៃយោបល់ជាសាធារណៈរបស់ចៅក្រម CARTWRIGHT នៅវិទ្យាស្ថាន Aspen មានការពាក់ព័ន្ធ[228]។ ភាសាមួយចំនួនដែលត្រូវបានជំទាស់ដោយ នួន ជា សំដៅលើសំអាងហេតុជាក់លាក់ដែលអង្គជំនុំជម្រះសាលាដំបូងបានលើកឡើង។ ឧទាហរណ៍ ការតវ៉ាថា សាលក្រមសំណុំរឿង០០២/០១ បានប្រើប្រាស់ "នាមប្រមាថមើលងាយ ដូចជា *ការបិទបាំង*" ទាក់ទងនឹងសំអាងហេតុជាក់លាក់។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា "ការងាររដ្ឋបាលរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា គឺគ្រាន់តែជាសំបកក្រៅតែប៉ុណ្ណោះ"[229]។

៨៦. ការដែល នួន ជា មិនយល់ស្របជាមួយនឹងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងនោះ មិនគាំទ្រដល់ការចោទប្រកាន់អំពីភាពលម្អៀងនោះទេ។ ឧទាហរណ៍ នៅពេលដែលបណ្តឹងឧទ្ធរណ៍របស់ នួន ជា កំណត់ ឧត្តុង្គ ថាជា "ជោគជ័យផ្នែកយោធាសាមញ្ញមួយ"[230] អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានយកទៅសម្លាប់ក្នុងទ្រង់ទ្រាយធំភ្លាមៗ បន្ទាប់ពីកាន់កាប់បានទីតាំង ឧត្តុង្គ រួចមក[231] ហើយប្រជាជននៅទីនោះត្រូវបានផ្លាស់ទីលំនៅដោយបង្ខំ ត្រូវបានធ្វើបាប ហើយប្រជាជនជាច្រើនត្រូវបានសម្លាប់ចោល[232]។ ចំពោះការប្រើប្រាស់អព្ភន្តរសញ្ញារបស់អង្គជំនុំជម្រះសាលាដំបូង ឧទាហរណ៍ នៅពេលសំដៅទៅលើ "ខ្មាំង" "សមាសធាតុមិនល្អ" ឬ "ពួកក្បត់" អង្គជំនុំជម្រះសាលាដំបូងបានព្យាយាមប្រើប្រាស់ពាក្យរបស់ខ្មែរក្រហម និងសេចក្តីសន្និដ្ឋានរបស់ភាគី ដោយមិនមានន័យថា ឯកភាពតាមការពិពណ៌នាទាំងនោះទេ។ អង្គជំនុំជម្រះសាលាដំបូង

[227] បណ្តឹងរបស់ នួន ជា កថាខណ្ឌ ៦២-៦៤។

[228] បណ្តឹងរបស់ នួន ជា កថាខណ្ឌ ៦៨។

[229] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១១០។

[230] បណ្តឹងឧទ្ធរណ៍របស់ នួន ជា កថាខណ្ឌ ៦៦។

[231] សាលក្រម សំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៩១៨។

[232] សាលក្រម សំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៩៩៩។

បានពន្យល់អំពីវិធីសាស្ត្រនេះ នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ រួចមកហើយ[233] ។ ចុងក្រោយបំផុត នៅក្នុងការប្រើប្រាស់ពាក្យទាំងឡាយរបស់អង្គជំនុំជម្រះសាលាដំបូង មិនមានអ្វីដូចដែល "បានអះអាង" ឬ "បានយល់ឃើញ" អាចធ្វើឱ្យអ្នកសង្កេតការណ៍មិនលម្អៀងយល់ឃើញថាមានភាពលំអៀងនោះទេ។ ឧទាហរណ៍មួយដែលត្រូវបានជំទាស់ គឺការយោងទៅលើ "សកម្មភាពខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង និងខ្មាំងខាងក្រៅ"[234]។ នៅក្នុងកថាខណ្ឌនេះ អង្គជំនុំជម្រះសាលាដំបូងរម្លឹកឡើងវិញអំពីខ្លឹមសារនៃរបាយការណ៍មួយចំនួនរបស់ភូមិភាគ ផ្ញើមកគណៈមជ្ឈិម ដែលលើកឡើងអំពីខ្មាំង។ នៅពេលសំដៅទៅលើខ្មាំង "ស៊ីរូងផ្ទៃក្នុង" អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញថា វាជាការលើកឡើងវិញតាមខ្លឹមសារនៃរបាយការណ៍របស់ភូមិភាគ និងជាការវាយតម្លៃរបស់អ្នកនិពន្ធចំពោះបុគ្គល ឬ ក្រុមនានាដែលគេបានរៀបរាប់ថាជាខ្មាំង មិនមែនជាការសម្រេចណាមួយថា បុគ្គល ឬ ក្រុមមនុស្សនោះ ជាខ្មាំងនោះទេ។

៨៧. ចៅក្រមមានឆន្ទានុសិទ្ធិច្រើនចំពោះរបៀបដែលពួកគាត់ជ្រើសរើស ដើម្បីបង្ហាញអំពីសំអាងហេតុរបស់ខ្លួន ហើយនៅក្នុងបណ្តឹងមិតចិត្តរបស់ នួន ជា មិនមានអ្វីគាំទ្រទៅដល់ការសន្និដ្ឋានដែលថាអ្នកសង្កេតការណ៍មិនលម្អៀងយល់ឃើញថាមានភាពលម្អៀង ចេញពីចរិតលក្ខណៈដែលបានបង្ហាញនៅក្នុងសាលក្រមសំណុំរឿង ០០២/០១ នោះទេ។ យោងតាមសេចក្តីសន្និដ្ឋាននេះ មិនចាំបាច់ត្រូវដោះស្រាយចំពោះការសន្និដ្ឋានរបស់ នួន ជា ដែលព្យាយាមភ្ជាប់ការលើកឡើងរបស់ចៅក្រម CARTWRIGHT នៅឯវិទ្យាស្ថាន Aspen ទៅនឹងលក្ខណៈដែលត្រូវបានបង្ហាញនៅក្នុងសាលក្រមសំណុំរឿង ០០២/០១ នោះទេ។

---

[233] សាលក្រមសំណុំរឿងលេខ ០០២/០១ លេខយោងជើងទំព័រ ២៨៨ ("អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ពាក្យ "ជម្លៀស" ត្រូវបានខ្មែរក្រហមខ្លួនឯងប្រើដើម្បីពិពណ៌នាអំពីគោលនយោបាយរបស់ពួកគេផ្ទាល់តែម្តង។ ទោះបីជាពាក្យនេះសំដៅទៅលើគំនិតនៃការផ្លាស់ទីលំនៅប្រជាជនចេញពីកន្លែងគ្រោះថ្នាក់ ឬ ការផ្តល់ទីកន្លែងមានសុវត្ថិភាពក៏ដោយ ក៏អង្គជំនុំជម្រះប្រើពាក្យនេះត្រឹមតែពិពណ៌នាអំពីការផ្លាស់ទីលំនៅប្រជាជនចេញពីទីប្រជុំជន ជាពិសេស ពីទីក្រុងភ្នំពេញប៉ុណ្ណោះ។ ការវាយតម្លៃត្រឹមត្រូវទៅលើការផ្លាស់ទីលំនៅ មាននៅក្នុងសាលក្រមនេះ ប៉ុន្តែ អង្គជំនុំជម្រះមិនយកតាមការប្រើប្រាស់ពាក្យរបស់ខ្មែរក្រហមនោះទេ") ហើយលេខយោងជើងទំព័រ ៣៨៤ ("អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ពាក្យ "រំដោះ" ត្រូវបានខ្មែរក្រហមខ្លួនឯងប្រើប្រាស់ ដើម្បីពិពណ៌នាអំពីការទទួលជ័យជំនះលើកម្លាំងនៃរបបសាធារណរដ្ឋខ្មែរ ការកាន់កាប់តំបន់នានា ដែលរបបសាធារណរដ្ឋខ្មែរគ្រប់គ្រង និងការដាក់ឱ្យប្រជាជនស្ថិតក្រោមការគ្រប់គ្រងរបស់ពួកខ្មែរក្រហមផ្ទាល់។ ការវាយតម្លៃត្រឹមត្រូវទៅលើព្រឹត្តការណ៍នេះ គឺមានពន្យល់នៅក្នុងសាលក្រមនេះ ប៉ុន្តែ អង្គជំនុំជម្រះមិនយកតាមការប្រើប្រាស់ពាក្យរបស់ខ្មែរក្រហមនោះទេ")។

[234] សាលក្រម សំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ២៧៨។

## កំហុសឆ្គងទៀតដែលត្រូវបានចោទប្រកាន់

៨៨. ការសន្និដ្ឋានរបស់ ខៀវ សំផន ដែលថា សាលក្រមសំណុំរឿង ០០២/០១ ហួសពីយុត្តាធិការពេលវេលារបស់ អ.វ.ត.ក នោះគឺជាបញ្ហាសម្រាប់ការប្តឹងសាទុក្ខ ជាជាងការប្តឹងជំទាស់ ហើយដូចគ្នាផងដែរទៅនឹងការសន្និដ្ឋានរបស់ នួន ជា ដែលថា សាលក្រមសំណុំរឿង ០០២/០១ បានផ្អែកយ៉ាងច្រើនលើសលុបទៅលើភ័ស្តុតាងរបស់អ្នកជំនាញ។ មិនមានមូលដ្ឋានអ្វីដែលអាចឱ្យសន្និដ្ឋានបានថា កំហុសដែលបានចោទប្រកាន់ កើតចេញពីបុរេវិនិច្ឆ័យប្រឆាំងនឹងជនជាប់ចោទ ឬ មិនមានអ្វីក្រៅតែពីការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ ដែលក្នុងនោះ អាចមានការបកស្រាយលើសពីមួយឡើងទៅ ឬ ការវាយតម្លៃរបស់ចៅក្រមទៅលើអង្គហេតុនានានោះទេ។ អាស្រ័យហេតុនេះ ការសន្និដ្ឋាននៅក្នុងបណ្តឹងជំទាស់ទាក់ទងទៅនឹងកំហុសដែលបានចោទប្រកាន់នៅក្នុងសាលក្រមក្នុងសំណុំរឿង ០០២/០១ ត្រូវបានបដិសេធចោល។

### (៣) ការចោទប្រកាន់ថាមានបុរេវិនិច្ឆ័យ ដោយសំអាងលើសាលក្រមសំណុំរឿង ០០១

៨៩. ក្រុមប្រឹក្សាជំនុំជម្រះដែលត្រូវបានរៀបចំឡើង ដើម្បីដោះស្រាយទៅលើបណ្តឹងជំទាស់មុនរបស់ នួន ជា លើសាលក្រមសំណុំរឿង ០០១ បានបដិសេធការសន្និដ្ឋានផ្សេងៗរបស់គាត់ ដោយបានកត់សម្គាល់ថា ចៅក្រមទាំងឡាយមិនត្រូវបានហាមឃាត់មិនឱ្យគ្រប់គ្រងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌពីរផ្សេងគ្នា ដែលកើតចេញពីអង្គហេតុតែមួយនោះទេ ទោះបីជារឿងក្តីទាំងពីរនេះពាក់ព័ន្ធទៅនឹងអង្គហេតុ និងអង្គច្បាប់ដូចគ្នាក៏ដោយ[235]។ នួន ជា ខកខានមិនបានបង្ហាញថា សាលក្រមសំណុំរឿង ០០១ មានបុរេវិនិច្ឆ័យមកលើពិរុទ្ធភាពរបស់គាត់ ទាក់ទងនឹងបទចោទប្រកាន់នានា ប្រឆាំងនឹងរូបគាត់នៅក្នុងសំណុំរឿង ០០២ នោះទេ[236]។ ពេលនេះ នួន ជា ជំទាស់ថា ការបដិសេធលើបណ្តឹងជំទាស់មុនរបស់គាត់ បណ្តាលមកពីការបកស្រាយច្បាប់ខុស និងតឹងរ៉ឹង ប៉ុន្តែអំណះអំណាងរបស់គាត់ចំពោះ

---

[235] សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្តឹងជំទាស់ចំពោះចៅក្រម ណិល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី ឯកសារ E55/4 ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១១ កថាខណ្ឌ ១៥។

[236] សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្តឹងជំទាស់ចំពោះចៅក្រម ណិល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី ឯកសារ E55/4 ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១១ កថាខណ្ឌ ២០-២៥។

បទដ្ឋានកម្រិតទាបនោះ ត្រូវបានបដិសេធចោលខាងលើរួចហើយ[237]។ ក្នុងករណីណាក៏ដោយ ប្រសិនបើ នួន ជា ជំទាស់តវ៉ាថា ការបដិសេធលើបណ្តឹងជំទាស់មុនរបស់គាត់បណ្តាលមកពីកំហុសអង្គច្បាប់ នោះវាគឺជាបញ្ហាដែលត្រូវប្តឹងសាទុក្ខ។

៩០. ទាក់ទងនឹងបញ្ហាមួយចំនួនដែលបានកំណត់ថាជា "ការផ្តោតការយកចិត្តទុកដាក់ថ្មី" របស់ នួន ជា ទៅលើសាលក្រមសំណុំរឿង ០០១ នោះ បញ្ហានានានៅក្នុងសំណុំរឿង ០០២/០២ ក៏ជាបញ្ហាដែលត្រូវសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកទៅលើភស្តុតាងដែលបានយកមកបង្ហាញនៅក្នុងរឿងក្តីនោះដែរ។ ចៅក្រមវិជ្ជាជីវៈនឹងមិនត្រូវទទួលរងឥទ្ធិពលដោយមិនត្រឹមត្រូវដោយសារតែភស្តុតាង និងសំអាងហេតុពីរឿងក្តីមួយផ្សេងទៀតនោះឡើយ ។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់អំពីករណីយុត្តិសាស្ត្រនៅត្រង់ចំណុចនេះរួចមកហើយ[238]។ ហេតុដូច្នេះ នួន ជា ខកខានមិនបានបង្ហាញថា អ្នកសង្កេតការណ៍មិនលម្អៀងយល់ឃើញថាមានភាពលំអៀងរបស់ចៅក្រម និល ណុន ចៅក្រម យ៉ា សុខន និងចៅក្រម Jean-Marc LAVERGNE ដោយសារតែសំអាងហេតុនៅក្នុងសំណុំរឿង ០០១ នោះទេ។ ទោះជាយ៉ាងណាក៏ដោយ មិនមានសំអាងហេតុណាមួយដែល នួន ជា បានលើកឡើង បង្ហាញពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់គាត់ទៅលើបញ្ហាណាមួយ ឬ បង្ហាញជាការសន្មតនូវការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះរូបគាត់ ទាក់ទងនឹងបទចោទប្រកាន់ទាំងឡាយដែលត្រូវយកមកវិនិច្ឆ័យក្នុងសំណុំរឿង ០០២/០២ នោះទេ។ ហេតុដូច្នេះ អំណះអំណាងរបស់ នួន ជា ត្រូវបានបដិសេធចោល។

### (៤) ការចោទប្រកាន់ថាមានបុរេវិនិច្ឆ័យ ដោយផ្អែកលើសាលក្រមសំណុំរឿង ០០២/០១

៩១. ខៀវ សំផន បានលើកឡើងថា សាលក្រមសំណុំរឿង ០០២/០១ មានសំអាងហេតុដែលបានធ្វើបុរេវិនិច្ឆ័យលើពិរុទ្ធភាពរបស់គាត់នៅក្នុងសំណុំរឿង ០០២/០២[239]។ ផ្ទុយទៅវិញ នួន ជា ហាក់មិនបានជំទាស់តវ៉ាថា សាលក្រមសំណុំរឿង ០០២/០១ ពិតជាបានធ្វើឱ្យមានបុរេវិច្ឆ័យលើពិរុទ្ធភាពរបស់គាត់នៅក្នុងសំណុំរឿង ០០២/០២ ទាក់ទងនឹងបទចោទប្រកាន់ទាំងឡាយដែលត្រូវយកមកវិនិច្ឆ័យក្នុងសំណុំរឿង ០០២/០២ នោះទេ។ ប៉ុន្តែ គាត់ស្នើសុំឱ្យជំទាស់ចៅក្រមដោយសំអាងថា ចៅក្រមអង្គជំនុំ-ជម្រះសាលាដំបូងបានធ្វើបុរេវិនិច្ឆ័យ "លើពិរុទ្ធភាពរបស់គាត់" និង/ឬ "បានបង្កើតទស្សនៈយល់ឃើញ

---

[237] *សូមមើល* កថាខណ្ឌ ៣៧-៤៨ ខាងលើ។

[238] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីលើកទីបីរបស់អង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌ ៨៣។

[239] បណ្តឹងជំទាស់ចៅក្រមសាជាថ្មីរបស់ ខៀវ សំផន កថាខណ្ឌ ១០។

ជាមុន" លើរឿងក្ដីរបស់គាត់[240]។ ការសន្និដ្ឋានរបស់ នួន ជា មិនបានឆ្លើយតបទៅនឹងលក្ខខណ្ឌសម្រាប់បុរេវិនិច្ឆ័យ ដែលអង្គជំនុំជម្រះតុលាការកំពូលបានកំណត់ឡើង គឺថាតើសំអាងហេតុតុលាការ "បង្ហាញឲ្យឃើញជាការសន្មតនូវការទទួលខុសត្រូវព្រហ្មទណ្ឌ [...] ទាក់ទងនឹងបទចោទដែលត្រូវជំនុំជម្រះរឿងក្ដីបន្តបន្ទាប់ទេ"[241]។

៩២. សំណួរថាតើសំអាងហេតុតុលាការពិតជាមានបុរេវិនិច្ឆ័យទៅលើពិរុទ្ធភាពរបស់ជនជាប់ចោទឬយ៉ាងណានោះគឺវាអាស្រ័យទៅលើកាលៈទេសៈផ្សេងៗនៃរឿងក្ដីនីមួយៗ។ យ៉ាងណាក៏ដោយ តុលាការអន្តរជាតិ ឬតុលាការដែលមានលក្ខណៈអន្តរជាតិ បានផ្ដល់វិធីសាស្ត្រក្នុងការដោះស្រាយទៅលើបណ្ដឹងជំទាស់ដែលចោទប្រកាន់ថា សំអាងហេតុតុលាការពីមុនមានបុរេវិនិច្ឆ័យទៅលើពិរុទ្ធភាពរបស់បុគ្គល។ យុត្តិសាស្ត្របែបនេះមានភាពល្អប្រសើរជាងករណីផ្សេងៗពីយុត្តាធិការជាតិពាក់ព័ន្ធនឹងរឿងក្ដី និងយុត្តាធិការដែលមានភាពខុសគ្នាពីរឿងក្ដីនៅ អ.វ.ត.ក ។

៩៣. សំណុំរឿង ០០២/០១ និង ០០២/០២ កើតចេញពីការបំបែកដីកាដំណោះស្រាយ និងជាប់ពាក់ព័ន្ធជាមួយជនជាប់ចោទដដែល។ ប៉ុន្តែ សំណុំរឿងទាំងនេះពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងព្រឹត្តិការណ៍ផ្សេងគ្នា។ ក្នុងសំណុំរឿង ០០២/០១ នួន ជា និង ខៀវ សំផន ត្រូវបានរកឃើញថា មានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានប្រព្រឹត្តក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញក្នុងឆ្នាំ ១៩៧៥ ការផ្លាស់ទីលំនៅប្រជាជនចេញពីភូមិភាគកណ្ដាល (ឧត្តរចាស់) ភូមិភាគនិរតី ភូមិភាគបស្ចិម និងភូមិភាគបូព៌ា ចាប់ពីខែ កញ្ញា ឆ្នាំ ១៩៧៥ ដល់ ១៩៧៧ និងការសម្លាប់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ នៅក្នុងខែ មេសា ឆ្នាំ ១៩៧៥[242]។ ផ្ទុយទៅវិញ សំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹងបទចោទប្រកាន់ដែលទាក់ទងនឹងអំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម អំពើប្រល័យពូជសាសន៍លើជនជាតិចាម (និងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនានៅក្នុងអំឡុងពេលផ្លាស់ទីលំនៅជនជាតិចាម) ការរៀបការដោយបង្ខំនៅទូទាំងប្រទេស និងអំពើអមនុស្សធម៌ផ្សេងទៀត តាមរយៈការរំលោភនៅទីតាំងជាក់លាក់មួយចំនួន នៅក្នុងបរិបទនៃការរៀបការដោយបង្ខំ ការបោសសម្អាតផ្ទៃក្នុង (កម្រិតត្រឹមតែបទល្មើសដូចដែលបានកំណត់ ប្រព្រឹត្ត

---

[240] បណ្ដឹងជំទាស់របស់ នួន ជា កថាខណ្ឌ ២៩-៣០, ៥៤-៥៥, ៧០, ៩២, ៩៣, ១០០, ១០៥, ១១០-១១១, ១១៦។

[241] ចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីលើកទីបីរបស់អង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌ ៨៥។

[242] សេចក្ដីសម្រេចលើកលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលកាលពីថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E284 ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣។

ឡើងនៅទីតាំងឧក្រិដ្ឋកម្មដែលបានកំណត់អត្តសញ្ញាណរួចហើយ) និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ព្រមទាំងឧក្រិដ្ឋកម្មសង្គ្រាម ដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តនៅមន្ទីរសន្តិសុខ ស-២១ ការដ្ឋានទំនប់ ១-មករា សហករណ៍ត្រាំកក់ មន្ទីរសន្តិសុខក្រាំងតាចាន់ ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង មន្ទីរសន្តិសុខអូរកន្សែង មន្ទីរសន្តិសុខភ្នំក្រោល និងការដ្ឋានទំនប់ត្រពាំងថ្ម[243]។ សាលក្រមសំណុំរឿង ០០២/០១ មិនបានដាក់ការទទួលខុសត្រូវព្រហ្មទណ្ឌទាក់ទងនឹងបទល្មើសផ្សេងៗដែលត្រូវជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ នោះទេ។ ទោះបីជាមានបញ្ហាត្រួតគ្នាពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២ ក៏ដោយ ក៏សំណុំរឿងទាំងពីរនេះមានលក្ខណៈខុសគ្នាយ៉ាងខ្លាំង។

៩៤. ភាពខុសគ្នាទាំងនេះក៏មិនមានត្រឹមតែអ្វីដែលអាចត្រូវបានកំណត់ថាជាភ័ស្តុតាងផ្អែកលើមូលដ្ឋានបទឧក្រិដ្ឋនោះទេ។ ទោះបីជាសាលក្រមសំណុំរឿង ០០២/០១ បានលើកឡើងពីការចូលរួមរបស់ ខៀវ សំផន និង នួន ជា នៅក្នុងសហឧក្រិដ្ឋកម្មរួម ហើយនៅក្នុងករណីរបស់ នួន ជា គឺការត្រួតត្រាជាក់ស្តែងរបស់គាត់ទៅលើកម្មាភិបាលខ្មែរក្រហមក៏ដោយ ក៏សាលក្រមសំណុំរឿង ០០២/០១ មិនបានវាយតម្លៃ ឬសម្រេចអំពី*ចេតនា* របស់ ខៀវ សំផន ឬ នួន ជា ទាក់ទងនឹងឧក្រិដ្ឋកម្មទាំងឡាយក្នុងសំណុំរឿង ០០២/០២ នោះដែរ។ ឧទាហរណ៍ ទោះបីជាសាលក្រមសំណុំរឿង ០០២/០១ សន្និដ្ឋានថា ខៀវ សំផន និង នួន ជា មានចេតនាប្រព្រឹត្តអំពើអមនុស្សធម៌ផ្សេងទៀតនៃការផ្លាស់ទីប្រជាជនដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ការធ្វើមនុស្សឃាតដែលបានប្រព្រឹត្តក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១ និងទី ២) ក៏ដូចជាការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ និងចេតនាក្នុងការរើសអើងទាក់ទងនឹងឧក្រិដ្ឋកម្មស្តីពីការធ្វើទុក្ខបុកម្នេញដែលបានប្រព្រឹត្តក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១ និងទី ២)[244] ក៏ *ចេតនា* របស់ពួកគាត់ទាក់ទងនឹងឧក្រិដ្ឋកម្មក្នុងសំណុំរឿង ០០២/០២ មិនត្រូវបានយកមកពិចារណាឡើយ។ អង្គជំនុំជម្រះសាលាដំបូងមិនមានសំអាងហេតុអំពីថាតើសហឧក្រិដ្ឋកម្មរួមនេះ បណ្តាលឲ្យ និង/ឬកើតមានឧក្រិដ្ឋកម្មក្នុងសំណុំរឿង ០០២/០២ ដែរ ឬយ៉ាងណានោះទេ។ ដោយពិចារណាទៅលើការពុំមានសំអាងហេតុត្រង់ចំណុចនេះ ទោះជាដោយផ្ទាល់ ឬដោយប្រយោល ទៅលើបញ្ហានៃការទទួលខុសត្រូវ

---

243 សេចក្តីសម្រេចលើកលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ឯកសារ E301/9/1។

244 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៩៥ ទាក់ទងនឹង ខៀវ សំផន ហើយកថាខណ្ឌ ៩៧៦ ទាក់ទងនឹង នួន ជា។

ពាក់ព័ន្ធនឹងសំណុំរឿង ០០២ នោះ ក្រុមប្រឹក្សាជំនុំជម្រះពិសេសយល់ឃើញថា បណ្តឹងជំទាស់មិនបាន បង្ហាញពីភាពលម្អៀង ឬការយល់ឃើញសមហេតុផលអំពីភាពលម្អៀងឡើយ។

៩៥. បណ្តឹងជំទាស់នេះក៏មិនបានបង្ហាញថា អ្នកសង្កេតការណ៍មិនលម្អៀងម្នាក់អាចនឹងសន្និដ្ឋានថា ចៅក្រមនឹងមានភាពលម្អៀងចំពោះភាគីណាមួយដែលចៅក្រមនោះ បានធ្វើឱ្យប៉ះពាល់ដោយសារតែសម្អាងហេតុដែលខ្លួនបានរកឃើញនោះឡើយ។ មានយុត្តិសាស្ត្រមួយចំនួនពីតុលាការដទៃទៀតពាក់ព័ន្ធនឹងករណីទាំងឡាយដែលអង្គជំនុំជម្រះតុលាការកំពូលហៅថាជា "ភស្តុតាងស្វយ័ត"។ បើទោះជាសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២ សុទ្ធតែកើតចេញពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ដូចគ្នាក្តី តែសំណុំរឿងនីមួយៗមានភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងខុសគ្នាយ៉ាងខ្លាំង។ ភាគីបានដាក់បញ្ជីឯកសារ[245] សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញជាច្រើន[246] ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២។ សូម្បីតែការពិនិត្យត្រួសៗទៅលើបញ្ជីទាំងនេះក៏បង្ហាញថា

---

[245] សូមមើល បញ្ជីឯកសារសវនាការរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៨០(៣) នៃវិធានផ្ទៃក្នុង ឯកសារ E305/13 ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤។ សំណើរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាវិធាន ៨៧(៤) ស្នើដាក់ឯកសារ វត្ថុតាង និងសក្ខីកម្មផ្ទាល់មាត់ទាក់ទងនឹងសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានស្នើឱ្យផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ បញ្ចូលជាភស្តុតាង។ ឯកសារ E307/6 ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤។ បញ្ជីឯកសារបឋមសម្រាប់សំណុំរឿង ០០២/០២ ឯកសារ E307/5 ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៤។ ឯកសារស្នើឡើងដោយមេធាវីការពារក្តីលោក ខៀវ សំផន សម្រាប់សំណុំរឿង ០០២/០២ ឯកសារ E305/12 ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤។

[246] សូមមើល បញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា និងសេចក្តីសង្ខេបសម្រាប់ជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ (ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ចំនួន៥៖ I, II, IIក, III និង IIIក) ឯកសារ E305/6 ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤។ សំណើរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងសាក្សីដែលបានស្នើសុំសម្រាប់សវនាការ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សម្រាប់សំណុំរឿង ០០២/០២ ឯកសារ E307/3/2 ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៤។ បញ្ជីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់សំណុំរឿង ០០២/០២ អនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ ឯកសារ E305/7 ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ។ បញ្ជីឈ្មោះ និងព័ត៌មានសង្ខេបដែលបានធ្វើបច្ចុប្បន្នភាព ស្តីពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើសុំ ឯកសារ E305/4 ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៤។ បញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញថ្មី សម្រាប់សំណុំរឿង ០០២/០២ របស់ នួន ជា ឯកសារ E307/4 ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៤។ សាក្សី និងអ្នកជំនាញស្នើឡើងដោយមេធាវីការពារក្តីលោក ខៀវ សំផន សម្រាប់សំណុំរឿង ០០២/០២ ឯកសារ E305/5 ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤។

ឯកសារជាច្រើននឹងត្រូវដាក់ជូនដល់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០២ ដែលអង្គជំនុំជម្រះមិនមានទេនៅក្នុងសំណុំរឿង ០០២/០១ នោះ។

៩៦. លើសពីនេះទៀត អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ជាមុនចំពោះសាលក្រមសំណុំរឿង ០០២/០១ ថា ធាតុផ្សំរួមនៃអង្គហេតុក្នុងសំណុំរឿងទាំងអស់ត្រូវតែយកមកបង្ហាញសាជាថ្មី[247]។ អង្គ-ជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់ភាពត្រួតគ្នារវាងសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២ និងថា អាចមាន "ការយល់ឃើញជាមុនទៅលើបញ្ហាដែលជាប់ពាក់ព័ន្ធជារួម"[248]។ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលមិនបានសម្រេច ហើយយុត្តិសាស្ត្រខាងលើក៏មិនបានបង្ហាញថា ការយល់ឃើញជាមុនពាក់ព័ន្ធនឹងភាគីមានន័យថា ចៅក្រមមិនត្រូវបានចាត់ទុកថាមានអនាគតិភាពនោះទេ។

៩៧. ចំពោះសំអាងហេតុជាក់លាក់នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ដែលជាមូលដ្ឋាននៃបណ្តឹងជំទាស់ចិត្តនោះ បណ្តឹងជំទាស់ចិត្តទាំងពីរបានអះអាងថា សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើគោលនយោបាយទាំងប្រាំនៅក្នុងសំណុំរឿង ០០២/០១ គឺជាបុរេវិនិច្ឆ័យចំពោះសំណុំរឿង ០០២/០២[249]។ ប៉ុន្តែ ទាក់ទងនឹងគោលនយោបាយបី ក្នុងចំណោមគោលនយោបាយទាំងប្រាំ អង្គជំនុំ-ជម្រះសាលាដំបូងបានកម្រិតសំអាងហេតុរបស់ខ្លួនយ៉ាងច្បាស់ត្រឹមតែលើអត្ថិភាពនៃគោលនយោបាយទាំងនោះមុនឆ្នាំ ១៩៧៥ ប៉ុណ្ណោះ។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់យ៉ាងច្បាស់ និងដដែលៗថា លក្ខណៈ និងការអនុវត្តគោលនយោបាយទាំងនោះក្រោយឆ្នាំ ១៩៧៥ គឺជាបញ្ហាសម្រាប់សំណុំរឿង ០០២/០២។ បណ្តឹងជំទាស់ចិត្តទាំងពីរអះអាងថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គង ប៉ុន្តែ មិនមានអ្វីដែលបញ្ជាក់ថា សំអាងហេតុបែបនេះបង្ហាញពីការសន្និដ្ឋានការទទួលខុសត្រូវព្រហ្ម-ទណ្ឌចំពោះឧក្រិដ្ឋកម្មទាំងឡាយ ដែលត្រូវបានយកមកចោទប្រកាន់មកលើជនជាប់ចោទក្នុងសំណុំរឿង ០០២/០២ នោះទេ។

៩៨. បណ្តឹងជំទាស់ចិត្តរបស់ នួន ជា បានអះអាងថា សាលក្រមសំណុំរឿង ០០២/០១ បានធ្វើបុរេវិនិច្ឆ័យទៅលើគោលនយោបាយនៃការកំណត់គោលដៅចំពោះខ្មាំង។ នួន ជា បានបង្ហាញសំអាងហេតុនានាក្នុងសាលក្រមសំណុំរឿង ០០២/០១ អំពីការកំណត់គោលដៅមកលើប្រជាជនថ្មី និងអ្នករដ្ឋការនៃ

---

[247] សេចក្តីសម្រេចលើកទីបីរបស់ អ.ជ.ត.ក លើការបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ ៨៥។

[248] សេចក្តីសម្រេចលើកទីបីរបស់ អ.ជ.ត.ក លើការបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ ៨៣។

[249] បណ្តឹងជំទាស់ចិត្តរបស់ នួន ជា កថាខណ្ឌ ១០០។

របបសាធារណរដ្ឋខ្មែរ[250]។ ប៉ុន្តែ សំអាងហេតុទៅលើគោលនយោបាយនៃការអប់រំកែប្រែសមាសភាពអាក្រក់ និងការសម្លាប់ខ្មាំង ត្រូវបានកម្រិតត្រឹមអំឡុងពេលមុនឆ្នាំ ១៩៧៥[251]។ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា "ភស្តុតាងទាក់ទងនឹងខ្លឹមសារ និងការអនុវត្តគោលនយោបាយអប់រំកែប្រែសមាសភាពអាក្រក់ និងការសម្លាប់ខ្មាំង និងវិសាលភាពគោលនយោបាយនេះ គឺជាកម្មវត្ថុនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២[252]។ សំណុំរឿង ០០២/០១ ពាក់ព័ន្ធនឹងការកំណត់គោលដៅមកលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ ចំណែកឯសំណុំរឿង ០០២/០២ វិញ ពាក់ព័ន្ធនឹងការកំណត់គោលដៅទៅលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅតាមទីកន្លែងដូចតទៅនេះ៖ សហករណ៍ត្រាំកក់ ការដ្ឋានទំនប់ ១-មករា មន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់។ មានភាពខុសគ្នាយ៉ាងខ្លាំងរវាងសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២ ហើយ នួន ជា ខកខានមិនបានបង្ហាញឱ្យឃើញថា អ្នកសង្កេតការណ៍មិនលម្អៀងអាចយល់ឃើញថាចៅក្រមមានភាពលម្អៀង ដោយសារតែពួកគាត់មានសំអាងហេតុប្រឆាំងនឹងភាគីណាមួយនៅក្នុងការជំនុំជម្រះមុនៗនោះទេ។

៩៩. ចំពោះការសន្និដ្ឋានរបស់ នួន ជា ដែលថាអង្គជំនុំជម្រះសាលាដំបូងមានសំអាងហេតុអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការកំណត់គោលដៅទៅលើប្រជាជនថ្មីនោះ នេះមិនមែនជាគោលនយោបាយដែលត្រូវបានយកមកចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយនោះទេ។ ទោះជាយ៉ាងណាក្តី សាលក្រមសំណុំរឿង ០០២/០១ មានសំអាងហេតុទៅលើគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែលត្រូវបានកំណត់សម្រាប់ "ការអប់រំកែប្រែ"[253] និងសំអាងហេតុទាក់ទងនឹងការធ្វើទុក្ខបុកម្នេញមកលើប្រជាជនទីក្រុង ឬប្រជាជនថ្មី ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ[254] និងដំណាក់កាលទីពីរ។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ត្រូវបានរកឃើញថាជាប់ទាក់ទងនឹងការធ្វើបាបមកលើ "ប្រជាជនថ្មី" តាមរយៈការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ[255]។ សំអាងហេតុទាំងនេះខុសគ្នាពីបញ្ហានៃការទទួលខុសត្រូវរបស់ នួន ជា ចំពោះការចោទប្រកាន់ក្នុងសំណុំរឿង ០០២/០២។ តាម

---

[250] បណ្តឹងជំទាស់ចិត្តរបស់ នួន ជា កថាខណ្ឌ ១០៣-១០៥។

[251] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១១៧-១១៨។

[252] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១១៨។

[253] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៥៣។

[254] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៧៤។

[255] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៥២-៦៥៧។

ពិតទៅ សាលក្រមសំណុំរឿង ០០២/០១ បានលើកឡើងថា "អ្នកត្រូវគេផ្លាស់ទីត្រូវបានទទួលការស្វាគមន៍ខុសៗគ្នាទៅតាមគោលដៅរបស់ពួកគេ"[256]។

១០០. ពាក់ព័ន្ធនឹងតួនាទីរបស់ នួន ជា នៅក្នុងការរៀបចំតាក់តែង និងការជំរុញគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាវិញថា បណ្តឹងឧទ្ធរណ៍ដ៏តចិត្តរបស់ នួន ជា បានបង្ហាញសំអាងហេតុមួយចំនួនជាទូទៅ និងជាក់លាក់ក្នុងសាលក្រមសំណុំរឿង ០០២/០១ ដែលគាត់ជំទាស់តវ៉ាថា ជាការសម្រេចជាមុនទៅលើពិរុទ្ធភាពរបស់គាត់ ដែលជាការទទួលខុសត្រូវរបស់គាត់ចំពោះ "អំពើប្រល័យពូជសាសន៍ ដែលបានចោទប្រកាន់ថា បានកើតឡើងមកលើជនជាតិវៀតណាម និងជនជាតិចាម និងការសម្លាប់អ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ ព្រមទាំងការបោសសម្អាតផ្ទៃក្នុង"[257]។

១០១. ទាក់ទងនឹងការចោទប្រកាន់អំពីបទប្រល័យពូជសាសន៍វិញ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធយ៉ាងច្បាស់លាស់ថាមិនពិនិត្យទៅលើគោលនយោបាយក្នុងការកំណត់គោលដៅចំពោះជនជាតិចាម និងជនជាតិវៀតណាមនោះទេ ដោយសំអាងទៅលើមូលដ្ឋានថា "មានភស្តុតាងតិចតួចប៉ុណ្ណោះដែលត្រូវបានពិនិត្យមកទល់នឹងពេលនេះ"[258]។ អង្គជំនុំជម្រះសាលាដំបូងមិនបានបន្តពិនិត្យលើអង្គហេតុនានាដែលបានកំណត់សម្រាប់បទចោទប្រកាន់ទាំងនេះទេ។ ទាក់ទងនឹងមន្ទីរសន្តិសុខ ស-២១ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធយ៉ាងជាក់ច្បាស់ថា មិនមានសំអាងហេតុណាមួយ "ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ នួន ជា ចំពោះប្រតិបត្តិការនៅមន្ទីរសន្តិសុខ ស-២១" នោះទេ ដោយសារការចោទប្រកាន់ទាំងនោះ "ត្រូវបានបំបែកចេញពីសំណុំរឿង ០០២/០១ រួចហើយ ហើយនឹងត្រូវយកមកពិចារណានៅក្នុងកិច្ចដំណើរការនីតិវិធីនៅថ្ងៃនាខាងមុខ"[259]។

១០២. ទាក់ទងនឹង "ការបោសសម្អាតផ្ទៃក្នុង" វិញ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា នួន ជា "ក៏ជាប់ពាក់ព័ន្ធនឹងការបោសសម្អាតកម្មាភិបាល និងយោធា ជាពិសេស អ្នកដែលមកពីភូមិភាគបូព៌ា"[260]។ ប៉ុន្តែ កថាខណ្ឌដែលមានសំអាងហេតុនេះ មានប្រវែងតែបីបន្ទាត់ ហើយមានភាពច្បាស់លាស់ណាស់ថា កថាខណ្ឌនេះកម្រិតត្រឹមតែសំអាងហេតុថា នៅក្នុងឆ្នាំ ១៩៧៨ នួន ជា "បាននិយាយអំពីការ

---

[256] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៥១៦។

[257] បណ្តឹងឧទ្ធរណ៍ដ៏តចិត្តរបស់ នួន ជា កថាខណ្ឌ ១១០។

[258] សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ ១១៩។

[259] សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ ៣៤៦។

[260] សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ ៣៤០។

ចាប់ខ្លួនសមាជិកជាច្រើនរបស់ភូមិភាគបូព៌ា"[261]។ មិនមានក្នុងផ្នែកណាមួយនៃសាលក្រមសំណុំរឿង ០០២/០១ ដែលអង្គជំនុំជម្រះសាលាដំបូងបានពិចារណា ឬសម្រេច ថាតើការបោសសម្អាតផ្ទៃក្នុងប្រព្រឹត្តទៅហួសពីការចាប់ខ្លួនចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ក្នុងសំណុំរឿង ០០២/០២ ដែរ ឬអត់នោះទេ ដែលក្នុងនោះរួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំងដោយខុសច្បាប់ ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ដទៃទៀត តាមរយៈការវាយប្រហារមកលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស និងការបាត់ខ្លួនដោយបង្ខំនៃសមាជិកកម្មាភិបាល និងកងទ័ពបក្សកុម្មុយនីស្តកម្ពុជា[262] ដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តនៅមន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង មន្ទីរសន្តិសុខភ្នំក្រោល និងព្រលានយន្តហោះកំពង់ឆ្នាំង[263]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា ខ្លួននឹងមិនពិភាក្សាទៅលើការអនុវត្តគោលនយោបាយអប់រំកែប្រែសមាសភាពអាក្រក់ ឬគោលនយោបាយសម្លាប់ខ្មាំង និងវិសាលភាពនៃគោលនយោបាយនេះទេ ដោយសារតែវាជាកម្មវត្ថុនៃការជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២"[264]។ សំអាងហេតុតិចតួចនៅក្នុងសាលក្រមសំណុំរឿង ០០២/០១ មិនមែនជាការធ្វើបុរេវិនិច្ឆ័យទៅលើពិរុទ្ធភាពរបស់ នួន ជា ទាក់ទងនឹងបញ្ហាទាំងឡាយដែលត្រូវយកមកពិភាក្សានៅក្នុងសំណុំរឿង ០០២/០២ នោះទេ។

១០៣. នួន ជា លើកឡើងពីបញ្ហាពាក់ព័ន្ធនឹងសំអាងហេតុផ្នែកអង្គហេតុចំនួនប្រាំក្នុងសាលក្រមសំណុំរឿង ០០២/០១។ ទីមួយ សំអាងហេតុថា ភាគច្រើននៃវណ្ណៈដឹកនាំថ្មីទទួលការអប់រំក្នុងប្រព័ន្ធបានតិចតួចបំផុត ហើយពួកគេត្រូវឆ្លងកាត់វិន័យ ទទួលការបំពាក់បំប៉នមនោគមន៍វិជ្ជា ហើយត្រូវបានបង្រៀនយ៉ាងតឹងរ៉ឹងឱ្យចេះ *បោកបញ្ឆោត* ប្រជាជន និងអនុវត្តតាមគោលការណ៍រក្សាការសម្ងាត់។ ទីពីរ គឺបក្សកុម្មុយនីស្តកម្ពុជាបានប្រើប្រាស់ទស្សនៈអំពីការទម្លាក់គ្រាប់បែកដោយសហរដ្ឋអាមេរិក ដែលជាលេសដើម្បីផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញ។ ទីបី ការផ្លាស់ទីលំនៅក្នុងទ្រង់ទ្រាយធំនៅពេលក្រោយៗមកទៀត ត្រូវបានផ្អែកទៅលើលេសថាជាការយកចិត្តទុកដាក់លើប្រជាជន។ ទីបួន បក្ស

---

[261] សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ ៣៤០។

[262] សេចក្ដីសម្រេចអំពីការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ ឧបសម្ព័ន្ធ កថាខណ្ឌ ៥ (ii), អាចផ្ទួបគ្នាជាមួយនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៩៣-២០៣។

[263] សេចក្ដីសម្រេចអំពីការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ ឧបសម្ព័ន្ធ, កថាខណ្ឌ ២(iii) និង ៣(v-ix) និងជើងទំព័រយោងលេខ ៩។

[264] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១១៨។

កុម្មុយនីស្តកម្ពុជាបានប្រមូលផ្តុំអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ តាមរយៈមធ្យោបាយបោកបញ្ឆោត នៅមុនពេលសម្លាប់ពួកគេចោល។ ទីប្រាំ ការភូតកុហកត្រូវបានប្រើប្រាស់ ដើម្បីគ្រប់គ្រងទៅលើស្ថានភាពនោះ ហើយប្រជាជនគឺជាមូលដ្ឋានដ៏សំខាន់របស់របបនោះ[265]។ នួន ជា លើកឡើងថា ចៅក្រមទាំងអស់បានបង្កើតទស្សនៈមិនពេញចិត្តចំពោះបក្សកុម្មុយនីស្តកម្ពុជា និងទឡ្ហីករណ៍សំខាន់ខ្លះទៀតរបស់គាត់រួចទៅហើយ។

១០៤. នួន ជា មិនបានកំណត់អំពី "ទឡ្ហីករណ៍សំខាន់" របស់គាត់ និងលើកឡើងទាំងមិនត្រឹមត្រូវអំពីសំអាងហេតុមួយចំនួនរបស់អង្គជំនុំជម្រះសាលាដំបូង។ ការពិនិត្យឡើងវិញទៅលើបណ្តាកថាខណ្ឌមួយចំនួននៃសាលក្រមសំណុំរឿង ០០២/០១ ដែល នួន ជា ផ្អែកនោះ បង្ហាញឱ្យឃើញថា សំអាងហេតុជាច្រើនត្រូវបានកម្រិតយ៉ាងច្បាស់លាស់ត្រឹមតែការផ្លាស់ទីលំនៅប្រជាជនពីទីក្រុងភ្នំពេញ[266] ឬក៏ការចាប់ខ្លួន និងការសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរ ព្រមទាំងអ្នករដ្ឋការ នៅក្នុងរយៈពេលប៉ុន្មានថ្ងៃភ្លាមៗក្រោយមក[267]។ សំអាងហេតុទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជនទ្រង់ទ្រាយធំ នៅពេលក្រោយៗមកទៀត ប៉ះពាល់ដល់សំណុំរឿង ០០២/០២ តិចតួចបំផុត ប៉ុន្តែ បញ្ហានៃការធ្វើទុក្ខបុកម្នេញមកលើជនជាតិចាម លើកឡើងនូវបញ្ហាដោយឡែក[268]។ សេចក្តីថ្លែងការណ៍ដែលកុហកភូតភរគឺជា "មូលដ្ឋានដ៏សំខាន់" ដែលចាប់ផ្តើមជាមួយឃ្លាថា៖ "សាក្សី François PONCHAUD និងអ្នកជំនាញ Philip SHORT បានផ្តល់សក្ខីកម្មថា ..."[269]។ សេចក្តីសន្និដ្ឋានទៅលើភ័ស្តុតាងបែបនេះមិនសម្រេចសេចក្តីអំពីពិរុទ្ធភាពនោះទេ ដូច្នេះ មិនអាចគាំទ្រដល់ការចោទប្រកាន់អំពីការយល់ឃើញប្រកបដោយហេតុផលថាមានភាពលម្អៀងឡើយ។

---

[265] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១១២។

[266] *សូមមើល ជាឧទាហរណ៍* សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៣០, ៥៤៨ *ដែលត្រូវបានយកមកសម្អាង*នៅក្នុងសារណារបស់ នួន ជា, ជើងទំព័រយោងលេខ ២១៤។

[267] *សូមមើល ជាឧទាហរណ៍* សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១២០, ៥១១, ៨៥៣, ៩៥៤ *ដែលត្រូវបានយកមកសម្អាង*នៅក្នុងសារណារបស់ នួន ជា, ជើងទំព័រយោងលេខ ២១៤។

[268] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៣៤, ៨០៣ *ដែលត្រូវបានយកមកសម្អាង*នៅក្នុងសារណារបស់ នួន ជា, ជើងទំព័រយោងលេខ ២១៤។

[269] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៣៤ *ដែលត្រូវបានយកមកសម្អាង*នៅក្នុងសារណារបស់ នួន ជា, ជើងទំព័រយោងលេខ ២១៤។

១០៥. ទោះជាក្នុងករណីណាក៏ដោយ ការដែលអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញទៅលើទឡ្ហីករណ៍ខ្លះដែលបានលើកឡើងដោយ នួន ជា ថាមិនអាចឲ្យជឿជាក់បាននៅពេលធ្វើការពិនិត្យទៅលើបទចោទនានានៅក្នុងសំណុំរឿង ០០២/០១ នោះ មិនគាំទ្រដល់ការយល់ឃើញណាមួយដែលថា ចៅក្រមនឹងពិនិត្យទៅលើបទចោទនៅក្នុងសំណុំរឿង ០០២/០២ ដោយភាពលម្អៀង និងបុរេវិនិច្ឆ័យឡើយ។ ការសន្និដ្ឋានរបស់ នួន ជា មិនអាចច្រានចោលសច្ចធារណ៍នៃអនាគតិ ដែលមានជាប់មកជាមួយចៅក្រម ឬបង្ហាញឲ្យឃើញថា អ្នកសង្កេតការណ៍មិនលម្អៀងអាចពិចារណាឃើញថា ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងនឹងមិនមានអនាគតិក្នុងសំណុំរឿង ០០២/០២ នោះឡើយ។

១០៦. តាមរយៈការពិនិត្យទៅលើសាលក្រមសំណុំរឿង ០០២/០១ ទាំងមូល រួមទាំងផ្នែកផ្សេងៗនៃសាលក្រមដែលបណ្តឹងឧទ្ធរណ៍លើកឡើង ចៅក្រមអង្គជំនុំជម្រះសាលាដំបូងយល់ថា សំអាងហេតុរបស់ពួកគាត់ត្រូវបានកម្រិតត្រឹមតែចំពោះសំណុំរឿង ០០២/០១ ប៉ុណ្ណោះ។ អ្នកសង្កេតការណ៍មិនលម្អៀងនឹងទទួលស្គាល់ថា ចៅក្រមវិជ្ជាជីវៈមានលទ្ធភាពកាត់សេចក្តីលើរឿងក្តីជាប់ៗគ្នាប្រឆាំងនឹងជនជាប់ចោទដដែល ដូចទៅនឹងការដែលគាត់អាចជំនុំជម្រះលើរឿងក្តីជាប់ៗគ្នាពាក់ព័ន្ធនឹងព្រឹត្តិការណ៍ដែលជាប់ទាក់ទងគ្នា និងភ័ស្តុតាងស្រដៀងគ្នាដែរ។ បណ្តឹងឧទ្ធរណ៍ខកខានមិនបានបង្ហាញឲ្យឃើញថា អ្នកសង្កេតការណ៍មិនលម្អៀងអាចយល់ឃើញថា ចៅក្រមទាំងនោះអាចមិនមានលទ្ធភាពប្រកាន់គំនិតឥតលម្អៀងចំពោះសំណុំរឿង ០០២/០២ បាន ដោយសារតែចៅក្រមទាំងនោះបានធ្វើការវិនិច្ឆ័យដោយផ្អែកទៅលើភ័ស្តុតាងក្នុងសំណុំរឿង ០០២ /០១ នោះទេ។ ហេតុដូច្នេះ សារណារបស់ នួន ជា និង ខៀវ សំផន ដែលថា សាលក្រមសំណុំរឿង ០០២/០១ មានបុរេវិនិច្ឆ័យទៅលើពិរុទ្ធភាពរបស់ពួកគេនៅក្នុងសំណុំរឿង ០០២/០២ ត្រូវបានច្រានចោល។

## (៥) បន្ទុកនៃការបង្ហាញភ័ស្តុតាង សុចរិតភាពតុលាការ និងមនោគមន៍វិជ្ជា

១០៧. នួន ជា លើកឡើងថា សំអាងហេតុនានាក្នុងសាលក្រមសំណុំរឿង ០០១ និងសាលក្រមសំណុំរឿង ០០២/០១ បង្ហាញ "លទ្ធផលយ៉ាងច្បាស់" អំពីការកែប្រែបន្ទុកនៃការបង្ហាញភ័ស្តុតាងក្នុងសំណុំរឿង ០០២/០២[270]។ ជនជាប់ចោទមិនបានពន្យល់អំពីភាពពាក់ព័ន្ធនៃការសន្និដ្ឋានេះទៅលើបណ្តឹងឧទ្ធរណ៍ដែលបានផ្អែកថាមានភាពលម្អៀងនេះទេ។ ការសន្និដ្ឋានរបស់ នួន ជា ដែលបានផ្អែកទៅលើសំអាងហេតុក្នុងសាលក្រមសំណុំរឿង ០០១ និងសាលក្រមសំណុំរឿង ០០២/០១ ត្រូវបានបដិសេធ

[270] បណ្តឹងឧទ្ធរណ៍របស់ នួន ជា ផ្នែក ជ កថាខណ្ឌ ១២២។

ចោលរួចមកហើយ។ ហេតុដូច្នេះ ការសន្និដ្ឋានបន្ថែមរបស់ នួន ជា ពាក់ព័ន្ធនឹងបន្ទុកនៃការបង្ហាញភ័ស្តុតាងត្រូវបានបដិសេធចោលដូចគ្នា។ ការអះអាងរបស់គាត់ដែលថា សំអាងហេតុក្នុងសាលក្រមសំណុំរឿង ០០២/០១ និងសេចក្តីសម្រេចចុងក្រោយអំពីសាក្សី បង្ហាញឱ្យឃើញពីកង្វះសុចរិតភាពតុលាការ គឺជាបញ្ហាសម្រាប់ការប្តឹងសាទុក្ខជំទាស់នឹងសាលក្រមសំណុំរឿង ០០២/០១។ ចុងក្រោយ ការសន្និដ្ឋានរបស់គាត់ដែលភ្ជាប់អ្វីដែលគាត់ហៅថាជា "ទំនៀមទម្លាប់មនោគមន៍វិជ្ជា" របស់បណ្តាប្រទេសដែលចៅក្រមអន្តរជាតិមួយចំនួនមានប្រភពមកពីនោះ និងការផ្អែកនៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ទៅលើអ្វីដែលគាត់ហៅថាជាភ័ស្តុតាងអ្នកជំនាញ "Anglo-French" មិនអាចឱ្យជឿជាក់ជាមូលដ្ឋានសម្រាប់ការដិតចិត្តបានទេ។ សាលក្រមសំណុំរឿង ០០២/០១ មានសំអាងហេតុលម្អិត។ ប្រសិនបើ នួន ជា មិនយល់ស្របទៅនឹងសំអាងហេតុទាំងនោះទេ មធ្យោបាយសមស្របនោះគឺការប្តឹងសាទុក្ខ។

## (៦) ការចោទប្រកាន់ថាមានភាពលម្អៀង ដោយផ្អែកទៅលើការខកខានមិនបានកោះហៅ ហេង សំរិន

១០៨. ការសន្និដ្ឋានរបស់ នួន ជា ទាក់ទងនឹងសេចក្តីសម្រេចស្តាពរស្តីពីសាក្សី ផ្តោតទៅលើការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការកោះហៅ ហេង សំរិន។ គាត់ហាក់មិនបានលើកឡើងថា ការលេចឡើងនូវភាពលម្អៀងកើតចេញពីការការខកខានមិនបានកោះហៅ អ៊ុក ប៊ុនឈឿន ដែលចៅក្រមកម្ពុជា និងចៅក្រមអន្តរជាតិក៏មិនយល់ស្របគ្នាដែរនោះ។ ដោយមិនគិតកង្វះខាតជាក់ស្តែងអំពីចំណុចលម្អិតទាក់ទងទៅនឹងសារណានេះ ក្រុមប្រឹក្សាជំនុំជម្រះពិសេសបានពិនិត្យមើលមតិយោបល់របស់ចៅក្រមកម្ពុជា និងចៅក្រមអន្តរជាតិឡើងវិញ ដើម្បីពិចារណាថាតើអ្នកសង្កេតការណ៍មិនលម្អៀងអាចយល់ថាមានភាពលម្អៀងដែរ ឬយ៉ាណា។ គោលបំណងនៃការពិនិត្យឡើងវិញនោះ គឺមិនមែនដើម្បីសម្រេចថាតើសេចក្តីសម្រេចមិនកោះហៅ ហេង សំរិន ឬ អ៊ុក ប៊ុនឈឿន មានកំហុសឆ្គងដែរ ឬយ៉ាងណានោះទេ ប៉ុន្តែ ដើម្បីវាយតម្លៃថាតើអាចនិយាយបានថា សេចក្តីសម្រេចនេះបណ្តាលមកពីអ្វីមួយក្រៅពីការអនុវត្តច្បាប់ និងការវាយតម្លៃពិតប្រាកដទៅលើអង្គហេតុដែរ ឬយ៉ាងណានោះ។

១០៩. នួន ជា លើកឡើងថា ចៅក្រមកម្ពុជាបានលើកឡើងថា "ការកោះហៅសមាជិកជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ដូចជា ហេង សំរិន ឱ្យមកធ្វើជាសាក្សីនឹងនាំឱ្យមានការលំបាកដែលចៅក្រមជាតិមិន

បានត្រៀមខ្លួនប្រឈមមុខ"[271]។ ក្នុងការសម្រេចមិនកោះហៅ ហេង សំរិន នោះ ចៅក្រមកម្ពុជាបាន សំអាងទៅលើវិធាន ៨៧ នៃវិធានផ្ទៃក្នុង និងយុត្តិសាស្ត្រថា ដីកាបង្គាប់ឱ្យនាំខ្លួនមិនគួរចេះតែធ្វើឡើង ដោយមិនពិចារណាឱ្យបានហ្មត់ចត់នោះទេ ហើយយន្តការចាប់បង្ខំ មិនគួរត្រូវបានប្រើដោយរំលោភបំពាន ឬប្រើប្រាស់ជាយុទ្ធសាស្ត្រនៅក្នុងការជំនុំជម្រះក្តីនោះទេ[272]។ ចៅក្រមកម្ពុជាបានធ្វើសេចក្តីសង្ខេបទៅលើចេតនានៃការកោះហៅ ហេង សំរិន នៅមុនដំណាក់កាលជំនុំជម្រះ និងបានសន្និដ្ឋានថា ការកោះហៅសាក្សីត្រូវទុកឱ្យអង្គជំនុំជម្រះសាលាដំបូងជាអ្នកសម្រេច ថាតើត្រូវប្រើប្រាស់វិធានការចាប់បង្ខំ ឬយ៉ាងណានោះ[273]។ ចៅក្រមកម្ពុជាបានវាយតម្លៃទៅលើមូលហេតុថាហេតុអ្វីបានជា នួន ជា ស្នើសុំឱ្យកោះហៅ ហេង សំរិន មកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១។ ចៅក្រមកម្ពុជាបានបដិសេធសំអាងហេតុភាគច្រើនដែលបានលើកឡើង ប៉ុន្តែបានទទួលស្គាល់ថា ហេង សំរិន មានការជាប់ទាក់ទងទៅនឹងផ្នែកជាក់លាក់មួយចំនួនតូចនៃសំណុំរឿង ០០២/០១[274]។ បន្ទាប់មក ចៅក្រមកម្ពុជាបានថ្លឹងថ្លែងទៅលើការវាយតម្លៃរបស់ខ្លួនចំពោះសារៈសំខាន់នៃសក្ខីកម្មរបស់ ហេង សំរិន ក្នុងសំណុំរឿង ០០២/០១ ធៀបជាមួយនឹងអ្វីដែលចៅក្រមកម្ពុជាហៅថា ជាការអនុវត្តជាក់ស្តែង មានន័យថា វិធានការចាប់បង្ខំសាក្សីមកផ្តល់សក្ខីកម្មតាមរយៈការដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌ[275]។

១១០. "ការលំបាកលំបិន" ដែលចៅក្រមកម្ពុជាបានលើកឡើងថា ពួកគាត់មិនបានត្រៀមខ្លួនប្រឈមមុខនោះ ត្រូវបានចាត់ទុកថាជាការលំបាកតាមផ្លូវច្បាប់ និងនៅក្នុងការអនុវត្តជាក់ស្តែង ដែលចោទជាបញ្ហាដោយសារតែអភ័យឯកសិទ្ធិសភា។ ចៅក្រមកម្ពុជាបានលើកឡើងថា "ប្រសិនបើការផ្តល់សក្ខីកម្ម មានភាពចាំបាច់សម្រាប់ការប្រព្រឹត្តិទៅ ក៏ដូចជាយុត្តិធម៌នៃការជំនុំជម្រះទាំងមូល នោះយើងនឹងពិចារណាថា គួរតែចេញដីកាកោះ និងតម្រូវឱ្យអនុវត្តតែម្តង"[276]។ ចៅក្រមកម្ពុជាជឿថា សក្ខីកម្មរបស់ ហេង សំរិន មិនមានសារៈសំខាន់ពេញលេញចំពោះសំណុំរឿង ០០២/០១ នោះទេ ហេតុដូច្នេះបានសន្និដ្ឋានថា វិធានការចាប់បង្ខំមិនគួរត្រូវបានយកមកប្រើប្រាស់នោះទេ[277]។ ចៅក្រមកម្ពុជាបាន

---

[271] បណ្តឹងឧទ្ធរណ៍របស់ នួន ជា កថាខណ្ឌ ១៤។

[272] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី កថាខណ្ឌ ៨៩។

[273] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី កថាខណ្ឌ ៩០-៩១។

[274] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី កថាខណ្ឌ ៩៦។

[275] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី កថាខណ្ឌ ៩៧។

[276] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី កថាខណ្ឌ ៨៩។

[277] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី កថាខណ្ឌ ៩៧។

ពិចារណាបន្ថែមទៀត ថាតើការបដិសេធរបស់ពួកគាត់មិនកោះហៅ ហេង សំរិន អាចចាត់ទុកថាប៉ះពាល់ដល់ នួន ជា ដែរ ឬអត់ ហើយបានសន្និដ្ឋានថា តាមការយល់ឃើញរបស់ពួកគាត់ វាមិនប៉ះពាល់ដល់សិទ្ធិរបស់ នួន ជា ឡើយ[278]។ នួន ជា មិនយល់ស្របជាមួយនឹងការវាយតម្លៃរបស់ចៅក្រមកម្ពុជា ចំពោះសារៈសំខាន់នៃការផ្តល់សក្ខីកម្មរបស់ ហេង សំរិន ក្នុងសំណុំរឿង ០០២/០១ នោះទេ។ នេះជាបញ្ហាដែលត្រូវលើកឡើងនៅក្នុងបណ្តឹងសាទុក្ខ។ បើទោះជាចៅក្រមកម្ពុជាមានកំហុសនៅក្នុងការវាយតម្លៃរបស់ខ្លួនក៏ដោយ ក៏មិនមានមូលដ្ឋានអាចធ្វើការសន្និដ្ឋានថា អ្នកសង្កេតការណ៍មិនលម្អៀងយល់ថាមានភាពលម្អៀង ដោយសារតែវិធីសាស្ត្ររបស់ចៅក្រមដែរ។

១១១. ចៅក្រមកម្ពុជាក៏បានវាយតម្លៃទៅលើសំណើរបស់ នួន ជា សុំឱ្យកោះហៅ ហេង សំរិន មកធ្វើជាសាក្សីបញ្ជាក់ពីអត្តចរិតតែម្នាក់គត់។ ចៅក្រមកម្ពុជាបានសម្តែងការព្រួយបារម្ភថា សំណើនេះគឺជា "យុទ្ធសាស្ត្រនៃការជំរុះក្តី" និងមាន "គោលបំណងធ្វើឱ្យមានភាពច្រមូកច្របល់ ដែលជាការប៉ុនប៉ងបន្ថែមឱ្យមានការអនុវត្តវិធានការចាប់បង្ខំចំពោះសមាជិកសភាកម្ពុជា ជាជាងជាសំណើដែលសមហេតុផល និងដោយសុចរិតដែលថា សក្ខីកម្មរបស់ ហេង សំរិន នឹងពិតជាជួយដល់ នួន ជា មែននោះ"[279]។ ចៅក្រមកម្ពុជាបានពន្យល់អំពីការវាយតម្លៃរបស់ពួកគាត់ថា សំណើសុំនឹងទំនងជាអូសបន្លាយកិច្ចដំណើរការនីតិវិធី ហើយពួកគាត់យល់ថា វិធីសាស្ត្ររបស់ នួន ជា ចំពោះបញ្ហាភស្តុតាងអត្តចរិតនេះ គឺជាយុទ្ធសាស្ត្រមួយ ហេតុដូច្នេះ សំណើសុំនេះត្រូវបានបដិសេធចោល[280]។

១១២. ចៅក្រមកម្ពុជាបានពិចារណារួចហើយចំពោះ "យុទ្ធសាស្ត្រនៃការជំរុះក្តី" ដែលចេញដោយតុលាការអន្តរជាតិនានា ថាតើវិធានការចាប់បង្ខំ គួរតែត្រូវបានយកមកប្រើប្រាស់ដែរ ឬអត់។ បណ្តឹងជំទាស់ថា កត្តាបែបនេះគឺជាការពិចារណាដែលជាប់ពាក់ព័ន្ធនោះទេ។ ដោយសារសំណើរបស់ នួន ជា សុំឱ្យកោះហៅ ហេង សំរិន មកធ្វើជាសាក្សីអត្តចរិតតែម្នាក់គត់របស់គាត់នោះ ត្រូវបានធ្វើឡើងនៅក្នុងខែ កុម្ភៈ ឆ្នាំ ២០១៣ មុនពេលបន្តិចនៃការបញ្ចប់សវនាការ ហើយចៅក្រមកម្ពុជាបានពន្យល់អំពីមូលហេតុរបស់ពួកគាត់ចំពោះការសង្ស័យទៅលើភាពពាក់ព័ន្ធនៃសក្ខីកម្មរបស់ ហេង សំរិន ទៅនឹងអត្តចរិតរបស់ នួន ជា នោះ មិនមានមូលដ្ឋានដែលបង្ហាញថា អ្នកសង្កេតការណ៍មិនលម្អៀងយល់ថាមានភាពលម្អៀងចេញពីការលើកឡើងរបស់ចៅក្រមកម្ពុជានោះទេ។

---

278 សេចក្តីសម្រេចស្តាពរស្តីពីសាក្សី កថាខណ្ឌ ៩៨។

279 សេចក្តីសម្រេចស្តាពរស្តីពីសាក្សី កថាខណ្ឌ ១១៧។

280 សេចក្តីសម្រេចស្តាពរស្តីពីសាក្សី កថាខណ្ឌ ១១៨។

១១៣. ចៅក្រមកម្ពុជាមិនបានកំណត់ជាមុនថាតើត្រូវកោះហៅ ហេង សំរិន ឬ អ៊ុក ប៊ុនឈឿន ឱ្យមកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២ ឬអត់នោះទេ។ ផ្ទុយទៅវិញ យោបល់របស់ចៅក្រមកម្ពុជាសំដៅទៅតែសំណុំរឿង ០០២/០១ ប៉ុណ្ណោះ។ ជាឧទាហរណ៍ ចៅក្រមបានបង្ហាញយោបល់ថាសក្ខីកម្មរបស់ ហេង សំរិន ដែលបានស្នើឡើងអំពីតួនាទីរបស់ប្រទេសវៀតណាម "មិនពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ នោះទេ"[281] ហើយថា សក្ខីកម្មរបស់ អ៊ុក ប៊ុនឈឿន អំពីជម្លោះរវាងភូមិភាគបូព៌ា និងមជ្ឈិមបក្សនៅចុងទសវត្សរ៍ឆ្នាំ ១៩៧០ មាន "សារៈសំខាន់តិចតួចចំពោះបញ្ហានៅក្នុងសំណុំរឿង ០០២/០១"[282]។ តាមពិតទៅ បណ្តឹងជំទាស់របស់ នួន ជា សង្កត់ធ្ងន់ទៅលើសារៈសំខាន់យ៉ាងខ្លាំងនៃបញ្ហាទាំងនេះចំពោះសំណុំរឿង ០០២/០២[283]។ ចៅក្រមកម្ពុជាមិនបានកំណត់ជាមុនទៅលើភាពពាក់ព័ន្ធ ឬសារៈសំខាន់នៃសក្ខីកម្មរបស់ ហេង សំរិន ឬ អ៊ុក ប៊ុនឈឿន ចំពោះបញ្ហាដែលត្រូវជំនុំ-ជម្រះនៅក្នុងសំណុំរឿង ០០២/០២ នោះទេ រួមទាំងការជាប់ទងនឹងអត្តចរិតរបស់ នួន ជា ផង ដោយសារថា គាត់មានសិទ្ធិបញ្ចុះបញ្ចូលចៅក្រមកម្ពុជាឱ្យជឿជាក់ថា មានមូលហេតុជាច្រើនដែលថាសំណើសុំនេះត្រូវបានធ្វើឡើងក្នុងពេលមួយសមស្រប ហើយពិតជាជួយដល់ការការពារក្តីរបស់គាត់នៅក្នុងសំណុំរឿង ០០២/០២។

១១៤. ដោយសារតែមិនមានមូលដ្ឋានក្នុងការសន្និដ្ឋានថា ការបដិសេធរបស់ចៅក្រមកម្ពុជាមិនព្រមកោះហៅ ហេង សំរិន "នាំឱ្យបាត់បង់នូវឯករាជ្យភាព ឬលេចឡើងនូវភាពលំអៀង" នោះ មិនចាំបាច់ត្រូវដោះស្រាយទៅលើការសន្និដ្ឋានរបស់ នួន ជា ដែលពាក់ព័ន្ធទៅនឹងការចោទប្រកាន់ពីកង្វះឯករាជ្យភាពរបស់តុលាការជាទូទៅនៅក្នុងប្រទេសកម្ពុជានោះទេ។ ទោះជាយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា បណ្តឹងជំទាស់ដែលមានគោលដៅចំពោះចៅក្រមម្នាក់ៗ មិនមែនជាយន្តការសមស្របក្នុងការដោះស្រាយកង្វះខាតដែលបានសន្មតក្នុងប្រព័ន្ធច្បាប់កម្ពុជាទាំងមូលនោះទេ[284]។

១១៥. ចុងក្រោយ នួន ជា បានវាយប្រហារទៅលើ "សុចរិតភាពផ្នែកសីលធម៌តុលាការ" របស់ចៅក្រម LAVERNGE ដោយសំអាងថា ការខកខានក្នុងការកោះហៅ ហេង សំរិន គួរនាំឱ្យគាត់

---

[281] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី កថាខណ្ឌ ៩៣។

[282] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី កថាខណ្ឌ ១០១។

[283] បណ្តឹងជំទាស់របស់ នួន ជា កថាខណ្ឌ ៤០។

[284] សេចក្តីសម្រេចលើបណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ សុំឱ្យដកហូតចៅក្រម សោម សិរីវុឌ្ឍ ដោយសារមិនមានឯករាជ្យភាព ឯកសារ , I/4 ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១ កថាខណ្ឌ ១៥។

សម្រេចដោះលែង នួន ជា តែម្តង[285]។ ប៉ុន្តែ នួន ជា មិនបានពន្យល់អំពីមូលដ្ឋានដែលនាំឱ្យមានការដោះលែងជាចាំបាច់នោះទេ។ គាត់បានអះអាងបន្ថែមទៀតថា ចៅក្រម LAVERNGE បាន "ធ្វើ-សេចក្តីសម្រេចយ៉ាងកំសាក" នៅពេលដែលគាត់មិនបញ្ចេញមតិយោបល់អំពីបញ្ហានៃភាពយុត្តិធម៌នៃកិច្ចដំណើរការក្នុងការជំនុំជម្រះ ដែលចៅក្រមកម្ពុជាបានលើកឡើង[286]។ បញ្ហានៃភាពយុត្តិធម៌ ដែលចៅក្រមកម្ពុជាបានលើកឡើងគឺជាការវាយតម្លៃអំពីកំណត់ត្រានៃកិច្ចសម្ភាសន៍របស់ Ben KIERNAN ជាមួយ ហេង សំរិន ដែល នួន ជា បានយកមកសំអាង[287]។ ពាក់ព័ន្ធនឹងកំណត់ត្រានៃកិច្ចសម្ភាសន៍ទាំងស្រុងដែល នួន ជា បានយកមកធ្វើជាមូលដ្ឋានសម្រាប់ការសន្និដ្ឋានរបស់គាត់នោះ ចៅក្រមកម្ពុជាបានបង្ហាញយោបល់ថា មិនគួរឱ្យជឿជាក់បានថា សក្ខីកម្មរបស់ ហេង សំរិន ពិតជាអាចមានប្រយោជន៍ធំធេងដល់ការការពារក្តីរបស់ នួន ជា នៅក្នុងសំណុំរឿង ០០២/០១ នោះទេ[288]។ ចៅក្រម LAVERNGE បានបដិសេធមិនបញ្ចេញយោបល់ទៅលើការវាយតម្លៃនេះ ក៏ដូចជាទៅលើសិទ្ធិរបស់គាត់ក្នុងនាមជាចៅក្រមឯករាជ្យមួយរូបនោះ។ មិនអាចមានការទាញសេចក្តីសន្និដ្ឋានណាមួយអំពីភាពមិនត្រឹមត្រូវដែលអាចឱ្យអ្នកសង្កេតការណ៍មិនលម្អៀងចោទសួរទៅលើសុចរិតភាពរបស់ចៅក្រម LAVERNGE ហើយផ្អែកទៅលើចំណុចនេះ លើកឡើងថាមានការលេចឡើងនូវភាពលម្អៀងនោះទេ។ ហេតុដូច្នេះ ការជំទាស់តវ៉ារបស់ នួន ជា ចំពោះចៅក្រម LAVERNGE ត្រូវបានបដិសេធចោល។

## (៦) ការចោទប្រកាន់អំពីភាពលម្អៀង ដោយផ្អែកទៅលើផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ចៅក្រមកម្ពុជា

១១៦. នួន ជា ស្នើសុំឱ្យដកចៅក្រមកម្ពុជាទាំងអស់ចេញពីកិច្ចដំណើរការនីតិវិធីនាថ្ងៃខាងមុខប្រឆាំងនឹងរូបគាត់ ដោយសំអាងថា ចៅក្រមទាំងនោះធ្លាប់បានរស់នៅឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យ និងប្រតិកម្មរបស់ពួកគាត់នៅក្នុងអំឡុងពេលសវនាការលើសំណុំរឿង ០០២/០១។ គាត់ផ្អែកទៅលើការលើកឡើងជាសាធារណៈរបស់ចៅក្រម CARTWRIGHT នៅឯវិទ្យាសាស្ថាន Aspen ដើម្បីជំទាស់ថា ចៅក្រមកម្ពុជាដែលបានចូលរួមពាក់ព័ន្ធនឹងសាលក្រមសុំណុំរឿង ០០២/០១ មានផលប្រយោជន៍

---

[285] បណ្តឹងជំទាស់ចិត្តរបស់ នួន ជា កថាខណ្ឌ ១៣២-១៣៣។

[286] បណ្តឹងជំទាស់ចិត្តរបស់ នួន ជា កថាខណ្ឌ ១៣២។

[287] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី កថាខណ្ឌ ៩៨។

[288] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី កថាខណ្ឌ ៩៨។

ផ្ទាល់ខ្លួនប្រឆាំងនឹងរូបគាត់។ គាត់លើកឡើងថា ចៅក្រម CARTWRIGHT បានលើកឡើងថា ចៅក្រមកម្ពុជាម្នាក់ធ្លាប់ត្រូវបានចាប់ខ្លួនដោយមានការភាន់ច្រឡំថាជាទាហាន លន់ នល់ នៅពេលមានការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញ ប៉ុន្តែ ក្រោយមកត្រូវបានដោះលែងវិញ ហើយថា គាត់ធ្លាប់បានធ្វើការងារនៅការដ្ឋានលើកទំនប់មួយកន្លែង ដែលក្រោយមក ប្រធានការដ្ឋាននេះត្រូវបានសម្លាប់ចោលនៅមន្ទីរសន្តិសុខ ស-២១ និងធ្លាប់បានរៀបអាពាហ៍ដែលត្រូវបានគេរៀបចំឱ្យ។ នួន ជា អះអាងបន្ថែមទៀតថា ចៅក្រម CARTWRIGHT បានលើកឡើងថា ចៅក្រមកម្ពុជាម្នាក់ទៀត ក្នុងចំណោមចៅក្រមកម្ពុជាទាំងអស់ ត្រូវបានគេបញ្ជូនឱ្យទៅធ្វើការងារនៅក្នុងកងកុមារនៅក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ[289]។

១១៧. នួន ជា មិនបានផ្តល់ប្រតិចារិកជាភាសាខ្មែរ ឬភាសាអង់គ្លេស នៃមតិយោបល់ដែលគាត់យកមកធ្វើជាសំអាងនោះទេ។ ប៉ុន្តែ បណ្តឹងជំទាស់ចិត្តរបស់ នួន ជា បានទទួលស្គាល់ថា ការដែលចៅក្រមកម្ពុជាធ្លាប់បានឆ្លងកាត់បទពិសោធន៍ដោយផ្ទាល់លើបញ្ហានានាដែលត្រូវវិនិច្ឆ័យក្នុងសំណុំរឿង ០០២ នោះ ពុំបណ្តាលឱ្យមានការប្តឹងជំទាស់ចិត្តដោយស្វ័យប្រវត្តិនោះទេ[290]។ ផ្ទុយទៅវិញ គាត់បានលើកឡើងថា ក្រោយពីបានពិនិត្យមើលឡើងវិញទៅលើសាលក្រមសំណុំរឿង ០០២/០១ និងសេចក្តីសម្រេចស្តាពរស្តីពីសាក្សី គាត់ "ត្រូវធ្វើការសន្និដ្ឋានដោយបង្ខំចិត្ត" ថា ចៅក្រមកម្ពុជាមិនអាចបំពេញភារកិច្ចរបស់ខ្លួនដោយអព្យាក្រឹតបានទេ[291]។ គាត់បានលើកឡើងចំណុចដូចតទៅនេះ ដើម្បីបង្ហាញពីភាពមិនលម្អៀងរបស់ចៅក្រមកម្ពុជា៖ (i) ការប្រើប្រាស់ពាក្យបច្ចេកទេសនៅក្នុងសាលក្រមសំណុំរឿង ០០២/០១ (ii) ការច្រានចោលការសន្និដ្ឋានរបស់គាត់ទាក់ទងនឹងការបែកបាក់ផ្ទៃក្នុងបក្សកុម្មុយនីស្តកម្ពុជា (iii) ការយល់ឃើញខុសទៅលើអត្ថិភាពនៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាស្តីពីការដាក់បទបញ្ជាទាក់ទងនឹងអាពាហ៍ពិពាហ៍ (iv) សំអាងហេតុមិនសមស្របទាក់ទងនឹងភ័ស្តុតាងស្តីពីប្រជាសាស្ត្រ និង (v) ការលើកយោងមិនសមហេតុផលចំពោះសាលក្រមសំណុំរឿង ០០១ ដើម្បីកំណត់និយមន័យនៃពាក្យថា "កម្ទេច"[292]។ បញ្ហានីមួយក្នុងចំណោមបញ្ហាទាំងនេះត្រូវបានពិចារណាលម្អិតដូចបង្ហាញខាងលើ និងត្រូវបានបដិសេធចោល។ អាស្រ័យហេតុនេះ មិនមានមូលដ្ឋានក្នុងការលើកឡើងថា វិធីសាស្ត្រ

[289] បណ្តឹងជំទាស់ចិត្តរបស់ នួន ជា កថាខណ្ឌ ៥៣។

[290] បណ្តឹងជំទាស់ចិត្តរបស់ នួន ជា កថាខណ្ឌ ៥៤។

[291] បណ្តឹងជំទាស់ចិត្តរបស់ នួន ជា កថាខណ្ឌ ៥៥។

[292] បណ្តឹងជំទាស់ចិត្តរបស់ នួន ជា កថាខណ្ឌ ៥៥។

របស់ចៅក្រមកម្ពុជាចំពោះបញ្ហាទាំងនេះបង្ហាញថា ពួកគាត់បំពេញភារកិច្ចរបស់ខ្លួនដោយលម្អៀងនោះទេ។

១១៨. នួន ជា បានដកស្រង់ចេញពីរឿងក្ដីរបស់ *Eichmann* និងបានលើកឧទាហរណ៍ពីចៅក្រម Jaranilla នៅក្នុងអំឡុងនៃកិច្ចដំណើរការនីតិវិធីនៅឯតុលាការយោធាអន្តរជាតិទីក្រុងតូក្យូ ដែលបាន "ដកខ្លួនចេញពីសវនាការពិនិត្យភ័ស្តុតាងទាក់ទងនឹងព្រឹត្តិការណ៍ទាំងឡាយពាក់ព័ន្ធនឹងបញ្ហាដំណើរឆ្ពោះទៅកាន់សេចក្ដីស្លាប់ (Bataan death march) ដែលជាព្រឹត្តិការណ៍នៃការផ្លាស់ទីដោយបង្ខំ ដែលគាត់ជាជនរងគ្រោះមួយរូប"[293]។ ទោះជាយ៉ាងណាក៏ដោយ ការដកស្រង់របស់ នួន ជា ចេញពីរឿងក្ដីរបស់ *Eichmann* គឺជាការជ្រើសរើសមិនត្រូមត្រូវ។ គាត់គួរលើកឡើងផងដែរពីការសម្រេចសេចក្ដីទាំង-ស្រុងរបស់ចៅក្រមជំនុំជម្រះក្នុងរឿងក្ដីនោះដែលបានបដិសេធបណ្ដឹងជំទាស់ចំពោះចៅក្រមទាំងឡាយដោយសារថាចៅក្រមទាំងនោះគឺជាបុត្រារបស់ប្រជាជនជ្វីប (Jewish) និងជាប្រជាពលរដ្ឋនៃប្រទេសអ៊ីស្រាអែល។

> ទាក់ទងនឹងទឡ្ហីករណ៍នៃការប្ដឹងជំទាស់នេះ បណ្ឌិត Servatius មានប្រសាសន៍ថា ជនជាប់ចោទមានការបារម្ភយ៉ាងខ្លាំងថា ចៅក្រមទាំងនោះមិនអាចជំនុំជម្រះលើរឿងក្ដីនេះដោយឥតលម្អៀងបានទេ។ ការបារម្ភនេះមិនមែនចំពោះចៅក្រមណាម្នាក់ពិតប្រាកដនោះទេ ប៉ុន្តែចំពោះចៅក្រមទាំងបីរូបបានអះអាងថា ពួកគាត់ជាបុត្រារបស់ប្រជាជនជ្វីប និងជាប្រជាពលរដ្ឋរបស់ប្រទេសអ៊ីស្រាអែល។ មានមូលដ្ឋានសម្រាប់ការយល់ឃើញដូចនេះ ហេតុដូច្នេះ មេធាវីការពារក្ដីជំទាស់ថា ការចងចាំអំពីហាយនភាព (Holocaust) ដែលក្នុងនោះប្រជាជនរាប់លាននាក់ត្រូវបានកម្ទេចចោល ហើយហាយនភាពដែលជាសាវតារនៃឧក្រិដ្ឋកម្មទាំងឡាយដែលមាននៅក្នុងដីកាដំណោះស្រាយបញ្ជូនជនជាប់ចោទទៅជំនុំជម្រះនឹងធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានដល់ភាពអនាគតិរបស់ចៅក្រម និងលទ្ធភាពរបស់ពួកគាត់ក្នុងការស្វែងរកយុត្តិធម៌។ គាត់ក៏បានស្នើសុំចៅក្រមម្នាក់ៗក្នុងចំណោមចៅក្រមទាំងនោះ សួរខ្លួនឯង ថាតើការឈឺចាប់ផ្ទាល់ខ្លួនគាត់ ឬរបស់សមាជិកគ្រួសាររបស់គាត់នៅក្នុងរយៈពេលប៉ុន្មានឆ្នាំនៃអំពើឃោរឃៅនោះ ធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពរបស់គាត់ក្នុងការវិនិច្ឆ័យជនជាប់ចោទនៅក្នុងរឿងក្ដីនេះដែរ ឬទេ។
>
> ចំពោះទឡ្ហីករណ៍នេះ យើងឆ្លើយតបទៅវិញថា៖ កម្មវត្ថុនៃបទចោទនានានៅក្នុងរឿងក្ដីនេះ គឺជាការទទួលខុសត្រូវរបស់ជនជាប់ចោទចំពោះអំពើដូចដែលបានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅ-ជំនុំជម្រះ។ ក្នុងការពិនិត្យទៅលើបញ្ហានេះ វានឹងមិនមានអ្វីពិបាកសម្រាប់យើងក្នុងការរក្សា

---

[293] បណ្ដឹងជំទាស់របស់ នួន ជា កថាខណ្ឌ ៥៤, ៥៦។

ការធានាដល់ជនជាប់ចោទនៅក្នុងរឿងក្ដីទាំងអស់ ដែលត្រូវបានដំណើរការស្របតាមនីតិវិធីច្បាប់ព្រហ្មទណ្ឌរបស់យើង ដែលថា ជនគ្រប់រូបត្រូវទទួលបានការសន្មតទុកជាមុនថាគ្មានទោស ហើយរឿងក្ដីរបស់ខ្លួនត្រូវបានទទួលបានការជំនុំជម្រះដោយផ្អែកតែទៅលើភស្តុតាងដែលបានដាក់ជូននៅចំពោះមុខតុលាការ។ អ្នកដែលទទួលភារកិច្ចក្នុងការវិនិច្ឆ័យក្ដី ត្រូវតែជាចៅក្រមវិជ្ជាជីវៈ ដែលធ្លាប់មានបទពិសោធន៍ក្នុងការថ្លឹងថ្លែងភស្តុតាង ហើយពួកគាត់ត្រូវបំពេញភារកិច្ចរបស់ខ្លួន នៅក្រោមក្រសែភ្នែកសម្លឹងយ៉ាងយកចិត្តទុកដាក់ពីសំណាក់សាធារណជន ហើយមេធាវីការពារក្ដី ដែលមានចំណេះដឹង និងបទពិសោធន៍ជ្រៅជ្រះ កំពុងធ្វើជាអ្នកការពារក្ដីឱ្យជនជាប់ចោទ។

ចំពោះការព្រួយបារម្ភរបស់ជនជាប់ចោទពាក់ព័ន្ធនឹងសាវតារដែលត្រូវយកមកពិនិត្យនៅក្នុងការជំនុំជម្រះ យើងគ្រាន់តែអាចលើកឡើងវិញអំពីគោលការណ៍ដែលអនុវត្តនៅគ្រប់ប្រព័ន្ធតុលាការដែលមានកេរ្ដិ៍ឈ្មោះល្បីល្បាញតែប៉ុណ្ណោះ។ ជាការពិត នៅពេលធ្វើការជំនុំជម្រះ ចៅក្រមមិនអាចកាត់ផ្ដាច់សាច់ឈាមជាមនុស្ស មិនអាចជៀសផុតពីការរំជួលចិត្ត និងសន្ទុះផ្លូវចិត្តបានទេ។ ប៉ុន្តែ ច្បាប់តម្រូវឱ្យគាត់ត្រូវតែចេះគ្រប់គ្រងលើការរំជួលចិត្ត និងសន្ទុះផ្លូវចិត្តទាំងនេះ បើមិនដូច្នេះទេ ចៅក្រមនឹងមិនមានសម្បទាក្នុងការពិចារណាទៅលើការចោទប្រកាន់ពីបទព្រហ្មទណ្ឌដែលធ្វើឱ្យមានអារម្មណ៍ស្អប់ខ្ពើម ដូចជា អំពើក្បត់ជាតិ អំពើមនុស្សឃាត ឬឧក្រិដ្ឋកម្មធ្ងន់ធ្ងរដទៃទៀតឡើយ។ ជាការពិត ការចងចាំអំពីហាយនភាពនេះ ធ្វើឱ្យមានអារម្មណ៍រន្ធត់មកលើគ្រប់ជនជាតិជ្វីបដល់ទីជម្រៅរបស់ខ្លួន ប៉ុន្តែ នៅពេលដែលរឿងក្ដីនេះត្រូវបានដាក់នៅចំពោះមុខយើង នោះយើងមានកាតព្វកិច្ចត្រូវតែជំនះលើការរំជួលចិត្តទាំងនេះ នៅពេលធ្វើការជំនុំជម្រះលើរឿងក្ដីនេះ។ យើងត្រូវតែបំពេញកាតព្វកិច្ចនេះឱ្យបាន[294]។

១១៩. ចំពោះការលើកឡើងពីករណីចៅក្រម Jaranilla ក៏មិនគួរឱ្យជឿជាក់បានដែរ។ នួន ជា លើកឡើងថា ចៅក្រមរូបនេះបានដកខ្លួនចេញពីសវនាការពិនិត្យភស្តុតាងទាក់ទងនឹងព្រឹត្តិការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងដំណើរឆ្ពោះទៅកាន់សេចក្ដីស្លាប់ ដែលជាការផ្លាស់ទីដោយបង្ខំ ហើយគាត់គឺជាជនរងគ្រោះម្នាក់។ ប៉ុន្តែ នួន ជា មិនបានលើកថា ចៅក្រម Jaranilla ត្រូវបាន ឬគួរត្រូវបានដកចេញពីកិច្ចដំណើរការនីតិវិធីជំនុំជម្រះទាំងអស់នោះទេ។

[294] តុលាការក្រុង Jerusalem ប្រទេសអ៊ីស្រាអែល ទល់នឹង Adolf Eichmann Aff 40/61 វគ្គទី ៦ 1 Iyar 5721 (ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៦១) សេចក្ដីសម្រេចលេខ ៣។

១២០. នួន ជា បានធ្វើការសន្និដ្ឋានបន្ថែមទៀត ដោយសំអាងទៅលើអត្ថបទសិក្សាស្រាវជ្រាវដែលថា នៅក្នុងការជ្រើសរើសចៅក្រមលើកដំបូងនៅតុលាការ ICTY បេក្ខជនជ្រើសតាំងដោយប្រទេសសូវៀតពុំត្រូវបានតែងតាំងនោះទេ ព្រោះមានការភ័យខ្លាចថា ចៅក្រមរូបនេះនឹងលម្អៀង[295]។ នួន ជា មិនបានលើកឡើងថា នៅពេលនេះមានចៅក្រមជនជាតិរុស្ស៊ីម្នាក់នៅឯតុលាការ ICTY នោះទេ។ ក្នុងរឿងក្ដី *Martić* អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានបញ្ជាក់ថា ចៅក្រមអាចត្រូវបានចាត់ទុកថាមិនលម្អៀងបាន ទោះបីជាចៅក្រមរូបនោះត្រូវបានស្នើសុំឱ្យពិចារណាទៅលើអំពើរបស់រដ្ឋដែលចៅក្រមរូបនោះមានសញ្ជាតិក្នុងរដ្ឋនោះក៏ដោយ[296]។ នៅក្នុងរឿងក្ដី *Šešelj* តុលាការ ICTY បានសម្រេចថា សញ្ជាតិ និងសាសនារបស់ចៅក្រម មិនជាប់ពាក់ព័ន្ធ និងមិនត្រូវជាប់ពាក់ព័ន្ធទៅនឹងលទ្ធភាពរបស់ចៅក្រមក្នុងការជំនុំជម្រះរឿងក្ដីនានានៅចំពោះមុខពួកគាត់ដោយមិនលម្អៀងនោះទេ[297]។ ហេតុដូច្នេះ ការសន្និដ្ឋានរបស់ នួន ជា ថា ចៅក្រមកម្ពុជាពិតជាលម្អៀង ឬធ្វើឱ្យអ្នកសង្កេតការណ៍មិនលម្អៀងជឿជាក់ថាមានភាពលម្អៀងនោះ ត្រូវបានបដិសេធចោល។

ភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥

ចៅក្រម **ធូ មណី**

ចៅក្រម **CHANG-ho CHUNG** ចៅក្រម **ហួត វុទ្ធី** ចៅក្រម **ឡាក់ គឹមសាន**

[295] បណ្ដឹងមិនចិត្តរបស់ នួន ជា កថាខណ្ឌ ៥៨។

[296] *រដ្ឋអាជ្ញា តទល់នឹង Martić* អនុប្រធានតុលាការ ICTY សំណុំរឿងលេខ IT-95-11-A ដីកាសម្រេចទៅលើសំណើរបស់មេធាវីការពារក្ដីសុំមិនចិត្តចៅក្រម Wolfgang Schomburg មិនឱ្យជំនុំជម្រះបណ្ដឹងសាទុក្ខ ឧបសម្ព័ន្ធ របាយការណ៍ដាក់ជូនអនុប្រធានតុលាការ ICTY ដោយអនុលោមតាម វិធាន ១៥(ខ)(ii) ពាក់ព័ន្ធនឹងបណ្ដឹងមិនចិត្តរបស់មេធាវីការពារក្ដីសុំឱ្យដកហូតចៅក្រម Schomburg ចេញពីការជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៧។

[297] *រដ្ឋអាជ្ញា តទល់នឹង Šešelj* ការិយាល័យតុលាការ ICTY សំណុំរឿងលេខ IT-03-67-PT, សាលដីកាសម្រេចលើបណ្ដឹងមិនចិត្ត ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៣ កថាខណ្ឌ ៣។

## មតិដោយឡែករបស់ចៅក្រម ជូ មណី

១. ក្នុងនាមជាប្រធានក្រុមប្រឹក្សាជំនុំជម្រះពិសេសដែលតែងតាំងឡើងដើម្បីសម្រេចទៅលើបណ្តឹងជិតចិត្ត ខ្ញុំសូមកត់សំគាល់ថា ចៅក្រម DOWNING បានបដិសេធមិនព្រមផ្តល់មតិដោយឡែករបស់គាត់ ដូចដែលមាននៅក្នុងសំអាងហេតុនៃសេចក្តីសម្រេចនេះទេ។ ហេតុដូច្នេះ រូបខ្ញុំ មិនបានអាននូវសំអាងហេតុនៃការខ្វែងយោបល់របស់ចៅក្រម DOWNING ដូចដែលមានភ្ជាប់មកជាមួយនេះឡើយ។

២. ខ្ញុំយល់ឃើញថា ផលប្រយោជន៍នៃយុត្តិធម៌នឹងមានភាពល្អប្រសើរជាងនេះ ប្រសិនបើចៅក្រមមួយរូបចែករំលែកសំអាងហេតុជាលាយលក្ខណ៍អក្សររបស់ខ្លួនជាមួយសហការីមុនពេលចេញផ្សាយ។ ការផ្តល់ជូនឱ្យគ្នាទៅវិញទៅមកនូវសំអាងហេតុផ្សេងគ្នាអនុញ្ញាតចៅក្រមដែលយល់ឃើញខុសគ្នាមានលទ្ធភាពបញ្ជាក់នូវភាពខុសគ្នាទាំងនោះបានត្រឹមត្រូវ ដែលករណីនេះអាចជួយដល់អ្នកអានឱ្យយល់ដឹងអំពីសេចក្តីសម្រេចនោះបានល្អប្រសើរ។ ជាងនេះទៀត វាអាចមានករណីដែលចៅក្រមមួយរូបយល់ខុស ឬកំណត់ខុសទៅលើវិធីសាស្ត្ររបស់ចៅក្រមមួយរូបទៀត ដែលអាចបណ្តាលមកពីការភាន់ច្រឡំ ឬដោយសារតែបញ្ហាភាសានៃមតិយោបល់របស់ចៅក្រមនោះ ដែលគួរសរសេរឱ្យបានច្បាស់លាស់ជាងនេះ។ ហានិភ័យនេះកាន់តែមានកម្រិតខ្ពស់នៅក្នុងតុលាការដែលប្រើប្រាស់ពហុភាសា តាមរយៈការបកប្រែ។ ហានិភ័យបែបនេះ តាមយោបល់របស់ខ្ញុំ គឺគួរតែអាចកាត់បន្ថយទៅបានឱ្យអស់ពីលទ្ធភាពពីសំណាក់ចៅក្រម។ នៅក្នុងករណីនេះ ជំហរគួរឱ្យសោកស្តាយនេះ គឺថាខ្ញុំពុំបានឃើញជាមុននូវសំអាងហេតុពេញលេញរបស់លោកចៅក្រម DOWNING ឡើយ។

ភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥

ចៅក្រម **ជូ មណី**

# មតិជំទាស់មួយផ្នែករបស់ចៅក្រម Rowan DOWNING

## I. សេចក្ដីផ្ដើម

1. ខ្ញុំបានអានសំអាងហេតុចំពោះសេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចិត្តរបស់ចៅក្រមភាគច្រើន ដែលជាសមាជិកនៃក្រុមប្រឹក្សាជំនុំជម្រះពិសេស ("ចៅក្រមភាគច្រើន")។ ខ្ញុំយល់ស្របជាមួយនឹងចៅក្រមភាគច្រើនពាក់ព័ន្ធនឹងសេចក្ដីសន្និដ្ឋានទាំងអស់លើកលែងតែត្រង់សេចក្ដីសន្និដ្ឋានច្រានចោលបណ្ដឹងជំទាស់ចិត្តចៅក្រមប្រធាន និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc Lavergne និងចៅក្រម យូរ ឧត្តរា ចេញពីក្នុងសំណុំរឿង ០០២/០២ ដោយផ្អែកលើសំអាងហេតុមុនៗរបស់ពួកគាត់នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ចំពោះបញ្ហាអង្គហេតុទាក់ទងនឹងសំណុំរឿង ០០២/០២ (មូលដ្ឋាន ច នៃបណ្ដឹងជំទាស់ចិត្តរបស់ នួន ជា ដែលបានបញ្ចូលបណ្ដឹងជំទាស់ចិត្តសាជាថ្មីរបស់ ខៀវ សំផន)។ ខ្ញុំយល់ឃើញ អង្គជំនុំជម្រះសាលាដំបូងមានសំអាងហេតុនៅក្នុងសាលក្រមសំណុំរឿង ០០២/០១ លើបញ្ហាសំខាន់ៗចំពោះមុខមួយចំនួនសម្រាប់ធ្វើការសម្រេចនៅក្នុងសំណុំរឿង ០០២/០២។ សំអាងហេតុទាំងនេះមានអានុភាពបង្ហាញពីការសន្មតនូវការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ នួន ជា និង ខៀវ សំផន ចំពោះឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០២។ ខ្ញុំពិចារណាឃើញថា សំអាងហេតុទាំងនេះគឺជាមូលដ្ឋានក្នុងការសន្និដ្ឋានថា អ្នកសង្កេតការណ៍ដោយមិនលម្អៀង ដែលបានទទួលព័ត៌មានត្រឹមត្រូវនឹងមើលឃើញយ៉ាងសមហេតុផលនូវភាពលម្អៀងរបស់ចៅក្រម ដែលត្រូវបានប្ដឹងជំទាស់ចិត្តនៅក្នុងសំណុំរឿង ០០២/០២។

2. ខ្ញុំយល់ឃើញថា បណ្ដឹងរបស់ ខៀវ សំផន ប្ដឹងជំទាស់ចិត្តចៅក្រម Claudia FENZ គ្មានមូលដ្ឋានដោយហេតុថា ការចូលរួមរបស់លោកស្រីចៅក្រមក្នុងនាមជាចៅក្រមជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ មានចំនួនតិចតួច ហើយសេចក្ដីសម្រេចនានាដែលលោកស្រីចៅក្រមធ្វើឡើងពាក់ព័ន្ធតែបញ្ហានីតិវិធីតែប៉ុណ្ណោះ។ នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី និងការពិភាក្សាសម្រេចក្នុងសំណុំរឿង ០០២/០១ ចៅក្រម FENZ គឺជាចៅក្រមបម្រុងនៃអង្គជំនុំជម្រះសាលាដំបូង។ អនុលោមតាមវិធាន ៧៩(៣) នៃវិធានផ្ទៃក្នុង ចៅក្រមបម្រុង "មិនមានសិទ្ធិក្នុងការបញ្ចេញទស្សនៈ ឬសម្រេចអ្វីមួយឡើយ លើកលែងតែ និងរហូតដល់ពេល ដែលត្រូវបានតែងតាំងឱ្យជំនួស

ចៅក្រមពេញសិទ្ធិណាម្នាក់"។ ខៀវ សំផន ពុំបានផ្តល់មូលដ្ឋានថាតើអ្នកសង្កេតការណ៍ដោយមិនលម្អៀង ដែលបានទទួលព័ត៌មានត្រឹមត្រូវ នឹងយល់ឃើញថា ចៅក្រមបម្រុងដែលនឹងចូលរួមជំនុំជម្រះនៅក្នុងរឿងក្តីក្រោយពាក់ព័ន្ធនឹងជនជាប់ចោទដដែលមានភាពលម្អៀងយ៉ាងដូចម្តេច នៅពេលដែលចៅក្រមរូបនេះពុំបានចូលរួម នៅក្នុងការពិភាក្សាសម្រេចរបស់ចៅក្រមលើសេចក្តីសម្រេចក្នុងសាលក្រមប្រឆាំងនឹងជនជាប់ចោទផងនោះ។ ខ្ញុំយល់ឃើញថា ការចូលរួមរបស់លោកស្រីចៅក្រមនៅក្នុងសំណុំរឿង ០០២/០១ មាន*ចំនួនតិចតួច (de minimis)* ជាហេតុពុំបណ្តាលឱ្យឃើញមានភាពលម្អៀងនោះឡើយ។ អាស្រ័យហេតុនេះ ខ្ញុំសូមច្រានចោលបណ្តឹងជំទាស់ដោយសារការយល់ឃើញថាមិនមិនស្តីរបស់ ខៀវ សំផន ត្រង់ផ្នែកដែលពាក់ព័ន្ធនឹងចៅក្រម FENZ។

3. ជាបឋម ខ្ញុំសូមគូសបញ្ជាក់ថា ដោយសារមានការបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២ កាលៈទេសៈនៃរឿងក្តីបច្ចុប្បន្នមានលក្ខណៈពិសេស។ នេះជាលើកទីមួយនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ ដែលចៅក្រមត្រូវបានឱ្យវិនិច្ឆ័យលើរឿងក្តីពីរដោយឡែកពីគ្នា ដែលកើតចេញពីដីកាបញ្ជូនរឿងទៅជំនុំជម្រះតែមួយប្រឆាំងនឹងជនជាប់ចោទដដែល។ ទោះបីជាសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២ ទាក់ទងនឹងប្រធានបទខុសគ្នាក៏ដោយ ក៏មានអង្គហេតុជាន់គ្នាច្រើន។ នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ចៅក្រមដែលត្រូវបានប្តឹងជំទាស់បានសម្រេចហួសពីវិមតិសង្ស័យលើអង្គហេតុមួយចំនួន ដែលម្ចាស់បណ្តឹងជំទាស់អះអាងថា អង្គហេតុទាំងនេះ គឺមានសារសំខាន់ជាសារវ័ន្តចំពោះការសម្រេចលើការទទួលខុសត្រូវដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទនៅក្នុងសំណុំរឿង ០០២/០២។ បញ្ហាចោទដែលត្រូវដោះស្រាយនាពេលនេះ គឺថាតើការសម្រេចរបស់ចៅក្រមទាំងនោះនៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ចំពោះអង្គហេតុទាក់ទងនឹងការទទួលខុសត្រូវរបស់ជនជាប់ចោទក្នុងសំណុំរឿង ០០២/០២ ទាក់ទងនឹងភាគីដដែល នឹងនាំឱ្យអ្នកសង្កេតការណ៍ដោយមិនលម្អៀង មើលឃើញនូវភាពលម្អៀងដែរឬទេ។ ខ្ញុំយល់ឃើញថា ចៅក្រមភាគច្រើន ដែលព្យាយាមសំអាងយ៉ាងតឹងរ៉ឹងលើយុត្តិសាស្ត្រនានាពីសាលាក្តីអន្តរជាតិដែលពុំពាក់ព័ន្ធដោយផ្ទាល់លើបញ្ហាដែលកំពុងពិនិត្យ បានមើលរំលងកាលៈទេសៈពិសេសរបស់រឿងក្តីបច្ចុប្បន្ននេះ។

## II. បរិបទ និងផលវិបាកនៃការបំបែកកិច្ចដំណើរការនីតិវិធី

4. នៅមុនពេលឆ្លើយតបទៅនឹងមូលដ្ឋាននៃទឡ្ហីករណ៍ដែលម្ចាស់បណ្តឹងមិនតចិត្តបានលើកឡើង ខ្ញុំនឹងរម្លឹកដោយសង្ខេបអំពីបរិបទ និងផលវិបាកផ្នែកនីតិវិធីកើតចេញពីការបំបែកកិច្ចដំណើរការនីតិវិធី ដែលខ្ញុំយល់ឃើញថា គឺជាមូលដ្ឋានក្នុងការសម្រេចលើបញ្ហានាពេលបច្ចុប្បន្ននេះ។

5. ដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០២ ត្រូវបានចេញនៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ដោយបានចោទប្រកាន់ជនជាប់ចោទលើបទល្មើសព្រហ្មទណ្ឌដែលត្រូវបានចោទប្រកាន់ថា កងទ័ពខ្មែរក្រហមបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ជនជាប់ចោទពុំត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយដែលត្រូវបានចោទប្រកាន់ដោយផ្ទាល់នោះទេ ប៉ុន្តែពួកគេត្រូវបានចោទប្រកាន់ថាជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការប្រព្រឹត្តទាំងនេះ ដោយសារតួនាទីរបស់ពួកគេនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ *ក្នុងចំណោមនោះ* គឺដោយសារការចូលរួមរបស់ពួកគេនៅក្នុងសហឧក្រិដ្ឋកម្មរួម។ ដីកាដំណោះស្រាយបានផ្អែកលើការអះអាងថា មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ("ប.ក.ក") មានផែនការរួម "ដើម្បីបង្កើតនៅក្នុងប្រទេសកម្ពុជានូវបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សតាមរយៈគ្រប់មធ្យោបាយចាំបាច់ "សន្ទុះមហាលោតផ្លោះ" និងដើម្បីការពារបក្សប្រឆាំងនឹងសត្រូវផ្ទៃក្នុង ក៏ដូចជាសត្រូវខាងក្រៅ"[1]។ ដើម្បីសម្រេចផែនការរួមនេះ មេដឹកនាំ ប.ក.ក ត្រូវបានចោទប្រកាន់ថាបានរៀបចំផែនការ និងអនុវត្តគោលនយោបាយចំនួន ៥ ខាងក្រោម៖

- ការផ្លាស់ទីលំនៅដែលធ្វើឡើងជាច្រើនលើកច្រើនសារទៅលើប្រជាជនចេញពីទីប្រជុំជនទៅកាន់ទីជនបទ និងពីទីជនបទមួយទៅកាន់ទីជនបទមួយផ្សេងទៀត។
- ការបង្កើត និងដំណើរការសហករណ៍ និងការដ្ឋាន។
- ការអប់រំ "សមាសភាពមិនល្អ" និង ការកម្ទេច "ខ្មាំង" ទាំងនៅក្នុង និងនៅក្រៅបក្ស។
- ការកំណត់គោលដៅចំពោះក្រុមមនុស្សជាក់លាក់នានា ដូចជា ជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិកជន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (រួមទាំងមន្ត្រីរាជការ អតីតបុគ្គលិកយោធា ព្រមទាំងក្រុមគ្រួសាររបស់ពួកគេ)។

---

[1] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៦។

- ការដាក់បទបញ្ជាទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍[2]។

ឧក្រិដ្ឋកម្មនីមួយៗដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឡើងដើម្បីសម្រេចគោលបំណងមួយក្នុងចំណោមគោលបំណងទាំង ៥ នេះ[3]។

6. នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ នៅមុនពេលបើកសវនាការដេញដោលភ័ស្តុតាងក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះសាលាដំបូងបានបំបែករឿងក្តីអនុលោមតាមវិធាន *៨៩ស្ទួនពីរ* ទៅជាការជំនុំជម្រះដោយឡែកពីគ្នា ដែលការជំនុំជម្រះនីមួយៗរួមមានផ្នែកជាក់លាក់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ការជំនុំជម្រះនីមួយៗមានគោលបំណងបញ្ចប់ដោយមានសាលក្រម និងការកំណត់ទោសប្រសិនបើរកឃើញថាមានពិរុទ្ធភាព[4]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ការជំនុំជម្រះលើកទីមួយ ពោលគឺ សំណុំរឿង ០០២/០១ នឹងកម្រិតត្រឹម៖ "ប្រវត្តិ និងរចនាសម្ព័ន្ធរបបកម្ពុជាប្រជាធិបតេយ្យ។ តួនាទីរបស់ជនជាប់ចោទម្នាក់ៗ នៅមុនពេលមានការបង្កើត និងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងនៅពេលជនជាប់ចោទម្នាក់ៗបានទទួលការចាត់តាំងនូវតួនាទីទាំងនេះ ការទទួលខុសត្រូវរបស់ពួកគេតាមការចាត់តាំង ក្របខណ្ឌនៃសិទ្ធិអំណាចរបស់ពួកគេ និងខ្សែបណ្តាញទាក់ទង ការផ្លាស់ទីលំនៅប្រជាជនពីក្រុងភ្នំពេញនៅក្នុងឆ្នាំ ១៩៧៥ (ដំណាក់កាលទី ១") ការផ្លាស់ទីលំនៅប្រជាជនពីភូមិភាគកណ្តាល (ឧត្តរចាស់) និរតី បស្ចិម និងបូព៌ាចាប់ពីខែ កញ្ញា ឆ្នាំ ១៩៧៥ រហូតដល់ ឆ្នាំ ១៩៧៧ (ដំណាក់កាលទី ២") និងប្រភេទទាំង ៥ នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ (លើកលែងតែដោយមូលហេតុសាសនា) ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ) ប៉ុន្តែកម្រិតត្រឹមការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី ១ និង ទី ២ តែប៉ុណ្ណោះ"[5]។ ក្រោយមក

---

[2] *ដូចខាងលើ* កថាខណ្ឌ ១៥៧។

[3] *ដូចខាងលើ* កថាខណ្ឌ ២២១-៨៦១។

[4] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ឯកសារ E124 ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ("ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយ") កថាខណ្ឌ ២, ៦។

[5] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូងនៅក្នុងសំណុំរឿង ០០២ ដែលបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលា

វិសាលភាពនៃសំណុំរឿង ០០២/០១ ត្រូវបានពង្រីកដាក់បញ្ចូលការកាប់សម្លាប់អតីតអ្នករដ្ឋការនៃរបបសាធារណៈខ្មែរនៅទួលពោធិ៍ជ្រៃថែមទៀត[6]។ ផ្នែកធំៗនៃដីកាដំណោះស្រាយត្រូវបានដាក់បញ្ចូលនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១[7]។ ភាគីបានលើកការតវ៉ាជាច្រើនប្រឆាំងនឹងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនេះ ហើយដីកានេះបានចូលជាស្ថាពរនៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣[8] នៅពេលបញ្ចប់សវនាការដេញដោលភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០១។

7. នៅថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានបំបែកផ្នែកសេសសល់នៅក្នុងសំណុំរឿង ០០២ ដោយបានសម្រេចបញ្ចូលទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ នូវបទចោទនានាដែលពាក់ព័ន្ធនឹង៖ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើជនជាតិចាម (និងការធ្វើទុក្ខបុកម្នេញផ្នែកសាសនាពាក់ព័ន្ធនានា នៅក្នុងពេលផ្លាស់ទីលំនៅដោយបង្ខំលើជនជាតិចាមភាគតិច) ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើជនជាតិវៀតណាម ការរៀបការដោយបង្ខំ និងការរំលោភសេពសន្ថវៈនៅទូទាំងប្រទេស ការបោសសម្អាតផ្ទៃក្នុង ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង មន្ទីរសន្តិសុខភ្នំក្រោល ការដ្ឋានទំនប់ ១ មករា ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ការដ្ឋានទំនប់ត្រពាំងថ្ម សហករណ៍ត្រាំកក់ ការប្រព្រឹត្តិលើពុទ្ធសាសនិកជន (ដែលកម្រិតត្រឹមសហករណ៍ត្រាំកក់) និងការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ/ការកំណត់គោលដៅលើ

---

ដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿងលេខ ០០២/០១ (E163) ឯកសារ E124/7.3 ("បញ្ជីកថាខណ្ឌពាក់ព័ន្ធនឹងសំណុំរឿង ០០២") (គូសបញ្ជាក់បន្ថែម)។

[6] សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម នៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163) និងពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន ឯកសារ E163/5 ចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២ ទំព័រ ១។

[7] បញ្ជីកថាខណ្ឌពាក់ព័ន្ធនឹងសំណុំរឿង ០០២។

[8] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ឯកសារ E284/4/8 ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣។

អតីតអ្នករដ្ឋការនៃរបបសាធារណៈរដ្ឋខ្មែរ (ការអនុវត្តកម្រិតត្រឹមសហករណ៍ត្រាំកក់ ការដ្ឋានទំនប់ ១ មករា មន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់តែប៉ុណ្ណោះ)[9]។

8. អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចពុំស៊ីសង្វាក់គ្នា លើផលវិបាកផ្នែកនីតិវិធីកើតចេញពីការបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២[10] និងពុំបានពន្យល់ថាតើប្រធានបទសំខាន់ៗនៅក្នុងដីកាដំណោះស្រាយនឹងត្រូវរងការប៉ះពាល់ដោយរបៀបណា ទាក់ទងទៅនឹងភ័ស្តុតាង និងសំអាងហេតុរួមគ្នារវាងរឿងក្តីដែលត្រូវបានបំបែកនោះ[11]។ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងជាច្រើនលើកជាច្រើនសាថា រឿងក្តីដែលត្រូវបានបំបែកនោះគឺជារឿងក្តីបន្តគ្នា ពុំមែនជារឿងក្តីដោយឡែកពីគ្នាដូចបានប្រកាសពីដំបូងឡើយ[12]។ ជាពិសេស និងសំខាន់បំផុតនោះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់នៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ថា សំណុំរឿង ០០២/០១ នឹង "ផ្តល់នូវមូលដ្ឋានសម្រាប់ការពិនិត្យលម្អិតលើបទចោទ និងការចោទប្រកាន់នានាដែលនៅសេសសល់ប្រឆាំងនឹងជនជាប់ចោទនៅក្នុងការជំនុំជម្រះលើកក្រោយ" ហើយនឹង "ផ្តល់នូវមូលដ្ឋានមួយសម្រាប់ការពិចារណាអំពីទម្រង់នៃការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម"[13]។ ស្រប

---

[9] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ឯកសារ E301/9/1 ចុះថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤ ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២")។

[10] *សូមមើល* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ឯកសារ E301/9/1/1/3 ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២") កថាខណ្ឌ ៧០-៧៤។

[11] *ដូចខាងលើ* កថាខណ្ឌ ៨៤។

[12] *ដូចខាងលើ* កថាខណ្ឌ ៧១។

[13] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ ឯកសារ E124/7 ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ("សេចក្តីសម្រេចលើសំណើសុំឱ្យពិចារណាឡើងវិញអំពីការបំបែកកិច្ចដំណើរការនីតិវិធី") កថាខណ្ឌ ១០។ *សូមមើល ផងដែរ* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង កម្មវត្ថុ "ការបញ្ជាក់បំភ្លឺទាក់ទងទៅនឹងការប្រើប្រាស់ភ័ស្តុតាង និងនីតិវិធីដើម្បីកោះហៅសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញសាជាថ្មីឡើងវិញពីសំណុំរឿង ០០២/០១ សម្រាប់សំណុំរឿង ០០២/០២" ឯកសារ E302/5 ចុះថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ ("អនុស្សរណៈស្តីពីការបញ្ជាក់បំភ្លឺ") កថាខណ្ឌ ៧។

ជាមួយនឹងវិធីសាស្ត្រនេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចពិចារណាលើតួនាទី និងការទទួលខុសត្រូវរបស់ជនជាប់ចោទទាក់ទងនឹងគោលនយោបាយទាំង ៥ ដែលពាក់ព័ន្ធនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូលនៅក្នុងសំណុំរឿង ០០២/០១ ទោះបីជាការពិចារណាអង្គហេតុលម្អិតបានផ្តោតជាចំបងលើគោលនយោបាយចំនួន ២ ដែលទាក់ទងដោយផ្ទាល់ទៅនឹងឧក្រិដ្ឋកម្មនានាដែលត្រូវបានជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ ក៏ដោយ[14]។ នៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ការជំនុំជម្រះលើកទីមួយនឹងពិនិត្យ "ជាទូទៅ" លើការរៀបចំបង្កើតគោលនយោបាយទាំង ៥ ប៉ុន្តែ ការអនុវត្តលើគោលនយោបាយទាំងនេះនឹងត្រូវបានយកមកពិនិត្យដេញដោលនៅក្នុងរឿងក្តីទីមួយៗ ដែលត្រូវបានបំបែកតែប៉ុណ្ណោះ[15]។ នៅថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ នៅពេលឆ្លើយតបទៅនឹងសំណើសុំរបស់ភាគីអំពីភាពអាចទទួលយកបាននៃភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ ដែលភ័ស្តុតាងទាំងនេះត្រូវបានបង្កើតឡើងនៅក្នុងសំណុំរឿង ០០២/០១ នោះ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា "អានុភាពនៃការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ របស់អង្គជំនុំជម្រះសាលាដំបូងគឺដើម្បីបំបែកបទចោទផ្សេងៗ ដែលជាធម្មតាត្រូវបានយកមកវិនិច្ឆ័យនៅក្នុងការជំនុំជម្រះតែមួយ ឲ្យទៅជាការជំនុំជម្រះពីរ ឬ ច្រើនជាងនេះ ដែលអាចគ្រប់គ្រងបានល្អជាង មិនមែនជាការបង្កើតឲ្យមានការជំនុំជម្រះពីរដាច់ដោយឡែក និងខុសពីគ្នាស្រឡះនោះទេ"[16]។

9. នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់អំពីផលវិបាកផ្នែកនីតិវិធីនៃការបំបែកកិច្ចដំណើរការនីតិវិធី និងផលប៉ះពាល់របស់វាលើសំណុំរឿង ០០២/០២។ អង្គជំនុំជម្រះតុលាការកំពូលបានច្រានចោលសញ្ញាណដែលថា សំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២ គឺជា "សំណុំរឿងបន្តគ្នា" ឬ គឺជាដំណាក់ការចំនួន ២ នៃការជំនុំជម្រះតែមួយ ហើយបានសម្រេចថា រឿងក្តីទាំង ២ នេះដំណើរការដោយឡែកតែឯង នៅពេលការបំបែកកិច្ចដំណើរការ

---

[14] សេចក្តីសម្រេចលើសំណើសុំឲ្យពិចារណាឡើងវិញអំពីការបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ ១១។

[15] អនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូង កម្មវត្ថុ "ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១" ឯកសារ E141 ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ២។

[16] អនុស្សារណៈស្តីពីការបញ្ជាក់បំភ្លឺ កថាខណ្ឌ ៥។

នីតិវិធីចូលជាស្ថាពរ ពោលគឺ ក្រោយពេលបញ្ចប់សវនាការដេញដោលភ័ស្តុតាង[17]។ ជាលទ្ធផល អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា "បើទោះបីភ័ស្តុតាងនៅតែមានលក្ខណៈដូចគ្នាជាផ្លូវការទៅនឹងសំណុំរឿងដែលបានបំបែកក៏ដោយ ក៏ភាពរួមគ្នានេះមិនបានពន្លាតដល់ការយល់ឃើញ ហើយធាតុរួមនៃអង្គហេតុក្នុងសំណុំរឿងទាំងអស់ក្នុងសំណុំរឿង ០០២ ត្រូវបង្ហាញសាជាថ្មី"[18]។

10. សាលក្រមសំណុំរឿង ០០២/០១ ដែលមានចំនួន ៦២២ ទំព័រ ត្រូវបានចេញនៅក្នុងរយៈពេលតែប៉ុន្មានថ្ងៃក្រោយមកតែប៉ុណ្ណោះ ពោលគឺ នៅថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ ជាពីរភាសា។ វាបង្ហាញច្បាស់ពីពេលចេញសាលក្រម និងតាមរយៈវិធីសាស្ត្រដែលបានអនុវត្តនៅក្នុងសាលក្រមនោះថា អង្គជំនុំជម្រះសាលាដំបូងបានបន្តនីតិវិធីរបស់ខ្លួនដោយផ្អែកមូលដ្ឋានលើការសន្មតនាពេលមុនរបស់ខ្លួនថា សំអាងហេតុនៅក្នុងសំណុំរឿង ០០២/០១ នឹងយកមកធ្វើជាមូលដ្ឋានសម្រាប់ការជំនុំជម្រះនាពេលខាងមុខ។

## III. ច្បាប់ជាធរមាន

11. ជនជាប់ចោទមានសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះដោយសាលាក្តីអព្យាក្រឹត្យ។ សិទ្ធិនេះត្រូវបានធានានៅក្នុងមាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងត្រូវអនុវត្តនៅចំពោះមុខ អ.វ.ត.ក[19]។ សិទ្ធិទទួលបានការជំនុំជម្រះដោយសាលាក្តីអព្យាក្រឹត្យគឺជាធាតុមួយសំខាន់នៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌[20]។ សិទ្ធិនេះគឺជា

---

[17] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ កថាខណ្ឌ ៤២ ៤៣ និង ៧៤។

[18] *ដូចខាងលើ* កថាខណ្ឌ ៨៥។

[19] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា។ មាត្រា ១២(១) នៃកិច្ចព្រមព្រៀង។ មាត្រា ៣៣ថ្មី នៃច្បាប់ អ.វ.ត.ក។ វិធានផ្ទៃក្នុង ៣៤ (២) នៃវិធានផ្ទៃក្នុង។

[20] Manfred NOWAK *កតិកាសញ្ញារបស់ អ.ស.ប ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖ អធិប្បាយលើកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ* បោះពុម្ពលើកទី ២ ឆ្នាំ ២០០៥ ត្រង់ទំព័រ ៣២១ កថាខណ្ឌ ២៧។

“សិទ្ធិដាច់ខាតមួយដែលពុំចំណុះករណីលើកលែងណាមួយឡើយ”[21]។ តុលាការសិទ្ធិមនុស្សបានពន្យល់ថា៖

> លក្ខខណ្ឌនៃអព្យាក្រឹត្យមានទិដ្ឋភាពចំនួន ២។ ទីមួយ ចៅក្រមមិនត្រូវឱ្យសាលក្រមរបស់ខ្លួនរងឥទ្ធិពលនៃភាពលម្អៀង ឬ ការធ្វើបុរេវិនិច្ឆ័យរបស់ខ្លួននោះឡើយ ព្រមទាំងមិនត្រូវបង្កើតទស្សនៈជាមុនណាមួយអំពីករណីជាក់លាក់នៅចំពោះមុខពួកគាត់ និងមិនត្រូវបំពេញកិច្ចក្នុងរបៀបណាមួយដែលជួយដោយមិនសមស្របដោយផ្តល់ផលប្រយោជន៍ដល់ភាគីម្ខាងជាហេតុធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីម្ខាងទៀតនោះទេ។ ចំណុចទីពីរ សាលាក្តីត្រូវបង្ហាញឱ្យអ្នកសង្កេតការណ៍ដោយមិនលម្អៀងឃើញថាខ្លួនមានភាពអព្យាក្រឹត្យ។ ឧទាហរណ៍ ការជំនុំជម្រះមួយដែលត្រូវបានប៉ះពាល់យ៉ាងខ្លាំងដោយការចូលរួមរបស់ចៅក្រមម្នាក់ដែល អនុលោមតាមច្បាប់ក្នុងស្រុកគួរត្រូវបានដកសិទ្ធិជំនុំជម្រះនោះ ជាធម្មតា មិនអាចត្រូវបានចាត់ទុកថា តុលាការនេះមានភាពអព្យាក្រឹត្យឡើយ[22]។

អាចនិយាយម្យ៉ាងទៀតថា “លក្ខណៈវិនិច្ឆ័យនៃអនាគតិត្រូវបានរំលោភមិនមែនតែករណីចៅក្រមនោះមានភាពលម្អៀងជាក់ស្តែងនោះទេ តែក៏ក្នុងករណីដែលមានការស្តែងចេញឱ្យឃើញអំពីភាពលម្អៀងដែរ”[23]។ មូលដ្ឋាន ច នៃបណ្តឹងជំទាស់ចៅក្រមរបស់ នួន ជា ពាក់ព័ន្ធនឹងទិដ្ឋភាពទី ២ ពោលគឺ ការលេចចេញនូវភាពលម្អៀងដែលកើតចេញពីការសម្រេចមុនៗរបស់តុលាការ ដែលបានចេញដោយចៅក្រមដែលត្រូវបានប្តឹងជំទាស់។

12. ការលេចឡើងនូវភាពលម្អៀងត្រូវបានបង្ហាញប្រសិនបើ “កាលៈទេសៈទាំងនោះដែលធ្វើឱ្យអ្នកសង្កេតការណ៍មិនលម្អៀងម្នាក់ ដែលបានទទួលព័ត៌មានគ្រប់គ្រាន់យល់ឃើញដោយសមហេតុផល

---

[21] គណៈកម្មាធិការសិទ្ធិមនុស្ស មតិយោបល់ទូទៅលេខ ៣២ មាត្រា ១៤៖ សិទ្ធិទទួលបានសមភាពនៅចំពោះមុខតុលាការ និងសាលាក្តី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ឯកសារ អ.ស.ប CCPR/C/GC/32 (ឆ្នាំ ២០០៧) កថាខណ្ឌ ១៩ *ដកស្រង់*រឿងក្តី *Gonzalez del Rio* តទល់នឹងប្រទេសពេរូ សេចក្តីប្រកាសលេខ ២៦៣/១៩៨៧ កថាខណ្ឌ ៥១។

[22] *ដូចខាងលើ* កថាខណ្ឌ ២១ (លុបឯកសារយោង)។

[23] សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ ប្តឹងជំទាស់ចៅក្រម សោម សិរីវុឌ្ឍ ដោយសារពុំមានភាពឯករាជ្យ I/4 ចុះថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១១ កថាខណ្ឌ ១០ *ដែលបានយកតាម*សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ នួន ជា និង អៀង សារី ដែលប្តឹងជំទាស់ចំពោះលោកចៅក្រម និល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី ឯកសារ E55/4 ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១១ កថាខណ្ឌ ១១។

ថាមានភាពលម្អៀង"[24]។ លក្ខខណ្ឌនេះតម្រូវឱ្យមានវិធីសាស្ត្រសត្យានុម័តមួយ ដែលមានប្រភពទំនើបពីសុភាសិតមួយថា "តុលាការមិនត្រឹមតែរកយុត្តិធម៌ប៉ុណ្ណោះទេ ប៉ុន្តែត្រូវបង្ហាញឱ្យគេឃើញជាក់ស្តែង និងដោយគ្មានមន្ទិលសង្ស័យនូវការស្វែងរកយុត្តិធម៌នោះផងដែរ"។ សុភាសិតនេះត្រូវបានលើកឡើងដោយចៅក្រម Hewart CJ នៅក្នុងរឿងក្តី *R. ទល់នឹង Sussex Justices ex p McCarthy*[25]។ លក្ខខណ្ឌនេះបានវិវត្តន៍ចាប់តាំងពីត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩២៣ មកម្លេះ ហើយក្នុងពេលបច្ចុប្បន្ន យុត្តិសាស្ត្រក្នុងប្រព័ន្ធច្បាប់ខំមិនឡូស្របគ្នានឹងយុត្តិសាស្ត្រនៅក្នុងតុលាការសិទ្ធិមនុស្សអឺរ៉ុបក្រោមកថាខណ្ឌ ៦(១) នៃអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប[26] ដែលឆ្លុះបញ្ចាំងពីមាត្រា ១៤ (១) នៃកតិកាសញ្ញា ICCPR[27]។ នៅក្នុងរឿងក្តី *Kyprianou ទល់នឹង ប្រទេស Cyprus* តុលាការសិទ្ធិមនុស្សអឺរ៉ុបបានពន្យល់ក្នុងន័យសាមញ្ញអំពីវិធីសាស្ត្រសត្យានុម័តក្នុងការពិនិត្យមើលការចោទប្រកាន់អំពីការខ្វះអនាគតិ។ វិធីសាស្ត្រនេះត្រូវបានញែកដាច់ស្រឡះពីវិធីសាស្ត្រអត្តនោម័ត៖

---

[24] *ដូចខាងលើ*។

[25] [1924] 1 KB 256 [1923] All.E.R. 233។ ចៅក្រម Hewart CJ បានបន្តលើកឡើងថា៖ "មិនត្រូវធ្វើឡើង ដែលបង្កើតនូវមន្ទិលសង្ស័យមួយថា វាមានការជ្រៀតជ្រែកដោយមិនសមស្របលើដំណើរការស្វែងរកយុត្តិធម៌"។

[26] *សូមមើល ឧ.* រឿងក្តី *Metropolitan Properties Co. ទល់នឹង Lannon* [1969] 1 Q.B. 577 (CA) ត្រង់ ៥៩៩ (ដែលចៅក្រម Denning បានសម្រេចថា ចៅក្រមមិនគួរចូលរួមជំនុំជម្រះនៅក្នុងរឿងក្តីមួយនោះទេ "ប្រសិនបើអ្នកដែលមានការពិចារណាត្រឹមត្រូវនឹងយល់ឃើញថា នៅក្នុងកាលៈទេសៈនានា វានឹងមានលទ្ធភាពជាក់ស្តែងមួយថា គាត់នឹងមានភាពលម្អៀង"។ រឿងក្តី *R. ទល់នឹង Gough* [1993] A.C. 646 ត្រង់ ៦៧០ (ដែលអង្គជំនុំជម្រះតុលាការកំពូល (House of Lord) តាមរយៈចៅក្រម Goff បានលើកឡើងថា "[ខ្ញុំ]ចង់លើកឡើងលក្ខខណ្ឌទាក់ទងនឹងគ្រោះថ្នាក់ជាក់ស្តែងជាជាងលទ្ធភាពកើតមាន ដើម្បីធានាថា តុលាការកំពុងគិតអំពីលទ្ធភាព (possibility) ជាជាងភាពអាចកើតមាន (probability) ភាពលម្អៀង") និងរឿងក្តី *Porter ទល់នឹង Magill* [2002] 2AC 357 670 (ដែលអង្គជំនុំជម្រះតុលាការកំពូល (House of Lord) តាមរយៈចៅក្រម Hope បានសម្របលក្ខខណ្ឌដែលបានបង្កើតឡើងនៅក្នុងប្រព័ន្ធច្បាប់ខំមិនឡូជាមួយនឹងវិធីសាស្ត្រដែលបានបង្កើតឡើងដោយតុលាការសិទ្ធិមនុស្សអឺរ៉ុប៖ "បញ្ហាចោទនោះគឺថាតើ អ្នកសង្កេតការណ៍ដោយយុត្តិធម៌ និងទទួលបានព័ត៌មានត្រឹមត្រូវ ក្រោយពីបានពិចារណាអង្គហេតុរួចហើយនោះ នឹងសន្និដ្ឋានថា វាមានលទ្ធភាពជាក់ស្តែងបង្ហាញថា សាលាក្តីមានភាពលម្អៀងដែរឬទេ"។ ចៅក្រម Hope បានបន្តបញ្ជាក់ដដែលៗថា មូលដ្ឋាននៃការពិចារណាគឺ "ការចាប់អារម្មណ៍សំខាន់បំផុតរបស់សាធារណជនថា គេគួរជឿទុកចិត្តលើសុចរិតភាពនៃការស្វែងរកយុត្តិធម៌ដែរឬទេ")។

[27] មាត្រា ៦(១) នៃអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប បានចែងនៅក្នុងផ្នែកដែលពាក់ព័ន្ធថា "ក្នុងការសម្រេចទៅលើសិទ្ធិ និងកាតព្វកិច្ចពលរដ្ឋ ឬការសម្រេចទៅលើបទចោទព្រហ្មទណ្ឌណាមួយប្រឆាំងនឹងជនណាមួយ ជននោះមានសិទ្ធិទទួលបាននូវសវនាការជាសាធារណៈ និងយុត្តិធម៌នៅក្នុងពេលវេលាសមស្របមួយ របស់តុលាការឯករាជ្យ និងមិនលម្អៀង ដែលត្រូវបានបង្កើតឡើងដោយច្បាប់"។

តុលាការបញ្ជាក់ឡើងវិញពីដំបូងថា ជាការសំខាន់ជាសារវ័ន្តនៅក្នុងសង្គមប្រជាធិបតេយ្យដែលថា តុលាការធ្វើឱ្យមានការទុកចិត្តពីក្នុងចំណោមសាធារណជន ហើយសំខាន់បំផុតនោះ ក្នុងចំណោម ជនជាប់ចោទ ចំពោះកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ។ ដើម្បីឱ្យមានការទុកចិត្ត មាត្រា ៦ តម្រូវ ឱ្យសាលាក្ដីដែលស្ថិតនៅក្នុងវិសាលភាពនេះមានភាពអព្យាក្រឹត្យ។ ជាធម្មតា ភាពអព្យាក្រឹត្យមាន ន័យថា នត្ថិភាពនៃបុរេវិនិច្ឆ័យ ឬភាពលម្អៀង ហើយអត្ថិភាព ឬនត្ថិភាព នៃចំណុចទាំងនេះ អាច ត្រូវបានកំណត់នៅក្នុងវិធីផ្សេងៗជាច្រើន។ ដូច្នេះ តុលាការត្រូវញែកឱ្យដាច់រវាងវិធីសាស្ត្រអត្តនោ ម័ត ពោលគឺ ការព្យាយាមឱ្យអស់ពីលទ្ធភាពក្នុងការបញ្ជាក់ពីការជឿជាក់ ឬផលប្រយោជន៍ផ្ទាល់ ខ្លួនរបស់ចៅក្រមណាមួយនៅក្នុងរឿងក្ដីជាក់លាក់ ជាមួយនឹងវិធីសាស្ត្រសត្យានុម័ត ពោលគឺ ការ សម្រេចថាតើ ចៅក្រមបានផ្ដល់ការធានាគ្រប់គ្រាន់ក្នុងការបំបាត់ចោលនូវវិមតិសង្ស័យត្រឹមត្រូវ លើបញ្ហានេះ។ ចំពោះលក្ខខណ្ឌទី ២ នៅពេលអនុវត្តចំពោះអង្គចៅក្រមដែលចូលរួមជំនុំជម្រះ មានន័យថា ត្រូវសម្រេចថាតើវាអាចមានអង្គហេតុស្ដែងឱ្យមានវិមតិសង្ស័យអំពីអនាគតិនោះដែរ ឬទេ ក្រៅពីឥរិយាបថដោយផ្ទាល់ខ្លួនរបស់សមាជិកណាម្នាក់នៅក្នុងចំណោមក្រុមប្រឹក្សាជំនុំ ជម្រះនោះ។ នៅក្នុងករណីនេះ សូម្បីការលេចឡើងនូវវិមតិសង្ស័យណាមួយក៏អាចមានសារ សំខាន់ផងដែរ។ នៅពេលសម្រេចលើវិមតិសង្ស័យថាតើនៅក្នុងករណីជាក់លាក់មួយ មានហេតុ ផលសមស្របឱ្យមានការភ័យខ្លាចថា ក្រុមប្រឹក្សាជំនុំជម្រះណាមួយខ្វះនូវអនាគតិដែរឬទេនោះ ទស្សនៈអ្នកដែលអះអាងថាមានភាពលម្អៀង គឺជាចំណុចសំខាន់ ប៉ុន្តែពុំមែនជាកត្តាកំណត់នោះ ទេ។ អ្វីដែលជាកត្តាកំណត់នោះគឺថាតើការភ័យខ្លាចអាចជាការត្រឹមត្រូវដោយសត្យានុម័តដែរ ឬទេ[28]។

13. ករណីដែលថា ចៅក្រមធ្លាប់បានសម្រេចនាពេលមុនលើអង្គហេតុទាក់ទងនឹងរឿងក្ដីមួយ ពុំមែនជា មូលហេតុនៃការប្ដឹងជំទាស់ចៅក្រមនោះទេ។ ក៏ប៉ុន្តែ នៅក្នុងកាលៈទេសៈខ្លះ ករណីនេះអាចជាមូលដ្ឋាន គាំទ្រដល់ការភ័យខ្លាចដោយសត្យានុម័តថា ចៅក្រមនឹងពិចារណារឿងក្ដីនេះដោយមិនមានភាព អព្យាក្រឹត្យ និងមានបុរេវិនិច្ឆ័យ[29]។ ចំណុចសំខាន់នៃបញ្ហានេះគឺត្រង់ថា សំអាងហេតុនាពេលមុន អាចមើលឃើញថាមានផលប៉ះពាល់លើការសម្រេចលើរឿងក្ដី ដែលកំពុងត្រូវបានជំនុំជម្រះនេះ។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិបានសម្រេចថា បើទោះជារឿងក្ដីទាំងពីរពាក់ព័ន្ធនឹងអង្គហេតុ ឬ អង្គ

---

[28] ពាក្យបណ្ដឹងលេខ ៧៣៧៩៧/០១ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៥ កថាខណ្ឌ ១១៨ (ចំណុចយោងត្រូវបានលុបចោល)។

[29] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ កថាខណ្ឌ ៩៥។

ច្បាប់ជាន់គ្នាក៏ដោយ ក៏ចៅក្រមពុំត្រូវបានហាមឃាត់មិនឲ្យធ្វើជាចៅក្រមក្នុងការជំនុំជម្រះព្រហ្មទណ្ឌ ២ ផ្សេងគ្នា ដែលលេចចេញពីសំណុំអង្គហេតុតែមួយនោះទេ[30] លើកលែងតែចៅក្រមរូបនោះបានសម្រេចនាពេលមុនដោយបានប្រកាសអំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ[31]។ ស្រដៀងគ្នានេះដែរ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចនៅក្នុងរឿងក្តី *Poppe ទល់នឹង ប្រទេសហូឡង់ ថា* "ករណីត្រឹមតែថា ចៅក្រមធ្លាប់បានសម្រេចលើបទចោទព្រហ្មទណ្ឌស្រដៀងគ្នា ប៉ុន្តែពុំពាក់ព័ន្ធគ្នា ឬ ថា ចៅក្រមធ្លាប់បានជំនុំជម្រះសហជនជាប់ចោទនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌដោយឡែក ពុំគ្រប់គ្រាន់នាំដល់ការសង្ស័យអំពីអនាគតិរបស់ចៅក្រមនៅក្នុងរឿងក្តីក្រោយមួយទៀតនោះឡើយ។ ក៏ប៉ុន្តែ វាជាបញ្ហាមួយផ្សេង ប្រសិនបើសាលក្រមមុនមានសំអាងហេតុដែលពិតជាមានបុរេវិនិច្ឆ័យលើ *បញ្ហានៃពិរុទ្ធភាពរបស់ជនជាប់ចោទ* នៅក្នុងកិច្ចដំណើរការនីតិវិធី

---

[30] *សូមមើល ឧ.* សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង កថាខណ្ឌ ៨៣ ("នៅក្នុងរឿងក្តីដែលមានភ័ស្តុតាង ឬ ទម្រង់នៃអង្គហេតុជាន់គ្នា [សច្ចធារណ៍នៃភាពអព្យាក្រឹត្យ]អនុញ្ញាតឲ្យមានការបដិសេធចោលលើអញ្ញត្រកម្មទាក់ទងនឹងការជំនុំជម្រះដែលច្រំដែលលើធាតុនៃបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិលើធាតុនៃអង្គហេតុដទៃផ្សេងទៀត លើបញ្ហាជាក់លាក់ផ្នែកច្បាប់ និងលើការប្រើប្រាស់នូវមធ្យោបាយជាក់លាក់នៃភ័ស្តុតាង")។ សេចក្តីសម្រេចលើបណ្តឹងជំទាស់ ចុះថ្ងៃទី ២៣ ខែ មីនាឆ្នាំ ២០១១ កថាខណ្ឌ ១៥ ("ចៅក្រមមួយរូបមិនត្រូវបានហាមឃាត់មិនឲ្យជំនុំជម្រះលើការចោទប្រកាន់ពីបទព្រហ្មទណ្ឌពីរផ្សេងគ្នាដែលកើតចេញពីអង្គហេតុតែមួយនោះទេ")។

[31] *សូមមើល ឧ.* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Galić* ICTR-05-82-A សេចក្តីសម្រេចលើបណ្តឹងរបស់ Galić អនុលោមតាមវិធាន ១៥(B) ការិយាល័យរបស់សាលាក្តី ICTY ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៣ ("សេចក្តីសម្រេចលើបណ្តឹងរបស់ Galić") កថាខណ្ឌ ១៦។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karadžič* IT-95-05/18-PT សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម Picard និងរបាយការណ៍ដាក់ជូនអនុប្រធានអនុលោមតាមវិធាន ១៥(B)(ii) អង្គជំនុំជម្រះរបស់សាលាក្តី ICTY បង្កើតឡើងដោយដីកាបង្គាប់របស់អនុប្រធាន ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៩ ("សេចក្តីសម្រេចលើបណ្តឹងជំទាស់របស់ *Karadžič*") កថាខណ្ឌ ២១។ រឿងក្តី *Ntawukulilyayo ទល់នឹង រដ្ឋអាជ្ញា* ICTR-05-82-A សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម អង្គជំនុំជម្រះតុលាការកំពូលរបស់សាលាក្តី ICTR ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១១ ("សេចក្តីសម្រេចលើបណ្តឹងជំទាស់របស់ *Ntawukulilyayo*") កថាខណ្ឌ ១៧-១៨។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Nyiramasuhuko និងអ្នកផ្សេងទៀត* ICTR-98-42-A សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម Fausto Pocar អង្គជំនុំជម្រះតុលាការកំពូលរបស់សាលាក្តី ICTR ចុះថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០១២ ("សេចក្តីសម្រេចលើបណ្តឹងជំទាស់របស់ *Nyiramasuhuko*") កថាខណ្ឌ ១៥។ *សូមមើលផងដែរ* សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ កថាខណ្ឌ ៨៥ *និង* សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើបណ្តឹងជំទាស់ កថាខណ្ឌ ២០។

ក្រោយៗ”[32]។ សំអាងលើយុត្តិសាស្ត្រនេះ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងក្នុងពេលពិនិត្យមើលការព្រួយបារម្ភរបស់ ខៀវ សំផន អំពីផលវិបាកនៃការបំបែកកិច្ចដំណើរការនីតិវិធីចំពោះលទ្ធភាពរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការដំណើរការសវនាការលើសំណុំរឿង ០០២/០២ ថា សច្ចធារណ៍នៃអនាគតិរបស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងនឹងមិនត្រូវបានយកចិត្តទុកដាក់ ប្រសិនបើចៅក្រមទាំងនេះសម្រេចនៅក្នុងសំណុំរឿង ០០២/០១ “ដែលនឹងទៅបង្ហាញជាការសន្មតនូវការទទួលខុសត្រូវព្រហ្មទណ្ឌទៅលើសហជនជាប់ចោទទាក់ទងនឹងបទចោទដែលត្រូវជំនុំជម្រះក្នុងរឿងក្តីបន្តបន្ទាប់នោះទេ”[33]។

14. សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការមើលឃើញពីភាពលម្អៀងនឹងកើតឡើងតែក្នុងករណីដែលចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងមានបុរេវិនិច្ឆ័យលើពិរុទ្ធភាពរបស់ជនជាប់ចោទ ទាក់ទងនឹងបទចោទដែលនឹងត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២ តែប៉ុណ្ណោះ។ សហព្រះរាជអាជ្ញាអះអាងថា ករណីនេះតម្រូវឲ្យមានសំអាងហេតុលើ “លក្ខណវិនិច្ឆ័យពាក់ព័ន្ធទាំងអស់ដែលចាំបាច់សម្រាប់បង្កើតជាបទល្មើសព្រហ្មទណ្ឌ ហើយ [...] ថាតើដោយហួសពីវិមតិសង្ស័យ ម្ចាស់បណ្តឹងពិតជាមានពិរុទ្ធភាព ឬអត់ ចំពោះការប្រព្រឹត្តិបទល្មើសបែបនេះ”[34]។ លក្ខខណ្ឌនេះត្រូវបានជំទាស់ដោយមេធាវីការពារក្តី នួន ជា ដែលអះអាងថា ចៅក្រមដែលបាន “សន្និដ្ឋានទូទៅ” ជាមុន អំពី “*គុណសម្បត្តិ* នៃ*ការជាប់ពាក់ព័ន្ធ* របស់អ្នកដាក់ពាក្យសុំ [...] *ឧក្រិដ្ឋជន ឬ ផ្សេងពីនេះ*” នឹងគ្រប់គ្រាន់សម្រាប់ការប្តឹងជំទាស់បាន[35]។ ខ្ញុំយល់ឃើញថា ការបកស្រាយក្នុងន័យចង្អៀតចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើការបំបែកកិចដំណើរការនីតិវិធីបន្ថែមក្នុងសំណុំរឿង ០០២ ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា និងដែលបានទទួលយកដោយចៅក្រមភាគច្រើន

---

[32] ពាក្យបណ្តឹងលេខ ៣២២៧១/០៤ សាលក្រម ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៩ (“សាលក្រមក្នុងរឿងក្តី *Poppe*”) កថាខណ្ឌ ២៦។

[33] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ កថាខណ្ឌ ៨៥។ *សូមមើលផងដែរ* កថាខណ្ឌ ៨៣។

[34] ចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះបណ្តឹងជំទាស់របស់ នួន ជា ឯកសារ E314/9 ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ៤៦ *ដកស្រង់* សាលក្រមក្នុងរឿងក្តី *Poppe* កថាខណ្ឌ ២៨។

[35] បណ្តឹងជំទាស់របស់ នួន ជា ប្រឆាំងនឹងចៅក្រម និល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម យូរ ឧត្តរា ឯកសារ E314/6 ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ (“បណ្តឹងជំទាស់របស់ នួន ជា”) កថាខណ្ឌ ៣០។

នោះ ពុំមានមូលដ្ឋានគាំទ្រណាមួយនៅក្នុងយុត្តិសាស្ត្រអន្តរជាតិនោះទេ ហើយអ្វីដែលសំខាន់នោះ ការបកស្រាយនេះមិនបានពិចារណាទៅលើកាលៈទេសៈជាក់លាក់នៃរឿងក្ដីបច្ចុប្បន្ននេះឡើយ។

15. នៅក្នុងការគាំទ្រលើសេចក្ដីសន្និដ្ឋានរបស់ខ្លួន សហព្រះរាជអាជ្ញាសំអាងលើចំណុចដកស្រង់មួយចេញពីសាលក្រមក្នុងរឿងក្ដី *Poppe* ដែលនៅក្នុងនោះតុលាការសិទ្ធិមនុស្សអឺរ៉ុបបានច្រានចោលទឡ្ហីករណ៍របស់ម្ចាស់បណ្ដឹងដែលបានលើកឡើងថា ចៅក្រមពីររូបដែលចូលរួមជំនុំជម្រះរូបគាត់លើបទល្មើសពាក់ព័ន្ធនឹងថ្នាំញៀន ពុំមានអនាគតិដោយហេតុថា ចៅក្រមទាំងពីររូបនេះធ្លាប់បានចេញសាលក្រមប្រឆាំងនឹងអ្នកសមគំនិតជាមួយនឹងម្ចាស់បណ្ដឹង។

> នៅក្នុងសាលក្រមទាំងពីរ ឈ្មោះរបស់អ្នកដាក់បណ្ដឹងតវ៉ា និងអ្នកផ្សេងទៀត ត្រូវបានលើកឡើងគ្រាន់តែដើម្បីបង្ហាញ និងបញ្ជាក់អំពីតួនាទីដឹកនាំដែលពិរុទ្ធជនបានបំពេញនៅក្នុងអង្គការឧក្រិដ្ឋកម្មពោលគឺ នៅ C3 និង C4។ ករណីថាតើការដែលអ្នកដាក់បណ្ដឹងបានចូលរួមជាមួយ C3 និង D បានបំពេញលក្ខណៈវិនិច្ឆ័យចាំបាច់ទាំងអស់ដែរឬអត់ដើម្បីចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ ហើយប្រសិនបើបានបំពេញមែននោះ ថាតើអ្នកដាក់បណ្ដឹងមានពិរុទ្ធភាពហួសពីវិមតិសង្ស័យថាបានប្រព្រឹត្តបទល្មើសបែបនេះដែរឬក៏អត់នោះ មិនត្រូវបានលើកឡើង សម្រេច ឬវាយតម្លៃដោយចៅក្រមជំនុំជម្រះដែលអ្នកដាក់បណ្ដឹងមានបំណងតវ៉ាលើអនាគតិរបស់ចៅក្រមទាំងនេះនោះទេ។ គ្មានការធ្វើការវិនិច្ឆ័យជាក់លាក់លើការចូលរួមរបស់អ្នកដាក់បណ្ដឹង ឬលើអំពើដែលបានប្រព្រឹត្តដោយជននេះ ជាឧក្រិដ្ឋជន ឬអ្នកផ្សេងទៀតនោះឡើយ។ នៅក្នុងករណីនេះ អង្គហេតុនៃរឿងក្ដីរបស់អ្នកដាក់បណ្ដឹងខុសពីអង្គហេតុនៃរឿងក្ដី Ferrantelli និង Santangelo និង Rojas Morales។ ដូច្នេះ គេមិនអាចនិយាយបានថា ការភ័យខ្លាចដែលអ្នកដាក់បណ្ដឹងអាចមានចំពោះភាពលម្អៀងរបស់តុលាការក្នុងតំបន់នោះមានត្រឹមត្រូវដោយសត្យានុម័ត[36]។

16. ខ្ញុំយល់ឃើញថា សេចក្ដីយោងរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបទៅនឹង "លក្ខណៈវិនិច្ឆ័យពាក់ព័ន្ធទាំងអស់ ដែលចាំបាច់បង្កើតបានជាបទល្មើសព្រហ្មទណ្ឌមួយនោះ" គឺគ្រាន់តែការស្រាយបំភ្លឺប៉ុណ្ណោះ ប៉ុន្តែ មិនបង្កើតបានជាលក្ខខណ្ឌសំខាន់សេចក្ដីសម្រាប់បុរេវិនិច្ឆ័យទេ។ បញ្ហាចម្បងសម្រាប់ការកំណត់ទៅលើការលេចឡើងនូវភាពលម្អៀងរបស់តុលាការ តាមរយៈបុរេវិនិច្ឆ័យ ឬមូលហេតុផ្សេងពីនេះក្ដី គឺនៅតែស្ថិតត្រង់ថាតើកាលៈទេសៈទាំងឡាយ អាចនាំឲ្យអ្នកសង្កេតការណ៍ឥត

[36] សាលក្រមក្នុងរឿងក្ដី *Poppe* កថាខណ្ឌ ២៨។

លម្អៀង ដែលបានទទួលព័ត៌មានត្រឹមត្រូវ យល់ឃើញប្រកបដោយហេតុផលថាមានភាពលម្អៀងដែរឬអត់។ ខណៈដែលកត្តាទាំងឡាយ ដូចជា ថាតើចៅក្រមបានវិនិច្ឆ័យទុកជាមុនចំពោះគ្រប់ធាតុផ្សំនៃបទល្មើសទាំងអស់ នឹងមានសារសំខាន់នៅក្នុងការវាយតម្លៃថាតើអ្នកសង្កេតការណ៍ឥតលម្អៀងអាចយល់ឃើញប្រកបដោយហេតុផលថាមានភាពលម្អៀងដែរឬយ៉ាងណា ហើយការមិនមានកត្តាទាំងអស់នេះ មិនមែនជាកត្តាកំណត់នោះទេ។ តាមពិតទៅ ក្នុងរឿងក្តីមួយចំនួនដែលចៅក្រមបានចូលរួមសម្រេចសេចក្តីមុនៗ ដែលពាក់ព័ន្ធទៅនឹងការចូលរួមរបស់ម្ចាស់បណ្តឹងដិតចិត្តចំពោះបទល្មើសដែលត្រូវជំនុំជម្រះនេះ ប៉ុន្តែ មិនបានប្រកាសអំពីគ្រប់ធាតុផ្សំនៃបទល្មើសទាំងអស់នោះតុលាការសិទ្ធិមនុស្សអឺរ៉ុបបានរកឃើញថា មានការរំលោភសិទ្ធិទទួលបានសាលាជម្រះក្តីមួយដែលមិនលម្អៀងហើយ។ ឧទាហរណ៍ នៅក្នុងរឿងក្តីរវាង *Rojas Morales* ***តទល់នឹង ប្រទេសអ៊ីតាលី*** តុលាការសិទ្ធិមនុស្សអឺរ៉ុបបានរកឃើញថា ចៅក្រមទាំងឡាយដែលបានចូលរួមនៅក្នុងសវនាការជំនុំជម្រះលើជនជាប់ចោទចំពោះបទល្មើសនានា ពាក់ព័ន្ធនឹងការចូលរួមក្នុងអង្គការព្រហ្មទណ្ឌ (*association de malfaiteurs*) ដែលមានបំណងប្រព្រឹត្តការជួញដូរគ្រឿងញៀន ពុំមានអនាគតិភាពទេ។ ចៅក្រមបានចេញសាលក្រមលើកមុនប្រឆាំងនឹងសហជនជាប់ចោទរបស់ម្ចាស់បណ្តឹងដិតចិត្ត ដោយមានសេចក្តីយោងមួយចំនួនទៅនឹងតួនាទីរបស់ម្ចាស់បណ្តឹងដិតចិត្តនៅក្នុងអង្គការឧក្រិដ្ឋកម្ម និងបានចាត់ទុកជនជាប់ចោទថាជា "អ្នករៀបចំផែនការ ឬអ្នកញុះញង់" ឱ្យមានការប្រព្រឹត្តិអំពើជួញដូរគ្រឿងញៀន[37]។ ស្រដៀងគ្នានេះដែរ ក្នុងរឿងក្តី *Ferrantelli* ***និង*** *Santangelo* ***តទល់នឹង ប្រទេសអ៊ីតាលី*** តុលាការបានរកឃើញថា ចៅក្រមម្នាក់ ក្នុងចំណោមចៅក្រមដែលបានសម្រេចផ្តន្ទាទោសម្ចាស់បណ្តឹងដិត្តចិត្តលើបទចោទប្រកាន់ស្តីពីអំពើមនុស្សឃាត មានភាពលម្អៀងដោយសារ ទីមួយ៖ គាត់បានសម្រេចកាលពីពេលកន្លងទៅទាក់ទងនឹងបទល្មើសតែមួយដែលមាន "សេចក្តីយោងមួយចំនួនទៅលើម្ចាស់បណ្តឹង និងតួនាទីរបស់ពួកគេម្នាក់ៗ" នៅក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ និងបានយោងទៅលើម្ចាស់បណ្តឹងថាជា "សហចារី" និង ទីពីរ៖ សាលក្រមសម្រេចជាចុងក្រោយផ្តន្ទាទោសម្ចាស់បណ្តឹងដិតចិត្តមាន "ការដកស្រង់មួយចំនួនចេញពីសាលក្រមមុន[38]។ ផ្ទុយទៅវិញ នៅក្នុងរឿងក្តីរបស់ *Schwarzenberg* ***ទតល់នឹង ប្រទេសអាល្លឺម៉ង់*** តុលាការសិទ្ធិមនុស្សអឺរ៉ុបបានបដិសេធការអះអាងរបស់ម្ចាស់បណ្តឹងដិតចិត្តថា ចៅក្រមពីររូប ក្នុងចំណោមចៅក្រម

---

[37] បណ្តឹងដិត្តចិត្តលេខ ៣៩៦៧៦/៩៨, សាលក្រម, ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០០, កថាខណ្ឌ ២៩, ៣៣-៣៥។

[38] បណ្តឹងដិតចិត្តលេខ ១៩៨៧៤/៩២, សាលក្រម, ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៦ កថាខណ្ឌ ៥៩។

ដែលបានចូលរួមជំនុំជម្រះលើបទចោទប្រកាន់ស្តីពីអំពើមនុស្សឃាតរបស់ខ្លួន មិនមានអនាគតិភាពទេ ដោយសារតែពួកគាត់បានចេញសេចក្តីសម្រេចទៅលើអ្នកសមគំនិតជាមួយម្ចាស់បណ្តឹងជិតចិត្ត។ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា ទោះបីជាសាលក្រមមុនមានចំណុចស្តីពីតួនាទីរបស់ម្ចាស់បណ្តឹងជិតចិត្ត នៅក្នុងអំពើមនុស្សឃាតក៏ដោយ ក៏មិនមានការវាយតម្លៃពីមុនទៅលើពិរុទ្ធភាពរបស់ម្ចាស់បណ្តឹងជិតចិត្តនោះទេ ដោយសារម្ចាស់បណ្តឹងជិតចិត្ត មិនបានផ្តល់សក្ខីកម្មនៅឡើយទេ ហើយតុលាការថ្នាក់តំបន់បានបញ្ជាក់ថា សាលក្រមរបស់ខ្លួនបានសំអាងទៅលើសក្ខីកម្មរបស់ជនសមគំនិត ហើយខ្លួនមិនបានពិនិត្យលើរឿងក្តីនោះ តាមការយល់ឃើញរបស់ម្ចាស់បណ្តឹងជិតចិត្តទេ[39]។ ច្បាប់យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបបង្ហាញថា មិនមានវិធានលម្អិតនោះទេចំពោះការពិនិត្យថាតើការយល់ឃើញថាមានភាពលម្អៀងណាមួយមានភាពត្រឹមត្រូវជាសត្យានុម័តនោះ។ ករណីនីមួយៗត្រូវយកមកពិនិត្យទៅតាមភាពជាក់ស្តែងរបស់វា ដោយពិចារណាទៅលើកាលៈទេសៈទាំងអស់ *ក្នុងនោះ* រួមទាំង វិសាលភាពនៃការពិនិត្យពិច័យកាលពីលើកមុន ទៅលើការចូលរួមរបស់ជនជាប់ចោទនៅក្នុងបទល្មើសនានាដែលកំពុងត្រូវបានជំនុំជម្រះ ដំណើរការនៃការកំណត់បទល្មើសតាមផ្លូវច្បាប់ និងបរិបទជាក់លាក់នៃសេចក្តីសម្រេចកាលពីលើកមុន។

17. ដូច្នេះ ខ្ញុំយល់ឃើញថា យុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិផ្តល់ជាជំនួយតិចតួចចំពោះការកំណត់ថាតើការយល់ឃើញផ្នែកអង្គហេតុ ដែលពាក់ព័ន្ធនឹងការចូលរួមរបស់ជនជាប់ចោទនៅក្នុងបទល្មើសដែលកំពុងត្រូវបានជំនុំជម្រះនេះ អាចនាំឲ្យមានការយល់ឃើញថាមានលម្អៀងដោយរបៀបណាដែរនោះ។ សេចក្តីសម្រេចលើបណ្តឹងជិតចិត្តភាគច្រើនរបស់តុលាការ ICTY និងតុលាការ ICTR ពាក់ព័ន្ធនឹងបញ្ហាអង្គហេតុផ្សេងទៀត ដូចជា អត្ថិភាពនៃជម្លោះប្រដាប់អាវុធ[40] ភាពអាចឲ្យជឿជាក់បានរបស់សាក្សីសំខាន់ៗ[41] និងព្រឹត្តិការណ៍ជាក់លាក់ដែលមិនប៉ះពាល់ដល់

---

[39] បណ្តឹងជិតចិត្តលេខ ៧៥៧៣៧/០១, សាលក្រម, ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៦ កថាខណ្ឌ ៤៣។

[40] *ជាឧទាហរណ៍ សូមមើល* រឿងក្តីរវាង *រដ្ឋអាជ្ញា តទល់នឹង Brđanin និង Talić*, សំណុំរឿងលេខ IT-99-36-T, សេចក្តីសម្រេចលើបណ្តឹងរបស់ Momir Talić សុំប្តឹងជិតចិត្តឲ្យដកហូតចៅក្រម, អង្គជំនុំជម្រះសាលាដំបូង II នៃតុលាការ ICTY, ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០០ កថាខណ្ឌ ១៥។

[41] *ជាឧទាហរណ៍ សូមមើល* រឿងក្តីរវាង *រដ្ឋអាជ្ញា តទល់នឹង Krajišnik* សំណុំរឿងលេខ IT-00-39-PT, សេចក្តីសម្រេចលើបណ្តឹងជិតចិត្តរបស់មេធាវីការពារក្តីសុំប្តឹងដកចៅក្រមចេញពីការជំនុំជម្រះ, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY, ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៣ កថាខណ្ឌ ៦។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Katanga* សំណុំរឿងលេខ ICC-01/04-01/07-3504-Anx សេចក្តីសម្រេចរបស់កិច្ចប្រជុំពេញអង្គរបស់ចៅក្រមលើបណ្តឹងរបស់តំណាងផ្លូវច្បាប់របស់ជនរងគ្រោះប្តឹងជិតចិត្តចៅក្រម

ទង្វើរបស់ជនជាប់ចោទ[42]។ ក្នុងចំណោមរឿងក្តីមួយចំនួនដែលពាក់ព័ន្ធនឹងការពិចារណាមុនៗទៅលើអង្គហេតុទាក់នឹងការចូលរួមរបស់ជនជាប់ចោទនៅក្នុងការប្រព្រឹត្តិបទល្មើស ដែលកំពុងត្រូវបានជំនុំជម្រះនេះ និងមានការពិនិត្យថាតើសេចក្តីសម្រេចមុនៗបានបណ្តាលឱ្យជនជាប់ចោទមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ឬក៏មិនមានទេនោះ ខ្ញុំសូមបញ្ជាក់ថា សេចក្តីសម្រេចលើរឿងក្តី *Galić*[43], *Nyiramasuhuko*[44], *Ntawukulilyayo*[45] មិនពាក់ព័ន្ធទៅនឹងការយល់ឃើញរបស់

---

Christine Van den Wingaert មិនឱ្យជំនុំជម្រះលើរឿងក្តី រដ្ឋអាជ្ញា តទល់នឹង Germain Katanga ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៤ កថាខណ្ឌ ១៨។

[42] *ជាឧទាហរណ៍ សូមមើល* រឿងក្តីរវាង *រដ្ឋអាជ្ញា តទល់នឹង* Kordić និង Čerkez, សំណុំរឿងលេខ IT-95-14/2, សាលដីការបស់គណៈកម្មាធិការរដ្ឋបាលតុលាការ, គណៈកម្មាធិការរដ្ឋបាលតុលាការ ICTY, ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ១៩៩៨ (សាលដីកាលើបណ្តឹងមិតចិត្តរបស់ *Kordić*) ទំព័រ ១ ដល់ ២។ (សាលដីកាលើបណ្តឹងមិតចិត្តរបស់ *Karadžić*) កថាខណ្ឌ ២១។ រឿងក្តីរវាង *Nahimana និងជនជាប់ចោទផ្សេងទៀត តទល់នឹង រដ្ឋអាជ្ញា,* អង្គជំនុំជម្រះសាលាដំបូង II នៃតុលាការ ICTY, សំណុំរឿង ICTR-99-52-A, សាលដីកា, អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR, ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ *Nahimana*") កថាខណ្ឌ ៧៨។

[43] សាលដីកាលើបណ្តឹងមិតចិត្តរបស់ *Galić* កថាខណ្ឌ ១៣ (Galić បានប្តឹងមិតចិត្តសុំឱ្យដកហូតចៅក្រម Orie ចេញពីការជំនុំជម្រះលើរឿងក្តីរបស់គាត់ ដោយយោងទៅលើការបញ្ជាក់អះអាងកាលពីមុនរបស់ចៅក្រម Orie នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងនឹង Ratko Mladić ដែលក្នុងនោះ Galić ត្រូវបានកំណត់ឈ្មោះថា ជាអ្នកចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម។ នៅក្នុងការបដិសេធអំណះអំណាងរបស់ Galić គណៈកម្មាធិការរដ្ឋបាលតុលាការបានអះអាងថា ដោយសារភារកិច្ចនៃការបញ្ជាក់អះអាងទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងការឈានដល់ការចេញសេចក្តីសម្រេចលើពិរុទ្ធភាពនៅក្នុងសវនាការ "ពាក់ព័ន្ធនឹងទស្សនៈផ្សេងៗគ្នាចំពោះភស្តុតាង និងបទដ្ឋានផ្សេងៗនៃសាលក្រម" "នោះការបញ្ជាក់អះអាងទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនពាក់ព័ន្ធទៅនឹងការធ្វើសេចក្តីសម្រេចណាមួយដោយមិនត្រឹមត្រូវចំពោះពិរុទ្ធភាពរបស់ជនជាប់ចោទនោះទេ")។ *សូមមើល ផងដែរ រឿងក្តីរវាងរដ្ឋអាជ្ញា តទល់នឹ Galić* សំណុំរឿងលេខ IT-98-29-A, សាលដីកា, អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY, ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៦, កថាខណ្ឌ ៤៤។

[44] សេចក្តីសម្រេចលើបណ្តឹងមិតចិត្តរបស់ *Nyiramasuhuko* កថាខណ្ឌ ១៥ (ជនជាប់ចោទបានសុំឱ្យដកហូតចៅក្រម Pocar ចេញពីការជំនុំជម្រះលើបណ្តឹងសាទុក្ខជំទាស់នឹងការសម្រេចសេចក្តីផ្តន្ទាទោសលើរូបគាត់ពីបទប្រល័យពូជសាសន៍ ដោយសម្អាងថា ចៅក្រម Pocar បានចេញមតិជំទាស់កាលពីលើកមុនទៅលើបណ្តឹងសាទុក្ខរបស់ *Kalimanzira* ដែលគាត់បានសម្អាងទៅលើការអំពាវនាវរបស់ជនជាប់ចោទឱ្យសម្លាប់ជនជាតិ Tutsis។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR បានរកឃើញថា មតិរបស់ចៅក្រម Pocar ដែលធ្វើការវាយតម្លៃអំពីភាពសមហេតុផលនៃការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើអង្គហេតុនោះ មិនឈានដល់ការសម្រេចសេចក្តីឱ្យជនជាប់ចោទទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនោះទេ ហើយហេតុដូច្នេះ មិនអនុញ្ញាតឱ្យមានការដកហូតចៅក្រមបានទេ)។

ចៅក្រមដែលត្រូវបានប្ដឹងទៅលើអង្គហេតុនោះទេ ប៉ុន្តែ ការពាក់ព័ន្ធរបស់គាត់ទៅនឹងសំណុំរឿង ដែលមានលក្ខណៈផ្សេង គឺ ការបញ្ជាក់អំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងការពិនិត្យឡើងវិញ ដោយតុលាការជាន់ខ្ពស់។ បណ្ដឹងជំទាស់នៅក្នុងរឿងក្ដីទាំងនោះ ត្រូវបានបដិសេធយ៉ាងច្បាស់ក្រឡែត ដោយសារចៅក្រមដែលគេជំទាស់ មិនបានចូលរួមនៅក្នុងការសម្រេចផ្នែកអង្គហេតុ ទាក់ទងនឹងទង្វើរបស់ជនជាប់ចោទឱ្យហួសពីវិមតិសង្ស័យទេ ប៉ុន្តែបានធ្វើសេចក្ដីសម្រេចដោយអនុលោមតាមបទដ្ឋាននៃបង្ហាញភស្តុតាងមួយខុសគ្នា និងមានកម្រិតទាប[46]។ មានតែនៅក្នុងរឿងក្ដីរបស់ *Mladic* និងសំណើមុនរបស់ នួន ជា ស្នើសុំឱ្យដកហូតចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ដោយសារតែចៅក្រមបានចូលរួមចេញសេចក្ដីសម្រេចនៅក្នុងសាលក្រម ០០២/០១ ទេ បានពិចារណាទៅលើការចោទប្រកាន់ថាមានភាពលម្អៀង ដែលកើតចេញពីការយល់ឃើញមុនៗនៅក្នុងការជំនុំជម្រះ ដែលតាមការចោទប្រកាន់ មានបុរេវិនិច្ឆ័យទៅលើពិរុទ្ធភាពរបស់ជនជាប់ចោទ។ សេចក្ដីសម្រេចទាំងនេះនឹងត្រូវបានដោះស្រាយតាមលំដាប់លំដោយ។

18. *Mladić* បានស្នើសុំឱ្យដកហូតចៅក្រម Orie ចេញពីការជំនុំជម្រះលើរឿងក្ដីរបស់គាត់ ដោយសារតែគាត់បានសម្រេចកាលពីលើកមុននៅក្នុងសាលក្រមលើរឿងក្ដី *Galić* និង *Krajišnik*[47]។ នៅក្នុងចម្លើយតបរបស់គាត់ទៅនឹងបណ្ដឹងជំទាស់នេះ ចៅក្រម Orie បានបង្ហាញនូវការយល់ឃើញ

---

[45] សេចក្ដីសម្រេចលើបណ្ដឹងជំទាស់របស់ *Ntawukulilyayo* កថាខណ្ឌ ១៣, ១៧-១៨ (Ntawukulilyayo បានស្នើសុំឱ្យដកហូតចៅក្រម Güney, ចៅក្រមVaz, ចៅក្រមMeron និង ចៅក្រម Agius ចេញពីការជំនុំជម្រះប្រឆាំងនឹងរូបគាត់ ដោយសារតែមានការបញ្ជាក់អះអាងកាលពីលើកមុនរបស់ចៅក្រមទាំងនេះ ទៅលើការសម្រេចផ្ដន្ទាទោស Kalimanzira នៅក្នុងការប្ដឹងសាទុក្ខ ដែលបានសម្អាងទៅលើចម្លើយរបស់សាក្សីពីរនាក់ ដែលបានឆ្លើយដាក់ Ntawukulilyayo។ ចៅក្រមទាំងនោះមិនត្រូវបានដកចេញពីការជំនុំជម្រះទេ ដោយសារពួកគាត់មិនត្រូវបានស្នើសុំឱ្យវាយតម្លៃភស្តុតាងហួសពីវិមតិសង្ស័យនោះទេ ប៉ុន្តែ វាយតម្លៃតែទៅលើភាពសមហេតុសមផលនៃការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងមកលើ *Kalimanzira* ។ អង្គជំនុំជម្រះតុលាកការកំពូលបានសង្កត់ធ្ងន់ថា "បទដ្ឋានដែលអង្គជំនុំជម្រះតុលាការកំពូលវាយតម្លៃតែទៅលើភាពសមហេតុសមផលនៃការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង គឺខុសគ្នាពីបទដ្ឋាននៃការអះអាងលើសពីវិមតិសង្ស័យដែលតម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូងឈានដល់ការវាយតម្លៃរបស់ខ្លួន")។

[46] *សូមមើល* លេខយោងជើងទំព័របីមុន។

[47] *រឿងក្ដីរវាង រដ្ឋអាជ្ញា តទល់នឹង* *Mladić*, សំណុំរឿងលេខ IT-09-92-PT, ដីកាសម្រេចបដិសេធបណ្ដឹងរបស់មេធាវីការពារក្ដីដោយអនុលោមតាមវិធាន ១៥(ខ) ស្នើសុំឱ្យដកហូតប្រធានអង្គជំនុំជម្រះ គឺចៅក្រម Alphons Orie និងស្នើសុំឱ្យបង្អង់កិច្ចដំណើរការនីតិវិធី, ប្រធានតុលាការ ICTY, ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១២ ("សាលដីកាសម្រេចលើបណ្ដឹងជំទាស់របស់ *Mladić*")។

មួយចំនួនក្នុងសាលក្រមលើរឿងក្តី *Krajišnik* ដែលប៉ះពាល់ដល់ការចូលរួមរបស់ Mladić នៅក្នុងបណ្តាឧក្រិដ្ឋកម្មដែលកំពុងត្រូវបានជំនុំជម្រះ និងការចូលរួមរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួមជាមួយ Galić និង Krajišnik ប៉ុន្តែ បានសង្កត់ធ្ងន់ថា អង្គជំនុំជម្រះសាលាដំបូងមិនបាន "កំណត់ថាតើទង្វើរបស់ Mladić បានបំពេញគ្រប់លក្ខណៈវិនិច្ឆ័យពាក់ព័ន្ធទាំងអស់នៃបទល្មើសដែលស្ថិតនៅក្រោមលក្ខន្តិកៈរបស់តុលាការនេះដែរឬអត់ ឬថាតើ Mladić មានពិរុទ្ធភាពហួសពីវិមតិសង្ស័យចំពោះបទល្មើសបែបនេះដែរឬទេ"[48]។ ប្រធានតុលាការ ICTY បានសម្រេចថា សំណើរបស់ Mladić សុំឱ្យដកហូតចៅក្រម Orie គ្មានមូលហេតុត្រឹមត្រូវ និងបានបដិសេធមិនបង្កើតក្រុមប្រឹក្សាចេញរបាយការណ៍ទេ។ ប៉ុន្តែ ប្រធានតុលាការ ICTY មិនបានបង្ហាញមូលហេតុសម្រាប់ការសម្រេចសេចក្តីរបស់គាត់ ឬបញ្ជាក់ថាតើគាត់យល់ស្របជាមួយមតិរបស់ចៅក្រម Orie ដែរឬអត់នោះទេ[49]។ កង្វះសំអាងហេតុរបស់ចៅក្រមរូបនេះ ធ្វើឱ្យប៉ះពាល់ដល់តម្លៃនៃសេចក្តីសម្រេចទៅលើបណ្តឹងជំទាស់នេះ។

19. នៅក្នុងបញ្ហាមុនមួយនៅចំពោះមុខក្រុមប្រឹក្សាជំនុំជម្រះពិសេស នៃអង្គជំនុំជម្រះសាលាដំបូងនេះ នួន ជា បានស្នើសុំឱ្យដកហូតចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ដោយគាត់បានសំអាងទៅលើមូលដ្ឋានមួយចំនួន ក្នុងនោះមានការសម្រេចលើកមុនរបស់ចៅក្រមទាំងនោះនៅក្នុងសាលក្រមលើសំណុំរឿង ០០១ ដែលចោទប្រកាន់ថាគាត់ "មានការជាប់ពាក់ព័ន្ធ" ជាមួយឧក្រិដ្ឋកម្មដែលត្រូវបានរកឃើញថា បានប្រព្រឹត្តនៅមន្ទីរសន្តិសុខ ស-២១[50]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសនោះបានអនុវត្តបទដ្ឋានមួយ ស្រដៀងគ្នាទៅនឹងបទដ្ឋានដែលសហព្រះរាជអាជ្ញាបានលើកឡើងនៅក្នុងរឿង

---

[48] អនុស្សរណៈពីចៅក្រម Orie ផ្ញើជូនប្រធានតុលាការ ICTY ដែលមានកម្មវត្ថុ "របាយការណ៍អនុលោមតាមវិធាន ១៥(ខ)" ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១២, ដែលបានដាក់ជាឧបសម្ព័ន្ធភ្ជាប់ទៅនឹងសាលដីកាសម្រេចលើបណ្តឹងជំទាស់របស់ *Mladić* កថាខណ្ឌ ៣៤-៣៧។

[49] សាលដីកាសម្រេចលើបណ្តឹងជំទាស់របស់ *Mladić* ទំព័រ ៣។ រូបភាពស្រដៀងគ្នាបានកើតឡើងនៅពេលដែល Mladić បានស្នើសុំឱ្យដកហូតចៅក្រម Orie នាពេលនេះ ដោយសារតែការយល់ឃើញនៅក្នុងរឿងក្តីរបស់ *Stanisić និង Simatović* ក៏ដូចជានៅក្នុងករណីរបស់ចៅក្រម Flugge ដោយសារតែការយល់ឃើញនៅក្នុងរឿងក្តីរបស់ *Tolimir*។ *សូមមើល* រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Mladić* សំណុំរឿងលេខ IT-09-92-T, សេចក្តីសម្រេចទាក់ទងនឹងសារណារបស់មេធាវីការពារក្តីស្នើសុំបន្ថែមលើចំនួនពាក្យ និងបណ្តឹងជំទាស់របស់មេធាវីការពារក្តី ដោយអនុលោមតាមវិធាន ១៥(ខ) ស្នើសុំឱ្យដកហូតចៅក្រម Christoph Flügge, ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៤ ប្រធានតុលាការ ICTY ទំព័រ ៣។

[50] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើបណ្តឹងជំទាស់ កថាខណ្ឌ ៥។

ក្តីបច្ចុប្បន្ន និងបានពិនិត្យថាតើរាល់ធាតុផ្សំទាំងអស់នៃបទល្មើសដែលចោទប្រកាន់ គឺជាកម្មវត្ថុនៃការសម្រេចលើកមុនដែរឬអត់[51]។ នៅក្នុងការបដិសេធបណ្តឹងជំទាស់នេះ ក្រុមប្រឹក្សាជំនុំជម្រះពិសេសបានសម្រេចជាដំបូងថា សម្រង់អត្ថបទខ្លះក្នុងសាលក្រមសំណុំរឿង ០០២ ដែល នួន ជា បានសំអាងនោះ គ្រាន់តែបានរម្លឹកឡើងវិញអំពីសក្ខីកម្មរបស់ ឌុច ប៉ុណ្ណោះ ដូច្នេះ មិនមែនជាការយល់ឃើញទៅលើអង្គហេតុនោះទេ ហើយបានសម្រេចទៀតថា ការយល់ឃើញពាក់ព័ន្ធនឹង "តួនាទីផ្លូវការរបស់ នួន ជា នៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា" "មិនគួរត្រូវបានយល់ឃើញប្រកបដោយហេតុផល ដើម្បីឆ្លុះបញ្ចាំងទៅលើការវិនិច្ឆ័យថា គាត់មានពិរុទ្ធភាពនោះទេ"[52]។ ខ្ញុំយល់ឃើញថា សេចក្តីសម្រេចនេះមិនបង្កើតជាយុត្តិសាស្ត្រក្នុងការកំណត់ ដើម្បីដោះស្រាយរឿងក្តីបច្ចុប្បន្ននេះ ដោយសារមូលហេតុសំខាន់ៗពីរ។ ទីមួយ នៅក្នុងរឿងក្តីនោះ មិនមានការយល់ឃើញទៅលើអង្គហេតុដែលបណ្តាលឲ្យប៉ះពាល់ដល់ការចូលរួមរបស់ នួន ជា ជាមួយការប្រព្រឹត្តិបទល្មើសនៅមន្ទីរសន្តិសុខ ស-២១ ទេ ប៉ុន្តែ គ្រាន់តែជាការពិភាក្សាអំពី តួនាទីរបស់គាត់នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងន័យទូទៅតែប៉ុណ្ណោះ និងទីពីរ សាលក្រមសំណុំរឿង ០០១ បានផ្តោតទៅលើការទទួលខុសត្រូវរបស់ ឌុច ហើយ នួន ជា មិនមែនជាភាគីនៃរឿងក្តីនោះ និងមិនបានសូម្បីតែផ្តល់សក្ខីកម្មផងទេ។

20. ខ្ញុំពិចារណាឃើញថា ករណីជាច្រើនដែលបានយកមកពិភាក្សាខាងលើពាក់ព័ន្ធនឹងជនជាប់ចោទផ្សេងគ្នា មានភាពខុសគ្នាយ៉ាងខ្លាំងទៅនឹងរឿងក្តីនៅចំពោះមុខ ដែលមិនអាចធ្វើមិនដឹងមិនឮបានទេ។ នៅក្នុងការកំណត់ និងការអនុវត្តលក្ខណវិនិច្ឆ័យខាងលើ តុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបានណែនាំដោយកត្តាសំខាន់ចំនួនពីរ។ ទីមួយ ភាពចាំបាច់កើតចេញពីការដែលថា តុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវដោះស្រាយរឿងក្តីដែលត្រួតគ្នាដោយជៀសមិនរួច នៅក្នុងកាលៈទេសៈដែលមានចៅក្រមតិចតួចបំផុតនោះ[53] ដោយសារតែចរិតលក្ខណៈនៃយុត្តាធិការរបស់តុលាការទាំងនេះ និងទី

---

[51] *ដូចគ្នា* កថាខណ្ឌ ២១, ២៤។

[52] *ដូចគ្នា* កថាខណ្ឌ ២៤។

[53] *សូមមើល* បណ្តឹងជំទាស់របស់ *Kordić* ទំព័រ ២-៣ ("ចរិតលក្ខណៈនៃយុត្តាធិការរបស់តុលាការនេះគឺថា ករណីជាច្រើននៅចំពោះខ្លួនមានភាពត្រួតគ្នាដោយចៀសមិនផុត។ ម្យ៉ាង បញ្ហាដូចគ្នា និងភស្តុតាងតែមួយ តែងជាប់ពាក់ព័ន្ធគ្នា។ ម្យ៉ាងវិញទៀត តុលាការនេះមានចៅក្រមដែលមានចំនួនកម្រិត។ តាមការយល់ឃើញផ្ទុយគ្នាដែលបានសម្រេចនៅក្នុងករណីនេះ គឺកិច្ចការរបស់

ពីរ តាមរយៈការបណ្ដុះបណ្ដាល និងបទពិសោធន៍របស់ពួកគាត់ មានការសន្មតថា ចៅក្រមអាជីព នឹងសម្រេចយ៉ាងត្រឹមត្រូវទៅលើបញ្ហានៅចំពោះមុខពួកគាត់ "ដោយសំអាងផ្ដាច់មុខ និងទាំងស្រុង តែទៅលើភស្តុតាងដែលបានយកមកអះអាងនៅក្នុងរឿងក្ដីជាក់លាក់នោះ"[54]។

21. ខ្ញុំយល់ឃើញថា កត្តាទីមួយ ត្រូវតែយកមកពិចារណាដោយសំអាងទៅលើសិទ្ធិដាច់ខាតក្នុងការ ទទួលបានសាលាជម្រះក្ដីមួយដែលមិនលម្អៀង។ ជាការពិត តុលាការសិទ្ធិមនុស្សបានក្រើនរម្លឹក យ៉ាងច្បាស់ចំពោះកត្តាភាពចាំបាច់ នៅពេលធ្វើការពិនិត្យទៅលើការរំលោភលក្ខខណ្ឌតម្រូវអំពីភាព មិនលម្អៀង និងបានបញ្ជាក់ថា ករណីនីមួយៗត្រូវតែបានយកមកពិនិត្យឡើងវិញដោយយោងទៅ លើស្ថានភាពរបស់វា៖

> តុលាការកត់សម្គាល់ទៅលើការទទួចករណ៍របស់រដ្ឋាភិបាលថា ក្នុងការអនុវត្តជាក់ស្ដែង កិច្ចការ របស់តុលាការព្រហ្មទណ្ឌ តែងតែពាក់ព័ន្ធនឹងចៅក្រមដែលចូលរួមនៅក្នុងការជំនុំជម្រះផ្សេងៗ ដែលសហជនជាប់ចោទមួយចំនួនត្រូវបានចោទប្រកាន់។ តុលាការពិចារណាថា កិច្ចការរបស់ តុលាការព្រហ្មទណ្ឌនឹងមិនអាចសម្រេចទៅបានទេ ប្រសិនបើផ្អែកទៅលើអង្គហេតុតែមួយគឺ ភាពមិនលម្អៀងរបស់ចៅក្រមដែលអាចចោទជាបញ្ហា។ ប៉ុន្តែ នៅក្នុងកិច្ចដំណើរការនីតិវិធី ដែលកើតចេញពីពាក្យបណ្ដឹងបុគ្គលតែម្នាក់ នោះតុលាការត្រូវតែកម្រិតខ្លួនឯងឱ្យបានច្រើន តាមដែលអាចធ្វើទៅបាន ចំពោះការពិនិត្យពិច័យទៅលើរឿងក្ដីជាក់លាក់នៅចំពោះមុខខ្លួន។ លើសពីនេះទៅទៀត តុលាការរម្លឹកឡើងវិញថា រដ្ឋជាភាគីមានកាតព្វកិច្ចរៀបចំប្រព័ន្ធយុត្តិធម៌ របស់ខ្លួន ដើម្បីធានាឱ្យស្របនឹងលក្ខខណ្ឌតម្រូវនៃមាត្រា ៦.១ ដែលនៅក្នុងចំណោមលក្ខខណ្ឌ

តុលាការនេះនឹងឈប់ដំណើរការជាបណ្ដើរៗរហូតដល់ទីបញ្ចប់ក្នុងពេលឆាប់ៗនេះ")។ សាលដីកាលើរឿងក្ដី *Nahimana* កថាខណ្ឌ ៧៨ (ដូចគ្នា)។

[54] *ជាឧទាហរណ៍ សូមមើល* សាលដីកាលើរឿងក្ដី *Nahimana* កថាខណ្ឌ ៧៨ ("តាមរយៈការបណ្ដុះបណ្ដាល និងបទពិសោធ របស់ខ្លួន ចៅក្រមទាំងឡាយនឹងសម្រេចសេចក្ដីដោយត្រឹមត្រូវទៅលើបញ្ហានៅចំពោះមុខខ្លួន ដោយសម្អាងតែមួយគត់ និង ទាំងស្រុងទៅលើភស្តុតាងដែលបានយកមកបង្ហាញនៅក្នុងរឿងក្ដីជាក់លាក់") កថាខណ្ឌ ៨៤ ("នៅក្នុងរឿងក្ដីជាក់លាក់មួយ ចៅក្រមចេញសេចក្ដីរបស់ខ្លួនដោយសម្អាងតែមួយគត់ និងទាំងស្រុង ទៅលើមូលដ្ឋានភស្តុតាងដែលបានយកមកបង្ហាញនៅក្នុង រឿងក្ដីនោះ")។ សេចក្ដីសម្រេចលើបណ្ដឹងមិតចិត្តរបស់ *Galić* កថាខណ្ឌ ១៦។

ទាំងនោះ ភាពមិនលម្អៀងគឺជាលក្ខខណ្ឌមួយដ៏សំខាន់បំផុត។ ភារកិច្ចរបស់តុលាការ គឺត្រូវពិចារណាថាតើរដ្ឋជាភាគីសម្រេចបានលទ្ធផលដែលកំណត់ដោយអនុសញ្ញានេះដែរឬអត់[55]។

22. ចំពោះកត្តាទីពីរ ខ្ញុំកត់សម្គាល់ឃើញថា វាអាស្រ័យទៅលើសេចក្តីសម្រេចរបស់ចៅក្រម Mason នៃតុលាការជាន់ខ្ពស់ប្រទេសអូស្ត្រាលីនៅក្នុងរឿងក្តី *Re JRL; Ex parte CJL*[56] ដែលត្រូវបានសម្រេចឡើងដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ៖

> "ត្រូវនិយាយឱ្យខ្លាំង និងច្បាស់ៗថា មូលដ្ឋានសម្រាប់ការប្តឹងជំទាស់ គឺការយល់ឃើញប្រកបដោយហេតុផលថា មន្ត្រីតុលាការនឹងមិនសម្រេចលើរឿងក្តីនោះដោយឥតលម្អៀង ឬដោយមិនមានបុរេវិនិច្ឆ័យ មិនមែនថា គាត់នឹងសម្រេចលើរឿងក្តីនោះដោយប្រឆាំងនឹងភាគីមួយ។ អាចមានស្ថានភាពច្រើន ដែលថាការសម្រេចមុនៗរបស់មន្ត្រីតុលាការម្នាក់លើបញ្ហាអង្គហេតុ និងអង្គច្បាប់ អាចនាំឱ្យមានការរំពឹងទុកថា គាត់ទំនងជានឹងសម្រេចលើបញ្ហានានានៅក្នុងរឿងក្តីជាក់លាក់មួយ ដោយប្រឆាំងទៅនឹងភាគីមួយក្នុងចំណោមភាគីជាច្រើនជាមិនខាន។ ប៉ុន្តែ ចំណុចនេះមិនមែនមានន័យថា ចៅក្រមនឹងដោះស្រាយបញ្ហាទាំងឡាយនៅក្នុងរឿងក្តីនោះបានដោយគ្មានចិត្តឥតលម្អៀង និងដោយគ្មានបុរេវិនិច្ឆ័យទេ ដែលការបញ្ជាក់នេះត្រូវបានប្រើប្រាស់នៅក្នុងឯកសារច្បាប់នានា ឬថា សេចក្តីសម្រេចមុនៗរបស់គាត់ ផ្តល់ជាមូលដ្ឋាន ដែលអាចទទួលយកបានសម្រាប់ការទាញសេចក្តីសន្និដ្ឋានថា មានការយល់ឃើញប្រកបដោយហេតុផលថា គាត់នឹងដោះស្រាយបញ្ហាទាំងនោះតាមរបៀបនេះឯង។ ក្នុងករណីបែបនេះ ការប្តឹងជំទាស់ត្រូវតែធ្វើឡើង ដោយបង្ហាញថា មានការយល់ឃើញប្រកបដោយហេតុផលថាមានភាពលម្អៀង ដោយសារបុរេវិនិច្ឆ័យ ហើយចំណុចនេះត្រូវតែ "បានបង្ហាញឱ្យបានច្បាស់" [...]។ ទោះបីជាសំខាន់ថា យុត្តិធម៌ត្រូវតែឱ្យគេមើលឃើញថា ត្រូវបានសម្រេចឡើងក៏ដោយ វាក៏សំខាន់ដូចគ្នាដែរថា មន្ត្រីតុលាការបំពេញភារកិច្ចរបស់ខ្លួនក្នុងការចូលរួម ឬមិនចូលរួមជំនុំជម្រះ ដោយការមានឆន្ទៈទទួលយកការលើកឡើងថាមានលេចឡើងនូវភាពលម្អៀង ត្រូវជំរុញភាគីទាំងឡាយឱ្យជឿជាក់ថា តាមរយៈការស្នើសុំឱ្យដកហូត

[55] សាលក្រមក្នុងរឿងក្តីរបស់ *Poppe* កថាខណ្ឌ ២៣ (លុបឯកសារយោង)។

[56] (ឆ្នាំ ១៩៨៦) 161 CLR 342 ត្រង់កថាខណ្ឌ ៣៥២។

ចៅក្រម នោះរឿងក្ដីរបស់ពួកគេនឹងត្រូវបានសម្រេចដោយអ្នក ដែលពួកគេបានគិតថា ទំនងជានឹងសម្រេចលើរឿងក្ដីនោះដោយផ្ដល់ផលប្រយោជន៍មកឱ្យពួកគេ”[57]។

ខ្ញុំសូមបញ្ជាក់ថា ការជំទាស់ទៅនឹងភាពឥតលម្អៀងរបស់ចៅក្រមនៅក្នុងរឿងក្ដីបច្ចុប្បន្ន មិនត្រូវបានផ្អែកទៅលើ “ការរំពឹងទុក” ថា ចៅក្រមទាំងនោះអាចសម្រេចប្រឆាំងនឹងជនជាប់ចោទនោះទេ ប៉ុន្តែ យោងទៅលើចំណុចដែលថា ពួកគាត់បានធ្វើបែបនេះរួចទៅហើយ។ ចៅក្រមដែលត្រូវបានគេជំទាស់ បានសម្រេចទៅលើបញ្ហាអង្គហេតុកាលពីមុន ហួសពីវិមតិសង្ស័យ ទាក់ទងនឹងជនជាប់ចោទដដែល និងបានយោងទៅលើភស្តុតាង ឬយ៉ាងហោចណាស់ផ្នែកខ្លះនៃភស្តុតាងដដែល។ ខ្ញុំយល់ឃើញថា អ្នកសង្កេតមិនលម្អៀង និងមានព័ត៌មានគ្រប់គ្រាន់ នឹងយល់ឃើញថា ចៅក្រមដែលត្រូវបានទាក់ទាញនៅក្នុងរឿងក្ដីមួយ ដែលមានបញ្ហាមួយចំនួន ក្នុងបទដ្ឋានកម្រិតខ្ពស់បំផុត ហួសពីវិមតិសង្ស័យ អាចមិនមានចិត្តមិនលម្អៀងមួយដោយមិនរងឥទ្ធិពលពីសេចក្ដីសន្និដ្ឋានមុនៗ ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ជនជាប់ចោទដដែល នៅក្នុងសំណុំរឿងក្រោយៗ ទោះបីជាត្រូវពួកគេបានបណ្ដុះបណ្ដាលប្រកបដោយវិជ្ជាជីវៈក៏ដោយ។ សំអាងហេតុមុនណាមួយនៅក្នុងសំណុំរឿងបច្ចុប្បន្ន មានផលប៉ះពាល់យ៉ាងខ្លាំងទៅលើការលេចឡើងនូវភាពមិនលម្អៀងរបស់ចៅក្រម ហើយចំណុចនេះត្រូវតែបានយកមកពិចារណា នៅពេលធ្វើការវាយតម្លៃលើការយល់ឃើញថាមានភាពលម្អៀងនោះ។ ក្នុងចំណុចនេះ ខ្ញុំកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានគិតថា ការបំបែកសំណុំរឿងមួយ ដែលធ្វើឱ្យមានការជំនុំជម្រះពីរដំណាក់កាលប្រឆាំងនឹងជនជាប់ចោទតែមួយ អាចបណ្ដាលឱ្យមានបញ្ហានៃភាពមិនលម្អៀងរបស់ចៅក្រមដដែល ដែលចូលរួមជំនុំជម្រះលើសំណុំរឿងដែលបានបំបែក[58]។

---

[57] រឿងក្ដីរវាង *រដ្ឋអាជ្ញា តទល់នឹង* *Brdjanin* *និង* *Talic*, សំណុំរឿងលេខ IT-99-36-T សេចក្ដីសម្រេចលើបណ្ដឹងជិតចិត្តរបស់ Momir Talic ស្នើសុំឱ្យដកហូតមួយរូប, អង្គជំនុំជម្រះសាលាដំបូង II នៃតុលាការ ICTY ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០០ កថាខណ្ឌ ១៨។

[58] រឿងក្ដីរវាង *រដ្ឋអាជ្ញា តទល់នឹង* *Mladić*, សំណុំរឿងលេខ IT-09-92-PT, សេចក្ដីសម្រេចលើពាក្យបណ្ដឹងចោទប្រកាន់រួមគ្នាដោយស្នើសុំបំបែកដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីដំណើរការសវនាការដាច់ដោយឡែកពីគ្នា និងដើម្បីកែប្រែដីកាបញ្ជូនរឿងទៅជំនុំជម្រះ, ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១១, អង្គជំនុំជម្រះសាលាដំបូង I នៃតុលាការ ICTY កថាខណ្ឌ ៣៥ (“លើសពីនេះទៀត ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានបំបែក ហើយមានសវនាការពីរ នោះអង្គជំនុំជម្រះដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងចៅក្រមអាសនៈដែលត្រូវបានចាត់តាំងឱ្យជំនុំជម្រះរឿងក្ដីបច្ចុប្បន្ន ក៏អាចនឹងត្រូវបានចាត់តាំងឱ្យឱ្យជំនុំជម្រះរឿងក្ដីទីពីរដែរ

23. យោងតាមអ្វីដែលរៀបរាប់ខាងលើ ខ្ញុំយល់ឃើញថា ការលេចឡើងនូវភាពលម្អៀងគឺជាបញ្ហាដ៏សំខាន់ដែលតម្រូវឱ្យពិចារណាទៅលើគ្រប់កាលៈទេសៈទាំងអស់នៃរឿងក្តី រួមទាំង ចរិតលក្ខណៈនៃរឿងក្តី សារៈសំខាន់នៃបញ្ហាអង្គហេតុពាក់ព័ន្ធ ដែលជាកម្មវត្ថុនៃការពិចារណាមុនៗសម្រាប់ជាដំណោះស្រាយរឿងក្តី ដំណើរការតាមផ្លូវច្បាប់ដែលចៅក្រមត្រូវបានគេជំទាស់នេះ បានចូលរួមកាលពីមុន បទដ្ឋាននៃការបង្ហាញភស្តុតាងដែលត្រូវបានប្រើប្រាស់ក្នុងការធ្វើសេចក្តីសម្រេចកាលពីលើកមុន ចំណុចដែលថាជនជាប់ចោទបានចូលរួម ឬមិនបានចូលរួមក្នុងដំណើរការនីតិវិធីលើកមុន និងភស្តុតាងដូចគ្នា ឬមិនដូចគ្នា។ ផលប៉ះពាល់ពីការសម្រេចតាមផ្លូវតុលាការកាលពីលើកមុនទៅលើការកំណត់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ គឺជាចំណុចដ៏សំខាន់នៅពេលធ្វើការពិនិត្យលើការយល់ឃើញថាមានភាពលម្អៀង ដោយសំអាងហេតុទាក់ទងនឹងការចូលរួមរបស់ជនជាប់ចោទក្នុងការប្រព្រឹត្តិបទល្មើសដែលកំពុងត្រូវជំនុំជម្រះ ងាយធ្វើអាចធ្វើឱ្យមានការប៉ះប៉ូងជិតចិត្ត ជាងការយល់ឃើញទៅលើអង្គហេតុដែលប៉ះពាល់ដល់បញ្ហាអង្គហេតុបន្ទាប់បន្សំ។

24. នៅក្នុងរឿងក្តីបច្ចុប្បន្ន ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមានតែមួយសម្រាប់រឿងក្តីទាំងពីរនេះ បានសំអាងជាសំខាន់ទៅលើការចោទប្រកាន់ថា ជនជាប់ចោទមានការទទួលខុសត្រូវលើបទល្មើសដែលកងទ័ពខ្មែរក្រហមបានប្រព្រឹត្ត ដោយសារតែការចូលរួមរបស់ពួកគេនៅក្នុងសហឧក្រិដ្ឋកម្មរួម (និងតាមរយៈទម្រង់នៃការទទួលខុសត្រូវដទៃទៀត)។ បញ្ហានៃការទទួលខុសត្រូវព្រហ្មទណ្ឌ គឺជាបញ្ហាសំខាន់ចំពោះការកំណត់លើពិរុទ្ធភាពរបស់ជនជាប់ចោទ ចំពោះបទចោទក្នុងសំណុំរឿង ០០២/០២ ហើយជាការពិត គឺជាចំណុចចម្រូងចម្រាស់សំខាន់នៅក្នុងរឿងក្តីនេះ។ ក្នុងចំណុចនេះ សំអាងហេតុសំខាន់ៗអាចធ្វើឱ្យមានការយល់ឃើញប្រកបដោយហេតុផលអំពីភាពលម្អៀង ទោះបីជាបញ្ហាអង្គហេតុបន្ទាប់បន្សំមិនទាន់ត្រូវបានវិនិច្ឆ័យនៅឡើយក្តី។ ក្នុងចំណុចនេះ ខ្ញុំកត់សម្គាល់ឃើញថា អង្គជំនុំតុលាការកំពូលបានប្រើពាក្យ "ការចូលរួមចំណែកទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ" ជាជាង "ការប្រកាស"[59] ទៅវិញ ដែលតាមរយៈនេះ បានលើកឡើងពីឥទ្ធិពលនៃសំអាង

---

[...]។ ក្នុងទិដ្ឋភាពនេះ អង្គជំនុំជម្រះពិចារណាឃើញថា មានការព្រួយបារម្ភយ៉ាងខ្លាំងផ្នែកនីតិវិធី និងការចាត់ចែង។ ភាពលម្អៀង និងការលេចឡើងនូវភាពលម្អៀងរបស់អង្គជំនុំជម្រះ អាចត្រូវបានលើកឡើង ប្រសិនបើអង្គជំនុំជម្រះតែមួយត្រូវបើកសវនាការលើរឿងក្តីទាំងពីរនោះ")។

[59] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមក្នុងសំណុំរឿង ០០២ កថាខណ្ឌ ៨៥។

ហេតុទាំងនោះ ដែលបង្កើតឲ្យមានទំនាក់ទំនងរវាងជនជាប់ចោទ និងបទល្មើសដែលត្រូវបានចោទប្រកាន់អាចមានទៅលើលទ្ធភាពរបស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ក្នុងការជំនុំជម្រះលើសំណុំរឿង ០០២/០២ ប្រកបដោយអនាគតិភាព ជាជាងការលើកឡើងថា មានតែការសម្រេចសេចក្តីលើកមុនទៅលើបញ្ហាទូទៅនៃពិរុទ្ធភាពរបស់ជនជាប់ចោទទេ ដែលអាចនាំឲ្យមានការប្តឹងជំទាស់ចិត្តនោះ។ ទីបំផុត ខ្ញុំត្រូវពិនិត្យ *ជាក់ស្តែង* (*in concreto*) ថាតើឥទ្ធិពលទូទៅនៃសំអាងហេតុក្នុងសាលក្រមសំណុំរឿង ០០២/០១ អាចនាំឲ្យអ្នកសង្កេតការណ៍មិនលម្អៀងយល់ឃើញថា ចៅក្រមដែលត្រូវបានជំទាស់ នឹងមិនអាចមានឯករាជ្យ មិនមានបុរេវិនិច្ឆ័យចំពោះសំណុំរឿង ០០២/០២ បានទេ។ ដើម្បីបង្ហាញចំណុចនេះ ខ្ញុំនឹងពិនិត្យមើលការជំទាស់តវ៉ានានា ដែលម្ចាស់បណ្តឹងបានលើកឡើង ទាក់ទងនឹងការសម្រេចជាមុនទៅលើបញ្ហាអង្គហេតុ ហើយនៅពេលចាំបាច់ និងសមស្រប នឹងពិចារណាលើបញ្ហាបន្ថែម *តាមគំនិតផ្តួចផ្តើមរបស់ខ្លួន* (*ex officio*)។ ក្នុងចំណុចនេះ ខ្ញុំកត់សម្គាល់ឃើញថា ទោះបីជាម្ចាស់បណ្តឹងបានអនុវត្តតាមអត្ថន័យទូទៅនៃវិធាន ៣៤.៣ ក្នុងការ "បង្ហាញឲ្យច្បាស់លាស់អំពីនៃមូលហេតុ" នៃបណ្តឹងជំទាស់ចិត្តរបស់ខ្លួនក៏ដោយ ក៏ពួកគាត់មិនមានភាពច្បាស់លាស់នៅត្រង់ចំណុចខ្លះដែរ។ ទោះបីជា ខៀវ សំផន បានអះអាងថា ខ្លួនយល់ស្របតាមទស្សនៈនានា និងច្បាប់យុត្តិសាស្ត្ររបស់ នួន ជា គាត់មិនបានគាំទ្រទស្សនៈទាំងនេះដោយមានឧទាហរណ៍ជាក់លាក់ចំពោះការចោទប្រកាន់លើការទទួលខុសត្រូវរបស់កូនក្តីខ្លួននោះទេ[60]។ អនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដោយកត់សម្គាល់ថា សិទ្ធិជាសារវន្តក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ មានសារសំខាន់ដែលថាតុលាការត្រូវមានកាតព្វកិច្ចធានាអំពីសិទ្ធិនេះ ខ្ញុំយល់ថាចាំបាច់ត្រូវពិនិត្យមើលកាលៈទេសៈជាក់លាក់ នៃការអះអាងជាទូទៅ*តាមគំនិតផ្តួចផ្តើមរបស់ខ្លួន*[61]។

---

[60]បណ្តឹងជំទាស់ចិត្តសាជាថ្មីប្រឆាំងនឹងសមាសភាពចៅក្រមបច្ចុប្បន្ននៃអង្គជំនុំជម្រះសាលាដំបូង ដែលត្រូវសម្រេចលើសំណុំរឿង ០០២/០២, ឯកសារ E314/8 , ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ៩។

[61] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ កថាខណ្ឌ ៤៥។ *សូមមើល ផងដែរ* គណៈកម្មាធិការសិទ្ធិមនុស្ស រឿងក្តីរវាង *Karttunen តទល់នឹង ប្រទេសហ្វាំងឡង់* ពាក្យបណ្តឹងលេខ 387/1989, ឯកសារ អ.ស.ប CCPR/C/46/D/387/1989 (១៩៩២) កថាខណ្ឌ ៧.២៖ ("ក្នុងករណីដែលមូលហេតុសម្រាប់ការប្តឹងជំទាស់ចិត្តសុំដកចៅក្រមត្រូវបានកំណត់ដោយច្បាប់ នោះវាជាតួនាទីរបស់ចៅក្រមក្នុងការពិចារណាដោយឯកឯងទៅលើមូលហេតុទាំងនេះ និងត្រូវជំនួសសមាជិកតុលាការដែលមិនបានបំពេញលក្ខណៈវិនិច្ឆ័យ សម្រាប់ការប្តឹងជំទាស់ចិត្តនេះ។ ការជំនុំជម្រះដែលមានកុណាវិបត្តិដោយសារការចូលរួមរបស់ចៅក្រម ដែលយោងតាមលក្ខន្តិកៈជាតិ គួរតែត្រូវបានដកហូតនោះ មិនត្រូវ

## IV. ការវិភាគ

25. ខ្ញុំបានពិនិត្យសាលក្រមសំណុំរឿង ០០២/០១ ហើយពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញសំអាងហេតុលើបញ្ហាចំពោះមុខ និងសំខាន់មួយចំនួនសម្រាប់ការសម្រេចនៅក្នុងសំណុំរឿង ០០២/០២ ដែលមានឥទ្ធិពលបង្ហាញនូវការសន្មតពីការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ នួន ជា និង ខៀវ សំផន ចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលនឹងត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២។ ខ្ញុំសូមបង្ហាញសំអាងហេតុដែលជាការព្រួយបារម្ភចំបងរបស់ខ្ញុំដូចខាងក្រោម។ ខ្ញុំក៏បានដាក់ឯកសារឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងមតិយោបល់នេះផងដែរ ដោយឯកសារឧបសម្ព័ន្ធនេះមានចំណុចដកស្រង់ចេញពីដីកាដំណោះស្រាយលើបញ្ហានានាដែលនឹងនឹងត្រូវវិនិច្ឆ័យនៅក្នុងសំណុំរឿង ០០២/០២ និងបង្ហាញសំអាងហេតុត្រង់ចំណុចទាំងនោះនៅក្នុងសាលក្រមសំណុំរឿង ០០២/០១។

### *(i) ការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល*

26. អង្គជំនុំជម្រះសាលាដំបូងបានផ្តល់សំអាងហេតុ ដែលជាមូលដ្ឋានសំខាន់ចំពោះការទទួលខុសត្រូវដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទទាំងពីរនៅក្នុងសំណុំរឿង ០០២។ នៅក្នុងសាលក្រម

---

ចាត់ទុកថាមានភាពយុត្តិធម៌ ឬមានអនាគតិភាពជុំវិញអត្ថន័យនៃមាត្រា ១៤ នោះទេ")។ រឿងក្តីរវាង *Remli តទល់នឹង ប្រទេសបារាំង* ពាក្យបណ្តឹងលេខ ១៦៨៣៩/៩០, សាលក្រម, តុលាការសិទ្ធិមនុស្ស, ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៩៦, កថាខណ្ឌ ៤៨ ("ដូចគណៈកម្មាធិការសិទ្ធិមនុស្សដែរ តុលាការយល់ឃើញថា មាត្រា ៦ កថាខណ្ឌ ១ (មាត្រា ៦-១) នៃកតិកាសញ្ញាកំណត់កាតព្វកិច្ចទៅលើតុលាការជាតិទាំងអស់ដើម្បីពិនិត្យមើល ដូចដែលមានចែងស្រាប់ ថាតើតុលាការនេះជា "តុលាការឥតលម្អៀង" ដែលស្ថិតនៅក្នុងអត្ថន័យនៃបទប្បញ្ញត្តិនោះ (មាត្រា ៦-១) ដែរឬអត់ ក្នុងករណីដែលត្រូវបានជំទាស់តវ៉ាដោយសារមូលហេតុដែលមិនបានលេចឡើងភ្លាមៗ ដូចជាគ្មានមូលហេតុអ្វីទាល់តែសោះនោះ")។ *ផលវិបាកតាមផ្លូវច្បាប់នៃការសាងសង់ជញ្ជាំងនៅក្នុងដែនដីដែលកាន់កាប់ដោយប៉ាឡេស្ទីន*, ដីកាសម្រេច ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០០៤, របាយការណ៍របស់តុលាការយុត្តិធម៌អន្តរជាតិឆ្នាំ ២០០៤ មតិជំទាស់របស់ចៅក្រម Buergenthal ទំព័រ ៩ កថាខណ្ឌ ១១ ("ការចាត់ចែងរដ្ឋបាលយុត្តិធម៌ឲ្យបានត្រឹមត្រូវ និងយុត្តិធម៌កំណត់ថា យុត្តិធម៌មិនត្រឹមតែត្រូវបានសម្រេចឡើងប៉ុណ្ណោះទេ ប៉ុន្តែ យុត្តិធម៌ក៏ត្រូវគេមើលឃើញថា ត្រូវបានសម្រេចឡើងផងដែរ។ តាមការយល់ឃើញរបស់ខ្ញុំ គោលការណ៍នេះត្រូវតែបានយកមកណែនាំដល់តុលាការទាំងអស់ ថាតើលក្ខន្តិកៈ ឬឯកសារដទៃទៀតរបស់ខ្លួនកំណត់យ៉ាងច្បាស់ឲ្យចៅក្រមទាំងអស់ធ្វើដូច្នោះដែរឬអត់។ សិទ្ធិអំណាច និងកាតព្វកិច្ចនេះមានលក្ខណៈច្បាស់លាស់នៅក្នុងទស្សនៈទានរបស់តុលាការទាំងអស់ ដែលត្រូវបានប្រគល់ភារកិច្ចឲ្យធ្វើការចាត់ចែងយុត្តិធម៌ប្រកបដោយភាពត្រឹមត្រូវ និងឥតលម្អៀង")។

០០២/០១ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា យ៉ាងហោចណាស់ក្នុងរយៈពេលចាប់ពីខែ មិថុនា ឆ្នាំ ១៩៧៤ រហូតដល់ ខែ ធ្នូ ឆ្នាំ ១៩៧៧ នួន ជា និង ខៀវ សំផន គឺជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម "ដែលមានផែនការរួម "ដើម្បីបង្កើតនៅក្នុងប្រទេសកម្ពុជានូវបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សតាមរយៈគ្រប់មធ្យោបាយចាំបាច់ "សន្ទុះមហាលោតផ្លោះ" និងដើម្បីការពារបក្សប្រឆាំងនឹងសត្រូវផ្ទៃក្នុង ក៏ដូចជាសត្រូវខាងក្រៅ"[62]។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានកម្រិតការវិភាគរបស់ខ្លួនលើការអនុវត្តគោលបំណងរួមត្រឹមផែនការ និងការអនុវត្តគោលនយោបាយចំនួន ២ ទាក់ទងនឹងសំណុំរឿង ០០២/០១ ពោលគឺ ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ និងការកំណត់គោលដៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដែលជាផ្នែកមួយនៃគោលនយោបាយធំៗរបស់ប.ក.ក ក្នុងការលុបបំបាត់ខ្មាំងក៏ដោយ[63] ក៏អង្គជំនុំជម្រះបានបង្ហាញសំអាងហេតុជាមូលដ្ឋានសំខាន់លើបញ្ហាចំពោះមុខ និងសំខាន់មួយចំនួនទាក់ទឹងនឹងសហឧក្រិដ្ឋកម្មរួមដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០២។ ឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ពហុភាពនៃបុគ្គល គោលបំណងរួម សមាជិកភាពរបស់ជនជាប់ចោទនៅក្នុងសហឧក្រិដ្ឋកម្មរួម និងការអនុវត្តសហឧក្រិដ្ឋកម្មរួម ដែលទាំងអស់នេះជាបញ្ហាចំពោះមុខនៅក្នុងសំណុំរឿង ០០២/០២ ត្រូវបានបង្ហាញហួសពីវិមតិសង្ស័យ។ លើសពីនេះទៀត ទោះបីជាអង្គជំនុំជម្រះសាលាដំបូងមិនបានវិភាគលើការអនុវត្តគោលនយោបាយទាំងអស់យ៉ាងស៊ីជម្រៅក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា គោលនយោបាយទាំង ៥ របស់ ប.ក.ក ដែលជនជាប់ចោទត្រូវបានចោទប្រកាន់ថាបានបង្កើតឡើង និងអនុវត្ត រួមទាំង គោលនយោបាយលុបបំបាត់ខ្មាំង បង្កើតសហករណ៍ និងការដ្ឋានការងារ បង្ខំប្រជាជនឱ្យរៀបការ និងកំណត់គោលដៅក្រុមជាក់លាក់ ដែលនឹងត្រូវយកមកវិនិច្ឆ័យនៅក្នុងសំណុំរឿង ០០២/០២ ត្រូវបានបង្ហាញភ័ស្តុតាងរួចអស់ហើយ[64]។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានអះអាងថាបានកម្រិតសំអាងហេតុខ្លះត្រឹមរយៈពេលមុនខែ មេសា ឆ្នាំ ១៩៧៥ ក៏ដោយ[65] ក៏សាលក្រមសំណុំរឿង ០០២/០១ ពោរពេញទៅដោយ

[62] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៧៧។

[63] *សូមមើល ឧ.* សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧២៣។

[64] *សូមមើល ឧ.* សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១១២ កថាខណ្ឌ ១១៦ កថាខណ្ឌ ១១៨ កថាខណ្ឌ ១២៧ និងកថាខណ្ឌ ១៣០។

[65] *សូមមើល ឧ.* សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១១២ ("អង្គជំនុំជម្រះយល់ថា គោលនយោបាយនៃការផ្លាស់ទីលំនៅម្តងហើយម្តងទៀត ពីទីប្រជុំជន និងទីក្រុង ទៅកាន់ទីជនបទ បានកើតមានតាំងពីមុនរបបកម្ពុជាប្រជាធិបតេយ្យមកម្ល៉េះ"

សំអាងហេតុដែលសន្មតអំពីអត្ថិភាពនៃគោលនយោបាយទាំងនេះ នៅក្នុងអំឡុងពេលនៃសម័យកម្ពុជាប្រជាធិបតេយ្យទាំងមូល ព្រមទាំងសំអាងហេតុដែលបានបង្ហាញថា គោលនយោបាយបែបនេះពិតជាមានអត្ថិភាពក្រោយខែ មេសា ឆ្នាំ ១៩៧៥[66]។ នៅក្នុងចំណុចជាច្រើន អង្គជំនុំជម្រះសាលាដំបូងក៏បានបង្ហាញសំអាងហេតុដែលពិតជាទំនងបញ្ជាក់អំពីការចូលរួមរបស់ជនជាប់ចោទនៅក្នុងសហឧក្រិដ្ឋកម្មរួមទាក់ទងនឹងគោលនយោបាយនៅក្នុងសំណុំរឿង ០០២/០២៖ ឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា នួន ជា ខៀវ សំផន និងអ្នកផ្សេងទៀត បានជួបប្រជុំ "ទៀងទាត់" ដើម្បី "ពិភាក្សាគោលនយោបាយ និងផែនការកសាង និងការពារប្រទេសសង្គមនិយម ឯករាជ្យ ខ្លួនទីពឹងខ្លួន ដូចជាការបង្កើតសហករណ៍ជាដើម"[67] ហើយមាន "ផែនការដែលមានផែនការ

---

។) កថាខណ្ឌ ១១៦ ("អង្គជំនុំជម្រះជឿជាក់ថា នៅមុនឆ្នាំ ១៩៧៥ ពិតជាមានគោលនយោបាយបក្សកុម្មុយនីស្ត-កម្ពុជា ដើម្បីបង្កើតសហករណ៍"។) កថាខណ្ឌ ១២៧ ("គោលនយោបាយរបស់បក្ស-កុម្មុយនីស្តកម្ពុជា ដែលកំណត់គោលដៅលើទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ មានអត្ថិភាពតាំងពីមុនឆ្នាំ ១៩៧៥ មកម្ល៉េះ")។

[66] *សូមមើល ខ.* គោលនយោបាយទាក់ទងនឹងការបង្កើត និងការដំណើរការសហករណ៍ និងការដ្ឋានការងារ៖ សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៤០ ("យ៉ាងយូរបំផុតត្រឹម" ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៧៥ នោះ គណៈកម្មាធិការថ្នាក់ដឹកនាំចម្រុះបានជួបប្រជុំគ្នាជាមួយនឹង "លេខាភូមិភាគ និងលេខាតំបន់ស្វយ័តនានា និងអ្នកផ្សេងទៀត" ដើម្បី "ពិភាក្សាអំពីគោលនយោបាយ និងផែនការនានា ដើម្បីកសាង និងការពារប្រទេសសង្គមនិយម ឯករាជ្យ ខ្លួនទីពឹងខ្លួន ក៏ដូចជាការបង្កើត សហករណ៍ផងដែរ"។) កថាខណ្ឌ ៧៥១ (ខៀវ សំផន បានចូលរួមប្រជុំ "នៅចុងខែ មេសា និងខែ ឧសភា ឆ្នាំ ១៩៧៥ ដែលក្នុងកិច្ចប្រជុំនេះ បានដោះស្រាយលើបញ្ហាគោលនយោបាយសេដ្ឋកិច្ចដទៃទៀត រួមទាំងការបង្កើតសហករណ៍ផងដែរ"។) កថាខណ្ឌ ៧៦៥ (ខៀវ សំផន បានយល់ស្របលើគោលនយោបាយទាក់ទងនងសហករណ៍។) កថាខណ្ឌ ៩០០ ("យ៉ាងយូរបំផុត ចាប់ពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៧៥ នួន ជា បានជួបប្រជុំជាមួយនឹងមេដឹកនាំជាន់ខ្ពស់ផ្សេងៗទៀត អំពីគោលនយោបាយកសាង និងការពារប្រទេសដែលមានឯករាជ្យ ខ្លួនទីពឹងខ្លួន និងសង្គមនិយម។ ផែនការនេះមានគោលបំណងបង្កើតសង្គមគ្មានវណ្ណៈមួយ ដែលប្រជាជនគ្រប់គ្នានឹងត្រូវបានរៀបចំបញ្ចូលទៅក្នុងសហករណ៍"។) កថាខណ្ឌ ៩៦៧ ("យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៧៥ ខៀវ សំផន បានបង្កើតក្រុមមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដែលស្ថិតនៅក្នុងស្ថានីយ៍អាយស្ម័យយានភ្នំពេញ និងក្រោយមកនៅអតីតអគាររបស់ក្រសួងហិរញ្ញវត្ថុ និងនៅព្រះវិហារប្រាក់ (ព្រះវិហារព្រះកែវមរកត) ដែលកិច្ចប្រជុំត្រូវបានធ្វើឡើងដើម្បីពិភាក្សាអំពីគោលនយោបាយ និងផែនការដើម្បីកសាង និងការពារប្រទេស ដែលអាចទីពឹងខ្លួនឯង ឯករាជ្យ និងសង្គមនិយម ដូចជាការបង្កើតសហករណ៍"។) កថាខណ្ឌ ៦០៤ ("ថ្នាក់ដឹកនាំបក្សបានសម្រេចថា បក្សនឹងពង្រីកសហករណ៍"។) កថាខណ្ឌ ៦១៦ ("នៅពាក់កណ្តាលឆ្នាំ ១៩៧៦ បក្សបានប្រកាសថា បក្សបានចាត់តាំង កសាង ពង្រឹង និងពង្រីករបបសមូហភាព")។

[67] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៤០។ *សូមមើលផងដែរ* កថាខណ្ឌ ៧៤៣ ("នួន ជា និង ខៀវ សំផន ព្រមទាំងអ្នកដទៃទៀតដែលរួមមានទាំងតំណាងមកពីគ្រប់ភូមិភាគ បានជួបប្រជុំគ្នានៅ ព្រះវិហារព្រះកែវមរកត ដើម្បីស្តាប់ទឡ្ហីករណ៍

គ្រោងទុកយ៉ាងប្រយ័ត្នប្រយែង” ដោយថ្នាក់ដឹកនាំ ប.ក.ក ក្នុងការ “បង្កើន និងធ្វើឱ្យការការពារជាតិ (តាមរយៈការបង្កើតសហករណ៍នានា) មានភាពល្អប្រសើរឡើង”[68]។ អង្គជំនុំជម្រះសាលាដំបូងក៏បានបង្ហាញសំអាងហេតុអំពីការគ្រប់គ្រងសហករណ៍ និងបានយកសហករណ៍ទាំងនេះមកដាក់បញ្ចូលនៅក្នុងខ្សែសង្វាក់នៃការបញ្ជាផងដែរ[69]។

27. ខ្ញុំទទួលស្គាល់ថា ដោយសារតែរបៀបរៀបចំដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងការចោទប្រកាន់លើសហឧក្រិដ្ឋកម្មរួម ទំនងជាមិនអាចដោះស្រាយដោយឡែកៗអំពីគោលនយោបាយផ្សេងៗដែលទាក់ទងគ្នាខ្លាំងនោះទេ (ឧទាហរណ៍ គោលនយោបាយស្តីពីការផ្លាស់ទីលំនៅប្រជាជន ដែលគោលបំណងមួយក្នុងចំណោមគោលបំណងផ្សេងៗរបស់គោលនយោបាយនោះគឺការបង្កើត និងពង្រីកសហករណ៍ និងគោលនយោបាយបង្កើត និងដំណើរការសហករណ៍ និងការដ្ឋានការងារ)[70]។ ជាមួយគ្នានេះដែរ គ្មានអ្វីត្រូវសង្ស័យទេថា សំអាងហេតុអំពីការចូលរួមរបស់ជនជាប់ចោទនៅក្នុងសហឧក្រិដ្ឋកម្មរួមជាការចាំបាច់សម្រាប់ការសម្រេចក្នុងសំណុំរឿង ០០២/០១។ ទោះបីជាយ៉ាងនេះក៏ដោយ ករណីនេះមិនអាចជាយុត្តិកម្មចំពោះការយល់ឃើញពីបុរេវិនិច្ឆ័យ ដោយសារតែសំអាងហេតុទាំងនោះឡើយ។ ក្រោយពីបានជឿជាក់លើបញ្ហាទាំងនេះហួសពីវិមតិសង្ស័យ យោងតាមកាតព្វកិច្ចតុលាការរបស់ចៅក្រមទាំងនេះ យើងពិបាកជឿថាតើចៅក្រមដដែលនេះអាចមាន

---

ចំពោះការជម្លៀសប្រជាជនចេញពីទីក្រុង ព្រមទាំងមានការផ្តល់អាទិភាពទៅលើតម្រូវការក្នុងការកសាង និងការពារប្រទេសយ៉ាងឆាប់រហ័ស តាមរយៈការបង្កើតសហករណ៍”)។

[68] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៨០៧ (“របាយការណ៍របស់ គណៈកម្មាធិការអចិន្ត្រៃយ៍ បានបង្ហាញពីឥរិយាបទទឹងសម្បាររបស់សមាជិកគណៈកម្មាធិការ អចិន្ត្រៃយ៍ចំពោះប្រជាជនថ្មី។ របាយការណ៍នេះបានកំណត់អំពីផែនការរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងការបង្ខំឱ្យប្រជាជនថ្មីទាំងអស់រស់នៅក្នុងសហករណ៍”។ អង្គជំនុំជម្រះយល់ឃើញថា របាយការណ៍នេះ បានបង្កើតផែនការដែលមានការគ្រោងទុកយ៉ាងប្រយ័ត្នប្រយែងរបស់ថ្នាក់ដឹកនាំដើម្បីបង្កើន និងធ្វើឱ្យការការពារជាតិ (តាមរយៈការបង្កើតសហករណ៍នានា) និងសេដ្ឋកិច្ច (តាមរយៈការផ្លាស់ទីលំនៅប្រជាជន) មានភាពល្អប្រសើរ ឡើង”)។

[69] ឧទាហរណ៍ អង្គជំនុំជម្រះបានរកឃើញថា “ឋានានុក្រមគ្រប់កំរិតទាំងអស់ ដែលមានភូមិភាគ តំបន់ ស្រុក ឃុំ និងសហករណ៍ ត្រូវបានគ្រប់គ្រងដោយគណៈកម្មាធិការ” (សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ២១៨) និង “ក្រៅពីកងទ័ពភូមិភាគ តំបន់ និងស្រុក ក៏នៅមានកងឈ្លបតាមមូលដ្ឋានផងដែរ ដែលស្ថិត នៅក្រោមការគ្រប់គ្រងរបស់គណៈឃុំ ដែលទទួលខុសត្រូវលើផ្នែកសន្តិសុខ និងវិន័យនៅតាមភូមិ ឃុំ និងសហករណ៍នានា” (សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ២៤៦) ។

[70] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៧៦ (“ដើម្បីកសាង និងពង្រីកសហករណ៍ឱ្យបាននោះ បក្សត្រូវផ្លាស់ទីលំនៅប្រជាជន។ ថ្នាក់ដឹកនាំបក្សមានជំនឿថា ការផ្លាស់ទីលំនៅប្រជាជន អនុញ្ញាតឱ្យបក្សអាចជម្នះលើបញ្ហាប្រឈមនានាក្នុងការកសាង និងការពារប្រទេស និងក្នុងការរៀបចំប្រជាជន សេដ្ឋកិច្ច នយោបាយ និងយោធាឡើងវិញ”)។

គំនិតមិនលម្អៀងដោយពុំទទួលរងឥទ្ធិពលនៃសេចក្តីសន្និដ្ឋានទាំងនេះយ៉ាងដូចម្តេច នៅពេលសម្រេចលើការចោទប្រកាន់អំពីការទទួលខុសត្រូវរបស់ជនជាប់ចោទដដែលក្នុងការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមដូចគ្នានៅក្នុងការជំនុំជម្រះក្រោយនោះ។

### *(ii) សំអាងហេតុជាក់លាក់ចំពោះ នួន ជា*

28. នួន ជា សន្និដ្ឋានថា សំអាងហេតុរបស់ចៅក្រមអំពីតួនាទី និងការទទួលខុសត្រូវរបស់គាត់ "ជាទូទៅ និងជាពិសេស" ធ្វើឱ្យមានបុរេវិនិច្ឆ័យលើបញ្ហានានា និងបានបង្កើត ទស្សនៈជាមុនដែលមានលក្ខណៈអវិជ្ជមានចំពោះការការពារក្តីរបស់មេធាវីនៅក្នុងសំណុំរឿង ០០២/០២[71]។ នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា នួន ជា បានត្រួតពិនិត្យលើសកម្មភាពទាំងអស់របស់បក្ស បានអនុវត្តអំណាចធ្វើសេចក្តីសម្រេចចុងក្រោយរបស់បក្ស និងបានកាន់កាប់ ព្រមទាំងអនុវត្តអំណាចក្នុងការបង្កើត និងអនុវត្តគោលនយោបាយ និងសេចក្តីសម្រេចរបស់ ប.ក.ក[72]។ ខ្ញុំពិចារណាឃើញថា សំអាងហេតុសំខាន់ៗទាំងនេះ ដែលទាក់ទងសំខាន់ជាគន្លឹះទៅនឹងការទទួលខុសត្រូវជាលក្ខណៈបុគ្គលរបស់ នួន ជា រួមជាមួយនឹងសំអាងហេតុផ្សេងទៀតដែលមានលក្ខណៈទូទៅអំពីការទទួលខុសត្រូវ ដូចជាថា នួន ជា បានធ្វើការគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពលើសមាជិក ប.ក.ក និងកងទ័ពខ្មែរក្រហមនោះ[73] អាចនាំឱ្យអ្នកសង្កេតការណ៍ដោយមិនលម្អៀងសន្និដ្ឋានយ៉ាងសមហេតុផលថា ចៅក្រមដែលបានចូលរួមជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ បានធ្វើការសម្រេចជាមុនពីការទទួលខុសត្រូវរបស់ នួន ជា ចំពោះឧក្រិដ្ឋកម្មនានា ដែលកងទ័ពខ្មែរក្រហមបានប្រព្រឹត្តនៅក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ។

---

[71] បណ្តឹងមិតចិត្តរបស់ នួន ជា កថាខណ្ឌ ១០៦-១១១។

[72] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៤៨ ("ដោយសារមានតួនាទីខ្ពស់នៅក្នុងថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា នួន ជា ទទួលខុសត្រូវលើសកម្មភាពទាំងអស់របស់បក្ស ដែលលើសពីតួនាទី និងការទទួលខុសត្រូវដែលត្រូវបានប្រគល់ជូនគាត់ជាផ្លូវការក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ")។ *សូមមើលផងដែរ* កថាខណ្ឌ ៨៧៥ ("នួន ជា គឺជាតួអង្គដ៏សំខាន់ដែលទទួលខុសត្រូវចំពោះការរៀបចំតាក់តែងគោលនយោបាយរបស់បក្ស")។

[73] *សូមមើល ឧ.* សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៨៧ កថាខណ្ឌ ៨៩៦ កថាខណ្ឌ ៩១៣ កថាខណ្ឌ ៩៣៣។ *សូមមើលផងដែរ* សំអាងហេតុជារួមថា "ការទទួលខុសត្រូវជាផ្លូវការរបស់ នួន ជា ខាងឃោសនាការ និងបញ្ហាពាក់ព័ន្ធនឹងសិក្សាធិការ ក៏រួមបញ្ចូលទាំងវិន័យរបស់កម្មាភិបាល និង បញ្ហាសន្តិសុខផ្ទៃក្នុងផ្សេងទៀតផងដែរ" (កថាខណ្ឌ ៣២៩)។

01059757



29. ខ្ញុំយល់ឃើញថា សំអាងហេតុទូទៅអំពីការទទួលខុសត្រូវទាំងនេះធ្វើឱ្យមានការព្រួយបារម្ភយ៉ាងខ្លាំងនៅពេលពិចារណារួមជាមួយនឹងសំអាងហេតុជាក់លាក់អំពីការទទួលខុសត្រូវរបស់ នួន ជា ចំពោះប្រធានបទជាក់លាក់ដែលត្រូវបានដាក់បញ្ចូលនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ដូចជា ការបោសសម្អាតផ្ទៃក្នុងជាដើម[74]។ អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសាលក្រមសំណុំរឿង ០០២/០១ បានយល់ឃើញថា "នួន ជា ក៏ជាប់ពាក់ព័ន្ធនឹងការបោសសម្អាតកម្មាភិបាល និងយោធា ជាពិសេសអ្នកដែលមកពីភូមិភាគបូព៌ាផងដែរ"[75]។ ដោយមានសំអាងហេតុថា (១) មានការបោសសម្អាតផ្ទៃក្នុងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និង (២) នួន ជា បានជាប់ពាក់ព័ន្ធជាមួយនឹងការបោសសម្អាតទាំងនេះ ខ្ញុំពិចារណាឃើញថា មានមូលដ្ឋានសម្រាប់សន្និដ្ឋានថា អ្នកសង្កេតការណ៍មិនលម្អៀង ដែលបានទទួលព័ត៌មានគ្រប់គ្រាន់នោះ នឹងមើលដឹងយ៉ាងសមហេតុផលអំពីភាពលម្អៀងរបស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងការចោទប្រកាន់អំពីការទទួលខុសត្រូវរបស់ នួន ជា លើការបោសសម្អាតផ្ទៃក្នុងដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ដោយសារថាអង្គជំនុំជម្រះសាលាដំបូងធ្លាប់មានសំអាងហេតុដោយផ្ទាល់លើបញ្ហាចំពោះមុខមួយនៅក្នុងសំណុំរឿង ០០២/០២ ដែលទាក់ទងដោយផ្ទាល់នឹងការចោទប្រកាន់អំពីការទទួលខុសត្រូវរបស់ នួន ជា នោះ ខ្ញុំយល់ឃើញថា សេចក្តីសន្និដ្ឋានរបស់ នួន ជា មានហេតុផលត្រឹមត្រូវ ដែលថា ការសម្រេចជាមុនរបស់ចៅក្រមលើបញ្ហាទាំងនេះនឹងបណ្តាលឱ្យមានការលេចឡើងនូវភាពលម្អៀង ប្រសិនបើចៅក្រមទាំងនេះបន្តចូលរួមជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២ នោះ[76]។

30. ស្រដៀងគ្នានេះដែរ សហករណ៍ និងការដ្ឋានការងារ ត្រូវបានដាក់បញ្ចូលនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ដោយសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមបានដាក់បញ្ចូល "មូលដ្ឋានឧក្រិដ្ឋកម្ម" នៃសហករណ៍ត្រាំកក់ និងការដ្ឋានទំនប់ ១ មករា និងការចោទប្រកាន់អំពីគោលនយោបាយសហឧក្រិដ្ឋកម្មរួមក្នុងការអនុវត្ត និងការពារ "បដិវត្តន៍សង្គមនិយមគឺការបង្កើត

[74] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ ទំព័រ ២១។

[75] សំណុំរឿង ០០២/០១ កថាខណ្ឌ ៣៩០។

[76] បណ្តឹងជំទាស់របស់ នួន ជា កថាខណ្ឌ ១១១។

និងការទាញយកផលប្រយោជន៍ពីសហករណ៍ និងពីការដ្ឋានតាមរយៈគ្រប់មធ្យោបាយចាំបាច់"[77]។ នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញសំអាងហេតុមួយចំនួនលើតួនាទីរបស់ នួន ជា នៅក្នុងការបង្កើត និងការអនុវត្តគោលនយោបាយលើសហករណ៍ (ពោលគឺនៅក្នុងបរិបទនៃសហឧក្រិដ្ឋកម្មរួម ប៉ុន្តែក៏ជាប់ទាក់ទងនឹងទម្រង់នៃការទទួលខុសត្រូវផ្សេងទៀតផងដែរ)[78]។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា "នួន ជា បានចូលរួមជាមួយនឹងមេដឹកនាំសំខាន់ៗផ្សេងទៀតនៅក្នុងកិច្ចប្រជុំក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ ដើម្បីពិភាក្សាអំពីផែនការរបស់ថ្នាក់ដឹកនាំក្នុងការសម្រេចឱ្យបាននូវបដិវត្តន៍សង្គមនិយម តាមរយៈការអនុវត្តសមូហភាវូបនីយកម្ម"[79]។ "នួន ជា បានជួបប្រជុំជាមួយនឹងមេដឹកនាំជាន់ខ្ពស់ផ្សេងៗទៀត អំពី

---

[77] បញ្ជីកថាខណ្ឌពាក់ព័ន្ធនឹង សំណុំរឿង ០០២/០២ (ដែលបានបញ្ចូលកថាខណ្ឌ ១៦៨-១៧៧ នៃដីកាដំណោះស្រាយ រួមទាំងចំណុចដកស្រង់ខាងលើពីកថាខណ្ឌ ១៦៨ នៃដីកាដំណោះស្រាយ) និងទំព័រ ២ (ដែលបានបញ្ចូលកថាខណ្ឌ ៣០២-៣២១ និង ៣៥១-៣៦៧ នៃដីកាដំណោះស្រាយលើសហករណ៍ត្រាំកក់ និងការដ្ឋានទំនប់ ១ មករា)។

[78] *សូមមើល ឧ.* សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៩០១ ស្តីពីការរៀបចំផែនការ។

[79] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៩០១។ *សូមមើលផងដែរ* កថាខណ្ឌ ៩០២ ("នៅចុងឆ្នាំ ១៩៧៥ នួន ជា រួមជាមួយនឹងអ្នកផ្សេងទៀត បានរួមគ្នាបង្កើតផែនការសេដ្ឋកិច្ចជាក់លាក់មួយ។ ផែនការនេះបានទទួលស្គាល់អំពីការខ្វះខាតស្បៀងអាហារ និងថ្នាំសង្កូវ ជាពិសេស ប៉ះពាល់លើ "ប្រជាជនថ្មី"។ ទោះបីជាយ៉ាងនេះក្តី ផែនការនេះពាក់ព័ន្ធនឹងការបែងចែកកម្លាំងពលកម្មទៅតាមយុទ្ធសាស្ត្រដែលជាគោលដៅនៃការផលិតស្រូវរបស់បក្ស និងអាទិភាពនៃហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងមានគោលបំណងពង្រីកសហករណ៍ និងផ្តល់ការលើកទឹកចិត្តដល់ "ប្រជាជនចាស់" ដែលធ្វើឱ្យប៉ះពាល់ដល់ "ប្រជាជនថ្មី" ដែលស្ថិតនៅក្រោមការសង្ស័យ។ ក្រោយពេល គណៈកម្មាធិការអចិន្ត្រៃយ៍ បានចុះធ្វើទស្សនកិច្ចនៅភូមិភាគពាយ័ព្យនៅក្នុងខែ សីហា ឆ្នាំ ១៩៧៥ (ដំណើរទស្សនកិច្ចដែលមានការចូលរួមពី នួន ជា ឬយ៉ាងហោចណាស់ គាត់បានដឹងអំពីដំណើរទស្សនកិច្ចនេះ តាមរយៈរបាយការណ៍ជាលាយលក្ខណ៍អក្សរ) គណៈកម្មាធិការអចិន្ត្រៃយ៍បានសម្រេចបែងចែកជាថ្មីដោយបញ្ជូនប្រជាជន ចំនួន ៤០០.០០០ នាក់ ទៅ ៥០០.០០០ នាក់ បន្ថែមទៀតទៅឱ្យតំបន់នេះ។ ថ្នាក់ដឹកនាំបក្សក៏បានរៀបចំផែនការ និងបានបញ្ជាឱ្យផ្លាស់ទីលំនៅប្រជាជនចំនួន ២០.០០០ នាក់ ទៅកាន់ខេត្តព្រះវិហារ (តំបន់ ១០៣) និងប្រជាជនខ្លះទៀតទៅកាន់ខេត្តកំពង់ធំ (ភូមិភាគកណ្តាល (ឧត្តរចាស់)) ។ នៅក្នុងខែ កញ្ញា ឆ្នាំ ១៩៧៥ គណៈកម្មាធិការមជ្ឈិម រួមទាំង នួន ជា ដែលជាសមាជិកពេញសិទ្ធិផងដែរនោះ បានឯកភាពគាំទ្រលើ សេចក្តីសម្រេចចុះខែ សីហា ឆ្នាំ ១៩៧៥។ ថ្នាក់ដឹកនាំបក្សបានផ្សព្វផ្សាយឯកសារមួយដែលវិភាគអំពីការវិវត្តនៅក្នុងការអនុវត្តគោលនយោបាយកសិកម្មរបស់បក្ស កាលពី ៤ ទៅ ៥ ខែមុន និងបានគូសបញ្ជាក់ពីផែនការផ្លាស់ទីលំនៅប្រជាជនជាង ៥០០.០០០ នាក់ ទៅកាន់ភូមិភាគផ្សេងៗ ដើម្បីបំពេញតម្រូវការនៃការបង្កបង្កើនផលស្រូវ ហើយបានទទួលស្គាល់ថា ការខ្វះខាតថ្នាំសង្កូវ និងស្បៀងអាហារ បានប៉ះពាល់លើ "ប្រជាជនថ្មី" ជាពិសេស អ្នកដែលត្រូវបានជម្លៀសដោយបង្ខំមកពីទីក្រុងភ្នំពេញ។ ទោះបីជាបក្សមានបទពិសោធន៍ជាច្រើនចំពោះបញ្ហាធ្ងន់ធ្ងរមួយចំនួនដែលទាក់ទងទៅនឹងការជម្លៀសប្រជាជនដោយបង្ខំពីទីប្រជុំជន និងការផ្លាស់ទីលំនៅពីទីជនបទមួយទៅទីជនបទមួយទៀតក៏ដោយ ក៏គ្មានភស្តុតាងណាមួយបង្ហាញថា

គោលនយោបាយកសាង និងការពារប្រទេសដែលមានឯករាជ្យ ខ្លួនទីពឹងខ្លួន និងសង្គមនិយម។ ផែនការនេះមានគោលបំណងបង្កើតសង្គមគ្មានវណ្ណៈមួយ ដែលប្រជាជនគ្រប់គ្នានឹងត្រូវបានរៀបចំបញ្ចូលទៅក្នុងសហករណ៍ដើម្បីការពារ និងកសាងប្រទេសឱ្យបានជឿនលឿន ដោយផ្តោតជាពិសេសលើការបង្កបង្កើនផល និងគម្រោងធារាសាស្ត្រ។ ផែនការទាំងនេះ ពីដំបូង បានកើតចេញមកពី និងផ្អែកលើបទពិសោធន៍របស់បក្សនៅតាមតំបន់ រំដោះ ដើម្បីផ្គត់ផ្គង់កម្លាំងមនុស្សដែលត្រូវការ ដើម្បីសម្រេចផែនការនេះ ហើយវិធីសាស្ត្រនៃការជម្លៀស និងផ្លាស់ទីលំនៅមានលក្ខណៈដូចៗគ្នា ពីទីជនបទមួយទៅកាន់ទីជនបទមួយទៀត នៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបន្តអនុវត្តក្រោយពីពេលនេះរហូតមក។ ទោះបីជាធ្លាប់មានបទពិសោធន៍ដូចនេះក៏ដោយ ក៏គ្មានភ័ស្តុតាងណាមួយបង្ហាញថា ផែនការនេះមានវិធានការនានាដែលផ្តល់សុខុមាលភាពដល់ប្រជាជនដែលត្រូវបានជម្លៀស ឬ មានការយល់ព្រមពីប្រជាជនដែលនឹងត្រូវប្រមូលផ្តុំទៅនៅសហករណ៍នោះឡើយ"[80]។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញទៀតថា "ភ្លាមៗបន្ទាប់ពីកិច្ចប្រជុំខែ ឧសភា ឆ្នាំ ១៩៧៥ នៅឯព្រះវិហារព្រះកែវមរកត នួន ជា រួមជាមួយនឹង ប៉ុល ពត ព្រមទាំងមេដឹកនាំសំខាន់ៗដទៃទៀត បានដឹកនាំកិច្ចប្រជុំមួយចំនួន។ នៅចន្លោះពីថ្ងៃទី ២០ ដល់ ២៥ ខែ ឧសភា ឆ្នាំ ១៩៧៥ នួន ជា ព្រមទាំងមេដឹកនាំដទៃទៀត បានណែនាំដល់តំណាងនានាមកពីអង្គភាពកងទ័ព និងលេខាស្រុក តំបន់ និងភូមិភាគទាំងអស់ អំពីគោលនយោបាយរបស់បក្សពាក់ព័ន្ធនឹងការរៀបចំសហករណ៍ [...]។ នៅក្នុងរយៈពេលប៉ុន្មានខែក្រោយមក ថ្នាក់ក្រោមបានអនុវត្តសេចក្តីណែនាំទាំងឡាយដែលពួកគេបានទទួល"[81]។ នួន ជា ក៏ត្រូវបានអង្គជំនុំជម្រះសាលាដំបូងរកឃើញទៀតថាបាន "ដឹកនាំវគ្គរៀនសូត្រក្នុងទីក្រុងភ្នំពេញ ដោយបានចាប់ផ្តើមវគ្គរៀនសូត្រទាំងនោះ ភ្លាមៗ

---

ផែនការដែលលេចជារូបរាងឡើងនៅចុងឆ្នាំ ១៩៧៥ នោះ រួមមានវិធានការនានាដែលមានការយល់ព្រមពីប្រជាជនដែលនឹងត្រូវជម្លៀស ឬវិធានការនានាដែលផ្តល់សុខុមាលភាពដល់អ្នកទាំងនោះឡើយ")។

[80] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៩០០។

[81] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៧១។ *សូមមើលផងដែរ* កថាខណ្ឌ ៧៤៣ ("បន្ទាប់ពីនោះ នៅក្នុងអំឡុងពេលពីថ្ងៃទី ២០ ដល់ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៧៥ នួន ជា ប៉ុល ពត ខៀវ សំផន អៀង ធីរិទ្ធ សុន សេន និងអ្នកដទៃទៀត បានចូលរួមក្នុងកិច្ចប្រជុំយ៉ាងតិចក៏មួយដែរ ដែលប្រារព្ធឡើងនៅពហុកីឡដ្ឋានជាតិអូឡាំពិក ឬក៏នៅវិទ្យាស្ថានបច្ចេកទេសខ្មែរ-សូវៀត។ នួន ជា ប៉ុល ពត និងអ្នកផ្សេងទៀត បានបង្គាប់ដល់តំណាងទាំងអស់ដែលមកពីគ្រប់អង្គភាពទ័ព ព្រមទាំងលេខាស្រុក តំបន់ ភូមិភាគ ឱ្យរៀបចំបង្កើតសហករណ៍ លុបបំបាត់ទ្រព្យសម្បត្តិឯកជន លុបបំបាត់រូបិយប័ណ្ណ និងបិទទីផ្សារ ព្រមទាំងកសាងទំនប់ប្រឡាយ")។

ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបានបន្តគ្រប់ពេលក្នុងអំឡុងសម័យកម្ពុជា ប្រជាធិបតេយ្យ" និងបានធ្វើបទឧទ្ទេសនាម "ចំពោះកម្មាភិបាលភូមិភាគ តំបន់ និងស្រុក ព្រមទាំង កម្មាភិបាលធម្មតា អំពីការកំណត់អត្តសញ្ញាណ និងការកម្ចាត់ខ្មាំង ការបន្តធ្វើការតស៊ូប្រដាប់អាវុធ ការបង្កើតសហករណ៍"[82]។ម្យ៉ាងវិញទៀត អង្គជំនុំជម្រះសាលាដំបូងបានរកឃើញទៀតថា នួន ជា "បានធ្វើការយ៉ាងសកម្មនៅក្នុងការឃោសនា និងការបណ្តុះបណ្តាលកម្មាភិបាលខ្មែរក្រហមនៅតាមទីជនបទ ដោយគាំទ្រ" *ក្នុងនោះ* "ការបង្កើតសហករណ៍"[83]។ តាមរយៈ "សម្ភារៈឯកសារសម្រាប់ឃោសនា និងវគ្គបំពាក់បំប៉ន នួន ជា បានផ្សព្វផ្សាយ អនុម័ត កោតសរសើរ និងជំរុញគោលនយោបាយសេដ្ឋកិច្ចរបស់បក្ស ដែលបានផ្តល់យុទ្ធសាស្ត្រក្នុងការបែងចែកកម្លាំងការងារ និងការតស៊ូវណ្ណៈ"[84]។ មានការកត់សម្គាល់ថា "តួនាទីរបស់ នួន ជា នៅក្នុងយុទ្ធនាការឃោសនា" និង "ការបណ្តុះបណ្តាលកម្មាភិបាល" គឺជាមូលដ្ឋានសម្រាប់សំអាងហេតុនៃអង្គជំនុំជម្រះសាលាដំបូងថាគាត់ "បានរួមចំណែកយ៉ាងធំធេងនៅក្នុងការផ្សព្វផ្សាយ និងការអនុវត្តគោលបំណងរួមនេះ"[85]។

31. ដូចការរៀបរាប់ឡើងវិញខាងលើអំពីសំអាងហេតុនៃសំណុំរឿង ០០២/០១ បានបង្ហាញ ចៅក្រមដែលត្រូវបានប្តឹងជំទាស់ធ្លាប់បានរកឃើញថា មានផែនការបង្កើតសហករណ៍ ដោយ នួន ជា បានចូលរួមបង្កើតឡើងផែនការនោះ។ ចៅក្រមទាំងនេះបានរកឃើញទៀតថា នួន ជា បានចូលរួមពាក់ព័ន្ធនៅក្នុងការផ្សព្វផ្សាយ និងអនុវត្តផែនការនេះ ឧទាហរណ៍ គាត់បានណែនាំ "តំណាងនានាមកពីអង្គភាពកងទ័ព និងលេខាស្រុក តំបន់ និងភូមិភាគទាំងអស់" ដែលជាតួអង្គ ដែល នួន ជា ត្រូវបានរកឃើញថាមានការគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពលើពួកគេ[86] លើផែនការនេះ ដែលក្រោយមកត្រូវបាន "អនុវត្ត" ដោយ "ថ្នាក់ក្រោម"[87]។ ខ្ញុំពិចារណាឃើញថា សំអាងហេតុទាំងនេះលើកឡើង

---

[82] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៧២។

[83] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៧០។ *សូមមើលផងដែរ* កថាខណ្ឌ ៣២៥ (ដែលរកឃើញថា នួន ជា "ធ្វើជាអធិបតី ជាគ្រូបណ្តុះបណ្តាល ឬជាអ្នកឧទ្ទេសនាម" នៅក្នុង "កិច្ចប្រជុំ វគ្គបណ្តុះបណ្តាល ឬ វគ្គរៀនសូត្រ" ដែលក្នុងវគ្គទាំងនោះ "គោលនយោបាយបដិវត្តន៍ត្រូវបានយកមកពិភាក្សា រួមទាំងគោលនយោបាយសេដ្ឋកិច្ច និងសហករណ៍")។

[84] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៩១០។

[85] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៧៤។

[86] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៩៣-៨៩៦ កថាខណ្ឌ ៩១៣។

[87] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៧១។

ហួសពីការបង្ហាញសាវតារអង្គហេតុសម្រាប់គោលបំណងបរិបទ ហើយពិតជាបង្ហាញអំពីការទទួលខុសត្រូវជាលក្ខណៈបុគ្គលមែន។

### *(iii) សម្អាងហេតុជាក់លាក់ចំពោះ ខៀវ សំផន*

32. អង្គជំនុំជម្រះសាលាដំបូងក៏មានសំអាងហេតុទូទៅនៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ដែលបង្ហាញអំពីការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលរបស់ ខៀវ សំផន ចំពោះបទល្មើសដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០២។ អង្គជំនុំជម្រះបានរកឃើញថា ខៀវ សំផន "បានដើរតួនាទីសំខាន់មួយនៅក្នុងការផ្សព្វផ្សាយខ្លឹមសារនៃគោលបំណងរួម និងគោលនយោបាយទាំងនេះថែមទៀតផង"[88]។ អង្គជំនុំជម្រះសាលាដំបូងមិនបានកម្រិតទៅលើតួនាទីនេះចំពោះការផ្សព្វផ្សាយគោលនយោបាយទាំងនេះទេ ជាពិសេស ចំពោះសំណុំរឿង ០០២/០១ ប៉ុន្តែ បានផ្តល់សំអាងនេះទាក់ទងនឹងគោលបំណងរួម ដែលពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួម នៅក្នុងសំណុំរឿង ០០២ទាំងមូលតែម្តង។

33. ដូចដែលបានកត់សម្គាល់ខាងលើរួចមកហើយ "ការបង្កើត និងការចាត់ចែងសហករណ៍" ដែលតាមការចោទប្រកាន់ជាគោលនយោបាយសហឧក្រិដ្ឋកម្មរួម ហើយទាំងសហករណ៍ត្រាំកក់ និងនៅការដ្ឋានទំនប់ ១ មករា ត្រូវបានដាក់បញ្ចូលទៅក្នុងវិសាលភាពវិសាលភាពនៃសំណុំរឿង ០០២/០២[89]។ នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា យ៉ាងយូរត្រឹមថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៧៥ "ខៀវ សំផន បានបង្កើតក្រុមមេដឹកនាំបក្សកុម្មុយនីស្ត" ដែលបានជួប "ពិភាក្សាអំពីគោលនយោបាយ និងផែនការកសាង និងការពារប្រទេស ដែលទីពឹងខ្លួនឯង ឯករាជ្យ សង្គមនិយម ដូចជាការបង្កើតសហករណ៍ ជាដើម"[90]។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា នៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ ខៀវ សំផន និងអ្នកផ្សេងទៀត បានចូលរួមក្នុងកិច្ចប្រជុំជាមួយអ្នកដទៃទៀត ដែលនៅក្នុងនោះ គោលនយោបាយសេដ្ឋកិច្ចផ្សេងៗ "រួមទាំង

---

[88] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៧៦។

[89] បញ្ជីកថាខណ្ឌទាក់ទងនឹងសំណុំរឿង ០០២/០២ ទំព័រ ១ (ដែលដាក់បញ្ចូលកថាខណ្ឌ ១៦៨-១៧៧ នៃដីកាដំណោះស្រាយ រួមទាំងការដកស្រង់ចេញពីកថាខណ្ឌ ១៦៨ នៃដីកាដំណោះស្រាយ) និងទំព័រ ២ (ដែលដាក់បញ្ចូលកថាខណ្ឌ ៣០២-៣២១ និង ៣៥១-៣៦៧ នៃដំកាដំណោះស្រាយ ស្តីពីសហករណ៍ត្រាំកក់ និងការដ្ឋានទំនប់ ១ មករា)។

[90] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៦៧។

ការបង្កើតសហករណ៍ ត្រូវបានដោះស្រាយ”[91]។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា នៅខែ ឧសភា ឆ្នាំ ១៩៧៥ ខៀវ សំផន បានជួបជាមួយមេដឹកនាំដទៃទៀត និងបានសម្រេចផ្តល់ “អាទិភាព” ទៅលើ “តម្រូវការក្នុងការពារ និងការកសាងប្រទេសយ៉ាងឆាប់រហ័ស តាមរយៈការបង្កើតសហករណ៍”[92]។ បន្ទាប់ពីកិច្ចប្រជុំនោះមក មេដឹកនាំជាន់ខ្ពស់ដែលត្រូវបានរកឃើញថា ជាសមាជិកសហឧក្រិដ្ឋកម្មរួម “បានបង្គាប់ដល់តំណាងទាំងអស់ដែលមកពីគ្រប់អង្គភាពទ័ព ព្រមទាំងលេខាស្រុក តំបន់ និងភូមិភាគឱ្យរៀបចំសហករណ៍” *នៅក្នុងចំណោមបញ្ហាជាច្រើនទៀត*[93]។

34. អង្គជំនុំជម្រះសាលាដំបូងក៏បានរកឃើញបន្ថែមទៀតថា ខៀវ សំផន “បានចូលរួមនៅក្នុងការរៀបចំផែនការ ដែលមាននៅក្នុងឯកសារគោលនយោបាយ ខែ កញ្ញា និងខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ដើម្បីចាត់ចែងកម្លាំងពលកម្មដោយបង្ខំ តាមយុទ្ធសាស្ត្រ ផ្អែកតាមទិសដៅបង្កបង្កើនផល និងអាទិភាពនៃហេដ្ឋារចនាសម្ព័ន្ធ ដើម្បីឱ្យបានទិន្នផលស្រូវ ៣ តោនក្នុង ១ ហិកតា ដោយយកចិត្តទុកដាក់ក្នុងការកសាងប្រព័ន្ធធារាសាស្ត្រ និងការលើកទឹកចិត្តដល់ ‘ប្រជាជនចាស់’ ប៉ុន្តែ ធ្វើឱ្យខូចប្រយោជន៍ដល់ ‘ប្រជាជនថ្មី’”[94]។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញទៀតថា គោលនយោបាយ “ដែលបានសម្រេចដោយថ្នាក់ដឹកនាំបក្ស និង ខៀវ សំផន” បានកំណត់ថា “ទាំងអស់គ្នាត្រូវប្រឹងប្រែងធ្វើការដើម្បីការពារ និងកសាងប្រទេសឱ្យបានឆាប់ដើម្បីសម្រេចឱ្យបានសេដ្ឋកិច្ចខាងកសិកម្មបែបទំនើបក្នុងរយៈពេលពី ១០ ទៅ ១៥ ឆ្នាំ ដោយបានសង្កត់ធ្ងន់ទៅលើគោលដៅផលិតកម្ម ៣ តោនក្នុង ១ ហិកតា សម្រាប់ឆ្នាំ ១៩៧៦ និងបានសម្រេចថា ការប្រកយុទ្ធប្រឆាំងនឹង

---

[91] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៥១ (“អង្គជំនុំជម្រះបានសម្រេចរួចមកហើយថា គាត់បានចូលរួមកិច្ចប្រជុំនៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ ដែលបានពិភាក្សាអំពីការជម្លៀសប្រជាជនចេញពីទីប្រជុំជន ក៏ដូចជានៅចុងខែ មេសា និងខែ ឧសភា ឆ្នាំ ១៩៧៥ ដែលបានពិភាក្សាអំពីគោលនយោបាយសេដ្ឋកិច្ច និងការបង្កើតសហករណ៍។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន ដែលជាសមាជិកត្រៀមរបស់គណៈកម្មាធិការមជ្ឈិម នៅក្នុងខែ កញ្ញា ឆ្នាំ ១៩៧៥ បានចូលរួមនៅក្នុងការរៀបចំផែនការផ្សេងៗ ដែលបានលើកឡើងនៅក្នុងឯកសារគោលនយោបាយ ខែ កញ្ញា ១៩៧៥”)។

[92] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៤៣។

[93] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៤៣។

[94] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៦៨។ សូមមើល ផងដែរ កថាខណ្ឌ ៧៤៨-៧៤៩ (ខៀវ សំផន “បានចូលរួមនៅក្នុងការរៀបចំផែនការ ដែលបានឆ្លុះបញ្ចាំងនៅក្នុងឯកសារគោលនយោបាយឆ្នាំ ១៩៧៥” ដែលបានលើកឡើងអំពីសារៈសំខាន់នៃ “ចលនាមហាជននៅក្នុងការអនុវត្តមាគ៌ាកសិកម្មរបស់បក្ស” បានពិនិត្យលើ “ការអនុវត្តមាគ៌ាបក្សដើម្បីកសាងប្រទេស” និង “បានផ្តល់ចំណុចពិសេសៗ និងសេចក្តីណែនាំបន្ថែមចំពោះការជម្លៀសប្រជាជន និងស្ថានភាពនានានៅតាមជនបទ”។

ពួកចក្រពត្តិនិយម និង "បរិវាររបស់ពួកវា" នៅតែជាការចាំបាច់ បានជំរុញការបង្កើនការតស៊ូវណ្ណៈ និងការពង្រីកសហករណ៍ ហើយបានណែនាំថា ត្រូវរៀបចំកម្លាំងទាំងអស់សម្រាប់គម្រោងបន្តបន្ទាប់ ទៅតាមរដូវកាល"[95]។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ផែនការសេដ្ឋកិច្ចជាក់លាក់មួយដែលបានរៀបចំដោយ ខៀវ សំផន ជាមួយអ្នកដទៃទៀត "បានទទួលស្គាល់នូវការខ្វះខាតម្ហូបអាហារ និងថ្នាំសង្កូវ ដែលប៉ះពាល់ជាពិសេសដល់ 'ប្រជាជនថ្មី'"។ ទោះជាយ៉ាងណាក៏ដោយ ផែនការនេះគឺដើម្បីបែងចែកកម្លាំងតាមបែបយុទ្ធសាស្ត្រ អនុលោមតាមទិសដៅបង្កបង្កើនផលស្រូវរបស់បក្ស និងអាទិភាពនៃហេដ្ឋារចនាសម្ព័ន្ធ ពង្រីកសហករណ៍ និងគិតគូរដល់ 'ប្រជាជនចាស់' ដែលប៉ះពាល់យ៉ាងខ្លាំងដល់ 'ប្រជាជនថ្មី' ដែលត្រូវបានគេសង្ស័យ"[96]។

35. ខៀវ សំផន ក៏ត្រូវបានរកឃើញថា "បានដឹកនាំវគ្គរៀនសូត្រនៅក្នុងទីក្រុងភ្នំពេញ ដោយបានចាប់ផ្តើមវគ្គរៀនសូត្រទាំងនោះភ្លាមៗ ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបានបន្តគ្រប់ពេលនៅក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ" ដើម្បីធ្វើបទឧទ្ទេសនាមដល់ "កម្មាភិបាលភូមិភាគ តំបន់ និងស្រុក ព្រមទាំង កម្មាភិបាលធម្មតា អំពីការកំណត់អត្តសញ្ញាណ និងការកម្ចាត់ខ្មាំង ការបន្តធ្វើការតស៊ូប្រដាប់អាវុធ និងការបង្កើតសហករណ៍"[97]។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញបន្ថែមទៀតថា នៅក្នុងខែ មេសា ឆ្នាំ ១៩៧៦ ខៀវ សំផន បានថ្លែងសុន្ទរកថានៅក្នុងសម័យប្រជុំរបស់សភាតំណាងប្រជាជន ដែលគាត់បានសម្រេចគោលនយោបាយទាក់ទងនឹងសហករណ៍[98] ហើយ "នៅទូទាំងសម័យកម្ពុជាប្រជាធិបតេយ្យ" គាត់ "បានធ្វើបទឧទ្ទេសនាមដល់កម្មាភិបាលភូមិភាគ តំបន់ និងស្រុក ព្រមទាំង កម្មាភិបាលធម្មតាអំពី "ការបង្កើតសហករណ៍" *រួមទាំងបញ្ហាជាច្រើនទៀត*[99]។

---

[95] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៥៣។

[96] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១០២៥។

[97] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៧២។ *សូមមើល ផងដែរ* កថាខណ្ឌ ៩៧៥ ("ខៀវ សំផន ក៏បានដឹកនាំវគ្គរៀនសូត្រ ក្នុងទីក្រុងភ្នំពេញ ពេញមួយអំឡុងពេលនៃសម័យកម្ពុជាប្រជាធិបតេយ្យផងដែរ។ គាត់បានឧទ្ទេសនាមជូនកម្មាភិបាលភូមិភាគ តំបន់ និងស្រុក ព្រមទាំងកម្មាភិបាលធម្មតា អំពីការកំណត់អត្តសញ្ញាណ និងកម្ចាត់ខ្មាំង ការបន្តការតស៊ូប្រដាប់អាវុធ ការបង្កើតសហករណ៍ ការកសាងទំនប់ និងជីកប្រឡាយ និងការបំពេញតាមផែនការការងារ។

[98] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៦៥។

[99] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៧៥។

01059764



36. ខ្ញុំយល់ឃើញថា ការរៀបរាប់ឡើងវិញអំពីសំអាងហេតុនៅក្នុងសាលក្រមសំណុំរឿង ០០២/០១ បង្ហាញពីការដាក់ឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលដល់ ខៀវ សំផន សម្រាប់សំណុំរឿង ០០២/០២។ សាលក្រមនេះបង្ហាញពីការចូលរួមទូទៅរបស់ ខៀវ សំផន ចំពោះគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម ដែលទាក់ទងនឹងសំណុំរឿង ០០២ ទាំងមូលតែម្តង។ សំអាងហេតុខាងលើបង្ហាញថា ចៅក្រមដែលត្រូវបានប្តឹងជំទាស់ មិតចិត្តបានសម្រេចកាលពីលើកមុនថា មានផែនការបង្កើតសហករណ៍ ដែល ខៀវ សំផន បានចូលរួមរៀបចំ ផ្សព្វផ្សាយ និងសម្រេច។

### *(iv) សំអាងហេតុនានាទៅលើ "មូលដ្ឋានឧក្រិដ្ឋកម្ម"*

37. អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញនូវសំអាងមួយចំនួនទៅលើ "មូលដ្ឋានឧក្រិដ្ឋកម្ម" ដែលត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២ ដែលខ្ញុំយល់ឃើញថា សំអាងហេតុទាំងនេះខ្លួនឯងមិនអាចនាំឱ្យមានការយល់ថាមានភាពលម្អៀងនោះទេ ប៉ុន្តែ ខ្ញុំយល់ឃើញថាធ្វើឱ្យមានការព្រួយបារម្ភ នៅពេលពិចារណារួមគ្នាជាមួយនឹងបញ្ហាដែលបានយកមកពិនិត្យខាងលើ។

38. ទីមួយ នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ប្រជាជន "ត្រូវបានឃុំខ្លួននៅមន្ទីរ ស-២១"[100]។ ការឃុំឃាំងខ្លួននៅមន្ទីរ ស-២១ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះ ត្រូវបានយកមកចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០២ ដែលជាផ្នែកមួយនៃហេតុការណ៍បោសសម្អាតផ្ទៃក្នុង[101]។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ការលើកឡើងរបស់ខ្លួនអំពីមន្ទីរ ស-២១ ដោយប្រកាសថា ខ្លួនមិនចេញសំអាងហេតុទៅលើ ("ការចោទប្រកាន់ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ នួន ជា ចំពោះប្រតិបត្តិការមន្ទីរសន្តិសុខ ស-២១

---

[100] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៤៥ ("ជនបរទេសជាច្រើននាក់ត្រូវបានឃុំខ្លួននៅមន្ទីរ ស-២១ ផងដែរ។ ក្នុងចំណោមអ្នកជាប់ឃុំទាំងនេះ មានទាហានវៀតណាម ដែលការចាប់ខ្លួន និងឃុំខ្លួនពួកគេនៅមន្ទីរ ស-២១ ត្រូវបានរាយការណ៍ជូនទៅគណៈកម្មាធិការមជ្ឈិមបក្ស រួមទាំង នួន ជា ផងដែរ"។ *ឧទាហរណ៍ សូមមើល ផងដែរ* កថាខណ្ឌ ២១១ ("[...] អ្នកទោសដែលគេបាននាំខ្លួនមកកាន់មន្ទីរសន្តិសុខ ស-២១ [...]") កថាខណ្ឌ ២១៤ ("មន្ទីរ ស-៧១ ក៏មានអំណាចក្នុងការចាប់ខ្លួន និងបញ្ជូនអ្នកត្រូវបានចាប់ខ្លួនទៅកាន់មន្ទីរសន្តិសុខ ស-២១") កថាខណ្ឌ ៣៤៥ ("នៅពេលនោះ អ្នកជាប់ឃុំទាំងអស់ដែលកំពុងជាប់ឃុំឃាំងនៅមន្ទីរ ស-២១ មានប្រហែល ៥០០ នាក់") កថាខណ្ឌ ៣៩២ ("ខឿន ត្រូវបានចាប់ខ្លួន និង នាំមកមន្ទីរ ស-២១ នៅខែ កុម្ភៈ ឆ្នាំ ១៩៧៧") កថាខណ្ឌ ៤០២ ("ក្រោយពេលខ្មែរក្រហមកាន់អំណាច បុគ្គលទីមួយដែលទទួលបន្ទុកសេដ្ឋកិច្ចគឺ កុយ ធួន។ កុយ ធួន ត្រូវបានចាប់ខ្លួននៅខែ មេសា ឆ្នាំ ១៩៧៦ និង យកទៅមន្ទីរ ស-២១ ក្នុងឆ្នាំ ១៩៧៧")។

[101] បញ្ជីកថាខណ្ឌទាក់ទងនឹងសំណុំរឿង ០០២/០២ ទំព័រ ៣។

ទេ")[102]។ ប៉ុន្តែ ទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងគ្រាន់តែកំណត់សំអាងហេតុរបស់ខ្លួនពាក់ព័ន្ធនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គលរបស់ នួន ជា តែប៉ុណ្ណោះ មិនមែន "មូលដ្ឋានឧក្រិដ្ឋកម្ម" ទេ។ សំអាងហេតុទៅលើ "មូលដ្ឋានឧក្រិដ្ឋកម្ម" ស្តីពីការឃុំឃាំងមនុស្សនៅមន្ទីរ ស-២១ ត្រូវបានលើកឡើងជាទូទៅ (មិនគ្រាន់តែជាការរៀបរាប់ឡើងវិញអំពីសក្ខីកម្មរបស់បុគ្គលជាក់លាក់ណាម្នាក់ប៉ុណ្ណោះទេ) ហើយត្រូវបានគាំទ្រដោយការសំអាងទៅលើសក្ខីកម្មរបស់សាក្សី និងអ្នកជំនាញ រួមទាំងជាឯកសារភស្តុតាងផងដែរ ដោយមិនមានការសំងាងទៅលើភស្តុតាងផ្ទុយនោះឡើយ។ អាស្រ័យហេតុនេះ ខ្ញុំយល់ឃើញថា នេះជាការសម្រេចទៅលើអង្គហេតុពាក់ព័ន្ធនឹង "មូលដ្ឋានឧក្រិដ្ឋកម្ម" ដែលបញ្ហាត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២ មិនមែនជាការរៀបរាប់ឡើងវិញធម្មតាទៅលើភស្តុតាងនោះទេ។ លើសពីនេះទៀត ខ្ញុំយល់ឃើញថា សំអាងហេតុទៅលើមូលដ្ឋានឧក្រិដ្ឋកម្ម កាន់តែធ្វើឱ្យមានព្រួយបារម្ភកាន់តែខ្លាំងថែមទៀត នៅពេលដែលបានពិនិត្យទៅលើការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា នួន ជា ជាប់ពាក់ព័ន្ធនឹងការបោសសម្អាតផ្ទៃក្នុង ដោយសារតែការឃុំឃាំង កម្មាភិបាល និងកងទ័ពបក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរ ស-២១ គឺជាបញ្ហាស្នូលចំពោះហេតុការណ៍នេះ។

39. ទីពីរ អង្គជំនុំជម្រះសាលាដំបូងមានសំអាងហេតុតិចតួចទៅលើការដ្ឋានទំនប់ ១ មករា ដែលជាទីតាំងឧក្រិដ្ឋកម្មមួយផ្សេង ដែលត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿង ០០២/០២ ថាជាផ្នែកមួយនៃគោលនយោបាយបង្កើតសហករណ៍ និងការដ្ឋានធ្វើការងារ[103]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ការសាងសង់ទំនប់ ១ មករា បានចាប់ផ្តើមនៅក្នុងខែ ធ្នូ ឆ្នាំ ១៩៧៦[104] និងថា "នៅក្នុងឆ្នាំ ១៩៧៧ ប្រជាជនប្រមាណពី ៨.០០០ នាក់ទៅ ២០.០០០នាក់ ត្រូវបានបញ្ជូនឱ្យទៅធ្វើការនៅការដ្ឋានទំនប់ ១ មករា"[105]។ តាមការយល់ឃើញរបស់ខ្ញុំ អ្នកសង្កេតការណ៍មិនលម្អៀងដែល

---

[102] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៩៦ ("ការចោទប្រកាន់ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ នួន ជា ចំពោះប្រតិបត្តិការនៃមន្ទីរសន្តិសុខ ស-២១ ត្រូវបានបំបែកចេញពីសំណុំរឿង ០០២/០១ ហើយនឹងត្រូវយកមកពិចារណានៅក្នុងកិច្ចដំណើរការនីតិវិធីនៅថ្ងៃខាងមុខ។ ហេតុដូច្នេះ អង្គជំនុំជម្រះនឹងមិនធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងចំណុចនេះនៅក្នុងសាលក្រមនេះទេ។

[103] *សូមមើល* បញ្ជីកថាខណ្ឌទាក់ទងនឹងសំណុំរឿង ០០២/០២ ទំព័រ ២-៣។

[104] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៦១២។

[105] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៨១។

ទទួលបានព័ត៌មានគ្រប់គ្រាន់អាចយល់ថា ចៅក្រមដែលត្រូវបានប្ដឹងជិតចិត្ត មានបុរេវិនិច្ឆ័យទៅលើមូលដ្ឋានអង្គហេតុដែលបានកំណត់ឡើងចំពោះឧក្រិដ្ឋកម្មមួយចំនួនប្រឆាំងនឹងមនុស្សជាតិ នៅការដ្ឋានទំនប់ ១ មករា នៅក្នុងសំណុំរឿង ០០២/០២។ ប៉ុន្តែ ដូចបានលើកឡើងខាងលើរួចមកហើយ ខ្ញុំយល់ឃើញថា សំអាងហេតុនេះខ្លួនឯងនឹងមិននាំឲ្យមានការយល់ឃើញថា មានភាពលម្អៀងនោះទេ ប៉ុន្តែ នៅពេលពិចារណារួមគ្នាជាមួយនឹងការវិភាគខាងលើអំពីការពាក់ព័ន្ធរបស់ នួន ជា និង ខៀវ សំផន ចំពោះការរៀបចំគោលនយោបាយបង្កើតសហករណ៍ និងការដ្ឋានធ្វើការងារ ខ្ញុំយល់ឃើញវាធ្វើឲ្យមានការព្រួយបារម្ភ។

## V. សេចក្ដីសន្និដ្ឋាន

40. ខ្ញុំយល់ឃើញថា ទោះបីជាសំអាងហេតុមួយចំនួននៅក្នុងសាលក្រមសំណុំរឿង ០០២/០១ អំពីបញ្ហាជាច្រើនដែលជាមូលដ្ឋានសម្រាប់សម្រេចក្នុងសំណុំរឿង ០០២/០២ ខ្លួនឯង មិនបង្ហាញឲ្យឃើញពីការលេចឡើងនូវភាពលម្អៀងក៏ដោយ ប៉ុន្តែ បើពិចារណាទៅលើសំអាងហេតុទាំងនោះរួមគ្នាទៅ ឃើញថា សំអាងហេតុទាំងនោះបានបង្ហាញពីភាពលម្អៀងហើយ។ ទាក់ទងនឹង នួន ជា វិញ ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងបានសម្រេចកាលពីមុនទៅលើបញ្ហាផ្សេងៗ ដែលខុសៗគ្នា និងគ្របដណ្ដប់ជារួម រួមមាន អត្ថិភាពនៃសហឧក្រិដ្ឋកម្មរួមពាក់ព័ន្ធនឹងជនជាប់ចោទរូបនេះ[106] គោលនយោបាយរបស់បក្សកុម្មុយនីស្ដកម្ពុជាដែលត្រូវបានយកមកចោទប្រកាន់[107] ការទទួលខុសត្រូវរួមរបស់ នួន ជា រួមទាំងការត្រួតត្រាប្រកបដោយប្រសិទ្ធភាពរបស់ នួន ជា ទៅលើបក្សកុម្មុយនីស្ដកម្ពុជា និងកងទ័ពខ្មែរក្រហម[108] ការពាក់ព័ន្ធរបស់ នួន ជា នៅក្នុងបញ្ហាជាក់លាក់ផ្សេងៗដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ដូចជា ការបោសសម្អាតផ្ទៃក្នុង និងការបង្កើតសហករណ៍[109] ភស្តុតាងពីមូលដ្ឋានឧក្រិដ្ឋកម្មទាក់ទងនឹងបញ្ហាទាំងពីរនេះ[110] និងធាតុផ្សំ *ទូទៅ*នៃឧក្រិដ្ឋ

[106] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៧៧។

[107] *សូមមើល* ការពិភាក្សាខាងលើស្ដីពីអត្ថិភាពនៃគោលនយោបាយ។

[108] *សូមមើល* កថាខណ្ឌទាំងឡាយដែលបានពិភាក្សាខាងលើ រួមទាំង សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៩៦, ៩១៣ និង ៩៣៣។

[109] *សូមមើល* កថាខណ្ឌទាំងឡាយដែលបានពិភាក្សាខាងលើ រួមទាំង សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៤០, ៨៧១ និង ៩០០-៩០២។

កម្មប្រឆាំងមនុស្សជាតិ[111]។ ស្រដៀងគ្នានេះដែរ ទាក់ទងនឹង ខៀវ សំផន វិញ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចកាលពីមុនទៅលើអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម ដែលពាក់ព័ន្ធនឹងជនជាប់ចោទរូបនេះ[112] គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែលត្រូវបានយកមកចោទប្រកាន់[113] ការចូលរួមពាក់ព័ន្ធទូទៅរបស់ ខៀវ សំផន នៅក្នុងគោលបំណងរួម និងនៅក្នុងបញ្ហាជាក់លាក់មួយចំនួន ដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ដូចជា ការបង្កើតសហការណ៍ និងការដ្ឋានធ្វើការងារ[114] ភស្តុតាងដែលជាមូលដ្ឋានឧក្រិដកម្មពាក់ព័ន្ធនឹងគោលនយោបាយនេះ[115] និងនិងធាតុផ្សំ*ទូទៅ* នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[116]។ ដោយសារតែសំអាងហេតុទាំងនេះធ្វើឡើងហួសពីវិមតិសង្ស័យ ទាក់ទងនឹងជនជាប់ចោទដដែល នោះខ្ញុំយល់ឃើញថា សំអាងហេតុទាំងនោះគឺជាមូលហេតុអាចឱ្យសន្និដ្ឋានបានថា អ្នកសង្កេតការណ៍មិនលម្អៀងដែលទទួលបានព័ត៌មានគ្រប់គ្រាន់ នឹងមានការយល់ឃើញប្រកបដោយហេតុផលថា ចៅក្រមប្រធាន និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc Lavergne និងចៅក្រម យូរ ឧត្តរា មានភាពលម្អៀងហើយ។

---

[110] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៤៥ ("ជនបរទេសជាច្រើននាក់ត្រូវបានឃុំខ្លួននៅមន្ទីរ ស-២១ ផងដែរ។ ក្នុងចំណោមអ្នកជាប់ឃុំទាំងនេះ មានទាហានវៀតណាម ដែលការចាប់ខ្លួន និងឃុំខ្លួនពួកគេនៅមន្ទរ ស-២១ ត្រូវបានរាយការណ៍ជូនទៅគណៈកម្មាធិការមជ្ឈិមបក្ស រួមទាំង នួន ជា ផងដែរ"។ *ឧទាហរណ៍ សូមមើល ផងដែរ* កថាខណ្ឌ ២១១ ("[...] អ្នកទោសដែលគេបាននាំខ្លួនមកកាន់មន្ទីរសន្តិសុខ ស-២១ [...]") កថាខណ្ឌ ២១៤ ("មន្ទីរ ស-៧១ក៏មានអំណាចក្នុងការចាប់ខ្លួន និងបញ្ជូនអ្នកត្រូវបានចាប់ខ្លួនទៅកាន់មន្ទីរសន្តិសុខ ស-២១") កថាខណ្ឌ ៣៤៥ ("នៅពេលនោះ អ្នកជាប់ឃុំទាំងអស់ដែលកំពុងជាប់ឃុំឃាំងនៅមន្ទីរ ស-២១ មានប្រហែល ៥០០ នាក់") កថាខណ្ឌ ៣៩២ ("ឌឿន ត្រូវបានចាប់ខ្លួន និង នាំមកមន្ទីរ ស-២១ នៅខែ កុម្ភៈ ឆ្នាំ ១៩៧៧") កថាខណ្ឌ ៤០២ ("ក្រោយពេលខ្មែរក្រហមកាន់អំណាច បុគ្គលទីមួយដែលទទួលបន្ទុកសេដ្ឋកិច្ចគឺ កុយ ធួន។ កុយ ធួន ត្រូវបានចាប់ខ្លួននៅខែ មេសា ឆ្នាំ ១៩៧៦ និង យកទៅមន្ទីរ ស-២១ ក្នុងឆ្នាំ ១៩៧៧")។

[111] អង្គជំនុំជម្រះយល់ឃើញថា ចាប់តាំងពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងយ៉ាងហោចណាស់ក៏រហូតមកដល់ខែ ធ្នូ ឆ្នាំ ១៩៧៧ គឺរយៈពេលជាងពាក់កណ្តាលនៃសម័យនោះ ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ មានការវាយប្រហារជាទូទៅ និងជាប្រព័ន្ធ ប្រឆាំងនឹងប្រជាជនស៊ីវិលក្នុងប្រទេសកម្ពុជា ដែលត្រូវបានអនុវត្តឡើងដោយសារតែការរើសអើង។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា លក្ខខណ្ឌទូទៅទាំងអស់សម្រាប់ការអនុវត្តមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ត្រូវបានបំពេញ៖ សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១៩៣ ដល់ ១៩៨។

[112] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៧៧។

[113] *សូមមើល* ការពិភាក្សាខាងលើស្តីពីអត្ថិភាពនៃគោលនយោបាយ។

[114] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៧៤-៩៧៥។

[115] *សូមមើល* ការពិភាក្សាខាងលើស្តីពីការយល់ឃើញទាក់ទងនឹងការដ្ឋានទំនប់ ១ មករា។

[116] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១៩៣-១៩៨។

ហេតុដូច្នេះ ខ្ញុំសម្រេចទទួលយកបណ្ដឹងជំទាស់ចិត្តរបស់ នួន ជា និង ខៀវ សំផន លើកលែងតែបណ្ដឹងជំទាស់ចិត្តរបស់ ខៀវ សំផន ទាក់ទងនឹងចៅក្រម FENZ តែប៉ុណ្ណោះ។

ភ្នំពេញ ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥

**ចៅក្រម** Rowan Downing

# ឧបសម្ព័ន្ធ

| ការកំណត់ជាមុននូវអង្គហេតុ ដែលទាក់ទងលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា ចំពោះបទល្មើស ដែលចោទប្រកាន់ ក្នុងសំណុំរឿង ០០២ | |
|---|---|
| បទចោទក្នុងសំណុំរឿង ០០២/០២ (ឯកសារយោង ជាដីកាដំណោះស្រាយ) | សំអាងហេតុក្នុងសំណុំរឿង ០០២/០១ (ឯកសារយោង ជាសាលក្រមនៃសំណុំរឿង ០០២/១) |
| <u>ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ៖ ធាតុផ្សំដែលជា "ធាតុផ្សំរួម"</u><br>**១៣៥០.** យោងតាមអង្គហេតុដូចបានរៀបរាប់នៅក្នុងផ្នែកនៃដីកាដំណោះស្រាយស្ដីពី "ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃសហឧក្រិដ្ឋកម្មរួម"និងផ្នែកស្ដីអំពី "ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃឧក្រិដ្ឋកម្ម" គោលនយោបាយដែលអនុវត្តដោយកម្មាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី ០៧ ខែ មករា ឆ្នាំ១៩៧៩ បង្កើតបានជាការវាយប្រហារជាទូទៅ និងជាប្រព័ន្ធ ប្រឆាំងទៅលើប្រជាជនស៊ីវិលទាំងអស់នៃប្រទេសកម្ពុជា ដោយសារ មូលហេតុនយោបាយជាចម្បង និងក្នុងបរិបទមួយចំនួនដោយសារមូលហេតុជនជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា។ បទល្មើសជាក់លាក់ ដែលនឹងរៀបរាប់ដូចតទៅនេះត្រូវបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃការវាយប្រហារនេះជាហេតុធ្វើឱ្យធាតុផ្សំដែលជា | <u>ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ៖ ធាតុផ្សំដែលជា "ធាតុផ្សំរួម"</u><br>**១៩៣.** អង្គជំនុំជម្រះយល់ឃើញថា ចាប់តាំងពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងយ៉ាងហោចណាស់ក៏រហូតមកដល់ខែ ធ្នូ ឆ្នាំ ១៩៧៧ ដែលជាអំឡុងពេលដែលត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ មានការវាយប្រហារជាទូទៅ និងជាប្រព័ន្ធ ប្រឆាំងនឹងប្រជាជនស៊ីវិលក្នុងប្រទេសកម្ពុជា។[...]<br><br>**១៩៥.**អង្គជំនុំជម្រះយល់ឃើញទៀតថា ការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិលនេះត្រូវបានអនុវត្តឡើងដោយសារមូលហេតុនយោបាយ ស្របតាមគោលនយោបាយ និងផែនការរបស់បក្សក្នុងការកសាងសង្គមនិយម និងការការពារប្រទេស។ [...]<br><br>**១៩៨.** ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា លក្ខខណ្ឌទូទៅទាំងអស់សម្រាប់ការអនុវត្តមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ត្រូវបានបំពេញ។ |

| | |
|---|---|
| "ធាតុផ្សំរួម" នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានចែងនា អំឡុងពេលនៃការកកើតអង្គហេតុត្រូវបានបំពេញ។ | |
| **សហឧក្រិដ្ឋកម្មរួម**<br><br>**១៥៦.**មេដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាមានផែនការរួមដើម្បីបង្កើតនៅក្នុងប្រទេសកម្ពុជានូវបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សតាមរយៈគ្រប់មធ្យោបាយចាំបាច់តាម "សន្ទុះមហាលោតផ្លោះ" និង ដើម្បីការពារបក្សប្រឆាំងនឹងសត្រូវផ្ទៃក្នុង ក៏ដូចជាសត្រូវខាងក្រៅ។<br><br>១៥៧. ដើម្បីធ្វើឱ្យសម្រេចនូវផែនការរួម មេដឹកនាំនៃរបស់បក្សកុម្មុយនីស្តកម្ពុជាបានឱ្យអត្តន័យ និង បានអនុវត្តនូវគោលនយោបាយទាំងប្រាំដូចជា ៖<br>• ការផ្លាស់ទីលំនៅដែលធ្វើឡើងជាច្រើនលើកច្រើនសារទៅលើប្រជាជនចេញពីទីប្រជុំជនទៅកាន់ទីជនបទ និង ពីទីជនបទមួយទៅកាន់ទីជនបទមួយផ្សេងទៀត ។<br>• ការបង្កើត និងការទាញយកផលប្រយោជន៍តាមរយៈសហករណ៍និងតាមការដ្ឋាន។<br>• ការអប់រំ "សមាសភាពមិនល្អ" និង ការកម្ទេច "ខ្មាំង" ដែលត្រូវបានរកឃើញទាំងនៅក្នុង និង នៅក្រៅបក្ស។ | **សហឧក្រិដ្ឋកម្មរួម**<br><br>**៧៧៧.** ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា យ៉ាងយូរបំផុតត្រឹមខែ មិថុនា ឆ្នាំ ១៩៧៤ រហូតដល់ខែ ធ្នូ ឆ្នាំ ១៩៧៧ មនុស្សជាច្រើនមានគោលបំណងរួមដើម្បី "បង្កើតបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សតាមរយៈមធ្យោបាយចាំបាច់តាម "សន្ទុះមហាលោតផ្លោះ" និងដើម្បីការពារបក្សប្រឆាំងនឹងសត្រូវផ្ទៃក្នុង ក៏ដូចជាសត្រូវខាងក្រៅ"។ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិម រដ្ឋមន្ត្រីនៃរដ្ឋាភិបាល លេខាភូមិភាគ និងលេខាតំបន់ស្វយ័ត រួមទាំង នួន ជា ខៀវ សំផន ប៉ុល ពត អៀង សារី សុន សេន វន វេត តា ម៉ុក សោ ភឹម រស់ ញឹម កុយ ធួន កែ ពក ចាន់ សំ ជូ ចេត ប៊ូ ផាត យ៉ុង យ៉ែម ប៊ិន ណាន អៀង ធីរិទ្ធ និងម៉ី ប្រាង គឺជាសមាជិកនៃក្រុមដែលមានគោលបំណងរួមដូចបានបញ្ជាក់នេះ។ ភ័ស្តុតាងបង្ហាញថា គោលបំណងរួមក្នុងការការពារ និងកសាងប្រទេសឱ្យបានឆាប់រហ័សតាមរយៈបដិវត្តន៍សង្គមនិយមនេះ ផ្អែកតាមគោលការណ៍រក្សាការសម្ងាត់ ឯករាជ្យ អធិបតេយ្យ ប្រជាធិបតេយ្យប្រមូលផ្តុំ ខ្លួនទីពឹងខ្លួន និងសមូហ-ភាវូបនីយកម្ម ត្រូវបានបង្កើតឡើងយ៉ាងច្បាស់លាស់នៅត្រឹមខែ មិថុនា ឆ្នាំ |

- ការចេញនូវវិធានការណ៍ជាពិសេសចំពោះក្រុមមនុស្សជាក់លាក់នានា ដូចជាជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិកជន និងអតីតអ្នករដ្ឋការនានានៃសាធារណៈរដ្ឋខ្មែរ (រួមទាំងមន្ត្រីរាជការ អតីតបុគ្គលិកយោធា ព្រមទាំងក្រុមគ្រួសាររបស់ពួកគេ)។
- ការដាក់បទបញ្ជារទាក់ទងនឹងការរៀបការ។

**១៥៩.** បុគ្គលដែលបានចូលរួមក្នុងផែនការរួមនេះ យ៉ាងហោចណាស់មានសមាជិកនៃគណៈកម្មាការអចិន្ត្រៃយ៍ ដូចជា នួន ជា និង អៀង សារី អ្នកដែលស្ថិតនៅក្នុងគណៈកម្មាធិការមជ្ឈិម ដូចជា ខៀវ សំផន រដ្ឋមន្ត្រីនានាដូចជា អៀង ធីរិទ្ធ លេខាភូមិភាគ និងតំបន់ស្វ័យត និងមេដឹកនាំកងពលយោធាមជ្ឈិម។

**១៥២៤.** ផែនការរួមរបស់មេដឹកនាំបក្សកម្ពុជាប្រជាធិបតេយ្យគឺធ្វើឱ្យសម្រេចបាននូវបដិវត្តន៍សង្គមនិយមឆាប់រហ័សនៅកម្ពុជា តាម "ជំហ៊ានមហាលោតផ្លោះ" និងការការពារប្រទេសប្រឆាំងទៅនឹងសត្រូវទាំងខាងក្នុង និងខាងក្រៅ តាមគ្រប់មធ្យោបាយចាំបាច់។ ផែនការរួមនេះពុំមែនមានលក្ខណៈឧក្រិដ្ឋទាំងស្រុងនោះទេ ប៉ុន្តែការធ្វើឱ្យសម្រេចផែនការរួមនេះរួមមាន ជាការប្រព្រឹត្តិនូវឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ឬក៏ជាការជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ។

១៩៧៤ និងបានបន្តមានអត្ថិភាពយ៉ាងហោចណាស់រហូតដល់ខែ ធ្នូ ឆ្នាំ ១៩៧៧។

**៨០៤.** អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ភ័ស្តុតាងដែលមាននៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ បានបង្ហាញអំពីអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម។ ទីមួយ ភ័ស្តុតាងបានបង្ហាញថា មនុស្សជាច្រើន រួមទាំងថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានយល់ស្របទៅនឹងគោលបំណងរួម ដែលរួមមាន ការអនុវត្តបដិវត្តន៍សង្គមនិយមនៅក្នុងប្រទេសកម្ពុជា។ ទីពីរ ក៏មានការបង្ហាញឱ្យឃើញផងដែរថា ទោះបីជា គោលបំណងរួមនេះមិនមានលក្ខណៈឧក្រិដ្ឋក៏ដោយ ក៏គោលនយោបាយដែលខ្មែរក្រហមបានបង្កើតឡើងពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលជាមធ្យោបាយមួយក្នុងការសម្រេចផែនការរួមនេះ។ គោលនយោបាយទាំងនេះ នាំឱ្យមាន និង/ឬរួមមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនានា រួមទាំង ការផ្លាស់ទីលំនៅដោយបង្ខំ ការធ្វើមនុស្សឃាត ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។ ការផ្លាស់ទីលំនៅប្រជាជនទាំងពីរដំណាក់កាលនេះ (ដំណាក់កាលទី១ និងទី២) អនុវត្តតាមវិធីសាស្ត្រដ៏ស៊ីសង្វាក់គ្នាមួយ នៅក្នុងករណីនីមួយៗដែលរួមទាំង និងមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម។ ចំណុចនេះបញ្ជាក់ថា គោលនយោបាយទាំងនេះ មានលក្ខណៈឧក្រិដ្ឋ និងត្រូវបានអនុម័តជាមុន ដើម្បីធានាថា គោល

| | |
|---|---|
| | បំណងរួមនេះអាចសម្រេចបាន។<br><br>**៨០៧.** ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា អ្នកចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម ដែលរួមមានយ៉ាងហោចណាស់ សមាជិកគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍មួយចំនួន ដូចជា ប៉ុល ពត តាម៉ុក សុន សេន សោ ភឹម វន វេត និង កុយធួន អាចត្រូវបានដាក់ឱ្យទទួលខុសត្រូវ នៅក្នុងសហឧក្រិដ្ឋកម្មរួម ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)។<br><br>*សូមមើលផងដែរ* ផ្នែក "ទម្រង់នៃការទទួលខុសត្រូវសម្រាប់ នួន ជា ៖ សហឧក្រិដ្ឋកម្មរួម" ដែលមាននូវសំអាងហេតុ អំពីអត្ថិភាព នៃ គោលនយោបាយទាំងអស់ ចំនួនប្រាំ។ |
| **<u>សហករណ៍ និងការដ្ឋាន</u>**<br><br>**១៦៨.** គោលនយោបាយមួយក្នុងចំណោមគោលនយោបាយទាំងប្រាំដែលត្រូវបានអនុវត្តដើម្បីសម្រេចបាន និងការពារបដិវត្តន៍សង្គមនិយម គឺការបង្កើត និង ការទាញយកផលប្រយោជន៍ពីសហករណ៍ និងពីការដ្ឋានតាមរយៈគ្រប់មធ្យោបាយចាំបាច់។ សហករណ៍ និងការដ្ឋាននានា ត្រូវបានរៀបចំឡើងនៅទូទាំងប្រទេសកម្ពុជា ចាប់តាំងពីមុនឆ្នាំ១៩៧៥ ដោយបក្សកុម្មុយនីស្តកម្ពុជាមកម្លេះ ពោលគឺដំណាក់កាលដំបូងនៃការត្រួតត្រារបស់បក្សកុម្មុយនី | **<u>សហករណ៍ និងការដ្ឋាន</u>**<br><br>**៦០៤.** នៅចន្លោះខែកញ្ញា និងខែតុលា ឆ្នាំ១៩៧៥ គណៈកម្មាធិការអចិន្ត្រៃយ៍បានជួបពិភាក្សាអំពី គោលនយោបាយការពារ និងកសាងប្រទេស។ នៅក្នុងខែវិច្ឆិកា ឆ្នាំ ១៩៧៥ សន្និបាតសេដ្ឋកិច្ចរបស់បក្សទូទាំងប្រទេសលើកទី១ បានដាក់ចេញផែនការដែលអាចនឹងប្រែក្លាយប្រព័ន្ធកសិកម្មអន់ថយមួយរបស់ប្រទេសឱ្យទៅជាប្រព័ន្ធកសិកម្មទំនើបមួយ ក្នុងរយៈពេល ១០ ឆ្នាំ ទៅ ១៥ ឆ្នាំ ខាងមុខ។ ថ្នាក់ដឹកនាំបក្សបានសម្រេចថា បក្ស |

01059773



ស្តកម្ពុជាលើដែនដីមួយចំនួនរបស់ ប្រទេស។ ការបង្កើតនេះបានបន្តយ៉ាងហោចណាស់រហូតដល់ថ្ងៃទី ៦ ខែមករា ឆ្នាំ១៩៧៩។ សហចៅក្រមស៊ើបអង្កេតត្រូវបានប្តឹងអំពីទីតាំងជាក់លាក់នៃការដ្ឋាន និងសហករណ៍ចំនួនប្រាំមួយកន្លែងដែលរួមមាន ទំនប់ត្រពាំងថ្ម ព្រលានយន្តហោះកំពង់ឆ្នាំង ទំនប់១មករា ការដ្ឋានស្រែអំបិល សហករណ៍ត្រាំកក់ និងការដ្ឋានស២៤។

**១៧០.** បក្សកុម្មុយនីស្តកម្ពុជាបានចាប់ផ្តើមអនុវត្តគោលនយោបាយសមូហភាពលើផលិតផលកសិកម្មក្នុងអំឡុងឆ្នាំ ១៩៧០ និងបានបង្កើនការអនុវត្តន៍នេះតាមរយៈមធ្យោបាយដែលបក្សកុម្មុយនីស្តកម្ពុជាបានពង្រឹងការកាន់កាប់លើទឹកដីទាំងមូលនៃប្រទេសកម្ពុជា។ សហករណ៍មួយចំនួនត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៧៣ មកម្លេះ។ នៅខែឧសភា ឆ្នាំ ១៩៧៥ សន្និបាតមួយត្រូវបានប្រារព្ធធ្វើឡើងដោយមានការចូលរួមពីតំណាងបក្សកុម្មុយនីស្តកម្ពុជាមកពីទូទាំងប្រទេសកម្ពុជាដែលនៅក្នុងនោះ ប៉ុល ពត និងមេដឹកនាំជាន់ខ្ពស់ផ្សេងទៀតបានសម្រេចថាបដិវត្តន៍សង្គមនិយមកម្ពុជាត្រូវយកចិត្តទុកដាក់លើវិស័យកសិកម្ម និងវិស័យឧស្សាហកម្មតាមរយៈការបន្តបង្កើតសហករណ៍ ក៏ដូចជាការកសាងទំនប់និងប្រឡាយ។ ផែនការនេះត្រូវបានដាក់ឱ្យអនុវត្តនៅឆ្នាំ ១៩៧៦។

នឹងពង្រីកសហករណ៍ លើកភ្លឺស្រែ ជីកប្រឡាយ និងលើកទំនប់ ហើយផ្តោតសំខាន់លើដីដែលមានជីជាតិបំផុតដើម្បីសម្រេចផលស្រូវ ៣ តោន ក្នុង ១ ហិកតាឱ្យបានត្រឹមឆ្នាំ ១៩៧៦។ កំណត់ហេតុនៃកិច្ចប្រជុំនាថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦ ដែលនៅពេលនោះ ខៀវ សំផន និង នួន ជា មានវត្តមាន បានបញ្ជាក់ថា បក្សសម្រេចបាន ទិសដៅឆ្នាំ ១៩៧៦ ចំនួន ៣០ ភាគរយ ហើយបានវាយតម្លៃថា ជោគជ័យនេះកើតឡើងដោយសារការរៀបចំផែនការបានហ្មត់ចត់ និងប្រុងប្រយ័ត្ន។ គិតមកត្រឹមខែឧសភា ឆ្នាំ ១៩៧៦ ស្រែត្រូវបានភ្ជួររាស់យ៉ាងហោចណាស់បានម្តង ហើយការសាបព្រោះ និងដកស្ទូងបានចាប់ផ្តើមរួចទៅហើយ។

**៦១២.** នៅចន្លោះខែធ្នូ ឆ្នាំ១៩៧៦ និងខែធ្នូ ឆ្នាំ១៩៧៧ កងចល័តត្រូវបានបញ្ជូនឱ្យទៅលើកទំនប់នៅក្នុងខេត្តកំពង់ធំ និងខេត្តកំពង់ចាម (ភូមិភាគ (ឧត្តរចាស់) កណ្តាល) និងខេត្តកំពត (ភូមិភាគនិរតី) ផងដែរ។ គ្មានគ្រឿងចក្រសម្រាប់លើកទំនប់ទេ ដូច្នេះគេប្រើប្រាស់កម្លាំងមនុស្ស។ ជាពិសេសប្រជាជនចំនួនរាប់ពាន់នាក់ត្រូវបានប្រមូលផ្តុំពីខេត្តកំពង់ចាម និងខេត្តកំពង់ធំ (ភូមិភាគ (ឧត្តរចាស់) កណ្តាល) ឱ្យទៅលើកទំនប់ ១ មករា ដែលស្ថិតនៅស្រុកបារាយណ៍ ខេត្តកំពង់ធំ ហើយការសាងសង់ទំនប់ទាំងមូលបានចាប់ផ្តើមនៅក្នុងខែ ធ្នូ ឆ្នាំ ១៩៧៦។ កងចល័តបានដើរពីការដ្ឋានលើកទំនប់មួយ

| | |
|---|---|
| | ទៅការដ្ឋានលើកទំនប់មួយទៀត ទោះជិត ឬ ឆ្ងាយក៏ដោយ និងពុំត្រូវបានឲ្យស្បៀងអាហារ ទឹក ឬ មុងនោះទេ។ ពេលខ្លះ ពួកគេដើរទៅដោយគ្មានអ្នកនាំផ្លូវទៅជាមួយឡើយ។ ទោះបីជាយ៉ាងនេះក្តី គ្មានប្រជាជនណាម្នាក់មិនព្រមផ្លាស់ទីលំនៅនោះទេ លើកលែងតែពួកគេឈឺ ឬ មិនអាចដើរបាន។<br><br>**៦១៦.** នៅពាក់កណ្តាលឆ្នាំ ១៩៧៦ បក្សបានប្រកាសថា បក្សបានចាត់តាំង កសាង ពង្រឹង និងពង្រីករបបសមូហភាព វាយរបបនាយទុន និងបញ្ចប់របបសក្តិភូមិម្ចាស់ដី។ ហេតុដូច្នេះ នៅពាក់កណ្តាល ឆ្នាំ ១៩៧៦ ការផ្តោតចម្បងជាសំខាន់នោះគឺការចាប់ផ្តើមងាកទៅរកខ្មាំងនៅក្នុងបក្ស។ ទោះបីជាយ៉ាងនេះក្តី បក្សនៅតែយល់ឃើញថា បក្សចាំបាច់ត្រូវវាយ "ប្រជាជនថ្មី" ដែលជាសំណល់ពីសក្តិភូមិ និងនាយទុន។ នៅក្នុងឆ្នាំ ១៩៧៦ សហករណ៍បានបន្តពង្រីកបន្ថែមទៀត ជាមធ្យមមានចំនួន ចន្លោះពី ១០០ គ្រួសារ ទៅ ៣០០ គ្រួសារ ហើយសហករណ៍ខ្លះមានរហូតដល់ ៥០០ គ្រួសារ និងនៅឃុំខ្លះទៀត សហករណ៍មានរហូតដល់ ១.០០០ គ្រួសារ។<br><br>**៧៥០.** ដោយបានធ្វើដំណើរមកដល់ទីក្រុងភ្នំពេញទាំងអស់គ្នា យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៧៥ នោះ នួន ជា ប៉ុល ពត ខៀវ សំផន អៀង សារី និង សុន សេន បានបង្កើតគណៈកម្មាធិការដឹកនាំរួមមួយ។ ពួកគេបានជួបប្រជុំជាទៀតទាត់ជាមួយលេខាភូមិ |

| | |
|---|---|
| | ភាគ និងលេខាតំបន់ស្វយ័តនានា និងអ្នកផ្សេងទៀត ដើម្បីពិភាក្សាអំពីគោលនយោបាយ និងផែនការនានា ដើម្បីកសាង និងការពារប្រទេសសង្គមនិយម ឯករាជ្យ ខ្លួនទីពឹងខ្លួន ក៏ដូចជាការបង្កើត សហករណ៍ផងដែរ។<br><br>**៧៥៩.** [...] អៀង សារី បានបញ្ជាក់ថា គាត់មានវត្តមាននៅក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំបក្ស កាលពីខែ កញ្ញា ឆ្នាំ ១៩៧៥ ដែលក្នុងកិច្ចប្រជុំនោះក៏មានវត្តមានរបស់ ខៀវ សំផន ប៉ុល ពត នួន ជា សោ ភឹម សុន សេន តា ម៉ុក វ៉ន វេត វស់ ញឹម កុយ ធួន និងមេបញ្ជាការយោធាមួយចំនួនទៀត ដែលពិភាក្សាអំពីបញ្ហាការពារ កសិកម្ម "បញ្ហាទឹក" និងឧស្សាហកម្ម។ អ្នកជំនាញ លោក Philip SHORT ក៏បានសរសេររៀបរាប់ពីកិច្ចប្រជុំគណៈកម្មាធិការមជ្ឈិមកាលពីពាក់កណ្ដាលខែ កញ្ញា ដែលពិភាក្សាពីបញ្ហាកសិកម្ម សង្គមកិច្ច និងការការពារ បើទោះបីជាប្រភពព័ត៌មានរបស់គាត់សម្រាប់ចំណុចនេះមិនមានភាពច្បាស់លាស់ក្ដី។ លើសពីនេះទៀត ទង់បដិវត្តចេញផ្សាយខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៥ បានលើកឡើងថា "មហាសន្និបាតរបស់មជ្ឈិមបក្ស" បានសម្រេចជាឯកច្ឆន្ទទៅលើគោលដៅផលិតស្រូវឱ្យបានបីតោនក្នុងមួយហិកតា តាំងពីមុនខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ដែលជាគោលដៅផលិតកម្មដែលត្រូវបានបញ្ជាក់យ៉ាងជាក់លាក់នៅក្នុងឯកសារគោលនយោបាយខែ កញ្ញា ឆ្នាំ ១៩៧៥។ |

ជាចុងក្រោយ អ្នកជំនាញលោក David CHANDLER បានពន្យល់ថាផែនការសេដ្ឋកិច្ចរួមដែលបានលេចឡើងនៅចុងឆ្នាំ ១៩៧៥ ហើយនាំឱ្យមានការផ្លាស់ទីលំនៅប្រជាជនពីទីជនបទមួយ ទៅកាន់ទីជនបទមួយទៀត ជាពិសេសនៅដើមឆ្នាំ ១៩៧៦ នោះ គឺជាលទ្ធផលនៃការដឹកនាំរួមរបស់មជ្ឈិម "ដែលពេលខ្លះស្ថិតនៅចំណុចស្នូលរបស់គណៈកម្មាធិការមជ្ឈិម" ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា មានកិច្ចប្រជុំថ្នាក់ដឹកនាំបក្សមួយនៅដើមខែ កញ្ញា ឆ្នាំ ១៩៧៥ ពាក់ព័ន្ធទៅនឹងគោលនយោបាយសេដ្ឋកិច្ច ហើយដែលក្រោយមកត្រូវបានពន្យល់នៅក្នុងឯកសារគោលនយោបាយខែ កញ្ញា ឆ្នាំ ១៩៧៥។ ដោយកត់សម្គាល់ពីតួនាទីក្នុងការសម្រេចចិត្តថ្នាក់មជ្ឈិមរបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងសមាជិកភាពរបស់គាត់នៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិមតាំងពីយូរមកហើយនោះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា នួន ជា មានវត្តមាននៅក្នុងកិច្ចប្រជុំនេះ។

**៨៦៧.** បន្ទាប់ពីគណៈកម្មាធិការអចិន្ត្រៃយ៍បានចុះធ្វើទស្សនកិច្ចនៅភូមិភាគពាយ័ព្យក្នុងខែ សីហា ឆ្នាំ ១៩៧៥ រួចមក គណៈកម្មាធិការនេះ បានសម្រេចផ្លាស់ទីលំនៅប្រជាជនចំនួនពី ៤០០.០០០ នាក់ ទៅ ៥០០.០០០ នាក់ ឱ្យមកកាន់តំបន់នេះ។ របាយការណ៍របស់គណៈកម្មាធិការអចិន្ត្រៃយ៍ស្ដីពីដំណើរទស្សនកិច្ចនេះបានផ្ដល់នូវ

| | |
|---|---|
| | "មតិណែនាំរបស់អង្គការ" ស្តីពីបញ្ហាសំខាន់ៗនៃ "ការចាត់ចែងកម្លាំងពលកម្ម" សហករណ៍នានា និងការចាត់ចែងចំពោះទីក្រុង។ របាយការណ៍របស់គណៈកម្មាធិការអចិន្ត្រៃយ៍ បានបង្ហាញពីឥរិយាបទខឹងសម្បាររបស់សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ចំពោះប្រជាជនថ្មី។ របាយការណ៍នេះបានកំណត់អំពីផែនការរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងការបង្ខំឱ្យប្រជាជនថ្មីទាំងអស់រស់នៅក្នុងសហករណ៍។ អង្គជំនុំជម្រះយល់ឃើញថា របាយការណ៍នេះ បានបង្កើតផែនការដែលមានការគ្រោងទុកយ៉ាងប្រយ័ត្នប្រយែងរបស់ថ្នាក់ដឹកនាំដើម្បីបង្កើន និងធ្វើឱ្យការការពារជាតិ (តាមរយៈការបង្កើតសហករណ៍នានា) និងសេដ្ឋកិច្ច (តាមរយៈការផ្លាស់ទីលំនៅប្រជាជន) មានភាពល្អប្រសើរឡើង។ ដោយសារគណៈកម្មាធិការអចិន្ត្រៃយ៍បានជួបប្រជុំរៀងរាល់សប្តាហ៍ ហើយកាន់តែញឹកញាប់ទៀតនៅពេលមានស្ថានភាពបន្ទាន់ចាំបាច់ អង្គជំនុំជម្រះជឿជាក់ថា ទោះបីជា នួន ជា មិនបានចូលរួមដោយផ្ទាល់នៅក្នុងដំណើរទស្សនកិច្ចទៅកាន់ភូមិភាគពាយ័ព្យក្តី ក៏តាមរយៈរបាយការណ៍ជាលាយលក្ខណ៍អក្សររបស់គណៈកម្មាធិការអចិន្ត្រៃយ៍នោះ គាត់បានដឹងពីលទ្ធផលនៃដំណើរទស្សនកិច្ចនេះ សេចក្តី-សម្រេចដែលបានធ្វើឡើងនាពេលក្រោយមក និងបញ្ហាផ្សេងៗដែលប្រជាជនថ្មីនៅក្នុងភូមិភាគនោះកំពុងប្រឈម។ យោងតាមសេចក្តីថ្លែងការណ៍មុនៗរបស់ នួន ជា អង្គជំនុំជម្រះក៏ជឿជាក់ថា គាត់មានទស្សនៈយល់ឃើញ |

ដូចគ្នា ទៅនឹងទស្សនៈយល់ឃើញរបស់ថ្នាក់ដឹកនាំដែលបានលើកឡើងនៅក្នុងរបាយការណ៍ពាក់ព័ន្ធនឹងប្រជាជនថ្មីនេះ។

**៨៧១.** ភ្លាមៗបន្ទាប់ពីកិច្ចប្រជុំខែ ឧសភា ឆ្នាំ ១៩៧៥ នៅឯព្រះវិហារព្រះកែវមរកត នួន ជា រួមជាមួយនឹង ប៉ុល ពត ព្រមទាំងមេដឹកនាំសំខាន់ៗដទៃទៀត បានដឹកនាំកិច្ចប្រជុំមួយចំនួន។ នៅចន្លោះពីថ្ងៃទី ២០ ដល់ ២៥ ខែ ឧសភា ឆ្នាំ ១៩៧៥ នួន ជា ព្រមទាំងមេដឹកនាំដទៃទៀត បានណែនាំដល់តំណាងនានាមកពីអង្គភាពកងទ័ព និង លេខាស្រុក តំបន់ និងភូមិភាគទាំងអស់ អំពីគោលនយោបាយរបស់បក្សពាក់ព័ន្ធនឹងការរៀបចំសហករណ៍ ការលុបបំបាត់កម្មសិទ្ធិឯកជន ការ ហាមមិនឱ្យចាយលុយ ការបិទទីផ្សារ ការលើកទំនប់ និងជីកប្រឡាយ។ នៅក្នុងរយៈពេលប៉ុន្មានខែក្រោយមក ថ្នាក់ក្រោមបានអនុវត្តសេចក្តីណែនាំទាំងឡាយដែលពួកគេបានទទួល។

**៩០០.** យ៉ាងយូរបំផុត ចាប់ពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៧៥ នួន ជា បានជួបប្រជុំជាមួយនឹងមេដឹកនាំជាន់ខ្ពស់ផ្សេងៗទៀត អំពីគោលនយោបាយកសាង និង ការពារប្រទេសដែលមានឯករាជ្យ ខ្លួនទីពឹងខ្លួន និង សង្គមនិយម។ ផែនការនេះមានគោលបំណងបង្កើតសង្គមគ្មានវណ្ណៈមួយ ដែលប្រជាជនគ្រប់គ្នានឹងត្រូវបានរៀបចំបញ្ចូលទៅក្នុងសហករណ៍ ដើម្បីការពារ និង កសាងប្រទេសឱ្យបានលឿនលឿន ដោយផ្តោតជា

ពិសេសលើការបង្កបង្កើនផល និងគម្រោងធារាសាស្ត្រ។ ផែនការទាំងនេះ ពីដំបូង បានកើតចេញមកពី និងផ្អែកលើបទពិសោធន៍របស់បក្សនៅតាមតំបន់រំដោះដើម្បីផ្គត់ផ្គង់កម្លាំងមនុស្សដែលត្រូវការ ដើម្បីសម្រេចផែនការនេះ ហើយវិធីសាស្ត្រនៃការជម្លៀស និងផ្លាស់ទីលំនៅមានលក្ខណៈដូចៗគ្នា ពីទីជនបទមួយទៅកាន់ទីជនបទមួយទៀត នៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបន្តអនុវត្តក្រោយពីពេលនេះរហូតមក។ ទោះបីជាធ្លាប់មានបទពិសោធន៍ដូចនេះក៏ដោយ ក៏គ្មានភ័ស្តុតាងណាមួយបង្ហាញថា ផែនការនេះមានវិធានការនានាដែលផ្តល់សុខុមាលភាពដល់ប្រជាជនដែលត្រូវបានជម្លៀស ឬមានការយល់ព្រមពីប្រជាជនដែលនឹងត្រូវប្រមូលផ្តុំទៅនៅសហករណ៍នោះឡើយ។

**៩០១.** នួន ជា បានចូលរួមជាមួយនឹងមេដឹកនាំសំខាន់ៗផ្សេងទៀតនៅក្នុងកិច្ចប្រជុំក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ ដើម្បីពិភាក្សាអំពីផែនការរបស់ថ្នាក់ដឹកនាំក្នុងការសម្រេចឱ្យបាននូវបដិវត្តន៍សង្គមនិយម តាមរយៈការអនុវត្តសមូហភាវូបនីយកម្ម [...]

**៩០២.** នៅចុងឆ្នាំ ១៩៧៥ នួន ជា រួមជាមួយនឹងអ្នកផ្សេងទៀត បានរួមគ្នាបង្កើតផែនការសេដ្ឋកិច្ចជាក់លាក់មួយ។ ផែនការនេះបានទទួលស្គាល់អំពីការខ្វះខាតស្បៀងអាហារ និងថ្នាំសង្កូវ ជាពិសេស ប៉ះពាល់លើ “ប្រជាជនថ្មី”។ ទោះបីជាយ៉ាងនេះក្តី ផែនការនេះពាក់ព័ន្ធនឹងការ

| | |
|---|---|
| | បែងចែកកម្លាំងពលកម្មទៅតាមយុទ្ធសាស្ត្រដែលជាគោលដៅនៃការផលិតស្រូវរបស់បក្ស និងអាទិភាពនៃហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងមានគោលបំណងពង្រីកសហករណ៍ និងផ្ដល់ការលើកទឹកចិត្តដល់ "ប្រជាជនចាស់" ដែលធ្វើឱ្យប៉ះពាល់ដល់ "ប្រជាជនថ្មី" ដែលស្ថិតនៅក្រោមការសង្ស័យ។ ក្រោយពេល គណៈកម្មាធិការអចិន្ត្រៃយ៍ បានចុះធ្វើទស្សនកិច្ចនៅភូមិភាគពាយ័ព្យនៅក្នុងខែ សីហា ឆ្នាំ ១៩៧៥ (ដំណើរទស្សនកិច្ចដែលមានការចូលរួមពី នួន ជា ឬយ៉ាងហោចណាស់ គាត់បានដឹងអំពីដំណើរទស្សនកិច្ចនេះ តាមរយៈរបាយការណ៍ជាលាយលក្ខណ៍អក្សរ) គណៈកម្មាធិការអចិន្ត្រៃយ៍បានសម្រេចបែងចែកជាថ្មីដោយបញ្ជូនប្រជាជន ចំនួន ៤០០.០០០ នាក់ ទៅ ៥០០.០០០ នាក់ បន្ថែមទៀតទៅឱ្យតំបន់នេះ។<br><br>**៩០៤.** មជ្ឈិមបក្ស រួមជាមួយនឹងកម្មាភិបាលភូមិភាគ តំបន់ និងស្រុក បានគ្រប់គ្រងមធ្យោបាយ និងវិធីសាស្ត្រនៃការដឹកជញ្ជូន។ ដូចមាននៅក្នុងផែនការ និងស្របតាមវិធីសាស្ត្រដែលធ្លាប់អនុវត្ត ប្រជាជនត្រូវបានបញ្ជូនទៅតាមការដ្ឋានធ្វើការងារ និងទៅតាមតំបន់ដែលសន្មតថាដីមានជីជាតិបំផុត។ |
| **"ការបោសសម្អាតផ្ទៃក្នុង"**<br><br>**១៩២.** "ការបោសសម្អាត" ផ្ទៃក្នុងបានកើនឡើងជាលំដាប់ស្របតាមការវិវឌ្ឍន៍របស់គោលនយោបាយ | **"ការបោសសម្អាតផ្ទៃក្នុង"**<br><br>**៣៥០.** នួន ជា ក៏ជាប់ពាក់ព័ន្ធនឹងការបោសសម្អាតកម្មាភិបាល និងយោធា ជាពិសេសអ្នកដែលមកពីភូមិភាគបូ |

នេះ។ "បោសសម្អាត"មានន័យថាធ្វើឱ្យបរិសុទ្ធផ្នែកគោលនយោបាយ តាមរយៈការដាក់ទណ្ឌកម្មដែលមានចាប់ពីការបញ្ចុះឋានន្តរសក្តិបុគ្គលណាម្នាក់ រហូតដល់យកទៅលត់ដំ ឬរហូតដល់កម្រិតធ្ងន់បំផុត គឺ "កម្ទេចចោល" ។ ទាំងសមាជិកបក្ស និងបុគ្គលដែលមិនមែនជាសមាជិកបក្សក៏មានជាប់ទាក់ទងផងដែរ។ មន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្សមួយ ចំនួនដែលស្ថិតនៅក្រោមការស៊ើបសួរបង្ហាញអំពីស្ថានភាពអង្គហេតុដែលត្រូវបានកំណត់ថាជាការបោសសម្អាត។ ជាពិសេសសហចៅក្រមស៊ើបអង្កេត ត្រូវបានប្តឹងអំពីព្រឹត្តិការណ៍បោសសម្អាតជាក់លាក់ចំនួនពីរ ដែលបានកើតឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ៖ ការបោសសម្អាតនៅភូមិភាគឧត្តរចាស់ និងនៅភូមិភាគឧត្តរថ្មី ព្រមទាំងការបោសសម្អាតនៅភូមិភាគបូព៌ា។

**១៩៣.** ក្រោយពីមានសេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ ១៩៧៦ ឱ្យមានការកម្ទេចនៅក្នុងជួរបដិវត្តន៍ ការបោសសម្អាតដែលពាក់ព័ន្ធនឹងការកាប់សម្លាប់យ៉ាងច្រើន ត្រូវបានធ្វើឡើងនៅក្នុងភូមិភាគឧត្តរ និងនៅក្នុងតំបន់១០៦ ចាប់តាំងពីចុងឆ្នាំ១៩៧៦។ ការបោសសម្អាតទាំងនេះបានកើនឡើងយ៉ាងគំហុកនៅដើមឆ្នាំ១៩៧៧ និងបន្តរហូតដល់ចុងឆ្នាំ១៩៧៧នេះ។

**១៩៤.** មុនខែមេសា ឆ្នាំ១៩៧៥ ភូមិភាគឧត្តរ (ឬ

ព៌ា។ នៅឆ្នាំ ១៩៧៨ គាត់បានចូលរួមក្នុងកិច្ចប្រជុំមួយជាមួយមេដឹកនាំដទៃទៀតរបស់បក្ស រួមមាន ប៉ុល ពត សុន សេន និង តាម៉ុក ព្រមទាំងមេបញ្ជាការយោធាជាច្រើនរូបទៀត ដោយនៅក្នុងកិច្ចប្រជុំនោះ សមាជិករបស់ភូមិភាគបូព៌ា ជាពិសេស សោ ភឹម ត្រូវបានប្រកាសថាជាខ្មាំងផ្ទៃក្នុងរបស់បក្ស ដែលត្រូវបោសសម្អាត។ នៅក្នុងកិច្ចប្រជុំនោះ នួន ជា បាននិយាយអំពីការចាប់ខ្លួនសមាជិកជាច្រើនរបស់ភូមិភាគបូព៌ា។

**៣៤៥.** ជនបរទេសជាច្រើននាក់ត្រូវបានឃុំខ្លួននៅមន្ទីរ ស-២១ ផងដែរ។ ក្នុងចំណោមអ្នកជាប់ឃុំទាំងនេះ មានទាហានវៀតណាម ដែលការចាប់ខ្លួន និងឃុំខ្លួនពួកគេនៅមន្ទីរ ស-២១ ត្រូវបានរាយការណ៍ជូនទៅគណៈកម្មាធិការមជ្ឈិមបក្ស រួមទាំង នួន ជា ផងដែរ។ កាំង ហ្កេកអ៊ាវ បានផ្តល់សក្ខីកម្មថា នៅមុនពេលដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា បានបញ្ជាឱ្យគាត់ "កម្ទេច" (មានន័យថា សម្លាប់) អ្នកជាប់ឃុំឃាំងទាំងអស់ដែលនៅសេសសល់នៅមន្ទីរស-២១។ នៅពេលនោះ អ្នកជាប់ឃុំទាំងអស់ដែលកំពុងជាប់ឃុំឃាំងនៅមន្ទីរ ស-២១ មានប្រហែល ៥០០ នាក់។

| | |
|---|---|
| ភូមិភាគ ៣០៤ ដោយយោងតាមលេខកូដរបស់ខ្លួន) ត្រូវបានបង្កើតឡើង ហើយត្រូវបានប្រែក្លាយបន្ទាប់មកទៀតទៅជាតំបន់៤១ តំបន់៤២ តំបន់៤៣ និងតំបន់១០៦។ ភូមិភាគឧត្តរត្រូវបានដឹកនាំដោយលេខា កុយ ធួន និងអនុលេខា កែ ពក (អ្នកទាំងពីរជាសមាជិកគណៈមជ្ឈិម)។ បន្ទាប់ពីខែមេសា ឆ្នាំ ១៩៧៥ ភូមិភាគឧត្តរ (ដោយត្រូវបានដាក់ថាជាភូមិភាគ ៣០៣ វិញ) ដោយរួមមានតំបន់ ៤១ ៤២ និង ៤៣ តែប៉ុណ្ណោះ ដោយសារតំបន់ ១០៦ បានក្លាយជាតំបន់ស្វយ័ត។ នៅពេលនោះ កុយ ធួន ត្រូវបានគេផ្ទេរទៅគណៈមជ្ឈិម ហើយក្លាយជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ខណៈដែល កែ ពក បានជំនួស កុយ ធួន ជាលេខាភូមិភាគឧត្តរ។ ស្ថានភាពនេះនៅដូច្នេះរហូតដល់ពេលការបោសសម្អាត ក្នុងឆ្នាំ ១៩៧៧ មានការកើនឡើងយ៉ាងខ្លាំង។ នៅក្នុងបរិបទនៃការបោសសម្អាតទាំងនេះ កែ ពក បានក្លាយជាលេខាភូមិភាគឧត្តរ ដែលត្រូវបានពង្រីកដោយរួមបញ្ចូលជាថ្មីនូវតំបន់១០៦។ ចាន់ សំ ហៅ កង ចាប ហៅ សែ បានក្លាយជាអនុលេខាភូមិភាគនេះ និងជាលេខាតំបន់១០៦ នៅពេលជាមួយគ្នានោះដែរ ដោយត្រូវបានគេផ្ទេរមកពីមុខតំណែងមុនៗរបស់គាត់ នៅក្នុងភូមិភាគនិរតី។ ក្រោយមកនៅក្នុងឆ្នាំនោះដដែល ភូមិភាគឧត្តរថ្មីមួយ (ដោយមានលេខកូដ ៨០១) ត្រូវបានបង្កើតឡើងដោយរួមបញ្ចូលតំបន់១០៦ និង | |

តំបន់១០៣ ដោយមាន សែ ជាលេខា។ តំបន់៤១ តំបន់៤២ និងតំបន់៤៣ ត្រូវបានផ្លាស់ប្តូរឈ្មោះជាភូមិភាគកណ្តាល ដោយមាន កែ ពក ជាលេខា។

**១៩៥.** ក្នុងរយៈពេលប៉ុន្មានថ្ងៃក្រោយពីមានសេចក្តីសម្រេចនៃគណៈមជ្ឈិមចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ លេខាភូមិភាគឧត្តរ កែ ពក បានជូនដំណឹងដល់ ប៉ុល ពត និង នួន ជា អំពីឆន្ទៈរបស់ខ្លួនចង់ចាត់វិធានការនឹងពួកក្បត់នៅក្នុងជួរបដិវត្តន៍។ ក្រោយមកតែបន្តិច អតីតលេខាភូមិភាគឧត្តរ និងអតីតរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម កុយ ធួន ត្រូវបានគេដាក់ឃុំឱ្យនៅក្នុងផ្ទះ ដោយកំហុសជាច្រើនដែលគេចោទប្រកាន់ (ដែលនាំឱ្យគេចោទគាត់ថាជាគិញរបស់ខ្មាំង) ដូច្នេះហើយទំនងជាត្រូវបានគេចាត់ទុកដូចជាសមាសភាពមួយដែលត្រូវការអប់រំផ្នែកគោលនយោបាយ ទៅតាមបទប្បញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យ។ កុយ ធួន ក៏ត្រូវបានគេបណ្តេញចេញពីបក្ស ដោយយោងតាមលក្ខន្តិកៈរបស់បក្សដែរ។

**១៩៦.** នៅក្នុងភូមិភាគឧត្តរ ការអនុវត្តសេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ បាននាំឱ្យមានការចាប់ខ្លួនកម្មាភិបាលជាន់ខ្ពស់ជាលើកដំបូងនៅចុងឆ្នាំ១៩៧៦ នៅពេល ឈឹម មាស ហៅ ហោះ (លេខាកងវរៈសេនាធំនៃកងពល ១១៧ របស់ភូមិ

ភាគឧត្តរ) ត្រូវបានគេបញ្ជូនទៅ ស-២១ ហើយចម្លើយសារភាពរបស់គាត់បានឆ្លើយដាក់ កុយ ធួន។ នៅក្នុងពេលជាមួយគ្នានោះដែរ ស-២១ បានចាប់ខ្លួនកម្មាភិបាលជាន់ខ្ពស់មួយរូបមកពីក្រសួងពាណិជ្ជកម្មជាលើកដំបូង។ កម្មាភិបាលនេះជិតស្និទ្ធនឹង កុយ ធួន ណាស់ គឺកម្មាភិបាល ទិត សុន ហៅ ញ៉ែមដែលជាសមាជិកទីពីរនៅក្នុងជួរគណៈពាណិជ្ជកម្មនៃមជ្ឈិមហើយដែលបានចាប់ផ្ដើមឆ្លើយសារភាពក្រោមការធ្វើទារុណកម្មនៅអំឡុងខែវិច្ឆិកាឆ្នាំ១៩៧៦។

**១៩៧.** ក្រោយពីមានការឆ្លើយដាក់ជាលើកដំបូងពីកម្មាភិបាលរូបនេះ កុយ ធួន ត្រូវបានគេចាត់ទុកថាជាជនក្បត់ ហើយត្រូវបានចាប់ខ្លួនដោយសេចក្ដីសម្រេចរបស់គណៈអចិន្ត្រៃយ៍ និងត្រូវបានបញ្ជូនទៅ ស-២១ ដែលការសួរចម្លើយរបស់គាត់មួយផ្នែកត្រូវបានធ្វើឡើងដោយ ឌុច ផ្ទាល់។ កុយ ធួន បានឆ្លើយសារភាពថា ជាសមាជិករបស់ខ្សែក្បត់ដ៏ធំមួយ ដែលរួមមានកម្មាភិបាលរដ្ឋបាល និងយោធានៅក្នុងភូមិភាគឧត្តរជាច្រើន។ ការឆ្លើយសារភាពនេះបានបណ្ដាល ឱ្យមានការបោសសម្អាតរីករាលដាលគួរឱ្យកត់សម្គាល់ដោយមានមនុស្សជាច្រើនត្រូវបានគេចាប់ខ្លួន និងដឹកទាំងឡានៗបញ្ជូនទៅ ស-២១។ យោងតាម ឌុច ចម្លើយសារភាពដំបូងរបស់

| | |
|---|---|
| កុយ ធួន បណ្តាលឱ្យមានការបោសសម្អាតជាទ្រង់ទ្រាយធំ តាមរយៈការចាប់ខ្លួនកម្មាភិបាលភូមិភាគឧត្តរជាច្រើននាក់។ កែ ពក បានត្រួតពិនិត្យមើលដោយផ្ទាល់លើការបោសសម្អាតតំបន់១០៦ ហើយបានរាយការណ៍លើស្ថានភាពនេះទៅគណៈ ៨៧០។ ជនក្បត់ជាច្រើនមកពីតំបន់១០៦ ដែលត្រូវបានគេចោទប្រកាន់ បានទៅដល់ ស-២១ ចាប់តាំងពីដើមឆ្នាំ១៩៧៧មកម្លេះ។ ជនរងគ្រោះនៃការបោសសម្អាតដែលមានឋានៈតូចតាច ត្រូវបានគេសម្លាប់ចោលនៅក្នុងមូលដ្ឋាន ហើយដាក់ជំនួសដោយកម្មាភិបាលមកពីភូមិភាគនិរតី និងដោយសាច់ញាតិរបស់ កែ ពក ដើម្បីជួយបង្កើនកម្លាំងក្នុងការបោសសម្អាត។<br><br>**១៩៨.** ការបោសសម្អាតភូមិភាគឧត្តរបានបន្តរហូតដល់ឆ្នាំ១៩៧៨។ ក្រៅពីតំបន់ ១០៦ ការបោសសម្អាតបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កងពល ១៧៤ របស់ភូមិភាគ តំបន់ ១០៣ កងពល៩២០ របស់មជ្ឈិម និងតំបន់១០៥រួមទាំងកងពល៣១០ និង ៤៥០ របស់មជ្ឈិម មន្ទីរ ៨៧០ របស់មជ្ឈិម ព្រមទាំងអតីតកម្មាភិបាលភូមិភាគឧត្តរដែលកំពុងបម្រើការងារនៅក្នុងក្រសួងពាណិជ្ជកម្ម។ ព័ត៌មានបន្ថែមស្តីពីការបោសសម្អាតភូមិភាគឧត្តរថ្មី មានរៀបរាប់នៅក្នុងផ្នែកស្តីអំពីមន្ទីរសន្តិសុខនៅភូមិភាគឧត្តរនៃ | |

| | |
|---|---|
| ដីកាដំណោះស្រាយនេះ។<br><br>**១៩៩.** ការបោសសម្អាតនៅភូមិភាគបូព៌ាត្រូវបានចាប់ផ្តើមនៅពាក់កណ្តាលឆ្នាំ១៩៧៦ ដោយមានការចាប់ខ្លួន សួស នៅ ហៅ ឈូក អតីតលេខាតំបន់២៤ និងចាន់ ចក្រី ហៅ នៅ មាន អតីតកម្មាភិបាលកងពល១៧០ នៃភូមិភាគបូព៌ា។ អ្នកទាំងពីរត្រូវបានចាប់ខ្លួន តាមសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍។ ឈូក និង ចក្រី ត្រូវបានគេសួរចម្លើយ ធ្វើទារុណកម្ម និងទាញយកចម្លើយសារភាព ដែលក្នុងនោះបានឆ្លើយដាក់កម្មាភិបាលនៅតំបន់២៤ មួយចំនួនទៀត។ ចម្លើយសារភាពទាំងនេះត្រូវបានគេវិភាគ ហើយនៅត្រឹមពាក់កណ្តាលខែកញ្ញា ឆ្នាំ១៩៧៦ សុន សេន និងបុគ្គលិក ស-២១ បានបង្កើនការដេញតាមចាប់អ្នកដែលត្រូវបានគេចោទថាជាជនក្បត់ដែលជាកម្មាភិបាល និងអតីតកម្មាភិបាលភូមិភាគបូព៌ា ដែលត្រូវបានគេឆ្លើយដាក់ថាជាភ្នាក់ងារ សេ.អ៊ី.អា ក.ហ្សេ.បេ និងវៀតណាម ហើយនាំឱ្យមានការចាប់ខ្លួនកម្មាភិបាលភូមិភាគបូព៌ាជាហូរហែ ដែលភាគច្រើនត្រូវបានគេបញ្ជូនទៅ ស-២១ រហូតដល់ឆ្នាំ១៩៧៧។ ឧទាហរណ៍ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៧ ស៊ាត ឆែ ហៅ ទុំ អតីតលេខាតំបន់២២ ត្រូវបានគេចាប់ខ្លួន។ ចម្លើយសារភាពដែលទាញចេញពី ទុំ នៅ ស-២១ ចុះថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ | |

| | |
|---|---|
| ១៩៧៧ បាននាំឲ្យមានការបោសសម្អាតធំមួយនៅតំបន់២២។<br><br>**២០០.** ចាប់ពីពាក់កណ្តាលខែសីហា ឆ្នាំ១៩៧៧ ការចាប់ខ្លួន និងការបញ្ជូនខ្លួននៅក្នុងភូមិភាគបូព៌ាបានរៀបចំឡើងយ៉ាងហ្មត់ចត់ដោយ សុន សេន និង កែ ពក តាមរយៈការប្រើប្រាស់កងកម្លាំងអចិន្ត្រៃយ៍របស់គណៈមជ្ឈិម អង្គភាពមកពីភូមិភាគកណ្តាល និងកងទ័ពរបស់អតីតភូមិភាគនិរតី ដែលស្ថិតនៅក្រោមបញ្ជារបស់គណៈមជ្ឈិម។ នៅក្នុងខែមីនា ឆ្នាំ១៩៧៨ ការបោសសម្អាតដែលកើនឡើងយ៉ាងធំមួយលើកម្មាភិបាល និងយុទ្ធជននៅភូមិភាគបូព៌ា បានកើតឡើងនៅស្វាយរៀង (តំបន់២៣) ដោយក្រោយមកមានការចាប់ខ្លួន និងសម្លាប់ចោលកាន់តែច្រើនឡើងៗចាប់ពីខែឧសភា ដល់ខែមិថុនា ឆ្នាំ១៩៧៨ នៅតាមបណ្តាទីកន្លែងដទៃៗទៀតនៅក្នុងភូមិភាគបូព៌ាដែលក្នុងអំឡុងពេលនោះ លេខាភូមិភាគបូព៌ា សោ ភឹម បានធ្វើអត្តឃាដដោយមិនចង់ឲ្យគេចាប់ខ្លួន។<br><br>**២០១.** ដូចបានគូសបញ្ជាក់ខាងលើការបោសសម្អាតភូមិភាគបូព៌ាមិនមែនកំណត់តាមភូមិសាស្ត្រត្រឹមកម្មាភិបាលរបស់ភូមិភាគបូព៌ាប៉ុណ្ណោះទេ ពោលគឺកម្មាភិបាលដែលមានប្រភពមកពីភូមិភាគបូព៌ាដែលត្រូវបានគេឲ្យទៅធ្វើការនៅទីកន្លែងដទៃៗទៀត | |

| | |
|---|---|
| ដោយរួមទាំងនៅក្នុងបណ្ដាក្រសួងនានា ដូចជាក្រសួងសង្គមកិច្ចជាដើមក៏ត្រូវបានគេកំណត់មុខសញ្ញារហូតដល់ចុងបញ្ចប់របបកម្ពុជាប្រជាធិបតេយ្យ។ កម្មាភិបាលរាប់រយនាក់ត្រូវបានបញ្ជូនពីភូមិភាគបូព៌ាទៅមន្ទីរ ស-២១ ខណៈពេលដែលអ្នកផ្សេងទៀតត្រូវបានសម្លាប់នៅនឹងកន្លែងឬត្រូវបានផ្លាស់កន្លែងទៅកាន់តំបន់ផ្សេងទៀតនៃប្រទេស។ កម្មាភិបាលមួយចំនួន ដែលរួមមានអតីតកម្មាភិបាលនិងយុទ្ធជនរបស់ភូមិភាគបូព៌ាត្រូវបានដាក់ឱ្យធ្វើការនៅតាមការដ្ឋានដើម្បី "ការលត់ដំ" ដូចជានៅទីកន្លែងសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង។<br><br>**២០២.** ចំពោះការបោសសម្អាតនៅភូមិភាគឧត្តរនិងភូមិភាគដែលពាក់ព័ន្ធ មេដឹកនាំជាន់ខ្ពស់នៃ ប.ក.ក បានប្រើប្រាស់ឯកសារចេញផ្សាយរបស់បក្សគឺ *ទង់បដិវត្ត* ដើម្បីផ្ដល់យុត្តិកម្មដល់ការបោសសម្អាតរបស់ខ្លួនដែលកំពុងកើតមាន ដើម្បីឱ្យកម្មាភិបាលទាំងឡាយជឿថា ខ្មាំងផ្ទៃក្នុងបានជ្រៀតចូលបក្ស និងដើម្បីជម្រុញកម្មាភិបាលទាំងនេះឱ្យវែកមុខ និងកម្ទេចខ្មាំងបែបនេះចោល។ | |
| **<u>ទម្រង់ផ្សេងទៀត នៃការទទួលខុសត្រូវរបស់ នួន ជា ៖ សហឧក្រិដ្ឋកម្មរួម</u>**<br><br>**១៥៣២.** មានភស្តុតាងដូចដែលបានរៀបរាប់នៅក្នុងផ្នែកស្ដីអំពី "តួនាទីរបស់ជនត្រូវចោទ" និង"ការកត់ | **<u>ទម្រង់ផ្សេងទៀត នៃការទទួលខុសត្រូវរបស់ នួន ជា ៖ សហឧក្រិដ្ឋកម្មរួម</u>**<br><br>**៣៤៨.** ដោយសារមានតួនាទីខ្ពស់នៅក្នុងថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា នួន ជា ទទួលខុសត្រូវលើ |

សម្គាល់ឃើញអំពីអង្គហេតុនៃសហឧក្រិដ្ឋកម្មរួម” បានបង្ហាញថា **នួន ជា** គឺជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម។ **នួន ជា** បានចូលរួម ឬរួមចំណែក ក្នុងការបង្កើត ការដាក់ឱ្យដំណើរការ និងបានត្រួតពិនិត្យការអនុវត្តផែនការរួម ដែលរួមមាន ជាការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬជាការជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម នៅមុន និងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ **នួន ជា** បានអនុវត្តនូវអំណាចក្នុងតួនាទីរបស់ខ្លួនជា អនុលេខាបក្ស សមាជិកគណៈកម្មាធិការឃោធានៃគណៈមជ្ឈិម និងសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ដែលជាស្ថាប័នមានសិទ្ធិចេញសេចក្ដីសម្រេចខ្ពស់បំផុតរបស់ប្រទេស និងនៅក្នុងការគោរពខ្សែសង្វាក់នៃការបញ្ជាដ៏តឹងរឹងពីមជ្ឈិមទីកាន់ថ្នាក់មូលដ្ឋាន ដែលបានដាក់ឱ្យអនុវត្តដោយបក្ស។ នៅក្នុងតួនាទីទាំងនេះ នួន ជា បានចូលរួមនៅក្នុងកិច្ចប្រជុំកម្រិតខ្ពស់បំផុតរបស់បក្ស ដែលនៅក្នុងកិច្ចប្រជុំនោះ មានការសម្រេចអំពីមាគ៌ានយោបាយ និងបានចូលរួមនៅក្នុងការតាក់តែងឯកសារផ្លូវការនានា។ ក្នុងការធានាការគ្រប់គ្រងមន្ទីរ ស-២១ និងសន្តិសុខផ្ទៃក្នុងនៅក្នុងប្រទេស នួន ជា មានការទទួលខុសត្រូវជាចំបងនៅក្នុងការដាក់ឱ្យអនុវត្តមាគ៌ានយោបាយ ដោយការផ្ដល់ការណែនាំ និងការទទួលសេចក្ដីរាយការណ៍ពីថ្នាក់ក្រោមរបស់គាត់។ នួន ជា បានពន្យល់ បានគាំទ្រ និងបានជំរុញសកម្មភាពទាំងអស់របស់បក្ស ដែលលើសពីតួនាទី និងការទទួលខុសត្រូវដែលត្រូវបានប្រគល់ជូនគាត់ជាផ្លូវការក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះសាលាដំបូង យល់ស្របតាមយោបល់របស់អ្នកជំនាញ David CHANDLER និង Philip SHORT ថា នៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស នួន ជា និង ប៉ុល ពត មានអំណាចធ្វើសេចក្ដីសម្រេចចុងក្រោយរបស់បក្ស។ ក្នុងឋានៈជាអនុលេខាបក្ស ការគ្រប់គ្រងរបស់គាត់មិនមែនមានត្រឹមតែក្នុងការធ្វើសេចក្ដីសម្រេចផ្នែកនយោបាយប៉ុណ្ណោះទេ ប៉ុន្តែមានរហូតដល់ខាងផ្នែករដ្ឋាភិបាល និងរដ្ឋបាលរបស់របបកម្ពុជាប្រជាធិបតេយ្យ រួមទាំងកិច្ចការឃោធាថែមទៀតផងដែរ។ សម្រាប់ហេតុផលទាំងអស់នេះហើយ អង្គជំនុំជម្រះយល់ឃើញថា នួន ជា មានតួនាទី និងបានអនុវត្តនូវសិទ្ធិអំណាចរបស់ខ្លួនដើម្បីបង្កើត និងអនុវត្តនូវគោលនយោបាយ និងសេចក្ដីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជា ។

**៨៦១.** អង្គជំនុំជម្រះយល់ឃើញថា នួន ជា ក្នុងឋានៈជាអនុលេខាបក្សដែលមានអំណាចក្នុងការធ្វើសេចក្ដីសម្រេចចុងក្រោយជាមួយនឹង ប៉ុល ពត មិនត្រឹមតែបានចូលរួមនៅក្នុងការរៀបចំគោលនយោបាយដំបូងរបស់របបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះទេ ប៉ុន្តែក៏បានចូលរួមយ៉ាងសកម្មនៅក្នុងអំឡុងពេលពាក់ព័ន្ធនៃសំណុំរឿង ០០២/០១ នៅក្នុងការអនុវត្តគោលនយោបាយទាំងនោះ

| | |
|---|---|
| ជាសាធារណៈ ដល់គោលនយោបាយនានារបស់បក្សកុម្មុយនីស្តកម្ពុជា តាមរយៈការចូលរួមយ៉ាងសកម្មនៅក្នុងការឃោសនារបស់ ប.ក.ក តាមរយៈសុន្ទរកថាដែលគាត់បានធ្វើ តាមរយៈការដឹកនាំ វគ្គសិក្សានយោបាយធំៗ នានា និងតាមរយៈការចុះទៅពិនិត្យដោយផ្ទាល់តាមបណ្ដាខេត្តនានា។<br><br>**១៥៣៣.** ដូចដែលបានរៀបរាប់ខាងលើ ការដាក់ឱ្យអនុវត្តផែនការរួមនៃសហឧក្រិដ្ឋកម្មរួម រួមមានជាការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬក៏ជាការជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម។ ចេតនាឧក្រិដ្ឋរបស់ នួន ជា អាចទាញសន្និដ្ឋានចេញពីសំដី ពីសកម្មភាពសកម្ម ឬពីសកម្មភាពអកម្ម របស់គាត់។ | ជាបន្ត។ ជាការកត់សម្គាល់ នួន ជា បានចូលរួមនៅក្នុងកិច្ចប្រជុំជាច្រើនលើក ដែលពិភាក្សាអំពីផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ហើយគាត់ក៏បានឯកភាពទៅលើផែនការនេះផង ដែរ។ នួន ជា ក៏បានដឹង និងបានអនុម័តចំពោះការផ្លាស់ទីលំនៅប្រជាជននាពេលបន្ទាប់មកទៀត ព្រមទាំងបានចូលរួមចំណែកក្នុងការរៀបចំ និងជំរុញគោលនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យ ក្នុងការកំណត់គោលដៅមកលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។<br><br>**៨៦២.** ដូចបានពន្យល់លម្អិតខាងក្រោមនេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា នួន ជា បាន ចូលរួមនៅក្នុងគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម ដែលការរួមចំណែករបស់គាត់មានឥទ្ធិពលខ្លាំងក្លា។ ដើម្បីឱ្យ នួន ជា ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្តដោយកងទ័ពខ្មែរក្រហម ដែលមិនមែនជាសមាជិកនៃសហឧក្រិដ្ឋកម្មរួមនោះ ត្រូវតែបង្ហាញឱ្យឃើញថា សមាជិកណាម្នាក់នៃសហឧក្រិដ្ឋកម្មរួម អាចត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋទាំងនេះ ហើយសមាជិកនោះ បានប្រើប្រាស់ចារីដោយផ្ទាល់ ដើម្បីសម្រេចគោលបំណងរួម។ អង្គជំនុំជម្រះសូមរម្លឹកឡើងវិញអំពីការសម្រេចរបស់ខ្លួនថា សមាជិកទាំងឡាយនៃសហឧក្រិដ្ឋកម្មរួមអាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះបាន។ ការយល់ឃើញនៅផ្នែកខាង |

| | |
|---|---|
| | ក្រោមដោយអង្គជំនុំជម្រះ ដែលថា នួន ជា បានរៀបចំផែនការ បានបញ្ជា បានញុះញង់ បានជួយ និងជំរុញដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលរងការចោទប្រកាន់នោះ (ផ្នែក ១៥.៤) ក៏បង្ហាញគ្រប់គ្រាន់ផងដែរពីទំនាក់ទំនងរវាង ចារី និង នួន ជា។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា នួន ជា អាចត្រូវដាក់ឱ្យទទួលខុសត្រូវដោយផ្ទាល់ចំពោះ ឧក្រិដ្ឋកម្មទាំងនេះ។<br><br>**៨៦៣.** នួន ជា ត្រូវបានតែងតាំងជាអនុលេខាបក្សនៅក្នុងមហាសន្និបាតបក្សលើកទី១ នាខែ កញ្ញា ឆ្នាំ ១៩៦០ ដោយគាត់បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការរៀបចំគាក់តែងគោលជំហររបស់បក្សស្តីពីហិង្សាបដិវត្តន៍ និងការប្រើប្រាស់ការតស៊ូប្រដាប់អាវុធ ដើម្បីសម្រេចគោលដៅរបស់បក្ស។ គាត់ក៏បានចូលរួមនៅក្នុងមហាសន្និបាតបក្សលើកទី២ និងលើកទី៣ (នៅខែ កុម្ភៈ ឆ្នាំ ១៩៦៣ និងឆ្នាំ ១៩៧១) ដែលបានបញ្ជាក់អំពីមាគ៌ានយោបាយដដែលនេះ។ នៅក្នុងមហាសន្និបាតបក្សលើកទីមួយ បក្សក៏បានកំណត់គោលដៅបដិវត្តន៍សង្គមនិយមរបស់ខ្លួន និងបានសម្រេចថា ពួកចក្រពត្តិបរទេស "បរិវារ" ឬអ្នកបំរើរបស់ពួកនេះ ព្រមទាំង "ពួកសក្តិភូមិ ពួកមូលធន និងពួកប្រតិកិរិយា" ទាំងអស់ គឺជាខ្មាំងវណ្ណៈ។ ក្នុងឋានៈគាត់ជាអនុលេខាបក្ស ហើយគាត់បានរួមចំណែកចំពោះគោលជំហររបស់បក្ស នួន ជា បានជួយផ្តួចផ្តើម និងបានអនុម័តជាផ្លូវការនូវមាគ៌ារបស់បក្ស។ |

| | |
|---|---|
| | **៨៦៩.** តាមរយៈការរួមចំណែករបស់គាត់នៅក្នុងមហាសន្និបាតបក្ស និងនៅក្នុងកិច្ចប្រជុំនានាជាមួយនឹងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀត អង្គជំនុំជម្រះជឿជាក់ថា នួន ជា មិនត្រឹមតែបានចូលរួមគាំទ្រដល់ផែនការរួមប៉ុណ្ណោះទេ ប៉ុន្តែគាត់ក៏បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការរៀបចំ គាក់តែងខ្លឹមសារផែនការរួមនេះផងដែរ។<br><br>**៨៧០.** អង្គជំនុំជម្រះយល់ឃើញថា ទាំងនៅក្នុងប៉ុន្មានឆ្នាំមុនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងទាំងក្នុងអំឡុងពេលក្រោយៗមកទៀតនៅក្នុងរបបកម្ពុជាប្រជាធិតេយ្យ នួន ជា បានធ្វើការយ៉ាងសកម្មនៅក្នុងការឃោសនា និងការបណ្តុះបណ្តាលកម្មាភិបាលខ្មែរក្រហមនៅតាមទីជនបទ ដោយគាំទ្រដល់គោលនយោបាយបដិវត្ត និងសេដ្ឋកិច្ចរបស់បក្ស ការបង្កើតសហករណ៍ និងការប្រុងប្រយ័ត្នចំពោះខ្មាំង។ នួន ជា ក៏ធ្លាប់ធ្វើជាប្រធាន ជាគ្រូបណ្តុះបណ្តាល ឬ ជាអ្នកឧទ្ទេសនាមនៅក្នុងកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល ឬ វគ្គសិក្សារៀនសូត្រ ដែលគាត់បានជំរុញមាគ៌ារបស់បក្សស្តីពីការប្រុងប្រយ័ត្នចំពោះខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅក្នុងចំណោមកម្មាភិបាលថ្នាក់ក្រោមផងដែរ។<br><br>**៨៧១.** ភ្លាមៗបន្ទាប់ពីកិច្ចប្រជុំខែ ឧសភា ឆ្នាំ ១៩៧៥ នៅឯព្រះវិហារព្រះកែវមរកត នួន ជា រួមជាមួយនឹង ប៉ុល ពត ព្រមទាំងមេដឹកនាំសំខាន់ៗដទៃទៀត បានដឹកនាំកិច្ចប្រជុំមួយចំនួន។ នៅចន្លោះពីថ្ងៃទី ២០ ដល់ |

| | |
|---|---|
| | ២៥ ខែ ឧសភា ឆ្នាំ ១៩៧៥ នួន ជា ព្រមទាំងមេដឹកនាំដទៃទៀត បានណែនាំដល់តំណាងនានាមកពីអង្គភាពកងទ័ព និងលេខាស្រុក តំបន់ និងភូមិភាគទាំងអស់ អំពីគោលនយោបាយរបស់បក្សពាក់ព័ន្ធនឹងការរៀបចំសហករណ៍ ការលុបបំបាត់កម្មសិទ្ធិឯកជន ការហាមមិនឱ្យចាយលុយ ការបិទទីផ្សារ ការលើកទំនប់ និងជីកប្រឡាយ។ នៅក្នុងរយៈពេលប៉ុន្មានខែក្រោយមក ថ្នាក់ក្រោមបានអនុវត្តសេចក្ដីណែនាំទាំងឡាយដែលពួកគេបានទទួល។<br>**៨៧៤.** អង្គជំនុំជម្រះយល់ឃើញថា តាមរយៈតួនាទីរបស់គាត់នៅក្នុងយុទ្ធនាការឃោសនា (រួមទាំងតួនាទីសំខាន់របស់គាត់នៅក្នុងការចេញផ្សាយទស្សនាវដ្ដីទង់បដិវត្ត) និងការបណ្ដុះបណ្ដាល កម្មាភិបាលទាំងនៅពេលមុន និងក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ នួន ជា បានរួមចំណែកយ៉ាងធំធេងនៅក្នុងការផ្សព្វផ្សាយ និងការអនុវត្តគោលបំណងរួមនេះ។<br>**៨៧៥.** ក្នុងឋានៈគាត់ជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា ជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ និងតាមរយៈទំនាក់ទំនងជិតស្និទ្ធរបស់គាត់ជាមួយ ប៉ុល ពត និងមេដឹកនាំកំពូលៗដទៃទៀតនៃបក្សកុម្មុយនីស្តកម្ពុជា នួន ជា គឺជាតួអង្គដ៏សំខាន់ដែលទទួលខុសត្រូវចំពោះការរៀបចំតាក់តែងគោលនយោបាយរបស់បក្ស។ នួន ជា ក៏បានចូលរួមនៅក្នុងកិច្ចប្រជុំនានាមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដែលអនុម័តទៅលើផែនការជម្លៀសប្រជាជនដោយបង្ខំ |

| | |
|---|---|
| | ចេញពីទីក្រុងភ្នំពេញ ហើយក្រោយពីនោះមក នៅគ្រប់ពេលទាំងអស់ គាត់គឺជាសមាជិកដ៏សំខាន់ម្នាក់នៃគណៈកម្មាធិការទាំងពីរ ដែលបានអនុម័តទៅលើការផ្លាស់ទីលំនៅប្រជាជនជាបន្តបន្ទាប់ នៅក្នុងប្រទេសកម្ពុជា ក្នុងអំឡុងពេលពាក់ព័ន្ធនៃសំណុំរឿង ០០២/០១។ ក្នុងចំណោមចំណុចជាច្រើនទៀត គាត់ក៏ជាអ្នកគាំទ្រដ៏ខ្លាំងក្លាម្នាក់ ឱ្យមាន "សង្គ្រាមវណ្ណៈ" ប្រឆាំងនឹងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងបានដើរតួនាទីនាំមុខនៅក្នុងការឃោសនា និងការបណ្ដុះបណ្ដាលកម្មាភិបាលដើម្បីសម្រេចគោលបំណងនេះ។ តាមការយល់ឃើញរបស់អង្គជំនុំជម្រះ ឥទ្ធិពលនៃ តួនាទីរបស់គាត់ កាន់តែកើនឡើងថែមទៀតដោយសារតែមានបុគ្គលតិចតួចណាស់ដែលមានតួនាទីជា "ថ្នាក់លើ"។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះជឿជាក់ថា ក្នុងនាមជាសមាជិកម្នាក់នៃសហ-ឧក្រិដ្ឋកម្មរួម នួន ជា បានរួមចំណែកដ៏សំខាន់ក្នុងការសម្រេចគោលបំណងរួម ហើយគាត់មានចេតនាជំរុញឱ្យមានការអនុវត្តគោលបំណងរួមនេះបន្ថែមទៀត តាមរយៈសកម្មភាពទាំងឡាយរបស់គាត់។<br><br>**៨៧៦.** យោងតាមមូលហេតុខាងលើនេះ អង្គជំនុំជម្រះយល់ឃើញថា នួន ជា ក៏មានចេតនាដូចសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួមដែរ ក្នុងការសម្រេចឱ្យបាននូវគោលបំណងរួម តាមរយៈការអនុវត្តគោលនយោបាយរបស់បក្សស្ដីពីការផ្លាស់ទីលំនៅប្រជាជន និងការកំណត់គោលដៅមកលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ |

| | |
|---|---|
| | គាត់ក៏មានចេតនាដូចទៅនឹងសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួម ក្នុងការប្រព្រឹត្តិអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលរួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ការធ្វើមនុស្សឃាតដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១ និងទី២) ក៏ដូចជា ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅទួលពោធិ៍ជ្រៃផងដែរ។ លើសពីនេះទៀត យោងទៅលើការរួមចំណែករបស់គាត់ក្នុងការរៀបចំមាគ៌ារបស់បក្សស្តីពីការតស៊ូវណ្ណៈ និងគោលនយោបាយកំណត់គោលដៅមកលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនោះ អង្គជំនុំជម្រះជឿជាក់ថា នួន ជា ក៏មានចេតនារើសអើង ដែលជាលក្ខខណ្ឌតម្រូវនៃបទល្មើសការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ (ដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១ និងទី២)) ដូចនឹងសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួមដែរ។ |
| **ទម្រង់ផ្សេងទៀតនៃការទទួលខុសត្រូវ**<br>ក្នុងសំណុំរឿង ០០២/០២ នួន ជា ត្រូវបានចោទប្រកាន់អំពីទំរង់នៃបទឧក្រិដ្ឋផ្សេងទៀត ដូចខាងក្រោម៖<br>• ការរៀបចំផែនការ,<br>• ការញុះញង់ឲ្យមានការប្រព្រឹត្ត, | **ទម្រង់ផ្សេងទៀតនៃការទទួលខុសត្រូវ (សំអាងហេតុនៃសាលក្រម ដែលបង្កើតនូវទម្រង់ផ្សេងទៀតនៃការទទួលខុសត្រូវ)**<br>***ការរៀបចំផែនការ***<br>**៨៧៨.** នួន ជា គឺជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការ |

| | |
|---|---|
| • ការសមគំនិតដោយការជួយ និង ជម្រុញ,<br>• ការបញ្ជា,<br>• ការទទួលខុសត្រូវរបស់ថ្នាក់លើ។ | មជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលមានសិទ្ធិចូលរួមនៅក្នុងកិច្ចប្រជុំនានា ហើយពិតជាបានចូលរួមនៅក្នុងកិច្ចប្រជុំទាំងអស់នោះមែន។<br>**៩០០.** យ៉ាងយូរបំផុត ចាប់ពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៧៥ នួន ជា បានជួបប្រជុំជាមួយនឹងមេដឹកនាំជាន់ខ្ពស់ផ្សេងៗទៀត អំពីគោលនយោបាយកសាង និងការពារប្រទេសដែលមានឯករាជ្យ ខ្លួនទីពឹងខ្លួន និងសង្គមនិយម។ ផែនការនេះមានគោលបំណងបង្កើតសង្គមគ្មានវណ្ណៈមួយ ដែលប្រជាជនគ្រប់គ្នានឹងត្រូវបានរៀបចំបញ្ចូលទៅក្នុងសហករណ៍ ដើម្បីការពារ និងកសាងប្រទេសឱ្យបានជឿនលឿន ដោយផ្តោតជាពិសេសលើការបង្កបង្កើនផល និងគម្រោងធារាសាស្ត្រ។ ផែនការទាំងនេះ ពីដំបូង បានកើតចេញមកពី និងផ្អែកលើបទពិសោធន៍របស់បក្សនៅតាមតំបន់រំដោះ ដើម្បីផ្គត់ផ្គង់កម្លាំងមនុស្សដែលត្រូវការ ដើម្បីសម្រេចផែនការនេះ ហើយវិធីសាស្ត្រនៃការជម្លៀស និងផ្លាស់ទីលំនៅមានលក្ខណៈដូចៗគ្នា ពីទីជនបទមួយទៅកាន់ទីជនបទមួយទៀត នៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបន្តអនុវត្តក្រោយពីពេលនេះរហូតមក។ ទោះបីជាធ្លាប់មានបទពិសោធន៍ដូចនេះក៏ដោយ ក៏គ្មានភស្តុតាងណាមួយបង្ហាញថា ផែនការនេះមានវិធានការនានាដែលផ្តល់សុខុមាលភាពដល់ប្រជាជនដែលត្រូវបានជម្លៀស ឬ មានការយល់ព្រមពីប្រជាជនដែលនឹងត្រូវ |

| | |
|---|---|
| | ប្រមូលផ្តុំទៅនៅសហករណ៍នោះឡើយ។<br><br>**៩០១.** នួន ជា បានចូលរួមជាមួយនឹងមេដឹកនាំសំខាន់ៗផ្សេងទៀតនៅក្នុងកិច្ចប្រជុំក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ ដើម្បីពិភាក្សាអំពីផែនការរបស់ថ្នាក់ដឹកនាំក្នុងការសម្រេចឱ្យបាននូវបដិវត្តន៍សង្គមនិយម តាមរយៈការអនុវត្តសមូហភាវូបនីយកម្ម[...]<br><br>**៩០២.** នៅចុងឆ្នាំ ១៩៧៥ នួន ជា រួមជាមួយនឹងអ្នកផ្សេងទៀត បានរួមគ្នាបង្កើតផែនការសេដ្ឋកិច្ចជាក់លាក់មួយ។ ផែនការនេះបានទទួលស្គាល់អំពីការខ្វះខាតស្បៀងអាហារ និងថ្នាំសង្កូវ ជាពិសេស ប៉ះពាល់លើ "ប្រជាជនថ្មី"។ ទោះបីជាយ៉ាងនេះក្តី ផែនការនេះពាក់ព័ន្ធនឹងការបែងចែកកម្លាំងពលកម្មទៅតាមយុទ្ធសាស្ត្រដែលជាគោលដៅនៃការផលិតស្រូវរបស់បក្ស និងអាទិភាពនៃហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងមានគោលបំណងពង្រីកសហករណ៍ និងផ្តល់ការលើកទឹកចិត្តដល់ "ប្រជាជនចាស់" ដែលធ្វើឱ្យប៉ះពាល់ដល់ "ប្រជាជនថ្មី" ដែលស្ថិតនៅក្រោមការសង្ស័យ។ ក្រោយពេល គណៈកម្មាធិការអចិន្ត្រៃយ៍ បានចុះធ្វើទស្សនកិច្ចនៅភូមិភាគពាយ័ព្យនៅក្នុងខែ សីហា ឆ្នាំ ១៩៧៥ (ដំណើរទស្សនកិច្ចដែលមានការចូលរួមពី នួន ជា ឬយ៉ាងហោចណាស់ គាត់បានដឹងអំពីដំណើរទស្សនកិច្ចនេះ តាមរយៈរបាយការណ៍ជាលាយលក្ខណ៍អក្សរ) គណៈកម្មាធិការអចិន្ត្រៃយ៍បានសម្រេចបែងចែកជាថ្មីដោយបញ្ជូនប្រជាជន ចំនួន |

| | |
|---|---|
| | ៤០០.០០០ នាក់ ទៅ ៥០០.០០០ នាក់ បន្ថែមទៀតទៅឲ្យតំបន់នេះ។<br><br>*ការបញ្ជា*<br><br>**៧៧២.** [...] មេដឹកនាំបក្ស រួមទាំង ប៉ុល ពត ខៀវ សំផន និង នួន ជា បានដឹកនាំវគ្គរៀនសូត្រក្នុងទីក្រុងភ្នំពេញ ដោយបានចាប់ផ្តើមវគ្គរៀនសូត្រទាំងនោះ ភ្លាមៗ ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបានបន្តគ្រប់ពេលក្នុងអំឡុងសម័យកម្ពុជា ប្រជាធិបតេយ្យ។ ពួកគេបានធ្វើបទឧទ្ទេសនាមចំពោះកម្មាភិបាលភូមិភាគ តំបន់ និងស្រុក ព្រមទាំង កម្មាភិបាលធម្មតា អំពីការកំណត់អត្តសញ្ញាណ និងការកម្ចាត់ខ្មាំង ការបន្តធ្វើការតស៊ូប្រដាប់អាវុធ ការបង្កើតសហករណ៍ ការលើកភ្លឺស្រែ ជីកប្រឡាយ និងការបំពេញការងារ និងបង្កបង្កើនផលតាមផែនការកំណត់។<br><br>**៨៨៥.** នួន ជា រួមជាមួយនឹង ប៉ុល ពត បានអនុវត្តសិទ្ធិអំណាចធ្វើសេចក្តីសម្រេចចុងក្រោយរបស់បក្ស និងប្រើប្រាស់សិទ្ធិអំណាចនេះតាមផ្លូវច្បាប់ (*de jure*) និងតាមព្រឹត្តិហេតុ (*de facto*) ដើម្បីបង្គាប់ទៅកម្មាភិបាល និងកងទ័ពខ្មែរក្រហមថ្នាក់ក្រោមឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលរួមមានការជម្លៀសដោយបង្ខំ និងការធ្វើ ឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស។[...] |

| | |
|---|---|
| | ក្រោយ ពីកិច្ចប្រជុំមួយទៀតដែលបានធ្វើឡើង នៅដើមខែ មេសា ឆ្នាំ ១៩៧៥ ដែលបានពិភាក្សាអំពីការជម្លៀសប្រជាជននោះមក បទបញ្ជាទាំងឡាយក៏ត្រូវបានបញ្ជូនទៅឱ្យមេបញ្ជាការកងទ័ពជាថ្មីទៀតដើម្បីធ្វើការអនុវត្ត។<br><br>**៨៨៥.** អង្គជំនុំជម្រះជឿជាក់ថា សេចក្តីសម្រេច និងសេចក្តីណែនាំនានារបស់គណៈកម្មាធិការមជ្ឈិម ដែលមាន នួន ជា ផងដែរនោះ គឺជាបញ្ជាដែលត្រូវបានអនុវត្ត។ អង្គជំនុំជម្រះក៏ជឿជាក់ថា កម្មាភិបាលថ្នាក់ក្រោមបានទទួលអំណាច និងសេចក្តីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជា។ បញ្ជាទាំងនេះ ត្រូវបានផ្តល់ទៅឱ្យមុនពេលប្រព្រឹត្ត និងបានរួមចំណែកយ៉ាងខ្លាំងក្លាដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មនានា។<br><br>**៩០៥.** [...]អង្គជំនុំជម្រះបានរកឃើញពីខាងលើរួចហើយថា នួន ជា ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការធ្វើសេចក្តីសម្រេចរបស់ថ្នាក់ដឹកនាំបក្ស ហើយសេចក្តីសម្រេចទាំងនេះត្រូវបានផ្សព្វផ្សាយតាមរយៈឋានានុក្រមរដ្ឋបាល និងយោធា ហើយបន្ទាប់មកត្រូវបានអនុវត្តដោយកងទ័ពខ្មែរក្រហម។ ការដែលកម្មាភិបាលថ្នាក់ក្រោមៗបានទទួលស្គាល់អំណាចតាមព្រឹត្តិហេតុ *(de facto)* និងសេចក្តីសម្រេចរបស់ នួន ជា តាមរយៈមជ្ឈិមបក្ស និងបានអនុវត្តគោលនយោបាយផ្លាស់ទីលំនៅប្រជាជន និងកំណត់អត្តសញ្ញាណខ្មាំង បង្ហាញឱ្យឃើញថា សេចក្តីសម្រេចទាំងនេះគឺជា បញ្ជា។ |

| | |
|---|---|
| | **៩២៣.** [...] នួន ជា មានអំណាចតាមព្រឹត្តិហេតុ (*de facto*) និងតាមផ្លូវច្បាប់ (*de jure*) ទៅលើកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោម។ [...] ។ នៅក្នុងការប្រជុំក្រោយៗមកទៀត ក្នុងចំណោមមេដឹកនាំជាន់ខ្ពស់ នៅដើមខែមេសា ឆ្នាំ ១៩៧៥ នួន ជា ក៏មានវត្តមាន និងបានចូលរួមក្នុងការសម្រេចលើផែនការវាយសម្រុកចុងក្រោយផងដែរ បញ្ជាត្រូវបានគេបញ្ជូនជាថ្មីម្តងទៀតទៅមេបញ្ជាការកងទ័ពដើម្បីអនុវត្ត។<br><br>***ការញុះញង់ឱ្យមានការប្រព្រឹត្ត***<br><br>**៨៨៧.** [...]អង្គជំនុំជម្រះក៏បានរកឃើញផងដែរថា នួន ជា រួមជាមួយនឹង ប៉ុល ពត បានអនុវត្តអំណាចក្នុងការធ្វើសេចក្តីសម្រេចចុងក្រោយរបស់បក្ស ហើយបានប្រើប្រាស់អំណាចតាមផ្លូវ ច្បាប់ (*de jure*) និងតាម ព្រឹត្តិហេតុ (*de facto*) បង្គាប់ឱ្យកម្មាភិបាល និងកងទ័ពខ្មែរក្រហមថ្នាក់ ក្រោមប្រព្រឹត្តឧក្រិដ្ឋកម្មនានាដែលកើតមានឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)។ នួន ជា បានដើរតួនាទីនាំមុខនៅក្នុងការបំពាក់បំប៉នផ្នែកមនោគមន៍វិជ្ជាដល់ កម្មាភិបាល និងកងទ័ពខ្មែរក្រហម ជាពិសេស នៅក្នុងការអប់រំកម្មាភិបាលឱ្យរក្សាការប្រុងប្រយ័ត្នចំពោះខ្មាំង និងនៅក្នុងការបំពាក់បំប៉នយ៉ាងច្បាស់លាស់ដល់កសិករអំពីការតស៊ូវណ្ណៈ ដែលរួមទាំងការកំណត់អត្តសញ្ញាណ “ប្រជាជនថ្មី” និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋ |

| | |
|---|---|
| | ខ្មែរទាំងអស់ថាជាខ្មាំង។ អង្គជំនុំជម្រះជឿជាក់ថា ការចូលរួមរបស់ នួន ជា ជាមួយនឹងមេដឹកនាំដទៃទៀត នៅក្នុងការរៀបចំតាក់តែងគោលនយោបាយនៃការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ និងកំណត់គោលដៅលើក្រុមជាក់លាក់ មានតាំងពីពេលមុនមកម្ល៉េះ ហើយបានរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មនានានៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)។ លើសពីនេះទៀត ដោយពិចារណាទៅលើសិទ្ធិអំណាចរបស់ នួន ជា នៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ អង្គជំនុំជម្រះជឿជាក់ថា ការបណ្ដុះបណ្ដាល សេចក្ដីថ្លែងការណ៍ និងការចូលរួមពាក់ព័ន្ធរបស់គាត់នៅក្នុងការចេញផ្សាយ *ទស្សនាវដ្ដីទង់បដិវត្ត* ត្រូវបានកងទ័ព និងកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមយល់ថា ជាការជំរុញពួកគេឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកទាំងឡាយណាដែលត្រូវបានចាត់ទុកថាជា "ខ្មាំង"។ [...]<br><br>**៩០៨.** [...]អង្គជំនុំជម្រះក៏បានយល់ឃើញផងដែរថា នួន ជា រួមជាមួយនឹង ប៉ុល ពត បានអនុវត្តអំណាចធ្វើសេចក្ដីសម្រេចចុងក្រោយរបស់បក្ស និងបានប្រើប្រាស់អំណាចតាមផ្លូវច្បាប់ (*de jure*) និងតាមព្រឹត្តហេតុ (*de facto*) បង្គាប់ឲ្យកម្មាភិបាល និងកងទ័ពខ្មែរក្រហមថ្នាក់ក្រោមប្រព្រឹត្តឧក្រិដ្ឋកម្មនានាដែលកើតមានឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន |

| | |
|---|---|
| | (ដំណាក់កាលទី២)។ នួន ជា បានដើរតួនាទីនាំមុខនៅក្នុងការបំពាក់បំប៉នផ្នែកមនោគមន៍វិជ្ជាដល់កម្មាភិបាល និងកងទ័ពខ្មែរក្រហម ជាពិសេសពាក់ព័ន្ធនឹងការអប់រំកម្មាភិបាលឱ្យរក្សាការប្រុងប្រយ័ត្នចំពោះខ្មាំង និងនៅក្នុងការបំពាក់បំប៉នយ៉ាងច្បាស់លាស់ដល់កសិករអំពីការតស៊ូវណ្ណៈ ដែលរួមទាំងការកំណត់អត្តសញ្ញាណចំពោះ "ប្រជាជនថ្មី" និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរទាំងអស់ថាជាខ្មាំង។<br><br>ដូចបានលើកឡើងខាងលើ ថ្នាក់ដឹកនាំ រួមទាំង នួន ជា ផងនោះ បានបង្កើតគោលនយោបាយដែលបានផ្តល់លទ្ធភាពក្នុងការកំណត់អត្តសញ្ញាណ "ខ្មាំង" និងអប់រំកែប្រែ ឬ ធ្វើឱ្យបាត់ខ្លួន ហើយថ្នាក់ដឹកនាំបានគូសបញ្ជាក់ជាហូរហែអំពីសារៈសំខាន់នៃគោលការណ៍រក្សាការសម្ងាត់។<br><br>**៩២៦.** នួន ជា បានដើរតួនាទីនាំមុខនៅក្នុងការបំពាក់បំប៉នផ្នែកមនោគមន៍វិជ្ជាដល់កម្មាភិបាល និងកងទ័ពខ្មែរក្រហម ជាពិសេសនៅក្នុងការអប់រំកម្មាភិបាលឱ្យរក្សាការប្រុងប្រយ័ត្នចំពោះខ្មាំង និងនៅក្នុងការបំពាក់បំប៉នយ៉ាងច្បាស់ លាស់ដល់កសិករអំពីការតស៊ូវណ្ណៈ ដែលរួមទាំងការកំណត់អត្តសញ្ញាណចំពោះ "ប្រជាជនថ្មី" និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរទាំងអស់ថាជាខ្មាំង។ ដូចបានលើកឡើងខាងលើ ថ្នាក់ដឹកនាំ រួមទាំង នួន ជា ផង នោះ បានបង្កើតគោលនយោបាយដែលបានផ្តល់លទ្ធភាពឱ្យមានការកំណត់អត្តសញ្ញាណ "ខ្មាំង" និង |

<table>
<tr><td></td><td>អប់រំកែប្រែ ឬធ្វើឱ្យបាត់ខ្លួន ហើយថ្នាក់ដឹកនាំបានបញ្ជាក់ជាហូរហែអំពីសារៈសំខាន់នៃគោលការណ៍នៃការរក្សាការសម្ងាត់។ [...] លើសពីនេះទៀត ដោយពិចារណាទៅលើសិទ្ធិអំណាចរបស់ នួន ជា នៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ អង្គជំនុំជម្រះជឿជាក់ថា ការបណ្ដុះបណ្ដាល សេចក្ដីថ្លែងការណ៍ និងការចូលរួមរបស់គាត់នៅក្នុងការចេញផ្សាយ ទស្សនាវដ្ដីទង់បដិវត្ត ត្រូវបានកងទ័ព និង កម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមយល់ថា ជាការជំរុញដោយផ្ទាល់ឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មនានាប្រឆាំងនឹងអ្នកទាំងឡាយដែលត្រូវបានចាត់ទុកថាជា “ខ្មាំង” [...]<br><br>ការជួយ និងជំរុញ<br><br>៨៩០. [...] ពាក្យសម្ដី និងសកម្មភាពរបស់ នួន ជា នៅក្នុងពេលផ្សព្វផ្សាយគោលនយោបាយនៃការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ និងគោលនយោបាយនៃការកំណត់គោលដៅ ដល់កម្មាភិបាល និងនៅក្នុងការជំរុញការអនុវត្តគោលនយោបាយទាំងនេះបានលើកទឹកចិត្តឱ្យចារីប្រព្រឹត្តឧក្រិដ្ឋកម្ម។ លើសពីនេះទៀត ការអនុម័តគោលនយោបាយទាំងនេះដោយបក្សកុម្មុយនីស្តកម្ពុជាមានឥទ្ធិពលផ្លូវច្បាប់ ដែលបានជួយសម្រួលដល់ការអនុវត្តឧក្រិដ្ឋកម្ម។<br><br>៩១០. នៅក្នុងសម្ភារៈឯកសារសម្រាប់ឃោសនា និងវគ្គ</td></tr>
</table>

01059804



បំពាក់បំប៉ន នួន ជា បានផ្សព្វផ្សាយ អនុម័ត កោតសរសើរ និងជំរុញគោលនយោបាយសេដ្ឋកិច្ចរបស់បក្ស ដែលបានផ្តល់យុទ្ធសាស្ត្រក្នុងការបែងចែកកម្លាំងការងារ និងការតស៊ូវណ្ណៈ។

***ការទទួលខុសត្រូវរបស់ថ្នាក់លើ***

**៨៩៦.** ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា យោងតាមស្មារតីនៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា និងភារកិច្ចដែលបានចាត់តាំងឱ្យគាត់ទទួលខុសត្រូវនោះ នួន ជា មានអំណាចតាមផ្លូវច្បាប់ *(de jure)* និងតាមព្រឹត្តិហេតុ *(de facto)* ក្នុងការដាក់វិន័យដល់សមាជិកក្រោមបង្គាប់បក្ស និងយោធា។

**៩១៣.** ដោយពិចារណាទៅលើតួនាទីជាន់ខ្ពស់របស់គាត់ក្នុងនាមជាអនុលេខាបក្ស និងទៅលើរចនាសម្ព័ន្ធរដ្ឋបាលដែលត្រូវបានបង្កើតឡើងតាមរយៈលក្ខន្តិកៈ បក្សកុម្មុយនីស្តកម្ពុជា នួន ជា មានអំណាចតាមផ្លូវច្បាប់ (*de jure*) លើបុគ្គលទាំងឡាយនៅក្នុង ខ្សែសង្វាក់បញ្ជាដែលមាន។ លើសពីនេះទៀត ដោយពិចារណាលើខ្សែសង្វាក់នៃការរាយការណ៍ ដ៏ច្បាស់លាស់ ដែលថ្នាក់ក្រោមបានផ្តល់ព័ត៌មានសង្ខេបដល់ថ្នាក់លើអំពីបញ្ហាសំខាន់ៗ និងស្នើសុំការណែនាំនោះ អង្គជំនុំជម្រះជឿជាក់ថា នួន ជា ក៏បានអនុវត្តអំណាចតាមព្រឹត្តិហេតុ (*de facto*) លើកម្មាភិបាលខ្មែរក្រហមទាំងអស់ផងដែរ។

**៩១៤.** [...] ដូច្នេះ អង្គជំនុំជម្រះក៏ជឿជាក់ផងដែរថា

| | |
|---|---|
| | បក្សកុម្មុយនីស្តកម្ពុជា រួមទាំង នួន ជា ផងដែរ បានរក្សាទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់ និងបានបន្តអនុវត្តការគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាព លើរចនាសម្ព័ន្ធកងទ័ពខ្មែរក្រហមដែលទើបតែបានរៀបចំថ្មីឡើងវិញ ដែលមានឈ្មោះថា កងទ័ពបដិវត្តន៍កម្ពុជា ក្រោយខែ កក្កដា ឆ្នាំ ១៩៧៥។<br><br>**៩៣៣.** មានភស្តុតាងបង្ហាញថា នួន ជា មានទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់ និងមានការគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពទៅលើកងទ័ពខ្មែរក្រហម និងលេខាភូមិភាគ នៅពេលចូលកាន់កាប់ទីក្រុងភ្នំពេញ។ អង្គជំនុំជម្រះជឿជាក់ថា ការវិភាគនេះអាចធ្វើឡើងដូចគ្នាជាមួយ នឹងហេតុការណ៍នៅទួលពោធិ៍ជ្រៃ ដែលបានកើតមាននៅភូមិភាគពាយ័ព្យ នៅប៉ុន្មានថ្ងៃក្រោយការចូលកាន់កាប់ទីក្រុងភ្នំពេញ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់លេខាភូមិភាគពាយ័ព្យ ឈ្មោះ មូល សម្បត្តិ ហៅ រស់ ញឹម។ អង្គជំនុំជម្រះកត់សម្គាល់ថា នួន ជា និង រស់ ញឹម មានទំនាក់ទំនងការងារជាប់រហូតតាំងពីយូរមកហើយនៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។ រស់ ញឹម គឺជាសមាជិកគណៈកម្មាធិការមជ្ឈិម ហើយគាត់បានចូលរួមក្នុងមហាសន្និបាតបក្សលើកទី២ និងលើកទី៣ ជាមួយ នួន ជា និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀត ដែលធ្វើឡើងនៅក្នុងឆ្នាំ ១៩៦៣ និងក្នុងឆ្នាំ ១៩៧១។ នួន ជា បានទៅជួប រស់ ញឹម នៅសំឡូត |

01059806



| | |
|---|---|
| | ជាច្រើនលើក ហើយ វស់ ញឹម មានវត្តមាននៅក្នុងកិច្ចប្រជុំខែ មិថុនា ឆ្នាំ ១៩៧៤ ដែលមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា រួមទាំង នួន ជា ផងនោះ បានសម្រេចឱ្យមានការផ្លាស់ទីលំនៅប្រជាជនឱ្យអស់ចេញពីទីក្រុងនានា រួមទាំងទីក្រុងភ្នំពេញ នៅពេលរំដោះប្រទេសបាន។<br><br>**៩៣៥.** ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ វស់ ញឹម និងលេខាភូមិភាគដទៃទៀត បានចូលរួមនៅក្នុងកិច្ចប្រជុំជាទៀងទាត់ជាមួយអ្នកដទៃទៀត ជាអាទិ នួន ជា ផង ដើម្បីពិភាក្សាពីការ អនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា រួមទាំងនៅក្នុងកិច្ចប្រជុំខែ ឧសភា ឆ្នាំ ១៩៧៥ នៅព្រះវិហារព្រះកែវមរកត [...] |

| **ការកំណត់ជាមុននូវអង្គហេតុ ដែលទាក់ទងលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន ចំពោះបទល្មើសដែលចោទប្រកាន់ ក្នុងសំណុំរឿង ០០២** | |
|---|---|
| បទចោទក្នុងសំណុំរឿង ០០២/០២ (ឯកសារយោង ជាដីកាដំណោះស្រាយ) | សំអាងហេតុនៃសំណុំរឿង ០០២/០១ (ឯកសារយោង ជាកថាខណ្ឌ នៃសាលក្រម ០០២/០១) |
| **ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖ ធាតុផ្សំដែលជា “ធាតុផ្សំរួម ”**<br><br>**១៣៥០.** យោងតាមអង្គហេតុដូចបានរៀបរាប់នៅក្នុងផ្នែកនៃដីកាដំណោះស្រាយស្តីពី “ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃសហឧក្រិដ្ឋកម្មរួម”និងផ្នែក | **ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖ ធាតុផ្សំដែលជា “ធាតុផ្សំរួម ”**<br><br>**១៩៣.** អង្គជំនុំជម្រះយល់ឃើញថា ចាប់តាំងពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងយ៉ាងហោចណាស់ក៏រហូតមកដល់ខែ ធ្នូ ឆ្នាំ ១៩៧៧ ដែលជាអំឡុងពេលដែលត្រូវ |

| | |
|---|---|
| ស្តីអំពី "ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃឧក្រិដ្ឋកម្ម" គោលនយោបាយដែលអនុវត្តដោយកម្មាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ បង្កើតបានជាការវាយប្រហារជាទូទៅ និងជាប្រព័ន្ធ ប្រឆាំងទៅលើប្រជាជនស៊ីវិលទាំងអស់នៃប្រទេសកម្ពុជា ដោយសារ មូលហេតុនយោបាយជាចម្បង និងក្នុងបរិបទមួយចំនួនដោយសារមូលហេតុជនជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា។ បទល្មើសជាក់លាក់ ដែលនឹងរៀបរាប់ដូចតទៅនេះត្រូវបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃការវាយប្រហារនេះ ជាហេតុធ្វើឱ្យធាតុផ្សំដែលជា "ធាតុផ្សំរួម" នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានចែងនា អំឡុងពេលនៃការកកើតអង្គហេតុត្រូវបានបំពេញ។<br><br>*(សូមមើលកថាខណ្ឌ ១៣៥០-១៣៧២ ដើម្បីវិភាគបន្ថែម)* | ជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ មានការវាយប្រហារជាទូទៅ និងជាប្រព័ន្ធ ប្រឆាំងនឹងប្រជាជនស៊ីវិលក្នុងប្រទេសកម្ពុជា។[...]<br><br>**១៩៥.** អង្គជំនុំជម្រះយល់ឃើញទៀតថា ការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិលនេះត្រូវបានអនុវត្តឡើងដោយសារមូលហេតុនយោបាយ ស្របតាមគោលនយោបាយ និងផែនការរបស់បក្សក្នុងការកសាងសង្គមនិយម និងការការពារប្រទេស [...]<br><br>**១៩៨.** ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា លក្ខខណ្ឌទូទៅទាំងអស់សម្រាប់ការអនុវត្តមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ត្រូវបានបំពេញ។ |
| **<u>សហឧក្រិដ្ឋកម្មរួម៖</u>**<br><br>**១៥៦.** មេដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាមានផែនការរួមដើម្បីបង្កើតនៅក្នុងប្រទេសកម្ពុជានូវបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សតាមរយៈគ្រប់មធ្យោបាយចាំបាច់តាម "សន្ទុះមហាលោតផ្លោះ" | **<u>សហឧក្រិដ្ឋកម្មរួម</u>**<br><br>**៧៧៧.** ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា យ៉ាងយូរបំផុតត្រឹមខែ មិថុនា ឆ្នាំ ១៩៧៤ រហូតដល់ខែ ធ្នូ ឆ្នាំ ១៩៧៧ មនុស្សជាច្រើនមានគោលបំណងរួមដើម្បី "បង្កើតបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សតាម |

និង ដើម្បីការពារបក្សប្រឆាំងនឹងសត្រូវផ្ទៃក្នុង ក៏ដូចជាសត្រូវខាងក្រៅ។

**១៥៧.** ដើម្បីធ្វើឱ្យសម្រេចនូវផែនការរួម មេដឹកនាំនៃរបស់បក្សកុម្មុយនីស្តកម្ពុជាបានឱ្យអត្ថន័យ និងបានអនុវត្តនូវគោលនយោបាយទាំងប្រាំដូចជា ៖

- ការផ្លាស់ទីលំនៅដែលធ្វើឡើងជាច្រើនលើកច្រើនសារទៅលើប្រជាជនចេញពីទីប្រជុំជនទៅកាន់ទីជនបទ និង ពីទីជនបទមួយទៅកាន់ទីជនបទមួយផ្សេងទៀត ។
- ការបង្កើត និងការទាញយកផលប្រយោជន៍តាមរយៈសហករណ៍និងតាមការដ្ឋាន។
- ការអប់រំ "សមាសភាពមិនល្អ" និង ការកម្ទេច "ខ្មាំង" ដែលត្រូវបានរកឃើញទាំងនៅក្នុង និង នៅក្រៅបក្ស។
- ការចេញនូវវិធានការណ៍ជាពិសេសចំពោះក្រុមមនុស្សជាក់លាក់នានា ដូចជាជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិកជន និងអតីតអ្នករដ្ឋការនានានៃសាធារណៈរដ្ឋខ្មែរ (រួមទាំងមន្ត្រីរាជការ អតីតបុគ្គលិកយោធាព្រមទាំងក្រុមគ្រួសាររបស់ពួកគេ)។
- ការដាក់បទបញ្ជារទាក់ទងនឹងការរៀបការ។

**១៥៩.** បុគ្គលដែលបានចូលរួមក្នុងផែនការរួមនេះយ៉ាងហោចណាស់មានសមាជិកនៃគណៈកម្មាការ

រយៈមធ្យោបាយចាំបាច់តាម "សន្ទុះមហាលោតផ្លោះ" និងដើម្បីការពារបក្សប្រឆាំងនឹងសត្រូវផ្ទៃក្នុង ក៏ដូចជាសត្រូវខាងក្រៅ"។ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិម រដ្ឋមន្ត្រីនៃរដ្ឋាភិបាល លេខាភូមិភាគ និងលេខាតំបន់ស្វយ័ត រួមទាំង នួន ជា ខៀវ សំផន ប៉ុល ពត អៀង សារី សុន សេន វន វ៉េត តា ម៉ុក សោ ភឹម រស់ ញឹម កុយ ធួន កែ ពក ចាន់ សំ ជូ ជេត ប៊ូ ផាត យ៉ុង យ៉ែម ប៊ិន ណាន អៀង ធីរិទ្ធ និងម៉ី ប្រាង គឺជាសមាជិកនៃក្រុមដែលមានគោលបំណងរួមដូចបានបញ្ជាក់នេះ។ ភ័ស្តុតាងបង្ហាញថា គោលបំណងរួមក្នុងការការពារ និងកសាងប្រទេសឱ្យបានឆាប់រហ័សតាមរយៈបដិវត្តន៍សង្គមនិយមនេះ ផ្អែកតាមគោលការណ៍រក្សាការសម្ងាត់ ឯករាជ្យ អធិបតេយ្យ ប្រជាធិបតេយ្យប្រមូលផ្តុំ ខ្លួនទីពឹងខ្លួន និងសមូហ-ភាវូបនីយកម្ម ត្រូវបានបង្កើតឡើងយ៉ាងច្បាស់លាស់នៅត្រឹមខែ មិថុនា ឆ្នាំ ១៩៧៤ និងបានបន្តមានអត្ថិភាពយ៉ាងហោចណាស់រហូតដល់ខែ ធ្នូ ឆ្នាំ ១៩៧៧។

**៨០៥.** អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ភ័ស្តុតាងដែលមាននៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងសំណុំរឿង 00២/0១ បានបង្ហាញអំពីអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម។ ទីមួយ ភ័ស្តុតាងបានបង្ហាញថា មនុស្សជាច្រើន រួមទាំងថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានយល់ស្របទៅនឹងគោលបំណងរួម ដែលរួមមាន ការអនុវត្តបដិវត្តន៍

អចិន្ត្រៃយ៍ ដូចជា នួន ជា និង អៀង សារី អ្នកដែលស្ថិតនៅក្នុងគណៈកម្មាធិការមជ្ឈិម ដូចជា ខៀវ សំផន រដ្ឋមន្ត្រីនានាដូចជា អៀង ធីរិទ្ធ លេខាភូមិភាគ និងតំបន់ស្វ័យត និងមេដឹកនាំកងពលយោធាមជ្ឈិម។

**១៥២៤.** ផែនការរួមរបស់មេដឹកនាំបក្សកម្ពុជាប្រជាធិបតេយ្យគឺធ្វើឱ្យសម្រេចបាននូវបដិវត្តន៍សង្គមនិយមឆាប់រហ័សនៅកម្ពុជា តាម "ជំហានមហាលោតផ្លោះ" និងការការពារប្រទេសប្រឆាំងទៅនឹងសត្រូវទាំងខាងក្នុង និងខាងក្រៅ តាមគ្រប់មធ្យោបាយចាំបាច់។ ផែនការរួមនេះពុំមែនមានលក្ខណៈឧក្រិដ្ឋទាំងស្រុងនោះទេ ប៉ុន្តែការធ្វើឱ្យសម្រេចផែនការរួមនេះរួមមាន ជាការប្រព្រឹត្តិនូវឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ឬក៏ជាការជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ។

សង្គមនិយមនៅក្នុងប្រទេសកម្ពុជា។ ទីពីរ ក៏មានការបង្ហាញឱ្យឃើញផងដែរថា ទោះបីជា គោលបំណងរួមនេះមិនមានលក្ខណៈឧក្រិដ្ឋក៏ដោយ ក៏គោលនយោបាយដែលខ្មែរក្រហមបានបង្កើតឡើងពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលជាមធ្យោបាយមួយក្នុងការសម្រេចផែនការរួមនេះ។ គោលនយោបាយទាំងនេះ នាំឱ្យមាន និង/ឬរួមមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនានា រួមទាំង ការផ្លាស់ទីលំនៅដោយបង្ខំ ការធ្វើមនុស្សឃាត ការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។ ការផ្លាស់ទីលំនៅប្រជាជនទាំងពីរដំណាក់កាលនេះ (ដំណាក់កាលទី១ និងទី២) អនុវត្តតាមវិធីសាស្ត្រដ៏ស៊ីសង្វាក់គ្នាមួយ នៅក្នុងករណីនីមួយៗ ដែលរួមទាំង និងមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម។ ចំណុចនេះបញ្ជាក់ថា គោលនយោបាយទាំងនេះ មានលក្ខណៈឧក្រិដ្ឋ និងត្រូវបានអនុម័តជាមុន ដើម្បីធានាថា គោលបំណងរួមនេះអាចសម្រេចបាន។

**៨០៧.** ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា អ្នកចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម ដែលរួមមានយ៉ាងហោចណាស់ សមាជិកគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍មួយចំនួន ដូចជា ប៉ុល ពត តាម៉ុក សុន សេន សោ ភឹម វន វេត និង កុយ ធួន អាចត្រូវបានដាក់ឱ្យទទួលខុសត្រូវ នៅក្នុងសហឧក្រិដ្ឋកម្មរួមចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងពេល

| | |
|---|---|
| | នៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)។<br><br>*សូមមើលផងដែរ* ផ្នែក "ទម្រង់នៃការទទួលខុសត្រូវសម្រាប់ ខៀវ សំផន ៖ សហឧក្រិដ្ឋកម្មរួម" ដែលមាននូវសំអាងហេតុ អំពីអត្ថិភាព នៃ គោលនយោបាយទាំងអស់ ចំនួនប្រាំ។ |
| **<u>សហករណ៍ និងការដ្ឋាន</u>**<br><br>**១៦៨.** គោលនយោបាយមួយក្នុងចំណោមគោលនយោបាយទាំងប្រាំដែលត្រូវបានអនុវត្តដើម្បីសម្រេចបាន និងការពារបដិវត្តន៍សង្គមនិយម គឺការបង្កើត និង ការទាញយកផលប្រយោជន៍ពីសហករណ៍ និងពីការដ្ឋានតាមរយៈគ្រប់មធ្យោបាយចាំបាច់។ សហករណ៍ និងការដ្ឋាននានា ត្រូវបានរៀបចំឡើងនៅទូទាំងប្រទេសកម្ពុជា ចាប់តាំងពីមុនឆ្នាំ១៩៧៥ ដោយបក្សកុម្មុយនីស្តកម្ពុជាមកម្លេះ ពោលគឺដំណាក់កាលដំបូងនៃការត្រួតត្រារបស់បក្សកុម្មុយនីស្តកម្ពុជាលើដែនដីមួយចំនួនរបស់ ប្រទេស។ ការបង្កើតនេះបានបន្តយ៉ាងហោចណាស់រហូតដល់ថ្ងៃទី ៦ ខែមករា ឆ្នាំ១៩៧៩។ សហចៅក្រមស៊ើបអង្កេតត្រូវបានប្តឹងអំពីទីតាំងជាក់លាក់នៃការដ្ឋាន និងសហករណ៍ចំនួនប្រាំមួយកន្លែងដែលរួមមាន ទំនប់ត្រពាំងថ្ម ព្រលានយន្តហោះកំពង់ឆ្នាំង ទំនប់១មករា ការដ្ឋានស្រែអំបិល សហករណ៍ត្រាំកក់ និងការដ្ឋាន | **<u>សហករណ៍ និងការដ្ឋាន</u>**<br><br>**៤០៦.** ទោះបីជា ខៀវ សំផន មិនដែលបានធ្វើជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មក៏ដោយ ក៏ឯកសារដែលនៅសេសសល់បង្ហាញថា ខៀវ សំផន មានតួនាទីសំខាន់ទាក់ទិននឹងសេដ្ឋកិច្ចរបស់កម្ពុជាប្រជា- ធិបតេយ្យដែលស្របនឹងការសារភាពរបស់គាត់ថា គាត់ជាសមាជិកមន្ទីរ ៨៧០ ទទួលបន្ទុក ពាណិជ្ជកម្ម។ នៅខែ តុលា ឆ្នាំ ១៩៧៦ គណៈកម្មាធិការពាណិជ្ជកម្មបានចាប់ផ្តើមរាយការណ៍ជូន ខៀវ សំផន មិនមែនរាយការណ៍ជូន ឌៀន ឡើយ។ ឯកសារនានាដែលផ្ញើជូន ឬចម្លងជូន ខៀវ សំផន រួមមាន របាយការណ៍នៃការពិភាក្សាជាមួយគណៈប្រតិភូពាណិជ្ជកម្មបរទេស និង ទំនាក់ទំនងផ្សេងៗទៀតទាក់ទិននឹងពាណិជ្ជកម្មអន្តរជាតិ របាយការណ៍ស្តីពីបរិមាណស្រូវ អង្ករ ដែលបញ្ជូនទៅឃ្លាំងរដ្ឋពីសំណាក់ភូមិភាគនានា និងរបាយការណ៍ស្តីពីការនាំចេញស្រូវអង្ករ [...]<br><br>**៤៨១.** [...] ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា នៅ |

សខ២៤។

១៧០. បក្សកុម្មុយនីស្តកម្ពុជាបានចាប់ផ្តើមអនុវត្តគោលនយោបាយសមូហភាពលើផលិតផលកសិកម្មក្នុងអំឡុងឆ្នាំ ១៩៧០ និងបានបង្កើនការអនុវត្តន៍នេះតាមរយៈមធ្យោបាយដែលបក្សកុម្មុយនីស្តកម្ពុជាបានពង្រឹងការកាន់កាប់លើទឹកដីទាំងមូលនៃប្រទេសកម្ពុជា។ សហករណ៍មួយចំនួនត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៧៣ មកម្ល៉េះ។ នៅខែឧសភា ឆ្នាំ ១៩៧៥ សន្និបាតមួយត្រូវបានប្រារព្ធធ្វើឡើងដោយមានការចូលរួមពីតំណាងបក្សកុម្មុយនីស្តកម្ពុជាមកពីទូទាំងប្រទេសកម្ពុជាដែលនៅក្នុងនោះ ប៉ុល ពត និងមេដឹកនាំជាន់ខ្ពស់ផ្សេងទៀតបានសម្រេចថា បដិវត្តន៍សង្គមនិយមកម្ពុជាត្រូវយកចិត្តទុកដាក់លើវិស័យកសិកម្ម និងវិស័យឧស្សាហកម្មតាមរយៈការបន្តបង្កើតសហករណ៍ ក៏ដូចជាការកសាងទំនប់និងប្រឡាយ។ ផែនការនេះត្រូវបានដាក់ឱ្យអនុវត្តនៅឆ្នាំ ១៩៧៦។

១៧១. នៅឯកិច្ចប្រជុំដែល គណៈអចិន្ត្រៃយ៍បានបង្កើតគណៈកម្មាធិការដែលនៅជុំវិញមន្ទីរ ៨៧០ ដោយមានការទទួលខុសត្រូវពាក់ព័ន្ធនឹងកសិកម្ម ពាណិជ្ជកម្ម និងសេដ្ឋកិច្ច និងបានផ្តល់ការណែនាំលើបញ្ហាទាំងឡាយ ដូចជាការចចារទាក់ទងនឹងវិស័យពាណិជ្ជកម្មក្រៅប្រទេស ជាមួយប្រទេសកូរ៉េខាង

ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅនីមួយៗ ទៅកាន់ និងមកពីសហករណ៍ និងការដ្ឋានធ្វើការងារនានា ពួកគាត់បាន ឃើញប្រជាជនរាប់រយ រាប់ពាន់ រាប់ម៉ឺននាក់ ត្រូវបានផ្លាស់ទីលំនៅ។ នៅក្នុងឆ្នាំ ១៩៧៧ ខៀវ សំផន បានរាយការណ៍ថា គម្រោងធារាសាស្ត្រកំពុងត្រូវបានអនុវត្តនៅទូទាំងប្រទេសដោយមានប្រជាជនធ្វើការងារប្រមាណ ពី ១០.០០០ នាក់ ទៅ ៣០.០០០ នាក់ នៅតាមការដ្ឋាននីមួយៗ។ ឧទាហរណ៍ នៅក្នុងឆ្នាំ១៩៧៧ ប្រជាជនប្រមាណពី៨.០០០ នាក់ទៅ ២០.០០០នាក់ ត្រូវបានបញ្ជូនឱ្យទៅធ្វើការនៅការដ្ឋានទំនប់ ១ មករា។ ប្រជាជនចំនួន ២០.០០០ នាក់ ដោយមួយចំនួននៅតាមកងចល័តបានលើកទំនប់ ១៧ មករា ហើយប្រជាជនចំនួន ២៣.០០០ នាក់ទៀត បានលើកទំនប់ ៥ មករា និងទំនប់ ៦ មករា។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ការផ្លាស់ទីលំនៅនៅក្នុងតំបន់ នៅអំឡុងពេលប្រហែល ពី ខែ កញ្ញា ឆ្នាំ ១៩៧៥ ដល់ ខែ ធ្នូ ឆ្នាំ ១៩៧៧ ក៏ត្រូវបានធ្វើឡើងក្នុងទ្រង់ទ្រាយធំដូចគ្នាផងដែរ។ ទោះបីជាយ៉ាងនេះក្តី ដោយសារពុំមានភ័ស្តុតាងបន្ថែមបញ្ជាក់អំពីភាគរយនៃប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅទៅតាមសហករណ៍ និងទៅតាមការដ្ឋានធ្វើការងារនានានោះ អង្គជំនុំជម្រះសាលាដំបូងបានត្រឹមតែអាចធ្វើការប៉ាន់ស្មានក្នុង ចំនួនអប្បបរមាតែប៉ុណ្ណោះថា យ៉ាងហោចណាស់មានប្រជាជនចំនួន ៣០.០០០ នាក់ ត្រូវបានផ្លាស់ទីលំនៅនៅក្នុងតំបន់ផ្សេងៗ នៅក្នុង

ជើង និងប្រទេសចិន ការអភិវឌ្ឍន៍លើផលិតកម្មកៅស៊ូ ការបង្កើនទិន្នផលស្រូវដើមរដូវ ហើយនឹងការផលិត និងការចែកចាយម៉ាស៊ីនបូមទឹក។ នៅថ្ងៃទី ៣០ ខែឧសភា ឆ្នាំ១៩៧៦ គណៈកម្មាធិការអចិន្ត្រៃយ៍បានដាក់ចេញនូវការណែនាំទាក់ទងនឹងតួនាទីដែលថា កងទ័ពដែលបានចូលរួមក្នុងផលិតកម្មកសិកម្មដោយស្របទៅតាម*"ភារកិច្ចរួមកសាងប្រទេស"* ដែលជាតួនាទីរបស់ពួកគេផងដែរ។ ចុងក្រោយនៅខែសីហា ឆ្នាំ១៩៧៦ គណៈកម្មាការអចិន្ត្រៃយ៍បានបង្កើតផែនការ ៤ឆ្នាំ ដើម្បីកសាងរបបសង្គមនិយមនៅគ្រប់វិស័យ និង ព្យាករណ៍ទៅលើបញ្ហាដូចជាការអភិវឌ្ឍន៍វិស័យកសិកម្មឲ្យបានឆាប់រហ័សផងដែរ។

**១៧៧.** ទោះបីជាការបង្កើតរបបនៃបក្សកុម្មុយនីស្តកម្ពុជាក្នុងប្រទេសកម្ពុជាបានបង្កឲ្យមានបញ្ហាសុខភាព និងបញ្ហាម្ហូបអាហារយ៉ាងធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ក៏មេដឹកនាំបក្សមិនបានគិតគូរដល់ប្រព័ន្ធដែលត្រឹមត្រូវដើម្បីឆ្លើយតបទៅនឹងបញ្ហាទាំងនេះដែរ និងមិនព្រមទទួលជំនួយអន្តរជាតិឡើយ លើកលែងតែជំនួយមានកម្រិតដែលផ្តល់មកពីប្រទេសចិន។ ផ្ទុយទៅវិញ គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានផ្តោតទៅលើភាពផ្តាច់ខ្លួនចេញពីគេ និងភាពម្ចាស់ការដោយខ្លួនឯងលើផ្នែកសេដ្ឋកិច្ចជាតិ។

**១១៦៥.** ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ **ខៀវ សំផន**

អំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) ។ ជាថ្មីម្តងទៀត អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា ចំនួនប្រជាជនដែលត្រូវបានផ្លាស់ ទីលំនៅនោះ ទំនងជាមានចំនួនច្រើនជាងចំនួនប៉ាន់ស្មាននេះ ប្រសិនបើពិចារណាលើវិសាលភាពភូមិសាស្ត្រពេលវេលានៃការផ្លាស់ទីលំនៅទាំងនេះ ចំនួនសហករណ៍ និងការដ្ឋានធ្វើការងារដែលមាននៅក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងចំនួនប្រជាជននៅតាមសហករណ៍ និងការដ្ឋានធ្វើការងារនីមួយៗ។

**៦០៤.** នៅចន្លោះខែកញ្ញា និងខែតុលា ឆ្នាំ១៩៧៥ គណៈកម្មាធិការអចិន្ត្រៃយ៍បានជួបពិភាក្សាអំពី គោលនយោបាយការពារ និងកសាងប្រទេស។ នៅក្នុងខែវិច្ឆិកា ឆ្នាំ ១៩៧៥ សន្និបាតសេដ្ឋកិច្ចរបស់បក្សទូទាំងប្រទេសលើកទី១ បានដាក់ចេញផែនការដែលអាចនឹងប្រែក្លាយប្រព័ន្ធកសិកម្មអន់ថយមួយរបស់ប្រទេសឲ្យទៅជាប្រព័ន្ធកសិកម្មទំនើបមួយ ក្នុងរយៈពេល ១០ ឆ្នាំ ទៅ ១៥ ឆ្នាំ ខាងមុខ។ ថ្នាក់ដឹកនាំបក្សបានសម្រេចថា បក្សនឹងពង្រីកសហករណ៍ លើកភ្លឺស្រែ ជីកប្រឡាយ និងលើកទំនប់ ហើយផ្តោតសំខាន់លើដីដែលមានជីជាតិបំផុតដើម្បីសម្រេចផលស្រូវ ៣ តោន ក្នុង ១ ហិកតា ឲ្យបានត្រឹមឆ្នាំ ១៩៧៦។ កំណត់ហេតុនៃកិច្ចប្រជុំនាថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦ ដែលនៅពេលនោះ ខៀវ សំផន និង នួន ជា មានវត្តមាន បានបញ្ជាក់ថា បក្សសម្រេច

បានចូលរួមចំណែក ក្នុងការរៀបចំផែនការនៃគោលនយោបាយបាយនេះ ដោយបានចូលរួមអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឬតាមរយៈការទទួលបាននូវកំណត់ហេតុប្រជុំរបស់គណៈអចិន្ត្រៃយ និងក្នុងការបង្កើតផែនការបួនឆ្នាំ ដើម្បីកសាងសង្គមនិយមគ្រប់វិស័យ។ គោលនយោបាយនេះក៏ត្រូវបានពិភាក្សាផងដែរ នៅក្នុងកិច្ចប្រជុំបើកទូលាយរបស់គណៈអចិន្ត្រៃយ៍នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៥ ដែលបានពិភាក្សាលើការងារពង្រឹងវិស័យកសិកម្មឱ្យបានឆាប់រហ័ស។ ជាងនេះទៅទៀត ខៀវ សំផន ប្រហែលជាបានចូលរួមចំណែកក្នុងការរៀបចំគោលនយោបាយនេះ តាមរយៈតួនាទីគាត់ជាសមាជិករបស់គណៈរដ្ឋមន្ត្រី។ ខៀវ សំផន បានគូសបញ្ជាក់ថាគោលនយោបាយ ។ ខៀវ សំផន បានចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងការធ្វើសេចក្តីសម្រេច ដើម្បីកសាងព្រលានយន្តហោះខេត្តកំពង់ឆ្នាំង។

**១១៦៨.** ខៀវ សំផន បានដឹងអំពីមធ្យោបាយផ្សេងៗ ដែលគោលនយោបាយនេះត្រូវបានអនុវត្តន៍នៅទូទាំងប្រទេស ។ ខៀវ សំផន បានធ្វើដំណើរជាច្រើនទៅកាន់គ្រប់ទិសទីនៃផ្ទៃប្រទេស ដើម្បីត្រួតពិនិត្យការដ្ឋាន និងសហករណ៍។ គាត់បានបញ្ជាក់ថា គាត់បានអមដំណើរសម្តេច **នរោត្តម សីហនុ** ទៅកាន់ភូមិភាគកណ្តាល និងពាយ័ព្យ និងបាន“*ឃើញ*

បាន ទិសដៅឆ្នាំ ១៩៧៦ ចំនួន ៣០ ភាគរយ ហើយបានវាយតម្លៃថា ជោគជ័យនេះកើតឡើងដោយសារការរៀបចំផែនការបានហ្មត់ចត់ និងប្រុងប្រយ័ត្ន។ គិតមកត្រឹមខែឧសភា ឆ្នាំ ១៩៧៦ ស្រែត្រូវបានភ្ជួររាស់យ៉ាងហោចណាស់បានម្តង ហើយការសាបព្រោះ និងដកស្ទូងបានចាប់ផ្តើមរួចទៅហើយ។

**៦១២.** នៅចន្លោះខែធ្នូ ឆ្នាំ១៩៧៦ និងខែធ្នូ ឆ្នាំ១៩៧៧ កងចល័តត្រូវបានបញ្ជូនឱ្យទៅលើកទំនប់នៅក្នុងខេត្តកំពង់ធំ និងខេត្តកំពង់ចាម (ភូមិភាគ (ឧត្តរចាស់) កណ្តាល) និងខេត្តកំពត (ភូមិភាគនិរតី) ផងដែរ។ គ្មានគ្រឿងចក្រសម្រាប់លើកទំនប់ទេ ដូច្នេះគេប្រើប្រាស់កម្លាំងមនុស្ស។ ជាពិសេសប្រជាជនចំនួនរាប់ពាន់នាក់ត្រូវបានប្រមូលផ្តុំពីខេត្តកំពង់ចាម និងខេត្តកំពង់ធំ (ភូមិភាគ (ឧត្តរចាស់) កណ្តាល) ឱ្យទៅលើកទំនប់ ១ មករា ដែលស្ថិតនៅស្រុកបារាយណ៍ ខេត្តកំពង់ធំ ហើយការសាងសង់ទំនប់ទាំងមូលបានចាប់ផ្តើមនៅក្នុងខែ ធ្នូ ឆ្នាំ ១៩៧៦។ កងចល័តបានដើរពីការដ្ឋានលើកទំនប់មួយទៅការដ្ឋានលើកទំនប់មួយទៀត ទោះជិត ឬ ឆ្ងាយក៏ដោយ និងពុំត្រូវបានឱ្យស្បៀងអាហារ ទឹក ឬ មុងនោះទេ។ ពេលខ្លះ ពួកគេដើរទៅដោយគ្មានអ្នកនាំផ្លូវទៅជាមួយឡើយ។ ទោះបីជាយ៉ាងនេះក្តី គ្មានប្រជាជនណាម្នាក់មិនព្រមផ្លាស់ទីលំនៅនោះទេ លើកលែងតែពួកគេឈឺ ឬ មិនអាចដើរបាន។

| | |
|---|---|
| *ដោយផ្ទាល់ផ្នែកនូវការខិតខំរបស់អង្គការនៅតាមជនបទ*និងបានចុះធ្វើ "*ទស្សនកិច្ចសិក្សា*" មួយទៀតនៅភូមិភាគបស្ចិម និងភូមិភាគនិរតី។ ក្នុងអំឡុងទស្សនកិច្ចមួយជាមួយសម្តេច **នរោត្តម សីហនុ** នៅចន្លោះថ្ងៃទី១៥ ដល់ថ្ងៃទី១៧ ខែមករា ឆ្នាំ ១៩៧៦ **ខៀវ សំផន** បានសង្កេតឃើញកម្មករចំនួនរាប់ម៉ឺននាក់ កំពុងធ្វើការងារប្រើកម្លាំងនៅតាមសហករណ៍។. [...]<br><br>**១១៧០. ខៀវ សំផន** ក៏បានដឹងផងដែរថា បក្សកុម្មុយនីស្តកម្ពុជាបាននាំចេញ ស្រូវ អង្ករ ខណៈដែលប្រជាជនកម្ពុជាកំពុងអត់ឃ្លាន ។ របាយការណ៍មួយដែល **វ៉ាន់ រិត** ផ្ញើទៅឱ្យ **ខៀវ សំផន** នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៧៨ បានរាយការណ៍ថា អំឡុងខែមករា ដល់ខែកញ្ញា ឆ្នាំ១៩៧៨ ស្រូវ និង អង្ករ ចំនួន ២៩.៧៥៨ តោន ត្រូវបាននាំចេញ។ [...] | **៦១៦.** នៅពាក់កណ្តាលឆ្នាំ ១៩៧៦ បក្សបានប្រកាសថា បក្សបានចាត់តាំង កសាង ពង្រឹង និងពង្រីករបបសមូហភាព វាយរបបនាយទុន និងបញ្ចប់របបសក្តិភូមិម្ចាស់ដី ។ ហេតុដូច្នេះ នៅពាក់កណ្តាល ឆ្នាំ ១៩៧៦ ការផ្តោតចម្បងជាសំខាន់នោះ គឺការចាប់ផ្តើមងាកទៅរកខ្មាំងនៅក្នុងបក្ស។ ទោះបីជាយ៉ាងនេះក្តី បក្សនៅតែយល់ឃើញថា បក្សចាំបាច់ត្រូវវាយ "ប្រជាជនថ្មី" ដែលជាសំណល់ពីសក្តិភូមិ និងនាយទុន។ នៅក្នុងឆ្នាំ ១៩៧៦ សហករណ៍បានបន្តពង្រីកបន្ថែមទៀត ជាមធ្យមមានចំនួន ចន្លោះពី ១០០ គ្រួសារ ទៅ ៣០០ គ្រួសារ ហើយសហករណ៍ខ្លះមានរហូតដល់ ៥០០ គ្រួសារ និងនៅឃុំខ្លះទៀត សហករណ៍មានរហូតដល់ ១.០០០ គ្រួសារ។<br><br>**៧៥០.** ដោយបានធ្វើដំណើរមកដល់ទីក្រុងភ្នំពេញទាំងអស់គ្នា យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៧៥ នោះ នួន ជា ប៉ុល ពត ខៀវ សំផន អៀង សារី និង សុន សេន បានបង្កើតគណៈកម្មាធិការដឹកនាំរួមមួយ។ ពួកគេបានជួបប្រជុំជាទៀតទាត់ជាមួយលេខាភូមិភាគ និងលេខាតំបន់ស្វយ័តនានា និងអ្នកផ្សេងទៀត ដើម្បីពិភាក្សាអំពីគោលនយោបាយ និងផែនការនានា ដើម្បីកសាង និងការពារប្រទេសសង្គមនិយម ឯករាជ្យ ខ្លួនទីពឹងខ្លួន ក៏ដូចជាការបង្កើត សហករណ៍ផងដែរ។<br><br>**៧៥៣.** ក្នុងរយៈពេលប្រមាណជាដប់ថ្ងៃ ក្នុងខែ ឧសភា |

| | |
|---|---|
| | ឆ្នាំ ១៩៧៥ ប៉ុល ពត នួន ជា និង ខៀវ សំផន ព្រមទាំងអ្នកដទៃទៀតដែលរួមមានទាំងតំណាងមកពីគ្រប់ភូមិភាគ បានជួបប្រជុំគ្នានៅ ព្រះវិហារព្រះកែវមរកត ដើម្បីស្តាប់ទស្សីករណ៍ចំពោះការជម្លៀសប្រជាជនចេញពីទីក្រុង ព្រមទាំងមានការផ្តល់អាទិភាពទៅលើតម្រូវការក្នុងការកសាង និងការពារប្រទេសយ៉ាងឆាប់រហ័ស តាមរយៈការបង្កើតសហករណ៍ និងការកសាងទំនប់ និងប្រឡាយ។ បន្ទាប់ពីនោះ នៅក្នុងអំឡុងពេលពីថ្ងៃទី ២០ ដល់ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៧៥ នួន ជា ប៉ុល ពត ខៀវ សំផន អៀង ធីរិទ្ធ សុន សេន និងអ្នកដទៃទៀត បានចូលរួមក្នុងកិច្ចប្រជុំយ៉ាងតិចក៏មួយដែរ ដែលប្រារព្ធឡើងនៅពហុកីឡាដ្ឋានជាតិអូឡាំពិក ឬក៏នៅវិទ្យាស្ថានបច្ចេកទេសខ្មែរ-សូវៀត។ នួន ជា ប៉ុល ពត និងអ្នកផ្សេងទៀត បានបង្គាប់ដល់តំណាងទាំងអស់ដែលមកពីគ្រប់អង្គភាពទ័ព ព្រមទាំងលេខាស្រុក តំបន់ ភូមិភាគ ឱ្យរៀបចំបង្កើតសហករណ៍ លុបបំបាត់ទ្រព្យសម្បត្តិឯកជន លុបបំបាត់រូបិយប័ណ្ណ និងបិទទីផ្សារ ព្រមទាំងកសាងទំនប់ ប្រឡាយ។<br><br>**៧៤៩.** […] អៀង សារី បានបញ្ជាក់ថា គាត់មានវត្តមាននៅក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំបក្ស កាលពីខែ កញ្ញា ឆ្នាំ ១៩៧៥ ដែលក្នុងកិច្ចប្រជុំនោះក៏មានវត្តមានរបស់ ខៀវ សំផន ប៉ុល ពត នួន ជា សោ ភឹម សុន សេន តាម៉ុក វ៉ន វេត រស់ ញឹម កុយ ធួន និងមេបញ្ជាការយោធាមួយចំនួនទៀត ដែលពិភាក្សាអំពីបញ្ហាការពារ កសិកម្ម |

“បញ្ហាទឹក” និងឧស្សាហកម្ម។ អ្នកជំនាញ លោក Philip SHORT ក៏បានសរសេររៀបរាប់ពីកិច្ចប្រជុំគណៈកម្មាធិការមជ្ឈិមកាលពីពាក់កណ្ដាលខែ កញ្ញា ដែលពិភាក្សាពីបញ្ហាកសិកម្ម សង្គមកិច្ច និងការការពារ បើទោះបីជាប្រភពព័ត៌មានរបស់គាត់សម្រាប់ចំណុចនេះមិនមានភាពច្បាស់លាស់ក្ដី។ លើសពីនេះទៀត ទង់បដិវត្តចេញផ្សាយខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៥ បានលើកឡើងថា “មហាសន្និបាតរបស់មជ្ឈិមបក្ស” បានសម្រេចជាឯកច្ឆន្ទទៅលើគោលដៅផលិតស្រូវឲ្យបានបីតោនក្នុងមួយហិកតា តាំងពីមុនខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ដែលជាគោលដៅផលិតកម្មដែលត្រូវបានបញ្ជាក់យ៉ាងជាក់លាក់នៅក្នុងឯកសារគោលនយោបាយខែ កញ្ញា ឆ្នាំ ១៩៧៥។ ជាចុងក្រោយ អ្នកជំនាញលោក David CHANDLER បានពន្យល់ថាផែនការសេដ្ឋកិច្ចរួមដែលបានលេចឡើងនៅចុងឆ្នាំ ១៩៧៥ ហើយនាំឲ្យមានការផ្លាស់ទីលំនៅប្រជាជនពីទីជនបទមួយ ទៅកាន់ទីជនបទមួយទៀត ជាពិសេសនៅដើមឆ្នាំ ១៩៧៦ នោះ គឺជាលទ្ធផលនៃការដឹកនាំរួមរបស់មជ្ឈិម “ដែលពេលខ្លះស្ថិតនៅចំណុចស្នូលរបស់គណៈកម្មាធិការមជ្ឈិម” ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា មានកិច្ចប្រជុំថ្នាក់ដឹកនាំបក្សមួយនៅដើមខែ កញ្ញា ឆ្នាំ ១៩៧៥ ពាក់ព័ន្ធទៅនឹងគោលនយោបាយសេដ្ឋកិច្ច ហើយដែលក្រោយមកត្រូវបានពន្យល់នៅក្នុងឯកសារគោលនយោបាយខែ កញ្ញា ឆ្នាំ ១៩៧៥។ ដោយកត់សម្គាល់ពីតួនាទីក្នុងការសម្រេចចិត្ត

| | |
|---|---|
| | ថ្នាក់មជ្ឈិមរបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងសមាជិកភាពរបស់គាត់នៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិមតាំងពីយូរមក ហើយនោះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា នួន ជា មានវត្តមាននៅក្នុងកិច្ចប្រជុំនេះ។<br><br>**៧៥១.** [...]អង្គជំនុំជម្រះសាលាដំបូងបានរកឃើញរួចហើយថា គាត់បានចូលរួមកិច្ចប្រជុំកាលពីខែ មិថុនា ឆ្នាំ ១៩៧៤ ដែលក្នុងកិច្ចប្រជុំនេះមានការពិភាក្សាពីការជម្លៀសប្រជាជនចេញពីទីក្រុង ហើយគាត់ក៏បានចូលរួមក្នុងកិច្ចប្រជុំនៅចុងខែ មេសា និងខែ ឧសភា ឆ្នាំ ១៩៧៥ ដែលក្នុងកិច្ចប្រជុំនេះ បានដោះស្រាយលើបញ្ហាគោលនយោបាយសេដ្ឋកិច្ចដទៃទៀត រួមទាំងការបង្កើតសហករណ៍ផងដែរ។ ហេតុដូច្នេះ អង្គ-ជំនុំជម្រះសាលាដំបូងយល់ឃើញថា ខៀវ សំផន ដែលជាសមាជិកត្រៀមរបស់គណៈកម្មាធិការមជ្ឈិម ក្នុងខែកញ្ញា ឆ្នាំ ១៩៧៥ ពិតជាបានចូលរួមក្នុងការបង្កើតផែនការផ្សេងៗ ដែលត្រូវបានលើកឡើងនៅក្នុងឯកសារគោលនយោបាយ ខែ កញ្ញា ឆ្នាំ ១៩៧៥។<br><br>**៧៥៣.** ទស្សនាវដ្តីទង់បដិវត្ត ចេញផ្សាយខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៥ បានរាយការណ៍ថា សន្និបាតសេដ្ឋកិច្ចទូទាំងប្រទេសលើកទីមួយ ដែលត្រូវបានចូលរួមដោយកម្មាភិបាលផ្នែកសេដ្ឋកិច្ច បានកំណត់ថា ទាំងអស់គ្នាត្រូវប្រឹង |

| | |
|---|---|
| | ប្រែងធ្វើការដើម្បីកសាង និងការពារប្រទេសឲ្យបានឆាប់ ដើម្បីសម្រេចឲ្យបានសេដ្ឋកិច្ចខាងកសិកម្មបែបទំនើបក្នុងរយៈពេល ១០ ទៅ ១៥ ឆ្នាំ ដោយបានបញ្ជាក់អំពីគោលដៅផលិតកម្ម ៣ តោន ក្នុង ១ ហិកតា សម្រាប់ឆ្នាំ ១៩៧៦។ សន្និបាតក៏បានសម្រេចថា ការប្រយុទ្ធប្រឆាំងនឹងពួកចក្រពត្តិនិយម និង "បរិវារបស់ពួកវា" នៅតែជាការចាំបាច់ បានជំរុញការបង្កើនការតស៊ូវណ្ណៈ និងការពង្រីកសហករណ៍ ហើយបានណែនាំថាត្រូវរៀបចំកម្លាំងទាំងអស់សម្រាប់គម្រោងបន្តបន្ទាប់ទៅតាមរដូវកាល។ ទោះបីជាមិនមានភ័ស្តុតាងផ្សេងក្រៅតែពី ទស្សនាវដ្ដីទង់បដិវត្ត ដែលបង្ហាញថាសន្និបាតនេះត្រូវបានប្រារព្ធឡើងក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ទស្សនាវដ្ដីនេះបានពន្យល់ថា ផែនការ និងគោលនយោបាយដែលទាក់ទងទៅនឹងទិសដៅនៃការបង្កបង្កើនផលស្រូវឲ្យបាន ៣ តោន ក្នុង ១ ហិកតា បានអនុមត័នៅក្នុងសន្និបាតដែលត្រូវបានសម្រេច និងយល់ព្រមដោយ "សន្និបាតមជ្ឈិមបក្ស" ។ អង្គជំនុំជម្រះ សាលាដំបូងក៏បានពិចារណាឃើញផងដែរថា សេចក្ដីសម្រេចរបស់សន្និបាតសេដ្ឋកិច្ចទូទាំងប្រទេសលើកទីមួយលើបញ្ហានេះ បានឆ្លុះបញ្ចាំងដូចគ្នាពីខ្លឹមសារនៃឯកសារគោលនយោបាយ ខែ កញ្ញា ឆ្នាំ ១៩៧៥។ ដោយពិចារណាទៅលើការយល់ឃើញខាងលើរបស់ខ្លួនពាក់ព័ន្ធទៅនឹងកិច្ចប្រជុំនានាដែលចាប់ផ្ដើមយ៉ាងយូរបំផុតត្រឹមខែ ឧសភា ឆ្នាំ ១៩៧៥ ហើយបន្ត |

| | |
|---|---|
| | រហូតដល់ចុងឆ្នាំ ១៩៧៥ នោះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា សេចក្តីសម្រេច ដែលក្រោយមកត្រូវបានផ្សព្វផ្សាយ ដែលជាលទ្ធផលនៃសន្និបាតសេដ្ឋកិច្ចទូទាំងប្រទេសលើកទីមួយនោះ តំណាងឲ្យ គោលនយោបាយដែលបានអនុម័តដោយថ្នាក់ដឹកនាំបក្ស រួមទាំង ខៀវ សំផន ផងដែរ។<br><br>**៧៦៥.**ខៀវ សំផន នួន ជា ប៉ុល ពត អៀង ធីរិទ្ធ និងថ្នាក់ដឹកនាំដទៃទៀត បានចូលរួមក្នុងសម័យប្រជុំលើកទីមួយរបស់សភាតំណាងប្រជាជន ដែលត្រូវបានប្រព្រឹត្តឡើងពីថ្ងៃទី ១១ ដល់ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៩៧៦។ ខៀវ សំផន បានថ្លែងសុន្ទរកថាបើកនៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៧៦ ដោយអះអាងថាការបោះឆ្នោតដោយយុត្តិធម៌ និងស្មោះត្រង់ត្រូវបានធ្វើឡើង ហើយបានអនុម័តគោលនយោបាយ ពាក់ព័ន្ធនឹងការដ្ឋាន សហករណ៍ និងការតស៊ូវណ្ណៈដែលកំពុងមាន [...]<br><br>**៧៧០.** នៅក្នុងខែ វិច្ឆិកា ឆ្នាំ ១៩៧៦ បក្សបានបើកសន្និបាតសេដ្ឋកិច្ចទូទាំងប្រទេសលើកទីពីររបស់ខ្លួន។ បន្ទាប់ពីបានវិភាគទៅលើជោគជ័យ និងបរាជ័យនៅក្នុងឆ្នាំ ១៩៧៦ រួចមក តំណាង “អង្គការបក្ស” បានដាក់ចេញផែនការឆ្នាំ ១៩៧៧ ដែលរួមមាន ទិសដៅផលិតផល ៣ តោន ក្នុង ១ ហិកតា និង ៦ តោន ក្នុង ១ ហិកតា សម្រាប់តំបន់ណាដែលអាចផលិតបានទាំងស្រូវប្រាំង និងស្រូវវស្សា។ ថ្នាក់ដឹកនាំបក្សមានបំណងថា |

កម្លាំងមនុស្សត្រូវបានបញ្ជូនជាមុនទៅកាន់តំបន់ដែលមានទឹកគ្រប់គ្រាន់ និងដីមានជីជាតិ ហើយនៅពេលណាដែលកម្លាំងមនុស្សទំនេរ ត្រូវចាត់ចែងឲ្យលើកទំនប់ និងជីកប្រឡាយ។ ប្រជាជនត្រូវបែងចែកទៅតាមវណ្ណៈរបស់ខ្លួន ដើម្បីធានាថា “ប្រជាជនថ្មី” ដែលមិនអាចទុកចិត្តបានត្រូវបានចាត់តាំងឲ្យបំពេញការងារបន្ទាប់បន្សំ។

**៩៦៧.** យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៧៥ ខៀវ សំផន បានបង្កើតក្រុមមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដែលស្ថិតនៅក្នុងស្ថានីយ៍អាយស្ម័យយាន ភ្នំពេញ និងក្រោយមកនៅអតីតអគាររបស់ក្រសួងហិរញ្ញវត្ថុ និងនៅព្រះវិហារប្រាក់ (ព្រះវិហារព្រះកែវមរកត) ដែលកិច្ចប្រជុំត្រូវបានធ្វើឡើងដើម្បីពិភាក្សាអំពីគោលនយោបាយ និងផែនការដើម្បីកសាង និងការពារប្រទេស ដែលអាចទីពឹងខ្លួនឯង ឯករាជ្យ និងសង្គមនិយម ដូចជាការបង្កើតសហករណ៍។

**៩៦៨.** ខៀវ សំផន បានចូលរួមនៅក្នុងការរៀបចំផែនការដែលមាននៅក្នុងឯកសារគោលនយោបាយខែ កញ្ញា និងខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ដើម្បីចាត់ចែងកម្លាំងពលកម្មដោយបង្ខំតាមយុទ្ធសាស្ត្រ ផ្អែកតាមទិសដៅបង្កបង្កើនផល និងអាទិភាពហេដ្ឋារចនាសម្ព័ន្ធ ដើម្បីឲ្យបានទិន្នផលស្រូវ ៣ តោនក្នុង១ ហិកតា ដោយយកចិត្តទុកដាក់ក្នុងការកសាងប្រព័ន្ធធារាសាស្ត្រ និងការលើកទឹកចិត្តដល់ “ប្រជាជនចាស់” ប៉ុន្តែធ្វើឲ្យខូចប្រយោជន៍ដល់

"ប្រជាជនថ្មី" ។ ក្នុងអំឡុងមហាសន្និបាតបក្សលើកទី៤ នៅខែ មករា ឆ្នាំ ១៩៧៦ ដែលរួមជាមួយសមាជិកបក្សផ្សេងទៀត គាត់បានអនុម័តលក្ខន្តិកៈដែលត្រូវបានធ្វើវិសោធនកម្ម ដោយបានបញ្ជាក់អំពីតម្រូវការនៃការតស៊ូវណ្ណៈ ប្រជាធិបតេយ្យប្រមូលផ្តុំ ការប្រុងប្រយ័ត្នចំពោះខ្មាំង និងការប្តេជ្ញាចិត្តគោរពតាមគោលការណ៍ឯករាជ្យអធិបតេយ្យភាព និងខ្លួនទីពឹងខ្លួន។

**៩៧៥.** ខៀវ សំផន ក៏បានដឹកនាំវគ្គរៀនសូត្រនៅក្នុងទីក្រុងភ្នំពេញ ពេញមួយអំឡុងពេលនៃសម័យកម្ពុជាប្រជាធិបតេយ្យផងដែរ។ គាត់បានឧទ្ទេសនាមជូនកម្មាភិបាលភូមិភាគ តំបន់ និងស្រុក ព្រមទាំងកម្មាភិបាលធម្មតាអំពីការកំណត់អត្តសញ្ញាណ និងកម្ចាត់ខ្មាំង ការបន្តការតស៊ូប្រដាប់អាវុធ ការបង្កើតសហករណ៍ ការកសាងទំនប់ និងដឹកប្រឡាយ និងការបំពេញតាមផែនការការងារ។ យ៉ាងហោចណាស់ គាត់ក៏បានបង្រៀនវគ្គរៀនសូត្រនយោបាយដល់អ្នកដែលបានវិលត្រលប់មកវិញនៅចុងឆ្នាំ ១៩៧៥ ផងដែរ។ នៅក្នុងអំឡុងពេលនៃវគ្គរៀនសូត្រទាំងនេះ គាត់បានផ្តល់ហេតុផលអំពីការជម្លៀសទីក្រុង និងទីប្រជុំជន និងបានឧទ្ទេសនាមថា ចំណេះដឹងដែលបានទទួលមកពីការអប់រំដោយ "ពួកអាណានិគម និងពួកចក្រពត្តិនិយម" ត្រូវបំភ្លេចចោល។

**៩៧៧.** ខៀវ សំផន បានដើរតួនាទីសំខាន់មួយនៅក្នុងប្រព័ន្ធសេដ្ឋកិច្ចនៃរបបកម្ពុជាប្រជាធិបតេយ្យ និង ជា

| | |
|---|---|
| | ពិសេស ក្នុងនាមគាត់ជាសមាជិកមួយរូបនៃមន្ទីរ៨៧០។ គាត់ទទួលខុសត្រូវលើការចែកចាយសម្ភារៈទៅតាមភូមិភាគ ការដឹកជញ្ជូន និងការគ្រប់គ្រង ស្រូវអង្ករពីភូមិភាគទៅកាន់ឃ្លាំងរដ្ឋ ពាណិជ្ជកម្មអន្តរជាតិ និងការនាំចូល/ការនាំចេញ និងការប្រើប្រាស់ឥណទាន។ ប្រហែលជាចាប់ពីខែ តុលា ឆ្នាំ ១៩៧៦ គាត់បានអនុវត្តការត្រួតពិនិត្យក្នុងកម្រិតខ្លះលើគណៈកម្មាធិការពាណិជ្ជកម្ម ដែលជារឿយៗរាយការណ៍ជូនគាត់ដើម្បីស្នើសុំការណែនាំ។<br><br>**៩៩០.** បន្ទាប់ពីសម្ដេច នរោត្តម សីហនុ បានវិលត្រឡប់មកប្រទេសកម្ពុជាវិញក្រោយពេល រំដោះប្រទេស ខៀវ សំផន បានអមដំណើរទ្រង់ក្នុងព្រះរាជដំណើរទស្សនកិច្ចទៅតាមទីជនបទ នាដើមឆ្នាំ ១៩៧៦ រួមទាំង នៅតាមការដ្ឋានធ្វើការងារ ដែលប្រជាជនរាប់ម៉ឺននាក់កំពុងប្រឹងប្រែងធ្វើការងារលើគម្រោងធារាសាស្ត្រ។ ក្នុងដំណើរទស្សនកិច្ចទាំងនេះ គាត់បានកោតសរសើរចំពោះការកសាងទំនប់ ប្រឡាយ និងការបង្កបង្កើនផលកសិកម្ម។ គាត់បានព្យាយាមបង្ហាញអំពីជោគជ័យ និងផលប្រយោជន៍ដែលទទួលបានពីបដិវត្តន៍សង្គមនិយម ដែលគាត់ខ្លួនឯងផ្ទាល់ជឿជាក់ ហើយដែលប្រជាជនទាំងអស់បានធ្វើការងារដោយដៃទទេ ក្នុងការកសាង និងការពារប្រទេស។<br><br>**១០២៥.** នៅចុងឆ្នាំ ១៩៧៥ ខៀវ សំផន រួមជាមួយអ្នក |

| | |
|---|---|
| | ផ្សេងទៀត បានបង្កើតផែនការសេដ្ឋកិច្ចជាក់លាក់មួយ។ ផែនការនេះបានទទួលស្គាល់នូវការខ្វះខាតម្ហូបអាហារ និងថ្នាំសង្កូវ ដែលប៉ះពាល់ជាពិសេសដល់ "ប្រជាជនថ្មី" ។ ទោះបីជាយ៉ាងណាក៏ដោយ ផែនការនេះគឺដើម្បីបែងចែកកម្លាំងពលកម្មតាមបែបយុទ្ធសាស្ត្រ អនុលោមទៅតាមទិសដៅបង្កបង្កើនផលស្រូវរបស់បក្ស និងអាទិ-ភាពនៃហេដ្ឋារចនាសម្ព័ន្ធ ពង្រីកសហករណ៍ និងគិតគូរដល់ "ប្រជាជនចាស់" ដែលនាំឱ្យប៉ះពាល់ ដល់ "ប្រជាជនថ្មី" ដែលត្រូវបានគេសង្ស័យ។ [...]<br><br>*សូមមើលផងដែរ កថាខណ្ឌទី ៦០៤ ៦១២ និង ៦១៦* |
| **<u>ការបោសសំអាតផ្ទៃក្នុង៖</u>**<br><br>**១១៨៤.** ខៀវ សំផន និយាយថា គាត់មិនដែលបានចូលរួមក្នុងអង្គប្រជុំណាមួយ ដែលបានសម្រេចពីការបោសសម្អាត ឬការចាប់ខ្លួននោះទេ ហើយក៏មិនបានដឹងពីវិសាលភាពនៃការចាប់ខ្លួន មុនឆ្នាំ១៩៧៩ ដែរ។ **ខៀវ សំផន** និយាយថា ប៉ុល ពត បានឱ្យគណៈអចិន្ត្រៃយ៍ពាក់ព័ន្ធនឹងការសម្រេចចាប់ខ្លួនកម្មាភិបាលសំខាន់ៗនៅក្នុងបក្សនោះទេ។ ប៉ុន្តែ **ខៀវ សំផន** ហាក់ដូចជាបានដឹងនិងពាក់ព័ន្ធនឹងការបោសសម្អាត មេដឹកនាំជាន់ខ្ពស់នានាក្នុងបក្សកុម្មុយនីស្តកម្ពុជា ព្រមទាំងមនុស្សនៅក្នុងមន្ទីរ៨៧០ នៅក្នុងក្រសួងពាណិជ្ជកម្ម និងមន្ទីរដែលចំណុះឱ្យក្រសួង | **<u>ការបោសសំអាតផ្ទៃក្នុង៖</u>**<br><br>**៤០៩.** បើទោះបីជា ខៀវ សំផន បានកាន់តួនាទីជាច្រើនក្តី ប៉ុន្តែភស្តុតាងបង្ហាញថា ខៀវ សំផន មានសិទ្ធិធ្វើសេចក្តីសម្រេចតែទៅលើបញ្ហាសេដ្ឋកិច្ច និងពាណិជ្ជកម្មមួយចំនួនប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ ខៀវ សំផន មានសិទ្ធិអំណាចធំជាងនេះ តាមរយៈតំណែងជាន់ខ្ពស់របស់គាត់ ដូចដែលបានស្តែងចេញតាមរយៈសមត្ថភាពក្នុងការធានាសុវត្ថិភាពនៃសមាជិកគ្រួសារមួយចំនួនរបស់គាត់នៅជនបទ។ តាមរយៈវត្តមានរបស់ខ្លួននៅក្នុងកិច្ចប្រជុំគណៈកម្មាធិការមជ្ឈិម និង គណៈកម្មាធិការអចិន្ត្រៃយ៍ នៅក្នុងមន្ទីរ៨៧០ ការគ្រប់គ្រងគណៈកម្មាធិការពាណិជ្ជកម្ម និងអត្ថន័យ នៃសុន្ទរកថានានា |

| | |
|---|---|
| នេះ។<br><br>**១១៨៥.** [...]ដោយសារគាត់មានវត្តមាន នឹងបាន ចូលរួមជាទៀងទាត់នៅក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ **ខៀវ សំផន** ច្បាស់ជាបានដឹង និងបានចូលរួមនៅ ក្នុងការចាប់ខ្លួន និងការសម្លាប់ដែលកើតមាន ក្រោយមក ឬការធ្វើអត្តឃាតរបស់សមាជិកគណៈ អចិន្ត្រៃយ៍ លេខាភូមិភាគ និងលេខាតំបន់ស្វ័យត និងរដ្ឋមន្ត្រី។ ម្យ៉ាងវិញទៀត **ខៀវ សំផន** ទទួល ស្គាល់ថា គាត់បានដឹងពីការចាប់ខ្លួន និងការបោស សម្អាតមេដឹកនាំជាន់ខ្ពស់ ហើយគាត់បានផ្តល់យុត្តិ កម្មចំពោះការបោសសម្អាតនានា នៅក្នុងជួររបស់ បក្សកុម្មុយនីស្តកម្ពុជាផងដែរ។ **ខៀវ សំផន** លើក ឡើងនៅក្នុងបទសម្ភាសន៍មួយនាឆ្នាំ១៩៨០ ថា មាន ភ្នាក់ងារវៀតណាមបង្កប់ខ្លួននៅក្នុងបក្សកុម្មុយនីស្ត កម្ពុជាជាច្រើន *"វាមាននាទីសំខាន់ៗ វាប្រើនាទី សំខាន់ ហើយអ្នកខ្លះកាន់ភាគអំណាចសំខាន់ៗ"* ។ **ខៀវ សំផន** បន្ថែមទៀតថា នៅក្នុងឆ្នាំ១៩៧៥ ប្រហែលជាពាក់កណ្តាលនៃចំនួនសមាជិកគណៈអ ចិន្ត្រៃយ៍ និង គណៈមជ្ឈិមគឺជា ភ្នាក់ងាររបស់វៀត ណាម។ នៅក្នុងបទសម្ភាសន៍មួយនៅឆ្នាំ២០០៦ **ខៀវ សំផន** បានលើកឡើងថា វន វ៉េត និង សោ ភឹ ម ត្រូវចាប់ខ្លួនដោយសារតែពួកគេជាភ្នាក់ងារយួន [...] | ដែលខ្លួនបានរៀបរៀង ខៀវ សំផន ពិតជាបានដឹងឮអំពី គោលនយោបាយ និងមានសិទ្ធិទទួលព័ត៌មានអំពីសភាព ការណ៍ទូទៅនៅក្នុងប្រទេសកម្ពុជា រួមទាំងការដឹងអំពី ការចាប់ខ្លួនកម្មាភិបាលជាន់ខ្ពស់ជាច្រើន ដូចជា កុយ ធួន, ឌឿន និង វន វ៉េត។<br><br>**៣៨៩.** ដើម្បីបញ្ជាក់បន្ថែមអំពីកម្រិតនៃការយល់ដឹង របស់គាត់ ខៀវ សំផន បានទទួលស្គាល់ថា គាត់បានរួម ចំណែកទទួលខុសត្រូវជាមួយ ប៉ុល ពត ក្នុងការធ្វើឱ្យ មានការបាត់ខ្លួនមិត្តភក្តិ និង សហការីរបស់ខ្លួន នៅក្នុងរ យៈកាលកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែ "តែងតែមាន សង្ឃឹមជានិច្ចថា ថ្ងៃណាមួយ ប៉ុល ពត នឹងត្រឡប់បក ក្រោយ" ។ ខៀវ សំផន ក៏បានទទួលស្គាល់ផងដែរថា នៅពាក់កណ្តាលឆ្នាំ ១៩៧៨ គាត់ដឹងអំពី "ការចាប់ចង និង អំពើឃោរឃៅ" នៅក្នុងខេត្តព្រះវិហារ ជាពិសេស អំពីការចាប់ខ្លួន និងការធ្វើបាបមកលើបងប្អូនរបស់ សហព័ទ្ធរបស់គាត់។ ស៊ីសង្វាក់ជាមួយនឹងចំណុចនេះ ផងដែរ សាក្សី មាស វឿន ជាកម្មាភិបាលយោធា ដែល ធ្វើដំណើរទៅភូមិភាគ ឧត្តរថ្មី ក្នុងឆ្នាំ ១៩៧៨ បានផ្តល់ សក្ខីកម្មថា ខៀវ សំផន បានបញ្ជូនទូរលេខមួយច្បាប់ មកឱ្យគាត់ក្នុងឆ្នាំ ១៩៧៨ ដោយផ្តាំផ្ញើការសាកសួរសុខ ទុក្ខបងប្អូនគាត់ និងបញ្ជាឱ្យគេបញ្ជូនបងប្អូនគាត់មក ភ្នំពេញ បើពួកគេជួបការលំបាក។ ជាលទ្ធផល សាក្សី មាស វឿន បានសួរដំណឹង ហើយក៏បានធានាឱ្យមាន |

01059825



| | |
|---|---|
| | ការដោះលែងប្អូន/បងថ្លៃស្រីរបស់ ខៀវ សំផន ដែលជាប់ឃុំនៅមន្ទីរសន្តិសុខនៅសៀមរាប។ សាក្សី កាំង ហ្គេកអ៊ាវ បានថ្លែងថា កង ចាប ដែលជាលេខាភូមិភាគឧត្តរថ្មី ត្រូវបាន ប៉ុល ពត ផ្តន្ទាទោសពាក់ព័ន្ធនឹងតួនាទីរបស់គាត់ក្នុងហេតុការណ៍នេះ។ នៅក្នុងលិខិតចំហមួយច្បាប់ដែលចុះផ្សាយនៅក្នុងសារព័ត៌មានជាតិនៅឆ្នាំ ២០០១ ខៀវ សំផន ទំនងជាទទួលស្គាល់ថា ការឃុំខ្លួនបងប្អូនរបស់គាត់បាននាំដល់ការចាប់ខ្លួន "លេខាបក្សភូមិភាគ" មួយចំនួន។ |
| **<u>ទម្រង់នៃការទទួលខុសត្រូវរបស់</u>**<br>**<u>ខៀវ សំផន ៖ សហឧក្រិដ្ឋកម្មរួម</u>**<br><br>**១៥៣៦.** មានភស្តុតាងដូចដែលបានរៀបរាប់នៅក្នុងផ្នែកស្តីអំពី "តួនាទីរបស់ជនត្រូវចោទ" និង "ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃសហឧក្រិដ្ឋកម្មរួម" បានបង្ហាញថា **ខៀវ សំផន** គឺជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម។ **ខៀវ សំផន** បានចូលរួម ឬរួមចំណែក ក្នុងការបង្កើត ការដាក់ឱ្យដំណើរការ និងបានត្រួតពិនិត្យការអនុវត្តផែនការរួម ដែលរួមមាន ជាការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬជាការជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម នៅមុន និងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ **ខៀវ សំផន** បានអនុវត្តនូវអំណាចក្នុងតួនាទីរបស់ខ្លួនជាសមាជិកនៃគណៈមជ្ឈិម និងការចូលរួមជាទៀងទាត់របស់គាត់នៅ | **<u>ទម្រង់នៃការទទួលខុសត្រូវរបស់</u>**<br>**<u>ខៀវ សំផន ៖ សហឧក្រិដ្ឋកម្មរួម</u>**<br><br>**៣៨៣.** ក្នុងនាមជាប្រធាន ខៀវ សំផន ក៏បានបន្តធ្វើសុន្ទរកថា សរសើរប្រជាជនកម្ពុជា និង កងទ័ពបដិវត្ត ដែលបានដើរតួនាទីនៅក្នុង "ការរំដោះ" ទីក្រុងភ្នំពេញ គាំទ្រការបង្កើតរដ្ឋកម្ពុជាប្រជាធិបតេយ្យថ្មីមួយ និងស្ថាប័ននានារបស់ខ្លួន យល់ស្របទៅនឹងគោលនយោបាយរបស់ បក្សកុម្មុយនីស្តកម្ពុជា ដូចជាការប្រើប្រាស់សហករណ៍ របបហូបចុក ពលកម្មកុមារ និងការដ្ឋាន សរសើរអំពីសមិទ្ធផលនានាដែលគេអះអាងថាសម្រេចបានក្នុងការកសាងជាតិ និងការកែលម្អជីវភាពរស់នៅ និងបកអាក្រាតចំពោះ "ការឈ្លានពាន"ពីសំណាក់វៀតណាម។ ខៀវ សំផន បានថ្លែងប្រាប់សហចៅក្រមស៊ើបអង្កេតថា អត្ថន័យនៃសុន្ទរកថារបស់គាត់ |

ក្នុងការងាររបស់គណៈអចិន្ត្រៃយ៍ ដែលជាស្ថាប័នមានសិទ្ធិចេញសេចក្តីសម្រេចខ្ពស់បំផុតរបស់ប្រទេស និងនៅក្នុងការគោរពខ្សែសង្វាក់នៃការបញ្ជាដ៏តឹងរឹងពីមជ្ឈិមទៅកាន់ថ្នាក់មូលដ្ឋាន ដែលបានដាក់ឱ្យអនុវត្តដោយបក្ស។ នៅក្នុងតួនាទីទាំងនេះ **ខៀវ សំផន** បានចូលរួមនៅក្នុងកិច្ចប្រជុំកម្រិតខ្ពស់បំផុតរបស់បក្ស ដែលនៅក្នុងកិច្ចប្រជុំនោះ មានការសម្រេច និងផ្សព្វផ្សាយអំពីមាគ៌ានយោបាយ និងបានចូលរួមនៅក្នុងកិច្ចប្រជុំជាមួយកម្មាភិបាលភូមិភាគ តំបន់ និងស្រុក។ គាត់បានធ្វើការនៅក្នុងមន្ទីរនយោបាយ៨៧០ ដែលក្នុងនោះការដែលដាក់ឱ្យអនុវត្តផែនការរួមត្រូវបានត្រួតពិនិត្យ ហើយគាត់ក៏បានចុះទៅពិនិត្យដោយផ្ទាល់ទៅតាមខេត្តនានាផងដែរ។ **ខៀវ សំផន** បានគាំទ្រ និងផ្សព្វផ្សាយផែនការរួម នៅថ្នាក់ជាតិ និងអន្តរជាតិ តាមរយៈសុន្ទរកថា និងកម្មវិធីផ្សាយវិទ្យុរបស់គាត់ តាមរយៈបទបង្ហាញដែលគាត់បានធ្វើនៅក្នុងកិច្ចប្រជុំសំខាន់ៗរបស់បក្ស និងនៅក្នុងវគ្គសិក្សា និងបំពាក់បំប៉នខនយោបាយនានា និង ដំណើរទស្សនៈកិច្ចរបស់គាត់ទៅបរទេសក្នុងនាមជាសមាជិកគណៈប្រតិភូរបស់ ប.ក.ក។

**១៥៣៧.** ដូចដែលបានរៀបរាប់ខាងលើ ការដាក់ឱ្យអនុវត្តផែនការរួមនៃសហឧក្រិដ្ឋកម្មរួម រួមមានជាការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬក៏ជាការជាប់ពាក់ព័ន្ធនឹង "ត្រូវបានបង្គាប់បញ្ជាដោយ" ប៉ុល ពត ហើយថ្លែងទៀតថា ទោះបីជាភាគច្រើនគាត់យល់ស្របតាមអ្វីដែលគាត់បាននិយាយក៏ពិតមែន ក៏ប៉ុន្តែជាបុគ្គល គាត់បង្ហាញការមិនយល់ស្របចំពោះឯកសារមួយចំនួន ដូចជាឯកសារពាក់ព័ន្ធនឹងការលុបបំបាត់រូបិយវត្ថុជាដើម។

**៣៨៨.** ជាងនេះទៅទៀត ទោះបីជា ខៀវ សំផន អះអាងម្តងហើយម្តងទៀតថា គាត់ពុំបានទទួល ព័ត៌មានពេញលេញនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ និងបដិសេធអំពីការដឹងឮជាក់លាក់អំពីការចាប់ខ្លួនយ៉ាងណាក្តី ក៏ខៀវ សំផន មានវត្តមាននៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ដែលនៅអំឡុងពេលនៃកិច្ចប្រជុំនីមួយៗ តែងតែមានការពិភាក្សាអំពីការចាប់ខ្លួនឃោសនាការ ជីវភាពរស់នៅនៅតាមទីជនបទ (រួមមានជំងឺរង្កាត់ ការស្លាប់ និងការខ្វះស្បៀងអាហារ) *ការងារពលកម្មកុមារ កិច្ចការបរទេស ការពារជាតិ* ជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាម និងពាណិជ្ជកម្ម។

**៩៤៥.** តាមរយៈសុន្ទរកថានានារបស់គាត់ និងតាមរយៈវគ្គរៀនសូត្រនានា ខៀវ សំផន បានចូលរួម ផ្ទាល់ក្នុងការបំពាក់បំប៉នមនោគមន៍វិជ្ជាដល់ប្រជាជន អំពីការតស៊ូវណ្ណៈ និងភាពចាំបាច់ក្នុងការធានាឱ្យប្រទេសកម្ពុជាមានឯករាជ្យ។ តាមរយៈសកម្មភាពទាំងនេះ គាត់ក៏បានរួមចំណែកក្នុងការកំណត់អត្តសញ្ញាណពួកនាយទុន និងពួកមូលធននិយម ថាជាខ្មាំង ហើយគាត់ក៏បានកំណត់ជា

| | |
|---|---|
| ការប្រព្រឹត្តឧក្រិដ្ឋកម្ម។ ចេតនាឧក្រិដ្ឋរបស់ **ខៀវ សំផន** អាចទាញសន្និដ្ឋានចេញពីសំដី ពីសកម្មភាពសកម្ម ឬពីសកម្មភាពអកម្ម របស់គាត់។ | ទូទៅ ថា "ប្រជាជនថ្មី" ទាំងអស់គឺជាប្រជាជនដែលត្រូវតែទទួលការលត់ដំ។ ខៀវ សំផន ដឹងថាការ បំពាក់បំប៉នមនោគមន៍វិជ្ជាឲ្យស្អប់ខ្ពើម ប្រាកដជានឹងនាំឲ្យមានអំពើហិង្សា។ គាត់ក៏បានយល់ស្របជាមួយទស្សនៈដែលថា បដិវត្តគួរពឹងផ្អែកលើកសិករថ្នាក់ទាបបំផុត ដើម្បីជួយឲ្យវណ្ណៈអធនគ្រប់គ្រងប្រទេសកម្ពុជាដោយតឹងរ៉ឹង។ អ្នកដែលស្ថិតក្នុងវណ្ណៈដឹកនាំថ្មីនេះ ទទួលការអប់រំក្នុងប្រព័ន្ធតិចតួចបំផុត ប៉ុន្តែពួកគេមានវិន័យតឹងរ៉ឹង ទទួលការបំពាក់បំប៉នមនោគមន៍វិជ្ជា ហើយត្រូវបានបង្រៀនឲ្យចេះបោកបញ្ឆោតប្រជាជន និងអនុវត្តតាមគោលការណ៍រក្សាការសម្ងាត់។ ខៀវ សំផន មិនអាចមិនដឹងទេថា ការផ្ដល់អំណាចយ៉ាងច្រើនទៅឲ្យពួកគេទាំងនោះបែបនេះ នឹងធ្វើឲ្យមានការអនុវត្តមាគ៌ាបក្ស ដោយគ្មានការពិចារណាឲ្យបានត្រឹមត្រូវ។ ដោយហេតុផលនេះ ការរំពឹងទុកសមហេតុផលតែមួយគត់គឺថា ប្រជាជនយ៉ាងច្រើននឹងត្រូវស្លាប់នៅក្នុងអំឡុងពេលផ្លាស់ទីលំនៅដោយបង្ខំ ដោយសារតែលក្ខខណ្ឌនៃការដឹកជញ្ជូន ហើយថាការផ្លាស់ទីលំនៅបែបនេះនឹងនាំឲ្យការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមានចំនួនច្រើន។ លើសពីនេះទៀត ដើម្បីកុំឲ្យមានបន្សល់ទុកនូវសាក្សី និងដើម្បីជៀសវាងការរិះគន់ជាអន្តរជាតិ ខៀវ សំផន គាំទ្រជានិច្ចដល់គោលការណ៍រក្សាការសម្ងាត់ និងរួមចំណែកក្នុងការសម្រេចជម្លៀសជនបរទេសទាំងអស់ដែលមានវត្តមាននៅក្នុងទីក្រុងភ្នំពេញ។ ជាការពិត គាត់ដើរតួនាទីយ៉ាង |

| | |
|---|---|
| | សំខាន់នៅក្នុងការរក្សាការសម្ងាត់ដែលបង្កើតឡើងដោយរបបនេះ ដោយបន្តលុបបំបាត់ និងលាក់បាំងការពិតនៃស្ថានភាពដែលប្រជាជនកម្ពុជាបានជួបប្រទះ។ ខៀវ សំផន បានដឹងថា ក្នុងការធ្វើដូច្នេះ គាត់បានការពារចារី និងបានអនុញ្ញាតឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនានាបន្ថែមទៀត។<br><br>**៩៦៣.** តាមសម្អាងហេតុដែលនឹងត្រូវរៀបរាប់លម្អិតនៅផ្នែកខាងក្រោមនេះ អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន បានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ហើយបានរួមចំណែកយ៉ាងសំខាន់ក្នុងសហឧក្រិដ្ឋកម្មរួម[...]<br><br>**៩៦៤.** ខៀវ សំផន បានចូលរួមកិច្ចប្រជុំរបស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ ព្រមទាំងសន្និបាតបក្សពេញមួយអំឡុងពេលបដិវត្តន៍ និងរបបកម្ពុជាប្រជាធិបតេយ្យដែលក្នុងកិច្ចប្រជុំទាំងនោះ មានការរៀបចំផែនការ និងសម្រេចលើគោលបំណងរួមដើម្បីធ្វើបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សមួយ និងការពារប្រទេស ព្រមទាំងគោលនយោបាយនានាដែលចាត់ទុកថាសំខាន់ដើម្បីសម្រេចបានគោលបំណងរួមនេះ។<br><br>**៩៦៥.** [...] ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ត្រឹមឆ្នាំ ១៩៦៩ នៅពេលដែលគាត់បានចូលរួមជាមួយបក្សកុម្មុយនីស្តកម្ពុជា ខៀវ សំផន បានដឹងយ៉ាងច្បាស់អំពីគោលបំណងរួមដែលបានសម្រេចនៅក្នុងមហាសន្និបាត |

| | |
|---|---|
| | បក្សលើកទី១ និងលើកទី២ ព្រមទាំងការវិវត្តន៍ក្នុងអំឡុងកិច្ចប្រជុំរបស់មេដឹកនាំបក្សនៅក្នុងភូមិភាគរំដោះ និងបានឯកភាពទៅនឹងគោលបំណងរួមនេះ ដោយគាត់បាននិយាយថា គាត់បានចូលរួមជាមួយបក្សកុម្មុយនីស្តកម្ពុជា ទោះបីជាគាត់មិនយល់ស្របជាមួយសកម្មភាពមួយចំនួនរបស់បក្សក៏ដោយ ក៏ប៉ុន្តែការចូលរួមរបស់គាត់គឺដើម្បីជាប្រយោជន៍ដល់ឯករាជ្យរបស់ប្រទេសកម្ពុជា។ នៅក្នុងមហាសន្និបាតបក្សលើកទី៣ នៅឆ្នាំ ១៩៧១ ខៀវ សំផន រួមជាមួយសមាជិកបក្សផ្សេងទៀត បានបញ្ជាក់អំពីមាគ៌ាយុទ្ធសាស្ត្ររបស់បក្សដែលបានសម្រេចនៅក្នុងមហាសន្និតបាតមុនៗ ដែលរួមមានការខិតខំប្រឹងប្រែងក្នុងការតស៊ូវណ្ណៈ។<br><br>**៨៧២.** ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា វត្តមានរបស់ ខៀវ សំផន នៅក្នុងកិច្ចប្រជុំ និងការ ផ្សព្វផ្សាយផែនការរបស់មជ្ឈិមបក្ស បានបង្ហាញឲ្យឃើញថា គាត់មិនត្រឹមតែមានគោលបំណងរួម នៅក្នុងគោលនយោបាយជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជន ផ្លាស់ទីលំនៅប្រជាជនពី តាមទីជនបទមួយទៅកាន់ទីជនបទមួយទៀត និងកំណត់គោលដៅចំពោះមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរប៉ុណ្ណោះនោះទេ ប៉ុន្តែគាត់ថែមទាំងដើរតួនាទីសំខាន់នៅក្នុងការបង្កើតនូវខ្លឹមសារនៃគោលបំណងរួម និងគោលនយោបាយទៀតផង។<br><br>**៨៧៤.** នៅខែ ឧសភា ឆ្នាំ ១៩៧៥ ខៀវ សំផន និងមេ |

| | |
|---|---|
| | ដឹកនាំជាន់ខ្ពស់ផ្សេងទៀត ដែលរួមទាំងតំណាងមកពីភូមិភាគទាំងអស់ បានចូលរួមការប្រជុំរយៈពេល១០ថ្ងៃ នៅព្រះវិហារព្រះកែវមរកត។ នៅក្នុងការប្រជុំ មេដឹកនាំបក្សបានលើកហេតុផលដើម្បីជាយុត្តិកម្មក្នុងការជម្លៀសប្រជាជនចេញពីទីក្រុង និងណែនាំឱ្យកសាង និងការពារប្រទេសឱ្យឆាប់រហ័សតាមរយៈការបង្កើតសហករណ៍ និងការលើកទំនប់ និងជីកប្រឡាយ។ ក្រោយមកនៅចន្លោះប្រហែលថ្ងៃទី ២០ ដល់ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៧៥ ខៀវ សំផន និងមេដឹកនាំជាន់ខ្ពស់ផ្សេងទៀត តំណាងមកពីអង្គភាពយោធាទាំងអស់ និងលេខាស្រុក តំបន់ និងភូមិភាគទាំងអស់ បានចូលរួមនៅក្នុងការប្រជុំទាំងនៅពហុ-កីឡាដ្ឋានជាតិអូឡាំពិក ឬនៅវិទ្យាស្ថានបច្ចេកវិទ្យាខ្មែរ-សូវៀត។ ការណែនាំបានលើកឡើងអំពីការ រៀបចំសហករណ៍ ការលុបបំបាត់ចោលទ្រព្យសម្បត្តិឯកជន ការហាមឃាត់មិនឱ្យមានផ្សារ និងការចាយលុយ។<br><br>**៩៧៥.** ខៀវ សំផន ក៏បានដឹកនាំវគ្គរៀនសូត្រនៅក្នុងទីក្រុងភ្នំពេញ ពេញមួយអំឡុងពេលនៃសម័យកម្ពុជាប្រជាធិបតេយ្យផងដែរ។ គាត់បានឧទ្ទេសនាមជូនកម្មាភិបាលភូមិភាគ តំបន់ និងស្រុក ព្រមទាំងកម្មាភិបាលធម្មតាអំពីការកំណត់អត្តសញ្ញាណ និងកម្ចាត់ខ្មាំង ការបន្តការតស៊ូប្រដាប់អាវុធ ការបង្កើតសហករណ៍ ការកសាងទំនប់ និងជីកប្រឡាយ និងការបំពេញតាមផែនការការ |

ងារ។ យ៉ាងហោចណាស់ គាត់ក៏បានបង្រៀនវគ្គរៀនសូត្រនយោបាយដល់អ្នកដែលបានវិលត្រលប់មកវិញនៅចុងឆ្នាំ ១៩៧៥ ផងដែរ។ នៅក្នុងអំឡុងពេលនៃវគ្គរៀនសូត្រទាំងនេះ គាត់បានផ្តល់ហេតុផលអំពីការជម្លៀសទីក្រុង និងទីប្រជុំជន និងបានឧទ្ទេសនាមថា ចំណេះដឹងដែលបានទទួលមកពីការអប់រំដោយ “ពួកអាណានិគម និងពួកចក្រពត្តិនិយម” ត្រូវបំភ្លេចចោល។

**៩៧៦.** អង្គជំនុំជម្រះយល់ឃើញថា វត្តមាន និង/ឬ ការចូលរួមនៅក្នុងកិច្ចប្រជុំទាំងនេះបង្ហាញឲ្យឃើញថា គាត់មិនត្រឹមតែមានគោលបំណងរួម និង/ឬមានគោលនយោបាយជម្លៀសប្រជាជន ចេញពីទីក្រុង និងទីប្រជុំជន ផ្លាស់ទីលំនៅប្រជាជនពីតាមទីជនបទមួយទៅកាន់ទីជនបទមួយទៀត និងកំណត់គោលដៅអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរប៉ុណ្ណោះនោះទេ គាត់ថែមទាំងបានដើរតួនាទីសំខាន់មួយនៅក្នុងការផ្សព្វផ្សាយខ្លឹមសារនៃគោលបំណងរួម និងគោលនយោបាយទាំងនេះថែម ទៀត។ ក្រោយពីបានពិចារណាលើតួនាទីផ្លូវការ និងកេរ្តិ៍ឈ្មោះនៅក្នុងចំណោមប្រជាជននោះ ត្រឹមតែវត្តមានរបស់គាត់នៅក្នុងកិច្ចប្រជុំទាំងនេះ បានជួយសម្រួលឲ្យការណែនាំទាំងនេះមានប្រសិទ្ធភាពរួចទៅហើយ។ ការណែនាំទាំងនេះបានបញ្ជាក់ប្រាប់អ្នកមានវត្តមានក្នុងកិច្ចប្រជុំថា គាត់បានឯកភាពលើគោលបំណងរួម និងគោលនយោបាយនានា។ ករណីនេះកាន់តែគូសបញ្ជាក់ឲ្យឃើញថែមទៀតនៅពេលគាត់បានចេញសេចក្តីណែនាំដោយខ្លួនឯង។

| | |
|---|---|
| | **៩៧៩.** គោលបំណងរួមនេះមានគោលដៅចង់បង្កើតរដ្ឋមួយដែលខ្លួនទីពឹងខ្លួន រដ្ឋមួយដែលពឹងលើកសិកម្មសម័យទំនើបក្នុងរយៈពេលពី ១០ ទៅ ១៥ ឆ្នាំ ខាងមុខ និងក្រោយមក ជារដ្ឋមួយដែលពឹងលើសេដ្ឋកិច្ចឧស្សាហ៍កម្ម។ ស្រូវអង្ករ និងផលកសិកម្មសម្រាប់នាំចេញផ្សេងទៀតនឹងផ្តល់ជាទុនចាំបាច់សម្រាប់បំពេញគោលដៅនេះ។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា តួនាទីរបស់គាត់លើការងារសេដ្ឋកិច្ចបង្ហាញឲ្យឃើញថា គាត់មិនត្រឹមតែមានគោលបំណងរួមប៉ុណ្ណោះទេ តែគាត់ថែមទាំងដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអនុវត្តផ្នែកមួយចំនួននៃគោលបំណងរួមនេះទៀត។<br><br>**៩៨០.** ខៀវ សំផន បានធ្វើសេចក្តីថ្លែងការណ៍នានា ក្នុងនាមកម្មាភិបាលជាន់ខ្ពស់បំផុតម្នាក់នៅ ក្នុងការតស៊ូក្នុងប្រទេស និងក្រោយមកនៅក្នុងនាមគាត់ជាថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យ ជាពិសេសជាគណៈប្រធានរដ្ឋដែលក្នុងសេចក្តីថ្លែងការណ៍ទាំងនោះ គាត់បានកោតសរសើរគោលនយោបាយ និងការធ្វើបដិវត្តន៍ប្រជាធិបតេយ្យ និងបដិវត្តន៍សង្គមនិយម។ គាត់បានគូសបញ្ជាក់អំពីជ័យជម្នះកាលពីអតីតកាល និងបានលើកទឹកចិត្តឲ្យបន្តធ្វើសកម្មភាព ជាពិសេស លើការបង្ក-បង្កើនផលកសិកម្ម ការកសាងគម្រោងធារាសាស្ត្រ និងការកម្ចាត់ខ្មាំង។ គាត់ក៏បានបញ្ជាក់ហេតុផលអំពីការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញផងដែរ។ ក្នុងមុខតំណែង |

ដ៏ខ្ពង់ខ្ពស់ និងគួរឱ្យគោរព ខៀវ សំផន បានឯកភាព និង គាំទ្រលើគោលនយោបាយរបស់ខ្មែរក្រហម និងបាន ទទួលការគាំទ្រក្នុងចំណោមប្រជាជន និងពីមជ្ឈដ្ឋាន អន្តរជាតិចំពោះបដិវត្តន៍ប្រជាធិបតេយ្យ និងបដិវត្តន៍ សង្គមនិយមនេះ។ [...].

**៩៨៥.** នៅក្នុងសុន្ទរកថាថ្លែងបើកសម័យប្រជុំលើកទី មួយ និងប្រហែលជាសម័យប្រជុំតែម្តងគត់ ប៉ុណ្ណោះនៃ សភាតំណាងប្រជាជននៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៧៦ ខៀវ សំផន បានភូតកុហកនៅពេលដែលគាត់ បានអះអាងថា ការបោះឆ្នោតដោយត្រឹមត្រូវនិងយុត្តិធម៌ ត្រូវបានរៀបចំឡើង ហើយថា គោលនយោបាយពាក់ ព័ន្ធនឹងការដ្ឋានធ្វើការងារ សហករណ៍ និងការបន្តតស៊ូវ ណ្ណៈត្រូវបានគាំទ្រពីអ្នកបោះឆ្នោត។ [...]

**៩៨៧.** សេចក្តីថ្លែងការណ៍ជាសាធារណៈទាំងនេះ ដែល បានគាំទ្រអស់ពីចិត្តថ្លើមលើបដិវត្តន៍ និងគ្មានតម្រុយនៃ ការរិះគន់ណាមួយ បង្ហាញឱ្យឃើញថា ខៀវ សំផន មានគោលបំណងរួម និងមានគោលនយោបាយជម្លៀស ប្រជាជនចេញពីទីក្រុង និងទីប្រជុំជន បានផ្លាស់ទីលំនៅ ប្រជាជនពីជនបទមួយទៅជនបទមួយទៀត និងបាន កំណត់គោលដៅលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ សម្រាប់ការចាប់ខ្លួន ការសម្លាប់ និងការបាត់ខ្លួន។ សេច ក្តីថ្លែងការណ៍ទាំងនេះក៏បានបង្ហាញផងដែរថា ទោះបីជា

| | |
|---|---|
| | មុខតំណែង និងតួនាទីរបស់គាត់គឺគ្រាន់តែជារូបភាពខាងក្រៅក៏ដោយ ក៏មុខតំណែង និងតួនាទីទាំងនេះគឺបានដើរតួនាទីជាក់ស្ដែងដ៏សំខាន់មួយយ៉ាងពិតប្រាកដ ដោយសារមុខតំណែង និង តួនាទីទាំងនេះ ត្រូវបានប្រើប្រាស់សម្រាប់ការឯកភាពលើគោលនយោបាយរបស់បក្សកុម្មុយនីស្ដកម្ពុជា និងសម្រាប់បោកបញ្ឆោតប្រជាជន។ ខៀវ សំផន បានប្រើប្រាស់តួនាទី និង មុខតំណែងទាំងនេះនៅពេលធ្វើសេចក្ដីថ្លែងការណ៍ ដែលគាត់ខ្លួនឯងបានបង្ហាញវត្តមានក្នុងនាមជាមេដឹកនាំសំខាន់មួយរូប និងបានលើកទឹកចិត្តឲ្យប្រជាជនកម្ពុជា និងកម្មាភិបាលខ្មែរក្រហមបន្តអនុវត្តបដិវត្តន៍សង្គមនិយម ដោយបិទបាំងនូវតម្លាភាព ឬជាសាធារណភាព និងទប់ស្កាត់ការជ្រៀតជ្រែក និងការប្រឆាំងពីប្រជាជន និងសហគមន៍អន្តរជាតិ។<br><br>**៩៩៣.** [...]ជាការពិត អង្គជំនុំជម្រះយល់ឃើញដូចបានរៀបរាប់ខាងក្រោមថា ការបន្តចូលរួមដោយចេតនានៅក្នុងសហឧក្រិដ្ឋកម្មរួម ដោយបានដឹងថាឧក្រិដ្ឋកម្មនានាកំពុងត្រូវបានប្រព្រឹត្តឡើងនោះ បញ្ជាក់ឲ្យឃើញនូវចេតនាឧក្រិដ្ឋរបស់គាត់។<br><br>**១០២១.** ជាចុងក្រោយ អង្គជំនុំជម្រះកត់សម្គាល់ទៅលើភាពស្និតស្នាលជាបន្តបន្ទាប់របស់ ខៀវ សំផន ជាមួយនឹងមេដឹកនាំជាន់ខ្ពស់នានា នៅពេញទូទាំងរយៈពេលដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ និងសារៈសំខាន់របស់គាត់នៅក្នុងរបបខ្មែរក្រហម និងការចូលរួមយ៉ាងសំខាន់ |

| | |
|---|---|
| | នៅក្នុង សហឧក្រិដ្ឋកម្មរួម ជាពិសេស វត្តមានយ៉ាងទៀងទាត់ និងការចូលរួមរបស់គាត់នៅក្នុងកិច្ចប្រជុំ និងការរៀបចំផែនការនានារបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និងស្ថាប័នផ្សេងៗទៀតរបស់មជ្ឈិមបក្ស។ [...] |
| **<u>ទម្រង់ផ្សេងទៀតនៃការទទួលខុសត្រូវ</u>**<br>ក្នុងសំណុំរឿង ០០២/០២ **ខៀវ សំផន** ត្រូវបានចោទប្រកាន់អំពីទំរង់នៃបទឧក្រិដ្ឋផ្សេងទៀតដូចខាងក្រោម៖<br>• ការរៀបចំផែនការ,<br>• ការញុះញង់ឲ្យមានការប្រព្រឹត្ត,<br>• ការសមគំនិតដោយការជួយ និង ជម្រុញ,<br>• ការបញ្ជា,<br>• ការទទួលខុសត្រូវរបស់ថ្នាក់លើ។ | **ទម្រង់ផ្សេងទៀតនៃការទទួលខុសត្រូវ (សំអាងហេតុនៃសាលក្រម ដែលបង្កើតនូវទម្រង់ផ្សេងទៀតនៃការទទួលខុសត្រូវ)**<br>***ការរៀបចំផែនការ***<br>**៩៩៧.** [...]អង្គជំនុំជម្រះរម្លឹកឡើងវិញថា ខៀវ សំផន គឺជាសមាជិកត្រៀមនៃគណៈកម្មាធិការមជ្ឈិមនៅក្នុងរយៈពេលដែលមានកិច្ចប្រជុំទាំងនេះ ដូច្នេះហើយគាត់មានសិទ្ធិក្នុងការចូលរួមប្រជុំ ទោះបីជាគាត់មិនមាន "សិទ្ធិសម្រេច" ជាផ្លូវការក៏ដោយ។ អង្គជំនុំជម្រះក៏ជឿជាក់ផងដែរថា អនុលោមតាមគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ គាត់មានសិទ្ធិចូលរួមក្នុងការពិភាក្សារបស់គណៈកម្មាធិការនេះ។ អង្គជំនុំជម្រះយល់ឃើញថា គាត់បានបញ្ចេញយោបល់របស់គាត់នៅក្នុងកិច្ចប្រជុំខែមេសា ឆ្នាំ ១៩៧៥ ប៉ុន្តែអង្គជំនុំ-ជម្រះមិនមានលទ្ធភាពក្នុងការសន្និដ្ឋានថា គាត់បានធ្វើអន្តរាគមន៍យ៉ាងសកម្មនៅក្នុងកិច្ចប្រជុំខែ មិថុនា ឆ្នាំ ១៩៧៤ ឡើយ។ ប៉ុន្តែ ទោះបីជាគាត់មិនបានធ្វើអន្តរាគមន៍យ៉ាងសកម្មក៏ដោយ ក៏គាត់មានសិទ្ធិធ្វើអន្តរាគមន៍បានដែរ ហើយតាមរយៈការនៅ |

ស្មៀមរបស់គាត់នោះ គាត់បានបង្ហាញអំពីការយល់ព្រម។ ដូច្នេះ គាត់បានចូលរួមក្នុងកិច្ចប្រជុំទាំងនេះ និងបានអនុម័តផែនការទាំងនេះ។

**១០២៤.** យ៉ាងយូរបំផុត ចាប់ពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៧៥ ខៀវ សំផន បានជួបពិភាក្សាជាមួយនឹងមេដឹកនាំជាន់ខ្ពស់ដទៃទៀត ពាក់ព័ន្ធនឹងគោលនយោបាយកសាង និងការពារប្រទេសសង្គមនិយម ឯករាជ្យ និងខ្លួនទីពឹងខ្លួន។ ផែនការនោះគឺដើម្បីបង្កើតសង្គមមួយដែលគ្មានវណ្ណៈ ដែលប្រជាជនទាំងអស់ត្រូវបានរៀបចំដាក់បញ្ចូលទៅក្នុងសហករណ៍ ក្នុងគោលបំណងដើម្បីកសាង និងការពារប្រទេសឲ្យបានឆាប់ ដោយផ្តោតជាពិសេសទៅលើការបង្កបង្កើនផលស្រូវ និងការកសាងប្រព័ន្ធធារាសាស្ត្រ [...]

**១០២៥.** នៅចុងឆ្នាំ ១៩៧៥ ខៀវ សំផន រួមជាមួយអ្នកផ្សេងទៀត បានបង្កើតផែនការសេដ្ឋកិច្ចជាក់លាក់មួយ។ ផែនការនេះបានទទួលស្គាល់នូវការខ្វះខាតម្ហូបអាហារ និងថ្នាំសង្កូវ ដែលប៉ះពាល់ជាពិសេសដល់ "ប្រជាជនថ្មី" ។ ទោះបីជាយ៉ាងណាក៏ដោយ ផែនការនេះគឺដើម្បីបែងចែកកម្លាំងពលកម្មតាមបែបយុទ្ធសាស្ត្រ អនុលោមទៅតាមទិសដៅបង្កបង្កើនផលស្រូវរបស់បក្ស និងអាទិភាពនៃហេដ្ឋារចនាសម្ព័ន្ធ ពង្រីកសហករណ៍ និងគិតគូរដល់ "ប្រជាជនចាស់" ដែលនាំឲ្យប៉ះពាល់ ដល់ "ប្រជាជនថ្មី" ដែលត្រូវបានគេសង្ស័យ។[...]

| | |
|---|---|
| | *ការបញ្ជា*<br><br>**៧៧២.** [...] មេដឹកនាំបក្ស រួមទាំង ប៉ុល ពត ខៀវ សំផន និង នួន ជា បានដឹកនាំវគ្គរៀនសូត្រក្នុងទីក្រុងភ្នំពេញ ដោយបានចាប់ផ្ដើមវគ្គរៀនសូត្រទាំងនោះ ភ្លាមៗ ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបានបន្តគ្រប់ពេលក្នុងអំឡុងសម័យកម្ពុជា ប្រជាធិបតេយ្យ។ ពួកគេបានធ្វើបទឧទ្ទេសនាមចំពោះកម្មាភិបាលភូមិភាគ តំបន់ និងស្រុក ព្រមទាំង កម្មាភិបាលធម្មតា អំពីការកំណត់អត្តសញ្ញាណ និងការកម្ចាត់ខ្មាំង ការបន្តធ្វើការតស៊ូប្រដាប់អាវុធ ការបង្កើតសហករណ៍ ការលើកភ្លឺស្រែ ជីកប្រឡាយ និងការបំពេញការងារ និងបង្កបង្កើនផលតាមផែនការកំណត់។<br><br>**១០០៦.** [...] ខៀវ សំផន ក៏ជាសមាជិកគណៈកម្មាធិការមជ្ឈិម និងជាសមាជិកត្រៀមនៃគណៈកម្មាធិការអចិន្ត្រៃយ៍ផងដែរ។ តួនាទីទាំងនេះធ្វើឱ្យគាត់អាចមានឥទ្ធិពលនៅក្នុងដំណើរការនៃការធ្វើសេចក្ដីសម្រេច ជាពិសេសដោយសារតែ សេចក្ដីសម្រេចទាំងនោះត្រូវបានធ្វើឡើងដោយអនុលោមតាមគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្ដុំ ហើយដោយសារតែមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀត រួមទាំង ប៉ុល ពត មានទំនុកចិត្តខ្លាំងមកលើរូបគាត់។ ដូច្នេះ អង្គ-ជំនុំជម្រះជឿជាក់ថា ភ័ស្តុតាងបង្ហាញថា ខៀវ សំផន បានកាន់តួនាទីមួយចំនួនដែលមានអំណាចខ្លះ។ តាមពិតទៅ គាត់មានទំនាក់ទំនង |

| | |
|---|---|
| | ជិតស្និតជាមួយនឹងមេដឹកនាំជាន់ខ្ពស់ដទៃទៀតនៅគ្រប់ពេល ក្នុងអំឡុងបដិវត្តសង្គមនិយម និងបដិវត្តប្រជាធិបតេយ្យបាយដែលរបបខ្មែរក្រហមបានសម្រេច និងអនុវត្តសំខាន់តាមរយៈវត្តមានជាទៀតទាត់ និងការចូលរួមនៅក្នុងកិច្ចប្រជុំសំខាន់ៗរបស់មជ្ឈិមបក្ស ដែលបានរៀបចំគោលបំណងរួម និងគោលនយោបាយនានា រួមទាំងសេចក្ដីសម្រេចក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញផងដែរ។<br><br>***ការញុះញង់***<br><br>**១០១៥.** [...] លើសពីនេះទៀត ខៀវ សំផន បានចូលរួមដោយផ្ទាល់នៅក្នុងការបំពាក់បំប៉នផ្នែកមនោគមន៍វិជ្ជាដល់ប្រជាជន អំពីការតស៊ូវណ្ណៈ ហើយគាត់ក៏បានដឹងថា ការបំពាក់បំប៉នផ្នែក មនោគមន៍វិជ្ជាបែបនេះពិតជាធ្វើឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មដោយជៀសមិនរួច។<br><br>**១០៣១.** ក្រោយពីបានចូលរួមក្នុងការរៀបចំផែនការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) ខៀវ សំផន បានថ្លែងសុន្ទរកថាជាសាធារណៈជាច្រើនដង មុនពេល និងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ដោយបានលើកសរសើរដល់ខ្មែរក្រហម និងគាំទ្រដល់គោលនយោបាយកសាងសេដ្ឋកិច្ច តាមរយៈការងារជាសមូហភាពនៅតាមស្រែចម្ការ។ សុន្ទរកថាជា សាធារណៈទាំងអស់នេះ បានធ្វើឱ្យកងទ័ព និងកម្មាភិបាលខ្មែរក្រហម ធ្វើការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំក្នុង |

| | |
|---|---|
| | ដំណាក់កាលទី២។ នៅខែ មេសា ឆ្នាំ ១៩៧៥ នៅចុងឆ្នាំ ១៩៧៥ និងចុងឆ្នាំ ១៩៧៦ នៅពេលដែលគាត់បានដឹងថា ស្ថានភាពរស់នៅក្នុងប្រទេសមានការលំបាកខ្លាំង ខៀវ សំផន រួមជា មួយនឹងថ្នាក់ដឹកនាំបក្សដទៃទៀត បានរៀបចំផែនការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ដោយមិនចាំបាច់មានការយល់ព្រម និងមិនគិតគូរអំពីបញ្ហាសុខុមាលភាពរបស់ប្រជាជនដែលត្រូវផ្លាស់ទីលំនៅឡើយ។ បន្ទាប់មក គាត់បានប្រកាសគាំទ្រដល់គោលនយោបាយទាំងអស់នេះជាសាធារណៈ។ នៅក្នុងខែ ធ្នូ ឆ្នាំ ១៩៧៥ ខៀវ សំផន បានថ្លែងសុន្ទរកថា ដោយសង្កត់ធ្ងន់ទៅលើគោលនយោបាយរួម និងលក្ខខណ្ឌតម្រូវដែលថា ប្រជាជនទាំងអស់ត្រូវធ្វើការនៅតាមស្រែចម្ការ ឬនៅក្នុងរោងចក្រ បង្កើនផលិតផលស្រូវ និងកសាងគម្រោងធារាសាស្ត្រ។ គាត់ក៏បានលើកសរសើរដល់កិច្ចខិតខំប្រឹងប្រែងរបស់ប្រជាជន និងកងទ័ព។ ដូចគ្នានេះដែរ នៅក្នុងខែ មេសា ឆ្នាំ ១៩៧៦ គាត់បានថ្លែងសុន្ទរកថា ដោយអះអាងដោយមិនត្រឹមត្រូវថា គោលនយោបាយពាក់ព័ន្ធនឹងការដ្ឋាន សហករណ៍ និងការតស៊ូវណ្ណៈដែលកំពុងតែមាននៅពេលនោះ ត្រូវបានគាំទ្រដោយអ្នកបោះឆ្នោតនៃសភាតំណាងប្រជាជន។ គាត់ក៏បានលើកសរសើរផងដែរដល់ប្រជាជនកម្ពុជា និងកងទ័ពបដិវត្តចំពោះតួនាទីរបស់ពួកគេក្នុងការរំដោះទីក្រុងភ្នំពេញ នៅពេលដែលគាត់បានដឹងអំពីឧក្រិដ្ឋកម្មដែលមាននៅក្នុងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ នោះ។ |

សុន្ទរកថាជាសាធារណៈទាំងអស់នេះបានគាំទ្រអស់ពីចិត្តដល់ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ដោយមិនមានការលើកឡើងណាមួយពីការរិះគន់អ្វីឡើយ។ ខៀវ សំផន ក៏នៅតែបន្តកាន់តួនាទីរបស់គាត់នៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា/រដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដោយបានផ្តល់ការគាំទ្រដល់ភាពស្របច្បាប់របស់ខ្មែរក្រហម ដោយមិនបានដោះស្រាយបញ្ហារងទុក្ខវេទនាដែលមិនអាចជៀសបានពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន ដោយបង្ខំទៅកាន់ការដ្ឋាន និងសហករណ៍នានានោះឡើយ។

***ការជួយ និងជំរុញ***

**១០០៨.** [...] ចុងក្រោយ បន្ទាប់ពីមានការប្រព្រឹត្តិឧក្រិដ្ឋកម្មរួចមក ខៀវ សំផន បានលើក សរសើរដល់កងទ័ព និងប្រជាជនកម្ពុជាចំពោះជ័យជម្នះរបស់ពួកគេ លើកសរសើរដល់គោល នយោបាយរបស់ខ្មែរក្រហមក្នុងការអនុវត្តបដិវត្តន៍សង្គមនិយម តាមរយៈសមូហភាវូបនីយកម្ម។ ខៀវ សំផន បានថ្កោលទោសរបបមុន និងបានផ្តល់យុត្តិកម្មចំពោះការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅក្នុងសុន្ទរកថាថ្លែងទៅកាន់ប្រជាជនកម្ពុជា សេចក្តីថ្លែងការណ៍ទៅកាន់សហគមន៍ អន្តរជាតិ និងនៅក្នុងវគ្គបំពាក់បំប៉នមនោគមន៍វិជ្ជាចំពោះអ្នកដែលវិលត្រឡប់ចូលមកក្នុងប្រទេសវិញ។

**១០០៩.** ជំនួយជាក់ស្តែង ការលើកទឹកចិត្ត និងជំនួយផ្នែកស្មារតីនេះ មានឥទ្ធិពលយ៉ាងខ្លាំងទៅលើ ការ

| | |
|---|---|
| | ប្រព្រឹត្តិឧក្រិដ្ឋកម្មក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១។ ខៀវ សំផន ដើរតួនាទីសំខាន់ជាមួយខ្មែរក្រហម បើទោះជាមិនមែនមិនអាចខ្វះបានក្ដី ដោយសារតែកេរ្ដិ៍ឈ្មោះ និងប្រជាប្រិយភាពរបស់គាត់ នៅក្នុងចំណោមប្រជាជន និងនៅលើឆាកអន្តរជាតិ។ ដោយផ្អែកទៅលើកេរ្ដិ៍ឈ្មោះ តួនាទីជាផ្លូវការរបស់គាត់ នៅក្នុងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងកម្ពុជាប្រជាធិបតេយ្យ និងការគាំទ្រទាំងស្រុងរបស់គាត់ចំពោះខ្មែរក្រហមនោះ អង្គជំនុំជម្រះជឿជាក់ថា សេចក្ដីថ្លែងការណ៍ជាសាធារណៈរបស់ ខៀវ សំផន បានលើកទឹកចិត្តដល់ចារីក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម។<br><br>**១០១១.** ចុងក្រោយ អង្គជំនុំជម្រះជឿជាក់ថា ចារីបានដឹង ឬយ៉ាងហោចណាស់ បានប្រមើលឃើញនៅមុន និងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញថា ខៀវ សំផន នឹងផ្ដល់ជំនួយ និងគាំទ្រនៅក្រោយព្រឹត្តិការណ៍នេះ។ តាមពិត ការរំពឹងទុកជាមុនដូច្នេះ ស្របគ្នាជាមួយនឹងការគាំទ្ររបស់គាត់ នៅក្នុងបដិវត្តន៍ប្រជាធិបតេយ្យទាំងមូល ជាពិសេសក្នុងអំឡុងពេលនៃការវាយលុកចុងក្រោយទៅលើទីក្រុងភ្នំពេញ និងនៅប៉ុន្មានថ្ងៃដំបូងបន្ទាប់ពី រំដោះ។ [...]<br><br>**១០៣៣.** អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន បានផ្ដល់ជំនួយជាក់ស្ដែង ការលើកទឹកចិត្ត និងការគាំទ្រខាងស្មារតីឱ្យចារីប្រព្រឹត្តឧក្រិដ្ឋកម្មផ្សេងៗ នៅក្នុងអំឡុង |

01059842



| | |
|---|---|
| | ពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)។ នៅក្នុងសេចក្ដីថ្លែងការណ៍នានា រយៈពេលជាច្រើនខែមុន និងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅដំណាក់កាលទី២ នេះ ខៀវ សំផន បានលើកសរសើរដល់ខ្មែរក្រហម បានផ្ដល់យុត្តិកម្ម និងបានគាំទ្រដល់គោលនយោបាយរបស់ពួកគេក្នុងការកសាង និងការពារប្រទេស ដោយការបែងចែកកម្លាំងពលកម្មជាយុទ្ធសាស្ត្រស្របតាមទិសដៅបង្កបង្កើនផល អាទិភាពផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងការតស៊ូវណ្ណៈ និងបានធ្វើយុត្តិកម្ម ឬបានបដិសេធការប្រព្រឹត្តិឧក្រិដ្ឋកម្មរបស់ពួកគេ។ គាត់និយាយដដែលៗ អំពីប្រធានបទទាំងនេះនៅក្នុងវគ្គបំពាក់បំប៉ន មនោគមន៍វិជ្ជាផ្សេងៗ រួមទាំង ជាមួយបញ្ញវន្តដែលបានវិលត្រឡប់មកពីបរទេសវិញ។ ខៀវ សំផន ក៏បានបំពេញភារកិច្ចផ្នែកការទូត និងបានធ្វើការទាក់ទងជាមួយសម្ដេច នរោត្ដម សីហនុ ដើម្បីធានាឲ្យមានការគាំទ្រ និងបានលើកសរសើរដល់ទង្វើរបស់បដិវត្តសង្គមនិយម រួមទាំង ពលកម្មដោយកម្លាំងគ្រប់ប្រភេទទាំងអស់ដើម្បីកសាង និងការពារប្រទេស។ |